9Marks

ការកសាងក្រុមជំនុំដែលមានសុខភាពល្អ

BUILDING HEALTHY CHURCHES

# តើសមាជិកពួកជំនុំដែលមានសុខភាពល្អជាអ្វី?

WHAT IS A HEALTHY CHURCH MEMBER?



THABITI M. ANYABWILE

9Marks Online PDF

សៀវភៅ *“តើសមាជិកពួកជំនុំដែលមានសុភាពល្អជាអ្វី?* គឺជាសៀវភៅ ដែលបំពេញចន្លោះខ្វះខាត យ៉ាងសម្បើមមួយនៅក្នុងជីវិតរស់នៅរបស់គ្រីស្ទបរិស័ទគ្រប់ៗរូប។ សៀវភៅនេះនិយាយចំៗ និងមានសេចក្តីណែនាំងាយស្រួលអានសម្រាប់ពួកជំនុំ។ សៀវភៅនេះក៏មានភាពស៊ីជម្រៅ និងបានវិភាគយ៉ាងល្អិតល្អន់អំពីព្រះគម្ពីរទាក់ទងនឹងការសិក្សាអំពីក្រុមជំនុំ ដែលបានសរសេរឡើងដោយចិត្តឆេះឆួល និងភាពបន្ទាន់សម្រាប់បច្ចុប្បន្ននេះ។ ជាក់ស្តែង នេះគឺជាធនធានមួយដ៏មានតម្លៃសម្រាប់ពួកជំនុំគ្រប់ៗគ្នា—រាប់ចាប់ពីសមាជិកថ្មីៗរហូតដល់គ្រូគង្វាលដែលមានបទពិសោធន៍ជាយូរឆ្នាំហើយ ក៏ប្រើបានដូចគ្នា។ នៅក្នុងសម័យកាលដែលគ្រីស្ទបរិស័ទភាគច្រើនហាក់បីដូចជាមានការភាន់ច្រឡំថា តើក្រុមជំនុំគួរជាសហគមន៍ប្រភេទណានោះ គឺសៀវភៅនេះបានណែនាំដ៏មានប្រយោជន៍ដោយបង្ហាញនូវអាទិភាពស្របតាមព្រះគម្ពីរពិតប្រាកដ ជាពិសេសនៅពេលអនុវត្តនៅក្នុងជីវិតពួកជំនុំម្នាក់ៗផ្ទាល់។

— លោកគ្រូ ចន មែកខធ័រ (John MacArthur) នាយកនៃព័ន្ធកិច្ចព្រះគុណសម្រាប់អ្នក (Grace to You)

លោកគ្រូ ថាប៊ីធី អេនីយ៉ាវាល់ (Thabiti Anyabwile) បានបំពេញចន្លោះយ៉ាងធំមួយនៅក្នុងអក្សរសាស្ត្រនៃគ្រីស្ទបរិស័ទសម័យទំនើបយើងនេះ។ សៀវភៅដែលនិយាយអំពីរបៀបធ្វើជាគ្រូគង្វាល ឬអ្នកដឹកនាំក្រុមជំនុំដ៏ស្មោះត្រង់មានច្រើនណាស់ ប៉ុន្តែកម្រនឹងឃើញមានសៀវភៅនិយាយអំពីរបៀបក្លាយជាសមាជិកពួកជំនុំដែលស្មោះត្រង់។ សៀវភៅនេះមានចំណេះដឹងខាងព្រះគម្ពីរ និងការណែនាំដែលអាចយកទៅអនុវត្តដ៏សម្បូរបែប។ លោក ថាប៊ីធី បានអំពាវនាវដល់រាល់គ្រីស្ទបរិស័ទឲ្យធ្វើលើសជាង

9Marks Online PDF

គ្រាន់តែចូលរួមវេនថ្វាយបង្គំនៅក្រុមជំនុំ ប៉ុន្តែឲ្យធ្វើជាសមាជិកពួកជំនុំដែលស្មោះត្រង់ ដែលមានចំណែកនៅក្នុងក្រុមជំនុំដែលព្រះជាម្ចាស់គាប់ព្រះទ័យឲ្យលោកអ្នកចូលរួម។ សៀវភៅនេះមកដល់មិនយឺតពេលពេកនោះទេសម្រាប់បរិបទនៃក្រុមជំនុំបច្ចុប្បន្នយើងនេះ។

—លោក អ. អាល់ប៊ឺត មូលើ ជេអ (R. Albert Mohler Jr.) នាយកនៃសាលាទេវសាស្ត្របាទីស្ទភូមិភាគខាងត្បូង

“មានសៀវភៅមួយចំនួនសាមញ្ញខ្លាំងពេក ស្ទើរតែមិនចង់មើល ហើយមានសៀវភៅខ្លះទៀតស្មុកស្មាញខ្លាំងពេក លុះត្រាតែសៀវភៅនោះមានប្រធានបទដែលទាក់ទាញក្នុងរបៀបដែលសំខាន់ខុសគេ គឺវាមិនស័ក្តិសមនឹងឲ្យយើងចំណាយពេលអានឡើយ។ យូរៗម្តង យើងអាចរកសៀវភៅដែលសាមញ្ញ និងមានភាពស៊ីជម្រៅ—ហើយសៀវភៅនេះស្ថិតក្នុងចំណោមសៀវភៅទាំងនោះឯង។ យើងរស់នៅក្នុងជំនាន់មួយ ដែលមានមនុស្សជាច្រើននិយាយអំពីសារៈសំខាន់នៃការដែលគ្រីស្ទបរិស័ទរស់នៅ «ក្នុងសហគមន៍» តែមានមនុស្សតិចណាស់ ដែលបានបកស្រាយអ្វីដែលជាអត្ថន័យពិត ស្មោះត្រង់តាមព្រះគម្ពីរ ដែលជំរុញបុគ្គលនីមួយៗឲ្យផ្លាស់ប្រែ។ លោក ថាប៊ីធី អេនីយ៉ាវាល់ បានបំពេញរាល់ទាំងចន្លោះខ្វះខាតនោះ។ ដូច្នេះ សូមអាន សូមសញ្ជឹងគិត សូមអធិស្ឋាន ហើយចែកចាយសៀវភៅនេះដោយសប្បុរសជាមួយក្រុមជំនុំរបស់លោកអ្នកចុះ។»

—ឌី. អេ. ខាសុន (D. A. Carson) សាស្ត្រាចារ្យផ្នែកស្រាវជ្រាវកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីនៃសាលាទ្រីនិធី អីវ៉ាន់ជិលិកខលឌីនិធី (Trinity Evangelical Divinity Research Professor of New Testament, Trinity Evangelical Divinity School)

9Marks Online PDF

«សៀវភៅនេះផ្តល់នូវការយកចិត្តទុកដាក់ដ៏ប្រសើរ និងចាំបាច់នៅក្នុងការផ្តោតទៅលើសមាជិកភាពម្នាក់នៃពួកជំនុំ។ យើងគ្រប់គ្នាអាចនឹងទទួលបានប្រយោជន៍តាមរយៈសៀវភៅដ៏ល្អនេះ។»

—លោកគ្រូ អា ស៊ី ស្រ្តូល (R. C. Sproul) ប្រធាន និងស្ថាបនិកព័ន្ធកិច្ចលីហ្គូនៀ (Ligonier) ជាព្រឹទ្ធបុរសនៃព័ន្ធកិច្ចបង្រៀន និងអធិប្បាយនៃសាលាទេវសាស្រ្តសេនអែនទ្រូ សាន់ហ្វដ ហ្វ្លរីដា (Saint Andrews Chapel, Sanford, Florida)

«គ្រូគង្វាលស្មោះត្រង់ក៏ជាសមាជិកពួកជំនុំដ៏ល្អផងដែរ។ លោក ថាប៊ីធី គឺជាសាក្សីនៃសេចក្តីពិតនេះ ហើយលោកក៏បានសរសេរសៀវភៅស្តីអំពីការក្លាយទៅជាសមាជិកពួកជំនុំដែលមានសុខភាពល្អនេះ ដោយសរសេរចេញមកពីការយល់ដឹងក្នុងនាមជាគ្រូគង្វាល និងបទពិសោធន៍របស់លោកផ្ទាល់។ ក្រុមជំនុំដែលមានបំណងចង់ពង្រឹងសមាជិកភាពក្នុងក្រុមជំនុំគួរតែលើកទឹកចិត្តសមាជិកឲ្យអានសៀវភៅនេះ។ ការធ្វើជាសមាជិកពួកជំនុំដែលមានភាព និងស្មោះត្រង់នៅក្នុងសម័យកាលដែលជំរុញឲ្យមានភាពភ្លើតភ្លើនហួសហេតុ និងភាពអាត្មានិយម គឺមិនមែនជាការងាយស្រួលនោះទេ។ លោកមិនត្រឹមតែរម្លឹកយើងថា វាអាចទៅរួចនោះទេ ប៉ុន្តែលោកក៏បានរម្លឹកយើងដោយមានសេចក្តីពិតដែលស្របតាមបទគម្ពីរ ដែលនេះហើយជារឿងចាំបាច់។ ខ្ញុំនៅតែបន្តអរព្រះគុណដល់ព្រះអម្ចាស់សម្រាប់គំនិត និងដួងចិត្តរបស់លោក ថាប៊ីធី អេនីយ៉ាវាល់។»

—អាន់ថូនី ជេ. ខាធើ (Anthony J. Carter) ជាគ្រូគង្វាល អ្នកនិពន្ធ អ្នកកែអត្ថបទនៅការដកពិសោធន៍សេចក្តីពិត (ជាអ្នកនាំយកការកំណែទម្រង់ទៅកាន់ក្រុមជំនុំជនជាតិអាហ្រ្វិក)

9Marks Online PDF

សៀវភៅ *«តើសមាជិកពួកជំនុំដែលមានសុខភាពល្អជាអ្វី?»* របស់លោក ថាប៊ីធី អេនីយ៉ាវាល់ (Thabiti Anyabwile) បានសួរនូវសំណួរដ៏ត្រឹមត្រូវអំពីការស្នើឲ្យមាននូវសមាជិកភាពសម្រាប់ក្រុមជំនុំ ដែលអំពាវនាវឲ្យសមាជិកក្រុមជំនុំនៅតាមតំបន់ឲ្យបង្កើត និងឲ្យទ្រទ្រង់ការអនុវត្តការបន្តជួបជុំគ្នា ដែលបានកើតឡើងដោយសារជំណឿងល្អ។ សៀវភៅនេះគឺជាសេចក្ដីណែនាំដែលត្រូវនឹងស្ថានភាពដែលពិតៗ ប៉ុន្តែវាមានសេរីភាពរួចផុតពីភាពរាក់កំផែលនៃសាសនាដែលផ្អែកទៅលើផលប្រយោជន៍ ដែលជាញឹកញាប់កំណត់សម្គាល់លើអ្នកដែលមកស្វែងយល់ថ្មីៗ ឲ្យអាចយល់តាមរបៀបនេះបាន។ ខ្ញុំសូមលើកទឹកចិត្តឲ្យអ្នកដឹកនាំ សមាជិកក្រុមជំនុំទាំងអស់ឲ្យអានសៀវភៅនេះជាមួយគ្នា ហើយការអនុវត្តតាមសេចក្តីដែលមាននៅក្នុងសៀវភៅនេះនឹងផ្តល់នូវជីវិតដល់លោកអ្នក ក្នុងនាមជាក្រុមគ្រួសារនៃព្រះជាម្ចាស់ ដែលនឹងបង្កើនប្រាជ្ញាញាណ អំណាច សេចក្តីស្រឡាញ់ និងទីបន្ទាល់ដល់លោកីយ៍នេះ។ យើងនឹងរកឃើញការកម្សាន្តចិត្តខ្លាំងយ៉ាងចេញពីពាក្យសម្តីក្នុងសៀវភៅនេះ!

—លោក អ៊ីរិក ស៊ី រ៉េដម៉ុនដ គ្រូគង្វាលរៀមច្បងនៃក្រុមជំនុំបាប់ទីស្ទ ហ៊ិលខ្រេសធ៍ ធិមភលហ៊ិល ម៉ារីលែន (Eric C. Redmond, Senior Pastor, Hillcrest Baptist Church, Temple Hills, Maryland)

# តើសមាជិកពួកជំនុំ ដែលមាន**សុខភាពល្អ** ជាអ្វី?

Thabiti M.
Anyabwile

CROSSWAY®
WHEATON, ILLINOIS

9Marks Online PDF

*What Is a Healthy Church Member?*

តើសមាជិកពួកជំនុំដែលមាន សុខភាព ល្អ ជាអ្វី?

រក្សាសិទ្ធិ© 2008 by Thabiti M. Anyabwile

Published by Crossway 1300 Crescent Street Wheaton, Illinois 60187

This edition in Khmer copyright ©2025 by ACTION Cambodia Organization

All rights reserved.
រក្សាសិទ្ធិ គ្រប់យ៉ាង ©២០២៥

ប្រអប់សំបុត្រលេខ ១១៧៨ រាជ ធានី ភ្នំពេញ, ព្រះរាជាណាចក្រកម្ពុជា
អ្នកបកប្រែ៖ លោក អ៊ុច អភិរិន
ជំនួយ ការបកប្រែ៖ លោក ឈាង ប៉ូវ៉ា និងលោក ឯក សត្យា
ពិនិត្យ ផ្ទៀងផ្ទាត់ ដោយ៖ លោក ទេព រ៉ូ, លោក ខែម បូឡុង,  លោក ហុង សម្ភស, លោក ឡង់ គីមឡុង, លោក ឯក សត្យា និង លោកស្រី អមរិន្ទ សុធាកែវ

សូមថ្លែងអំណរគុណដល់៖ លោកស្រី ឡុញ ស្រីរ័ត្ន, និង លោកស្រី ថាវ ប៊ុនរី
យើងខ្ញុំបាន រក្សាអក្ខរាវិរុទ្ធនៃ សម្រង់ខ គម្ពីរដែល មាន នៅក្នុងព្រះ គម្ពីរបកប្រែចាស់ រក្សាសិទ្ធិ©ឆ្នាំ១៩៥៤ ដោយ សមាគមព្រះ គម្ពីរ សកល, ព្រះ គម្ពីរ សញ្ញា ថ្មី កែសម្រួល រក្សាសិទ្ធិ ©ឆ្នាំ២០១៤, ២០១៦ (គកស) ដោយ សមាគម ព្រះ គម្ពីរ សកល, ព្រះ គម្ពីរដ៏វិសុទ្ធ ជាភាសា ខ្មែរបច្ចុប្បន្ន រក្សា សិទ្ធិ ©ឆ្នាំ២០០៥ (គខប) ដោយ សមាគមព្រះ គម្ពីរសកល, ព្រះ គម្ពីរគ្រិស្ត បរិស័ទ ខ្មែរ រក្សាសិទ្ធិ ©ឆ្នាំ២០១៤ (គគខ) ដោយ ព័ន្ធកិច្ច ព្រះបន្ទូល នៃ ជីវិត, ក៏ដូច ជា អសាធារណនាមមួយ ចំនួន ប៉ុន្តែសំណេរនៅក្នុងអត្ថបទ ទាំង មូល យើងខ្ញុំបានំ ខិតខព្យាយាម គោរពតាមអក្ខរាវិរុទ្ធនៃ វចនានុក្រម ខ្មែររបស់សម្តេច សង្ឃរាជ ជួន ណាត។

អ្នក រចនា អត្ថបទភាសា ខ្មែរ៖ លោក វ៉ើល ណាថាន, លោក ស៊ូ ទិត្យ
និង  លោក  វណ្ណដ្ឋា សុតរ៉ាប៊ី
For ordering information please visit:
ប្រសិនបើលោកអ្នកចង់ ជាវសៀវភៅនេះ សូម ចូលទៅ កាន់គេហទំព័រ៖
plovpitshop.com
បោះពុម្ព លើក ទី១ ចំនួន ៣.០០០ក្បាល គ.ស២០២៥

9Marks ISBN: 979-8-89218-162-4

ថ្វាយចំពោះព្រះយេស៊ូវគ្រីស្ទជាសិរសានៃក្រុមជំនុំសម្រាប់អវយវៈនៃព្រះកាយទ្រង់ដែលកំពុងបំពេញមុខងាររបស់ពួកគេ
និងសម្រាប់ក្រុមជំនុំដែលបានថ្នែសណ្ឋានជីវិតខ្ញុំ

ក្រុមជំនុំបាទីស្ទប្រ៉ែគ្គនដ៍ខេមិនទីមួយ
ក្រុមជំនុំបាទីស្ទកាភីថលហិល
ក្រុមជំនុំនៅលើថ្មដា

ហើយ

ក៏សម្រាប់ក្រុមជំនុំដែលនៅក្នុងផ្ទះខ្ញុំផងដែរ
គ្រីស្ទី ដែលជាប្រពន្ធខ្ញុំ និងកូនៗ៖ អាហ្វីយ៉ា, អេដែន, និង ទីតុស

9Marks Online PDF

# មាតិកា


**បុព្វកថា** **១១**

**អារម្ភកថា** **១៥**

**សេចក្ដីផ្ដើម** **១៩**

**សញ្ញាសម្គាល់ទី ១** **២៧**
សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជា
អ្នកស្ដាប់សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

**សញ្ញាសម្គាល់ទី២** **៣៩**
សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជា
អ្នកសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ

**សញ្ញាសម្គាល់ទី៣** **៥៧**
សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជា
អ្នកជ្រាបជោគនៅក្នុង
ដំណឹងល្អ

**សញ្ញាសម្គាល់ទី៤** **៧១**
សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជា
អ្នកដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ

**សញ្ញាសម្គាល់ទី៥** **៨៧**
សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជា
អ្នកដែលប្រកាសដំណឹងល្អតាមព្រះគម្ពីរ


9Marks Online PDF

**សញ្ញាសម្គាល់ទី៦** ៩៧

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាស
មាជិកដែលមានការប្ដេជ្ញាចិត្ត

**សញ្ញាសម្គាល់ទី៧** ១១១

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នក
ដែលស្វែងរកការដាក់វិន័យ

**សញ្ញាសម្គាល់ទី៨** ១២៥

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នក
ដែលលូតលាស់ខាងឯភាពជាសិស្ស

**សញ្ញាសម្គាល់ទី៩** ១៤៣

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នក
ដែលដើរតាមព្រះដោយចេះបន្ទាបខ្លួន

**សញ្ញាសម្គាល់ទី១០** ១៥៧

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នក
ចម្បាំងខាងសេចក្ដីអធិស្ឋាន

**បណ្ដាំកថា** ១៧៣

**ឧបសម្ព័ន្ធ** ១៧៩

សេចក្ដីសញ្ញាទូទៅនៃពួកជំនុំដែលមាន
សុខភាពល្អ

**កំណត់ចំណាំផ្សេងៗ** ១៨៣

**លិបិក្រមតាមព្រះគម្ពីរ** ១៨៩

# បុព្វកថា

**កម្រងសៀវភៅក្រុម 9Marks** ជាសៀវភៅដែលរែកញែកលើគំនិតសំខាន់ពីរយ៉ាង។ ទីមួយ ពួកជំនុំតាមតំបន់មានសារៈសំខាន់ចំពោះជីវិតគ្រីស្ទបរិស័ទលើសពីអ្វីដែលគ្រីស្ទបរិស័ទជាច្រើន នៅបច្ចុប្បន្ននេះ អាចនឹងគិតដល់ទៅទៀត។ យើងអាចហៅសៀវភៅមួយក្បាលដែលមានចំណងជើង «តើសមាជិកពួកជំនុំដែលមានសុខភាពល្អជាអ្វី?» ម្យ៉ាងទៀតថា «តើគ្រីស្ទបរិស័ទដែលមានសុខភាពល្អជាអ្វី?» បានដែរ។ យើងជឿថា គ្រីស្ទបរិស័ទដែលមានសុខភាពល្អ ក៏ជាសមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់ផងដែរ។

ទីពីរ ពួកជំនុំនៅតាមតំបន់ចម្រើនឡើងនៅក្នុងជីវិត ហើយនិងចម្រើនឡើងខាងឯកម្លាំង នៅពេលដែលពួកគាត់យកព្រះបន្ទូលរបស់ព្រះជាគោល។ ព្រះជាម្ចាស់មានព្រះបន្ទូល។ ពួកជំនុំគួរតែស្ដាប់ ហើយធ្វើតាម។ វាសាមញ្ញដូចហ្នឹង។ នៅពេលដែលពួកជំនុំស្ដាប់ ហើយធ្វើតាម ពួកជំនុំនោះនឹងចាប់ផ្ដើមមានលក្ខណៈដូចនឹងព្រះមួយអង្គដែលពួកជំនុំកំពុងតែដើរតាមជាមិនខាន។ ពួកជំនុំនោះនឹងឆ្លុះបញ្ចាំងអំពីសេចក្ដីស្រឡាញ់ និងសេចក្ដីបរិសុទ្ធរបស់ទ្រង់។ ពួកជំនុំនោះនឹងបង្ហាញអំពីសិរីល្អរបស់ទ្រង់។ ពួកជំនុំមួយនោះក៏នឹងមានលក្ខណៈដូចទ្រង់ នៅពេលដែលពួក

ជំនុំនោះស្តាប់ទ្រង់។

ដោយសេចក្តីនេះ មិត្តអ្នកអានអាចនឹងកត់សម្គាល់ឃើញថា “សញ្ញាសម្គាល់ទាំង៩” គឺជាការដកស្រង់ចេញពីសៀវភៅរបស់លោក ម៉ាក ដិវើរ នៅឆ្នាំ២០០១ ដែលមានចំណងជើងថា សញ្ញាសម្គាល់ទាំង៩នៃពួកជំនុំដែលមានសុខភាពល្អ (Nine Marks of a Healthy Church, Crossway Books) មានការចាប់ផ្តើមជាមួយនឹងព្រះគម្ពីរ។

- សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ
- ទេវវិទ្យាតាមព្រះគម្ពីរ
- ការយល់ដឹងអំពីដំណឹងល្អតាមព្រះគម្ពីរ
- ការយល់ពីការក្លាយជាគ្រីស្ទបរិស័ទតាមព្រះគម្ពីរ
- ការយល់ពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ
- ការយល់ដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ
- ការយល់ពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ
- ការយល់ពីការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ
- ការយល់ពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ

នៅមានចំណុចជាច្រើនទៀតដែលយើងអាចលើកឡើងអំពីអ្វីដែលពួកជំនុំគួរធ្វើ ដើម្បីឲ្យបានសុខភាពល្អ ដូចជាការអធិស្ឋានជាដើម។ ប៉ុន្តែ ការអនុវត្តទាំង៩នេះគឺជាការអនុវត្តដែលយើងជឿថា ត្រូវបានគេមើលរំលងជាញឹកញាប់ជាងគេបំផុត (មិនដូចជាសេចក្តីអធិស្ឋានទេ)។ ដូច្នេះ គំនិតជាមូលដ្ឋានរបស់យើងដែលយើងចង់លើកឡើងទៅកាន់ពួកជំនុំគឺថា កុំឲ្យមើលទៅកាន់ការអនុវត្តបែបជំនួញដ៏ល្អបំផុត ឬក៏របៀបសម័យថ្មីឡើយ

9Marks Online PDF

តែចូរសម្លឹងមើលទៅឯព្រះជាម្ចាស់វិញ។ សូមចាប់ផ្តើមដោយស្តាប់ព្រះបន្ទូលរបស់ព្រះជាថ្មីម្តងទៀតវិញ។

ដោយព្រោះការនេះ ទើបសៀវភៅភាគ 9Marks ចាប់ផ្តើមមានឡើង។ គោលបំណងនៃភាគទាំងអស់នេះគឺ ដើម្បីពិនិត្យមើលសញ្ញាសម្គាល់ទាំង៩ឲ្យកាន់តែច្បាស់ ហើយពីជ្រុងផ្សេងៗ។ ជ្រុងខ្លះផ្តោតទៅលើគ្រូគង្វាល។ ជ្រុងខ្លះទៀតផ្តោតទៅលើសមាជិកពួកជំនុំ។ យើងសង្ឃឹមថាគ្រប់ជ្រុង ទាំងអស់នឹងរួមបញ្ចូលគ្នានូវការពិនិត្យដោយប្រុងប្រយ័ត្នតាមព្រះគម្ពីរ ការឆ្លុះបញ្ចាំងអំពីទេវវិទ្យា ការពិចារណាខាងវប្បធម៌ ការប្រើប្រាស់ជាប្រយោជន៍ជារួម ហើយសូម្បីទាំងផ្នែកតូចៗមួយចំនួននៃការលើកទឹកសម្រាប់បុគ្គលម្នាក់ៗ។ សៀវភៅគ្រីស្ទបរិស័ទដែលល្អបំផុត គឺតែងតែទាក់ទងទៅនឹងការសិក្សាអំពីទេវវិទ្យា និងការអនុវត្ត។

យើងអធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រើប្រាស់សៀវភៅនេះ ហើយនិងសៀវភៅដទៃទៀតក្នុងភាគ ដើម្បីជួយរៀបចំក្រុមជំនុំ ដែលជាកូនក្រមុំរបស់ទ្រង់ ឲ្យមានភាពស្រស់បំព្រង និងមានសិរីល្អសម្រាប់ថ្ងៃដែលទ្រង់នឹងយាងមកវិញ។

9Marks Online PDF

# អារម្ភកថា

**«បងប្អូនស្ងួនភ្ងាអើយ»។** នៅថ្ងៃអាទិត្យពេលព្រឹក នេះជាពាក្យដែលលោកគ្រូ ថាប៊ីធី (Thabiti) តែងតែនិយាយ ដើម្បីថ្លែងកិច្ចស្វាគមន៍ទៅដល់ពួកជំនុំដែលពួកយើងទាំងអស់គ្នាមើលខុសត្រូវលើ។ ហើយគាត់ពិតជាមានន័យដូច្នោះមែន។ គាត់ស្រឡាញ់ពួកគេ ហើយពួកគេក៏ស្រឡាញ់គាត់ដូចគ្នាដែរ។ សមាជិកដែលមានវ័យចំណាស់មួយចំនួនមិនអាចហៅឈ្មោះរបស់គាត់បានត្រឹមត្រូវទេ ថាប៊ីធី ប៉ុន្តែពួកគាត់ដឹងថាលោកគ្រូ ថាប៊ីធី ពិតជាមានន័យដូចអ្វីដែលនិយាយនៅពេលដែលគាត់ហៅពួកគេថា «បងប្អូនស្ងួនភ្ងាអើយ» មែន។

«អរុណសួស្តី បងប្អូនស្ងួនភ្ងាអើយ»។ ខ្ញុំនៅតែចាំពីសម្លេងដែលនិយាយពាក្យនេះដល់សព្វថ្ងៃនេះ។

នោះក៏ជាពាក្យដែលសាវ័ក យ៉ូហាន បានប្រើម្តងហើយម្តងទៀតនៅក្នុងសំបុត្ររបស់គាត់ ទៅកាន់ពួកជំនុំដំបូងមួយចំនួនផងដែរ។ ដោយការទំនុកបម្រុងរបស់ព្រះ សំបុត្ររបស់សាវ័ក យ៉ូហាន និងរួមទាំងសំបុត្រដទៃទៀត នៅក្នុងព្រះគម្ពីរសញ្ញាថ្មីបានប្រាប់យើងឲ្យដឹងអំពីអត្ថន័យក្នុងការធ្វើជាគ្រីស្ទបរិស័ទជាមួយគ្នា។ សំបុត្រទាំងអស់នោះបានប្រាប់ពីអត្ថន័យក្នុងការធ្វើជាសមាជិកក្នុងពួកជំនុំ ហើយនេះក៏ជាអ្វីដែលសៀវភៅតូចនេះនឹង

9Marks Online PDF

រៀបរាប់ផងដែរ។

លោកគ្រូ ថាប៊ីធី បានដឹងតាមរយៈបទពិសោធន៍ថា ការរស់នៅជាគ្រីស្ទបរិស័ទ មិនមែនជាអ្វីម៉្យាងដែលយើងគួរធ្វើតែម្នាក់ឯងនោះទេ។ ការរស់នៅជាគ្រីស្ទបរិស័ទគឺជារឿងផ្ទាល់ខ្លួនមួយ តែមិនមែនជារឿងឯកជននោះទេ។ នៅពេលដែលលោកអ្នកបានកើតជាថ្មី នោះលោកអ្នកក៏បានកើតចូលមកឯគ្រួសារមួយដែរ។ ហើយគ្រួសារនោះមិនត្រឹមតែជាមហាគ្រួសារគ្រីស្ទបរិស័ទ ដែលមានសាច់ញាតិច្រើននៅទូទាំងពិភពលោកប៉ុណ្ណោះទេ ប៉ុន្តែក៏ជាគ្រួសារគោលនៃពួកជំនុំក្នុងតំបន់មួយផងដែរ។

ក្នុងនាមខ្ញុំជាសមាជិកក្រុមជំនុំម្នាក់ អស់រយៈពេលជាច្រើនឆ្នាំ ខ្ញុំមានសេចក្ដីអំណរដែលខ្ញុំបានស្គាល់ លោកគ្រូ ថាប៊ីធី និងប្រពន្ធរបស់គាត់ឈ្មោះលោកស្រី គ្រីស្ទី (Kristie)។ ខ្ញុំចាំអំពីថ្ងៃអាទិត្យដំបូងដែលខ្ញុំបានជួប លោកគ្រូ ថាប៊ីធី។ ខ្ញុំឃើញថាគាត់ជាមនុស្សដែលគួរឲ្យចាប់អារម្មណ៍មែនទែន (យើងអាចប្រៀបធៀបថាគាត់ជាកន្លែងផ្ដល់ប្រឹក្សាមួយ “think tank”) គាត់ជាមនុស្សគួរឲ្យគោរព (គាត់ចេះលៃលកតាមកាលៈទេសៈ) និងជាមនុស្សម្នាក់ដែលគិតបានហ្មត់ចត់ (គាត់គិតដោយចេះវាស់វែងលើពាក្យពេចន៍របស់គាត់)។ ប៉ុន្តែ គាត់មិនមែនគ្រាន់តែជាមនុស្សដែលមានគំនិតឈ្លាសវៃម្នាក់ប៉ុណ្ណោះទេ។ គាត់ក៏ជាមនុស្សម្នាក់ដែលមានដួងចិត្តដែរ។ ភ្លាមនោះ គាត់ក៏បានចាប់ផ្ដើមយកចិត្តទុកដាក់ជាមួយនឹងជីវិតរបស់អ្នកពួកជំនុំ។ ក្នុងរយៈពេលតែបីបួនសប្ដាហ៍លោក ថាប៊ីធី បានចាប់ផ្ដើមជួយដឹកនាំពួកជំនុំ។ ទោះបើបីបួនឆ្នាំមុនពេលដែលគេទទួលស្គាល់គាត់ថាជា *អ្នកចាស់ទុំ* ម្នាក់ (អ្នកដឹកនាំ) ក៏ដោយក៏តាមពិតទៅ គាត់ជាអ្នកដែលកំពុងតែក្លាយជាអ្នកដឹកនាំពួកជំនុំម្នាក់រួចស្រេចទៅហើយ។

ការទាំងអស់នេះបង្ហាញថាលោកគ្រូ ថាប៊ីធី យល់អំពីគំនិតដែលថា

9Marks Online PDF

ចៀមត្រូវតែនៅក្នុងក្រោលចៀម ហើយខ្ញុំបានឃើញថា គាត់ជាសមាជិកដ៏ល្អម្នាក់នៃក្រោលចៀម ហើយក៏ជាអ្នកគង្វាលហ្វូងចៀមរបស់ព្រះដ៏ពូកែម្នាក់ទៀតផង។

ខ្ញុំសូមនិយាយតែប៉ុណ្ណេះចុះ។ គោលបំណងរបស់យើងគឺឲ្យសៀវភៅនេះនៅខ្លី។ ខ្ញុំសូមអញ្ជើញលោកអ្នកអានឥឡូវនេះ ដើម្បីឲ្យលោកអ្នកនឹងទទួលបានអត្ថប្រយោជន៍។ ប៉ុន្តែ សូមចំណាយពេលអធិស្ឋានបន្តិចមុនពេលលោកអ្នកចាប់ផ្ដើមអាន។ សូមអធិស្ឋានសូមឲ្យព្រះជាម្ចាស់ប្រើប្រាស់លោកគ្រូ ថាប៊ីធី នៅក្នុងជីវិតរបស់លោកអ្នក ដូចដែលទ្រង់បានប្រើប្រាស់គាត់ នៅក្នុងជីវិតរបស់អ្នកដទៃជាច្រើនទៀតផងដែរ។ ចូរអធិស្ឋានសូមឲ្យទ្រង់ប្រើសៀវភៅនេះ ដើម្បីជួយដល់លោកអ្នកឲ្យបានស្គាល់ ហើយស្រឡាញ់ដល់ពួកជំនុំតាមតំបន់របស់លោកអ្នក ក្នុងរបៀបមួយដែលលោកអ្នកមិនធ្លាប់មានពីមុនមក។ ហើយនៅពេលដែលលោកអ្នកស្គាល់ និងស្រឡាញ់ដល់ពួកជំនុំរបស់ខ្លួន ចូរអធិស្ឋានទូលសូមឲ្យលោកអ្នកកាន់តែស្គាល់ និងចេះបង្ហាញសេចក្ដីស្រឡាញ់របស់ព្រះជាម្ចាស់កាន់តែច្រើនឡើងៗ។

បងប្អូនស្ងួនភ្ងាអើយ! សូមព្រះប្រទានពរ ហើយអានសៀវភៅនេះដោយរីករាយចុះ។ សម្រាប់ការសញ្ជឹងគិតបន្ថែម

សូមជ្រើសរើសក្រុមជាមួយមិត្តភក្តិ និងសមាជិកក្នុងពួកជំនុំ ហើយពិចារណា និងពិភាក្សាសំណួរដែលបានសួរនៅទំព័រទី ៧៧-៧៨។

លោកគ្រូ ម៉ាក ដិវើរ
ក្រុង Washington DC
ខែកញ្ញា ឆ្នាំ២០០៧

9Marks Online PDF

# សេចក្ដីផ្ដើម

**ប្អូនស្រី ចន្ទី បានធ្វើឲ្យខ្ញុំភ្ញាក់ផ្អើលមែនទែន** នៅពេលដែលគាត់ចាប់ផ្ដើម យំនៅពេលពួកយើងកំពុងសម្ភាសន៍គាត់សម្រាប់ចូលជាសមាជិកថ្មី។ ម្ភៃនាទីដំបូងនៃការសម្ភាសន៍មានដំណើរដូចធម្មតា។ គាត់បានរៀបរាប់អំពីកុមារភាពរបស់គាត់កាលគាត់ធំឡើង នៅក្នុងគ្រួសារគ្រីស្ទបរិស័ទមួយ អំពីការភ័យខ្លាចចាលគាត់នៅរៀនវិទ្យាល័យ និងអំពីអំឡុងពេលនៃការរស់នៅ របស់គាត់ជាមនុស្សអារ៉ាំសែកាលនៅមហាវិទ្យាល័យ។ បន្ទាប់មក គាត់បាននិយាយដោយអំណរអំពីបទពិសោធន៍នៃការផ្លាស់ប្រែចិត្តទទួលជឿព្រះនៅក្នុងក្រុមជំនុំមួយដែលនៅស្រុកមួយ ដែលជាពួកជំនុំតាមតំបន់របស់នាង។

ហេតុដូច្នេះហើយបានជាខ្ញុំមិនរំពឹងថាគាត់នឹងយំ នៅពេលដែលខ្ញុំសួរគាត់ថា “តើពួកជំនុំនោះជួយប្អូនស្រីខាងព្រលឹងវិញ្ញាណយ៉ាងដូចម្ដេចដែរ? តើប្អូនស្រីបានរីកចម្រើនខាងឯព្រលឹងវិញ្ញាណនៅទីនោះដែរឬទេ?”

បន្ទាប់ពីស្ងាត់មួយសន្ទុះ គាត់ក៏បានពន្យល់ថា “ខ្ញុំបានរំពឹងថាបន្ទាប់ពីការផ្លាស់ប្រែជឿហើយនោះ នឹងមានមនុស្សណាម្នាក់មកជួយខ្ញុំឲ្យរីកចម្រើនឡើងជាគ្រីស្ទបរិស័ទម្នាក់”។ គាត់បាននិយាយបន្តដោយមានការភាន់ភាំង និងខឹងបន្ថិចថា “ប៉ុន្តែ វាប្រៀបបីដូចជាគេបានដាក់ខ្ញុំ

9Marks Online PDF

កៀនជញ្ជាំងត្រង់ណាមួយ ប្រៀបបីដូចជាគេចង់ឲ្យខ្ញុំត្រិះរិះពិចារណាអ្វីៗដោយខ្លួនឯង។ នោះជាពេលដែលពិបាក ហើយឯកោណាស់សម្រាប់ខ្ញុំ»។

តើមានមនុស្សដូចប្អូនស្រី ចន្ទី ប៉ុន្មាននាក់ដែលលោកអ្នកធ្លាប់ជួបនៅក្នុងជីវិតរបស់ខ្លួន? ប្រហែលលោកអ្នកកំពុងតែស្ថិតនៅក្នុងស្ថានភាពដូចប្អូនស្រី ចន្ទី ដែរមើលទៅ។ ប្រហែលជាលោកអ្នកក៏ធ្លាប់បានចំណាយពេលដ៏យូរនៅក្នុងពួកជំនុំណាមួយ ឬក្នុងពួកជំនុំជាច្រើន។ ហើយប្រហែលជាជីវិតជាគ្រីស្ទបរិស័ទរបស់លោកអ្នកក៏មិនសូវខុសគ្នាប៉ុន្មានពីជីវិតរបស់ប្អូនស្រី ចន្ទី  នេះទេដឹង។ លោកអ្នកបានទទួលជឿដោយទឹកមុខសប្បាយស្រស់ថ្លា ប្រកបដោយថាមពល និងឧស្សាហ៍ និងមានបំណងចិត្តចង់ធ្វើការធំៗសម្រាប់ព្រះអម្ចាស់។ ប៉ុន្តែ មិនយូរប៉ុន្មាន លោកអ្នកឆ្ងល់ខ្លួនឯងថា «តើខ្ញុំគួរធ្វើអ្វីខ្លះក្នុងនាមជាសមាជិកនៃពួកជំនុំមួយនេះ?»

ប្រសិនបើដូច្នេះមែន នោះសៀវភៅនេះគឺសម្រាប់លោកអ្នកហើយ។ ហើយប្រសិនបើមិនដូច្នេះទេ នោះសៀវភៅនេះក៏នៅតែសម្រាប់លោកអ្នកដែរ។

មិនថាជីវិតជាគ្រីស្ទបរិស័ទរបស់លោកអ្នកបានចាប់ផ្តើមពីម្សិលមិញ ឬក៏ពីសាមសិបឆ្នាំមុនក៏ដោយ ក៏បំណងព្រះហឫទ័យរបស់ព្រះអម្ចាស់គឺចង់ឲ្យលោកអ្នកធ្វើជាអវយវៈដ៏សកម្ម និងជាអ្វីដែលសំខាន់នៅក្នុងរូបកាយរបស់ទ្រង់ ពោលគឺពួកជំនុំតាមតំបន់របស់លោកអ្នក។ ទ្រង់សព្វព្រះហឫទ័យចង់ឲ្យលោកអ្នកមានបទពិសោធន៍ថា ពួកជំនុំរបស់លោកអ្នកគឺកន្លែងដែលអស្ចារ្យ ហើយមានន័យយ៉ាងជ្រាលជ្រៅចំពោះលោកអ្នកជាជាងកន្លែងណាទាំងអស់នៅលើផែនដីនេះ។ ទ្រង់សព្វព្រះហឫទ័យចង់ឲ្យពួកជំនុំរបស់ទ្រង់ក្លាយជាកន្លែងដែលមានសុខភាពល្អ ហើយក៏សម្រាប់ឲ្យសមាជិកនៃពួកជំនុំនោះមានសុខភាពល្អផងដែរ។

9Marks Online PDF

យើងបានសរសេរសៀវភៅនេះឡើងក្នុងសេចក្ដីសង្ឃឹមថា លោកអ្នកអាចនឹងស្វែងរក ឬក៏ស្វែងរកម្ដងទៀតនូវអត្ថន័យអំពីសមាជិកភាពក្នុងពួកជំនុំដែលមានសុខភាពល្អ និងការរួមចំណែកក្នុងសុខភាពជារួមនៃពួកជំនុំទាំងមូល។

*នៅក្នុងឆ្នាំ ២០១៦* អង្គការសកម្មភាពកម្ពុជាបានបោះពុម្ពសៀវភៅរបស់ លោក ម៉ាក ដិវើរ ដែលមានចំណងជើងថា *«ពួកជំនុំដែលមានសុខភាពល្អ»*។ សៀវភៅនោះបានផ្ដល់នូវនិយមន័យមួយបែបអំពីលក្ខណៈនៃពួកជំនុំដែលមានសុខភាពល្អតាមព្រះគម្ពីរ និងតាមប្រវត្តិសាស្ត្រ ដែលបានតម្រង់គំនិតរបស់គ្រូគង្វាល និងពួកអ្នកដឹកនាំពួកជំនុំជាច្រើននាក់ តាំងពីពេលដែលសៀវភៅនោះត្រូវបានបោះពុម្ពជាលើកដំបូងមក។

សៀវភៅនេះទទួលឥទ្ធិពលពីសៀវភៅ *«ពួកជំនុំដែលមានសុខភាពល្អ»* ទោះបីជាវាព្យាយាមឆ្លើយតបនឹងសំណួរមួយដែលខុសគ្នាតែបន្តិចក៏ដោយ៖ «តើសមាជិកពួកជំនុំដែលមានសុខភាពល្អមានអត្ថន័យយ៉ាងដូចម្ដេចតាមអត្ថន័យព្រះគម្ពីរ?» សៀវភៅព្យាយាមលើកទឹកចិត្តដល់អ្នករួមចំណែកជួយពួកជំនុំតាមតំបន់ឲ្យបានឆ្លុះបញ្ចាំងអំពីសិរីល្អរបស់ព្រះជាម្ចាស់ឲ្យកាន់តែច្រើនឡើងៗ។

តើលោកអ្នក ដែលជាសមាជិកម្នាក់នៃពួកជំនុំតាមតំបន់មួយ អាចរួមចំណែកដោយរបៀបណាចំពោះសុខភាពនៃពួកជំនុំរបស់លោកអ្នក?

មានស្ត្រីម្នាក់ឈ្មោះលោកស្រី ប៊ើន (Burns) បានស្ទាក់និយាយជាមួយខ្ញុំបន្ទាប់ពីកម្មវិធីថ្វាយបង្គំនៅពេលព្រឹកនាថ្ងៃអាទិត្យមួយ។ គាត់បានខ្វល់ខ្វាយអំពីការខ្លះដែលកំពុងតែផ្លាស់ប្ដូរនៅក្នុងក្រុមជំនុំ និងការខ្លះទៀត

ដែលនៅតែដដែលមិនមានការផ្លាស់ប្តូរ។ នៅពេលនោះ ខ្ញុំកំពុងតែជម្រាបលាដល់អ្នកដែលកំពុងត្រឡប់ទៅផ្ទះវិញ ហើយនៅពេលនោះដែរខ្ញុំក៏បានងក់ក្បាលយ៉ាងសុភាពដល់លោកស្រី ប៊ើន ខណៈពេលដែលគាត់ត្អូញត្អែរអំពីការមិនពេញចិត្តរបស់គាត់។

នៅពេលគាត់ឈប់ក្នុងការនិយាយដដែលៗបន្តិច គំនិតដំបូងរបស់ខ្ញុំគឺចង់សួរគាត់ថា «បើអញ្ចឹង តើលោកស្រីចង់ឲ្យខ្ញុំធ្វើអ្វីចំពោះស្ថានភាពទាំងនេះ?» ប៉ុន្តែ នៅក្នុងពេលភ្លាមនោះ ចិត្តរបស់ខ្ញុំគិតថា មិនគួរសួរគាត់សំណួរនេះទេ។ ផ្ទុយទៅវិញខ្ញុំក៏សួរគាត់ថា «ដូច្នេះ តើលោកស្រីផ្ទាល់នឹងធ្វើអ្វីអំពីស្ថានភាពពួកជំនុំនេះ? តើលោកស្រី*ផ្ទាល់*នឹងក្លាយជាសមាជិកល្អជាងមុនម្នាក់ ហើយរួមចំណែកក្នុងសុខភាពរបស់គ្រួសាររបស់ព្រះដោយរបៀបណា?»

សំណួរទាំងនេះគឺសម្រាប់គ្រីស្ទបរិស័ទគ្រប់ៗរូប មិនមែនតែសម្រាប់អស់អ្នកដែលត្អូញត្អែរដូចជាលោកស្រី ប៊ើន នោះទេ។ សុខភាពរបស់ពួកជំនុំតាមតំបន់គឺពឹងលើការស្ម័គ្រចិត្តរបស់សមាជិកពួកជំនុំនោះ ក្នុងការពិនិត្យមើលចិត្ត កែគំនិត និងដាក់ដៃខ្លួនបម្រើក្នុងព័ន្ធកិច្ចរបស់ព្រះ។

ជំពូកនានាខាងមុខនេះនឹងបង្ហាញអំពីសំណើមួយ ដើម្បីឲ្យយើងក្លាយជាសមាជិកដែលមានសុខភាពល្អនៅក្នុងពួកជំនុំតាមតំបន់។ ជំពូកទាំងនោះបានលើកឡើងដោយសន្មតថា លោកអ្នកបានក្លាយជាសមាជិកនៅក្នុងពួកជំនុំតាមតំបន់ណាមួយរួចហើយ ហើយថាទំនងលោកអ្នកប្រហែលជាត្រូវការការជំរុញតែបន្តិច ឬក៏ឱកាសក្នុងការគិតដល់បញ្ហា

9Marks Online PDF

គន្លឹះមួយចំនួនប៉ុណ្ណោះ។[១]

ជំពូក១នឹងលើកទឹកចិត្តលោកអ្នកឲ្យ “ស្ដាប់សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ” ពីព្រះបន្ទូលរបស់ព្រះជាម្ចាស់។ សមាជិកពួកជំនុំដែលមានសុខភាពល្អ គឺជាអ្នកដែលស្ដាប់ក្នុងរបៀបជាក់លាក់មួយដល់ព្រះបន្ទូលរបស់ព្រះជាម្ចាស់ នៅពេលដែលព្រះបន្ទូលនោះត្រូវបានអធិប្បាយឡើង ឬក៏សិក្សា—ពោលគឺពួកគេអនុញ្ញាតឲ្យតែព្រះកំណត់របៀបវារៈដោយការស្វែងរកជានិច្ច ដើម្បីឲ្យបានឮពីអត្ថន័យពិតនៃបទគម្ពីរនោះ ដើម្បីឲ្យពួកគេអាចអនុវត្តព្រះបន្ទូលនោះនៅក្នុងជីវិតរបស់ខ្លួនបាន។

នៅក្នុងជំពូក២ យើងបានលើកទឹកចិត្តសមាជិកពួកជំនុំឲ្យប្ដេជ្ញាចិត្តក្នុងការសិក្សាស្រាវជ្រាវពីប្រធានបទគ្រប់ជ្រុងជ្រោយនៅក្នុងព្រះគម្ពីរ។ បើនិយាយម្យ៉ាងវិញទៀត គឺជំរុញឲ្យពួកគេក្លាយជា “ទេវវិទូព្រះគម្ពីរ” ដោយការប្រឹងប្រែងមួយ ដើម្បីការពារខ្លួន និងការពារពួកជំនុំពីសេចក្ដីបង្រៀនខុសឆ្គង។

ជំពូក៣ អញ្ជើញសមាជិកពួកជំនុំឲ្យបានជ្រាបជោគក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទ។ ជាដំណឹងល្អដែលសង្គ្រោះយើង (រ៉ូម ១:១៦) ហើយក៏ជាដំណឹងល្អដែលទ្រទ្រង់ និងលើកទឹកចិត្តយើងនៅក្នុងជីវិតរស់នៅជាគ្រីស្ទបរិស័ទប្រចាំថ្ងៃ។

ការស្ដាប់សេចក្ដីអធិប្បាយពន្យល់តាមអត្ថន័យពីព្រះបន្ទូល ការ

---

១ ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ ប៉ុន្តែលោកអ្នកមិនមែនជាសមាជិកម្នាក់នៅក្នុងក្រុមជំនុំណាមួយ សូមអនុញ្ញាតឲ្យខ្ញុំណែនាំសៀវភៅដ៏ល្អមួយក្បាល ដែលបានសរសេរឡើង ដើម្បីជួយឲ្យលោកអ្នកគិតអំពីមូលហេតុដែលលោកអ្នកគួរក្លាយជាសមាជិកនៅក្នុងក្រុមជំនុំ។ ចំណងជើងសៀវភៅជាភាសាអង់គ្លេសគឺ៖ Stop Dating the Church និពន្ធដោយលោក Joshua Harris (Sisters, OR: Multnomah, ឆ្នាំ២០០៤)។

9Marks Online PDF

សិក្សាស្រាវជ្រាវពីប្រធានបទគ្រប់ជ្រុងជ្រោយ និងការរស់នៅក្នុងជីវិតដែលជោគជាំទៅដោយដំណឹងល្អក៏នឹងមិនអាចទៅរួចបានទេ ប្រសិនបើលោកអ្នកគ្មានចិត្តចង់ និងការខំប្រឹងក្លាយជាអ្នកប្រកាសដំណឹងល្អតាមព្រះគម្ពីរ។ ជំពូក៤ និង៥ផ្តល់សំណើមួយចំនួន ដើម្បីគិតអំពីការប្រែចិត្ត និងការប្រកាសដំណឹងល្អនៅក្នុងរបៀបដែលមានសុខភាពល្អ ហើយតាមព្រះគម្ពីរ។

ជំពូក៦ ហៅឲ្យចូលមកក្នុងការប្ដេជ្ញាចិត្តដ៏មឹុងម៉ាត់ ហើយនិងមានសកម្មភាពក្នុងការធ្វើជាសមាជិកនៃពួកជំនុំតាមតំបន់។ បន្ទាប់មកជំពូក៧ផ្តល់នូវមូលហេតុផលមួយដែលថា ហេតុអ្វីបានជាសមាជិកភាពពួកជំនុំដែលមានការប្ដេជ្ញាចិត្តពិតជាមានសារៈសំខាន់ណាស់៖ ពោលគឺពួកជំនុំតាបតំបន់គឺជាកន្លែងដែលគ្រីស្ទបរិស័ទមានបទពិសោធន៍ជាមួយនឹងការដាក់វិន័យ និងការកែតម្រង់ពីព្រះជាម្ចាស់។

ជំពូក៨ ពិនិត្យមើលការធំចម្រើនឡើងខាងឯវិញ្ញាណតាមគំនិតនៅក្នុងព្រះគម្ពីរ។ រីឯជំពូក៩វិញ ផ្តល់អនុសាសន៍មួយចំនួន ដើម្បីគាំទ្រដឹកនាំនៃពួកជំនុំតាមតំបន់របស់លោកអ្នក ដោយមានប្រសិទ្ធភាព។

ជំពូក១០ គឺជាការត្រាស់ហៅឲ្យយើងគិតថា សេចក្តីអធិស្ឋានជាផ្នែកដ៏សំខាន់មួយ ដើម្បីឲ្យក្លាយជាសមាជិកពួកជំនុំម្នាក់ដែលមានសុខភាពល្អ។ ការផ្តល់ឲ្យនូវការពិភាក្សាខ្លីមួយលើមូលដ្ឋាននៃបទគម្ពីរសម្រាប់សេចក្តីអធិស្ឋាន និងការស្នើឡើងខ្លះសម្រាប់សមាជិកពួកជំនុំដែលមានសុខភាពល្អក្នុងការដាក់បញ្ចូលទៅក្នុងជីវិតអធិស្ឋានរបស់ពួកគាត់ផ្ទាល់។

នៅក្នុងជំពូកនីមួយៗយើងក៏មានផ្តល់បញ្ចូលអំណានយោបល់ខ្លះៗសម្រាប់ការសិក្សាបន្ថែមទៀតផងដែរ។ មិនមែនមានតែចំណុចទាំងនេះទេ សម្រាប់ឲ្យសមាជិកពួកជំនុំមានសុខភាពល្អ ពីព្រោះក៏នៅមានចំណុច

ផ្សេងៗទៀតដែលមានសារៈសំខាន់ដែរ។ ប៉ុន្តែ ខ្ញុំសង្ឃឹមថា ការទាំងអស់នេះនឹងជំរុញចិត្តយើងទាំងអស់គ្នាឲ្យមានសេចក្ដីស្រឡាញ់ និងទង្វើល្អសម្រាប់ជាសិរីល្អដល់ព្រះគ្រីស្ទ និងជាសេចក្ដីលម្អនៃកូនក្រមុំរបស់ទ្រង់។

ឱព្រះអម្ចាស់ដ៏ពេញដោយអធិបតេយ្យភាពអើយ សូមព្រះអង្គបានប្រទានពរដល់ទូលបង្គំយើងខ្ញុំ ដែលជារាស្ត្ររបស់ផងព្រះអង្គឲ្យទូលបង្គំ យើងខ្ញុំមានការបន្ទាបខ្លួនលើសពីធម្មតា សេចក្ដីរួបរួមតែមួយ សេចក្ដីអំណរ សេចក្ដីមេត្រី ហើយការយកចិត្តទុកដាក់ ចំពោះគ្នាទៅវិញទៅមក។ ទូលបង្គំយើងខ្ញុំអធិស្ឋានសូមឲ្យព្រះអង្គ បានធ្វើឲ្យរាស្ត្ររបស់ទ្រង់ទាំងអស់ មានសុខភាពល្អខាងឯវិញ្ញាណ និងបង្កើតផលផ្លែកាន់តែច្រើន មិនគ្រាន់តែជាបុគ្គលម្នាក់ៗនោះទេ ប៉ុន្តែជារូបកាយតែមួយផងដែរ ជាមនុស្សថ្មីម្នាក់ដែលធ្វើការរួមគ្នា ធ្វើការជាមួយគ្នា ដើម្បីឲ្យមានការរីកចម្រើនឡើងនៅក្នុងព្រះគ្រីស្ទ ហើយទាំងនៅក្នុងភាពពោរពេញនៃខ្ចាតរបស់ទ្រង់ផងដែរ។ សូមទ្រង់បានប្រទានពរដល់ការអាន ការស្ដាប់ និងការសិក្សាព្រះបន្ទូលរបស់ទ្រង់ឲ្យបានជាការថ្វាយសិរីល្អដល់ព្រះនាមទ្រង់។ ហើយឱព្រះអម្ចាស់អើយ! សូមទ្រង់បានសព្វព្រះហឫទ័យប្រើប្រាស់សៀវភៅតូចនេះនៅក្នុងរបៀបណាមួយ ដើម្បីឲ្យនគរទ្រង់បានរីកចម្រើន និងធ្វើឲ្យកូនក្រមុំរបស់ទ្រង់កាន់តែមានសេចក្ដីលម្អឡើងដែរ។ ឱព្រះវរបិតាអើយ! ទូលបង្គំយើងខ្ញុំសូមការទាំងអស់នេះដោយដឹងថា គ្មានអ្វីដែលពិបាកពេកសម្រាប់ទ្រង់ឡើយ ហើយទូលបង្គំយើងខ្ញុំសូមការទាំងអស់នេះដោយដឹងប្រាកដច្បាស់ ដោយសេចក្ដីជំនឿនៅក្នុងព្រះនាមព្រះយេស៊ូវគ្រីស្ទ។ អាម៉ែន។

សញ្ញាសម្គាល់ទី ១

# សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកស្តាប់សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

**តើអ្វីជា "ការស្តាប់សេចក្តីអធិប្បាយ តាមអត្ថន័យព្រះគម្ពីរ"?** មុនយើងឆ្លើយសំណួរនេះ យើងត្រូវផ្តល់និយមន័យលើពាក្យ "សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ" ជាមុនសិន។ សញ្ញាសម្គាល់ទីមួយ និងសំខាន់បំផុតនៃពួកជំនុំដែលមានសុខភាពល្អ គឺការអធិប្បាយតាមអត្ថន័យព្រះបន្ទូល។ សេចក្តីអធិប្បាយតាមអត្ថន័យព្រះបន្ទូល មិនមែនគ្រាន់តែជាការបង្កើតឲ្យមានសេចក្តីអត្ថាធិប្បាយ សម្រាយពន្យល់អំពីព្រះបន្ទូលប៉ុណ្ណោះទេ។ ប៉ុន្តែ សេចក្តីអធិប្បាយតាមអត្ថន័យព្រះបន្ទូល គឺជាការអធិប្បាយដែលដកយកគំនិតសំខាន់ពីគំនិតនៃអត្ថបទព្រះគម្ពីរនៅកន្លែងណាមួយ។[១] ប្រសិនពួកជំនុំចង់មានសុខភាពល្អ នោះគ្រូគង្វាល និងគ្រូបង្រៀនត្រូវតែប្តេជ្ញាចិត្តក្នុងការស្វែងរកអត្ថន័យក្នុងអត្ថបទព្រះគម្ពីរ ហើយអនុញ្ញាត

---

១ លោក Mark Dever, *Nine Marks of a Healthy Church* (Wheaton, IL: Crossway Books, ឆ្នាំ២០០៤), ទំព័រ៤០។

9Marks Online PDF

ឲ្យអត្ថន័យនោះ កំណត់របៀបវារៈជាមួយនឹងពួកជំនុំរបស់ពួកគាត់។

មានការទាញយក សេចក្ដីសន្និដ្ឋានដ៏មានសារៈសំខាន់មួយ សម្រាប់សមាជិកគ្រប់រូបនៃពួកជំនុំតាមតំបន់។ ដូចដែលរបៀបនៃការអធិប្បាយរបស់គ្រូគង្វាលគួរតែត្រូវបានកំណត់ ដោយអត្ថន័យនៃបទគម្ពីរយ៉ាងណា នោះរបៀបនៃការស្ដាប់របស់គ្រីស្ទបរិស័ទក៏គួរតែត្រូវបានជំរុញដោយអត្ថន័យនៃបទគម្ពីរយ៉ាងនោះដែរ។ នៅពេលដែលយើងស្ដាប់ការអធិប្បាយព្រះបន្ទូល យើងមិនគួរគ្រាន់តែស្ដាប់ដោយផ្ដោតសំខាន់លើ “ការណែនាំអំពីវិធីអនុវត្ត” នោះទេ។ ទោះបីជាព្រះគម្ពីរបង្រៀនយើងច្រើនអំពីការអនុវត្តប្រចាំថ្ងៃក៏ដោយ។ យើងក៏មិនគួរស្ដាប់ការអធិប្បាយនានា ដែលជំរុញឲ្យមានការគោរពឲ្យតម្លៃខ្លួនឯង ឬជំរុញឲ្យយើងទៅរកបុព្វហេតុនយោបាយ និងសង្គមនោះដែរ។ ផ្ទុយទៅវិញ ក្នុងនាមជាសមាជិកពួកជំនុំគ្រីស្ទបរិស័ទ យើងគួរតែស្ដាប់ដោយផ្ដោតសំខាន់លើ ព្រះសូរសៀង និងព្រះរាជសារនៃព្រះ ដូចដែលបានបង្ហាញនៅក្នុងព្រះបន្ទូលរបស់ទ្រង់។ យើងគួរស្ដាប់ ដើម្បីឲ្យបានឮនូវអ្វីដែលទ្រង់បានសរសេរចុះ នៅក្នុងសេចក្ដីស្រឡាញ់ដ៏ជ្រាបគ្រប់ការទាំងអស់របស់ទ្រង់ ដើម្បីជាសិរីល្អរបស់ទ្រង់ និងជាព្រះពរដល់យើង។

ដូច្នេះ តើការដែលខ្ញុំសរសេរថា “ការស្ដាប់តាមអត្ថន័យព្រះគម្ពីរ” នោះមានន័យយ៉ាងដូចម្ដេចឲ្យប្រាកដទៅ? ការស្ដាប់តាមអត្ថន័យព្រះគម្ពីរគឺជាការស្ដាប់យកអត្ថន័យចេញពីបទគម្ពីរ ហើយទទួលយកអត្ថន័យនោះជាគំនិតសំខាន់ ដើម្បីប្រកាន់ខ្ជាប់សម្រាប់ជីវិតផ្ទាល់ខ្លួនយើងម្នាក់ៗ និងជីវិតរួមគ្នាជាគ្រីស្ទបរិស័ទ។

9Marks Online PDF

## *តើអ្វីខ្លះជាអត្ថប្រយោជន៍នៃការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ?*

ទីមួយ៖ ការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ ផ្តល់ប្រយោជន៍ដល់យើង តាមរយៈការ*ជួយឲ្យយើងចេះស្រេកឃ្លានដល់ព្រះបន្ទូលរបស់ព្រះ*។ នៅពេលយើងផ្ទៀងត្រចៀក ស្តាប់ប្រភេទនៃការអធិប្បាយដែលយកគំនិតសំខាន់ពីអត្ថបទ ណាមួយនៅក្នុងបទគម្ពីរមកធ្វើជាចំណុចសំខាន់នៅក្នុងសេចក្តីអធិប្បាយ នោះយើងក៏នឹងកាន់តែមានទម្លាប់ស្តាប់ដល់ព្រះជាម្ចាស់។ យើងក៏ត្រឡប់ជាស្ទាត់ជំនាញក្នុងភាសានៃក្រុងស៊ីយ៉ូន ហើយជាអ្នកសន្ទនាក្នុងប្រធានបទនានារបស់អត្ថបទនោះ។ ព្រះបន្ទូល និងព្រះសូរសៀងរបស់ទ្រង់នឹងប្រែជាផ្អែមដល់យើង (ទំនុកតម្កើង ១១៩:១០៣-១០៤) ហើយនៅពេលដែលការនោះកើតឡើង នោះយើងក៏អាចរុញសម្លេងជាច្រើនទៀតដែលប្រជែងនឹងព្រះសូរសៀងរបស់ព្រះក្នុងការចង់មកគ្រប់គ្រងលើជីវិតរបស់យើងឲ្យទៅផ្ទៃខាងក្រោយវិញ។ ការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរផ្តល់ឲ្យយើងនូវត្រចៀកឮច្បាស់ក្នុងការស្តាប់ព្រះជាម្ចាស់។

អត្ថប្រយោជន៍ទីពីរ៖ គឺបន្តពីអត្ថប្រយោជន៍ទីមួយ។ ការស្តាប់តាមអត្ថន័យព្រះគម្ពីរ *ជួយយើងឲ្យផ្តោតលើបំណងព្រះហឫទ័យរបស់ព្រះ និងដើរតាមទ្រង់*។ របៀបវារៈរបស់យើងគឺសំខាន់ជាទីពីរវិញ។ របៀបវារៈរបស់គ្រូអធិប្បាយក្លាយជាសំខាន់ទីពីរវិញ។ របៀបវារៈរបស់ព្រះសម្រាប់រាស្ត្រទ្រង់ក្លាយជាចំណុចស្នូល ដែលរៀបចំចំណុចអាទិភាពរបស់យើងសារឡើងវិញ ហើយដឹកនាំយើងទៅក្នុងផ្លូវដែលថ្វាយសិរីល្អដល់ទ្រង់។ ព្រះអម្ចាស់ផ្ទាល់បានប្រកាសថា «ចៀមខ្ញុំវាស្តាប់ខ្ញុំ ហើយខ្ញុំស្គាល់វា ហើយវាដើរតាមខ្ញុំ» (យ៉ូហាន ១០:២៧)។ ការស្តាប់ព្រះសូរសៀងរបស់ព្រះយេស៊ូវដូចដែលបានឮនៅក្នុងព្រះបន្ទូលរបស់ទ្រង់គឺសំខាន់ណាស់ ដើម្បីឲ្យអាច

9Marks Online PDF

ដើរតាមទ្រង់បាន។

អត្ថប្រយោជន៍ទីបី៖ ការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ *ការពារជំណឿងល្អ និងជីវិតរបស់យើងពីសេចក្ដីពុករលួយ*។ ព្រះបន្ទូលបានប្រាប់យើងថា «ដ្បិតនឹងមានគ្រាមក ដែលគេមិនទ្រាំទ្រនឹងសេចក្ដីបង្រៀនដ៏ត្រឹមត្រូវទេ គឺគេនឹងមានត្រចៀករមាស់ ហើយនឹងហៅគ្រូកាន់តែច្រើនឡើង មកបង្រៀនឲ្យត្រូវចិត្ត គេនឹងងាកត្រចៀកចេញពីសេចក្ដីពិត បែរទៅតាមរឿងព្រេងវិញ» (២ធីម៉ូថេ ៤:៣-៤)។ ការដែលមិនបានស្ដាប់តាមអត្ថន័យ នៃព្រះគម្ពីរនឹងបង្កើតឲ្យមានផលវិបាកដ៏អាក្រក់។ គ្រូក្លែងក្លាយចូលមកឯពួកជំនុំ ហើយខ្ទប់ជំណឹងល្អមិនឲ្យចេញ។ នៅចុងបំផុតនោះគឺថា សេចក្ដីពិតត្រូវបានដាក់ជំនួសដោយរឿងព្រេង និងសេចក្ដីក្លែងក្លាយវិញ។ នៅពេលណាដែលសមាជិកពួកជំនុំមានទម្លាប់ និងចេះស្តាប់តាមអត្ថន័យតាមព្រះគម្ពីរ នោះពួកគាត់ចេះរក្សាខ្លួនដោយប្រឆាំងនឹងការមាន «ត្រចៀករមាស់» ព្រមទាំងការពារជំណឹងល្អពីសេចក្ដីពុករលួយទៀតផង។

អត្ថប្រយោជន៍ទីបួន៖ ការស្ដាប់តាមអត្ថន័យនៃព្រះគម្ពីរជំរុញ *ទឹកចិត្តដល់គ្រូគង្វាលដែលមានចិត្តស្មោះត្រង់*។ គ្រូប្រុសៗទាំងអស់នោះដែលបម្រើដោយស្មោះត្រង់នៅក្នុងព័ន្ធកិច្ចនៃព្រះបន្ទូល គឺស័ក្តិសមនឹងរាប់ជាគួរនឹងគោរពប្រតិបត្តិជាទ្វេគុណឡើងផង (១ធីម៉ូថេ ៥:១៧)។ គ្មានអ្វីដែលធ្វើឲ្យគ្រូប្រុសៗទាំងនេះបាក់ទឹកចិត្ត ឬខូចកិត្តិយសជាងការដែលមានពួកជំនុំដែលមិនយកចិត្តទុកដាក់ក្នុងការស្តាប់តាមព្រះបន្ទូលរបស់ព្រះនោះទេ។ គ្រូប្រុសៗដែលស្មោះត្រង់នឹងរីកចម្រើននៅពេលដែលអ្នកស្តាប់ ទទួលយកព្រះបន្ទូលដោយលូតលាស់។ ពួកគាត់នឹងកាន់តែមានសេចក្ដីក្លាហានឡើង នៅពេលពួកជំនុំរបស់ពួកគាត់បានផ្ទៀងត្រចៀកស្តាប់ព្រះសូរសៀង

របស់ព្រះអម្ចាស់ ហើយបង្ហាញចេញក្នុងជីវិតដែលស្តែងថា ពួកគេត្រូវបាន កែច្នៃដោយព្រះសូរសៀងនោះ។ ក្នុងនាមជាសមាជិកនៃពួកជំនុំ យើងអាច ថែរក្សាគ្រូគង្វាល និងគ្រូបង្រៀនរបស់យើង ហើយអាចជួយការពារមិនឲ្យ មានការបាក់ទឹកចិត្ត និងភាពនឿយហត់ ដោយយើងចេះមានទម្លាប់ស្តាប់ តាមអត្ថន័យនៃព្រះគម្ពីរបែបនេះ។

ទីប្រាំ៖ ការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ*ផ្តល់ជាប្រយោជន៍ដល់ពួកជំនុំ ដែលប្រជុំគ្នា*។ ម្តងហើយម្តងទៀត អ្នកសរសេរព្រះគម្ពីរសញ្ញាថ្មីបានលើក ទឹកចិត្តឲ្យពួកជំនុំតាមតំបន់ចេះរួបរួមគ្នា—គឺឲ្យមានគំនិតតែមួយ។ សាវ័ក ប៉ុល បានសរសេរទៅកាន់ពួកជំនុំតាមតំបន់មួយថា «បងប្អូនអើយ ខ្ញុំ ទូន្មានដល់អ្នករាល់គ្នា ដោយនូវព្រះនាមព្រះយេស៊ូវគ្រីស្ទ ជាព្រះអម្ចាស់ នៃយើងថា ចូរនិយាយសេចក្តីដដែលទាំងអស់គ្នា កុំឲ្យមានសេចក្តីបាក់ បែកក្នុងពួកអ្នករាល់គ្នាឡើយ ត្រូវឲ្យបានរួបរួមគ្នា ដោយមានចិត្តមានគំនិត តែ១វិញ» (១កូរិនថូស ១:១០ ហើយក៏សូមអានកណ្ឌគម្ពីរ រ៉ូម ១២:១៦; ២កូរិនថូស ១៣:១១; និង១ពេត្រុស ៣:៨ ផងដែរ)។ នៅពេលដែលយើង ប្រជុំគ្នានៅក្នុងពួកជំនុំតាមតំបន់របស់យើង ហើយព្យាយាមស្តាប់ព្រះសូរ សៀងរបស់ព្រះតាមរយៈព្រះបន្ទូលរបស់ទ្រង់ដែលគ្រូកំពុងអធិប្បាយ នោះ យើងនឹងត្រូវបានកែច្នៃឲ្យក្លាយទៅជារូបកាយតែមួយ។ យើងមានការរួបរួម គ្នានៅក្នុងការយល់ដឹង និងការមានគោលបំណងដូចគ្នា។ ហើយការរួបរួម គ្នានោះនឹងធ្វើជាបន្ទាល់អំពីសេចក្តីពិតនៃដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ (យ៉ូហាន ១៧:២១)។ ប៉ុន្តែ ប្រសិនបើយើងស្តាប់តាមចំណង់ចំណូលចិត្ត និងរបៀបវារៈដែលនៅក្នុងគំនិតរបស់យើង ហើយប្រសិនបើយើងបង្កើត «ការបកស្រាយផ្ទាល់ខ្លួន» ហើយនិងមានគំនិតប្លែកៗផ្សេងៗ នោះយើង នឹងប្រឈមមុខនឹងការបែកបាក់គ្នាក្នុងការរួបរួមគ្នាតែមួយនោះ។ ហើយ

ការនោះក៏នឹងជំរុញឲ្យមានទំនាស់អំពីសេចក្តីដែលពេញដោយការសង្ស័យ ហើយក៏នឹងធ្វើឲ្យស្មារបន្ទាល់ដំណើងល្អរួមគ្នារបស់យើងចុះខ្សោយដែរ។

## *តើសមាជិកពួកជំនុំអាចមានទម្លាប់ក្នុងការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរបានដោយរបៀបណា?*

ប្រសិនបើការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ មានសារៈសំខាន់ដល់សុខភាពរបស់សមាជិកពួកជំនុំម្នាក់ៗ និងពួកជំនុំខ្លាំងដល់ម្លេះ តើយើងអាចមានទម្លាប់ស្តាប់បែបនោះបានដោយរបៀបណា? មានយ៉ាងហោចណាស់ គំនិតជាក់ស្តែងចំនួនប្រាំមួយចំណុចដែលអាចជួយយើងឲ្យចេះស្តាប់ព្រះបន្ទូលរបស់ព្រះ កាន់តែប្រសើរឡើងជាងមុន។

## ១) ចូរសញ្ជឹងគិតចំពោះសេចក្តីអធិប្បាយក្នុងពេលស្ងៀមស្ងាត់ផ្ទាល់ខ្លួន

ប៉ុន្មានថ្ងៃមុនពេលដែលគ្រូគង្វាលអធិប្បាយ សូមសួរគាត់អំពីបទគម្ពីរដែលគាត់មានគម្រោងនឹងអធិប្បាយនៅថ្ងៃអាទិត្យខាងមុខនេះ។ សូមលើកទឹកចិត្តគាត់ដោយប្រាប់គាត់ឲ្យដឹងថា លោកអ្នកនឹងអធិស្ឋានសម្រាប់ការរៀបចំរបស់គាត់ ហើយថាលោកអ្នកក៏នឹងត្រៀមខ្លួនគំនិតក្នុងការស្តាប់សេចក្តីអធិប្បាយនោះដែរ។ សូមរៀបចំគម្រោងអត្ថបទ នៅក្នុងពេលវេលាស្ងៀមស្ងាត់ប្រចាំថ្ងៃផ្ទាល់ខ្លួនរបស់លោកអ្នក ហើយសូមប្រើប្រាស់គម្រោងនោះ ដើម្បីជាចំណុចអធិស្ឋានរបស់លោកអ្នក។ ការចេះរៀបចំគម្រោងបទគម្ពីរគឺជារបៀបដ៏ល្អមួយនៃការជីកកកាយរក ហើយបង្ហាញពីអត្ថន័យនៃអត្ថបទគម្ពីរនោះ។ បន្ទាប់មក លោកអ្នកអាចប្រើប្រាស់គម្រោងរៀបចំរបស់អ្នកនោះទុកជាជំនួយសម្រាប់ការស្តាប់ ហើយប្រៀបធៀបគម្រោងនោះទៅនឹងគម្រោងរៀបចំរបស់គ្រូអធិប្បាយ ដើម្បីឲ្យបាន

9Marks Online PDF

យល់ដឹងបន្ថែមទៀតនូវអ្វីដែលបានមើលរំលងនៅក្នុងការសិក្សាផ្ទាល់។

## ២) ចូរវិនិយោគនៅក្នុងសៀវភៅអត្ថាធិប្បាយដែលល្អៗ

សូមបន្ថែមចូលទៅក្នុងពេលវេលាសៀមស្ងាត់របស់លោកអ្នកដោយគំនិតល្អៗ ដែលមាននៅក្នុងប្រវត្តិសាស្ត្រគ្រីស្ទបរិស័ទ។ ចូរសិក្សាព្រះគម្ពីរជាមួយលោក ដន ហ្វីលេមីង (Don Fleming) ដោយប្រើប្រាស់សៀវភៅ "ស្ពានចម្លងសេចក្ដីអត្ថាធិប្បាយព្រះគម្ពីរ" ឬលោក ចេឌី. ក្រោលី (J.D. Crowley) ដោយទិញសៀវភៅ *"សង់លើគ្រឹះមាំ"* យកមកអាន និងសិក្សា។ ប្រសិនបើគ្រូគង្វាលរបស់លោកអ្នកកំពុងអធិប្បាយក្នុងកណ្ឌគម្ពីររ៉ូម ចូរទិញយកសៀវភៅអត្ថាធិប្បាយរបស់លោក ចេឌី. ក្រោលី។ សូមឲ្យអ្នកសិក្សាស្រាវជ្រាវ និងគ្រូគង្វាលទាំងនេះ ជួយឲ្យលោកអ្នកស្ដាប់ព្រះបន្ទូលរបស់ព្រះដោយមានត្រចៀក ដែលអាចស្ដាប់បានឮច្បាស់ ហើយឲ្យអាចរកឃើញនូវអត្ថន័យដ៏ជ្រាលជ្រៅបានចុះ។ សៀវភៅអត្ថាធិប្បាយព្រះគម្ពីរតាមភាគដែលមានចំណងជើងថា *"ការអធិប្បាយអំពីកណ្ឌគម្ពីរយ៉ូប ម៉ាកុស ភីលីព"* (*"Preaching Job, Mark and Philippians"*) គឺជាចំណុចចាប់ផ្ដើមដ៏ល្អសម្រាប់អស់អ្នកដែលចង់រៀបចំបណ្ណាល័យដែលមានសៀវភៅអធិប្បាយព្រះគម្ពីរល្អៗ និពន្ធដោយលោក ហ្វិល ក្រូត័រ (Phil Crowter)។ លើសពីនោះទៀត ប្រហែលជាអ្នកចង់ទិញ "សៀវភៅណែនាំព្រះគម្ពីរ" និពន្ធដោយលោក ឈាង ប៉ូវ៉ា ដើម្បីជួយលោកអ្នកឲ្យស្គាល់ព្រះគម្ពីរត្រួសៗតាមលំដាប់លំដោយ។ ការស្រាវជ្រាវអំពីព្រះគម្ពីរសញ្ញាចាស់ និងសញ្ញាថ្មីដែលមានចំណងជើងថា "ដំណើររឿងសង្ខេបព្រះគម្ពីរ" និពន្ធដោយលោកស្រី ហិនរីអេតា ស៊ី. ម៉រស៍ (Henrietta C. Mears)។

## ៣) ចូរនិយាយ និងអធិស្ឋានជាមួយនឹងមិត្តភក្តិអំពីសេចក្តីអធិប្បាយបន្ទាប់ពីចប់ការថ្វាយបង្គំហើយ

ជំនួសឲ្យការប្រញាប់ប្រញាល់ចេញក្រោយពេលថ្វាយបង្គំរួច ឬក៏ជំនួសឲ្យការនិយាយអំពីព័ត៌មានថ្មីៗ យើងគួររៀនបង្កើតទម្លាប់និយាយគ្នាអំពីសេចក្តីអធិប្បាយ ក្រោយពេលថ្វាយបង្គំចប់វិញ។ ចូរចាប់ផ្តើមការសន្ទនាខាងឯវិញ្ញាណដោយសួរថា «តើបទគម្ពីរបានហៅលោកអ្នកឲ្យធ្វើអ្វី ឬក៏ប៉ះពាល់ចិត្តលោកអ្នកដោយរបៀបណានៅថ្ងៃនេះ?» ឬក៏ «តើលក្ខណសម្បត្តិរបស់ព្រះមួយណាដែលបានធ្វើឲ្យលោកអ្នកភ្ញាក់ផ្អើល ឬលើកទឹកចិត្តលោកអ្នក?» សូមលើកទឹកចិត្តអ្នកដទៃដោយចែករំលែកអំពីអ្វីដែលអ្នកបានរៀនអំពីព្រះ និងព្រះបន្ទូលរបស់ទ្រង់ចេញពីសេចក្តីអធិប្បាយនៅថ្ងៃនោះ។ សូមកត់ត្រាអំពីរបៀបដែលការគិតរបស់លោកអ្នកបានមានការផ្លាស់ប្តូរដោយព្រោះតែអត្ថន័យនៃបទគម្ពីរផ្ទាល់។ ហើយចូរអធិស្ឋានជាមួយអ្នកដទៃទៀត ដើម្បីសូមឲ្យព្រះបានថែរក្សាពួកជំនុំកុំឲ្យត្រឡប់ជា «ព្រងើយកន្តើយនឹងការស្តាប់» ហើយទូលសូមទ្រង់បានប្រទានពរដល់ពួកជំនុំឲ្យមានចិត្តចង់បាន «អាហាររឹង» នៃព្រះបន្ទូលកាន់តែខ្លាំងជាងមុន (អេសាយ ៦:៩-១០; ហេព្រើរ ៥:១១-១៤)។

## ៤) សូមស្តាប់ហើយប្រព្រឹត្តិតាមសេចក្តីអធិប្បាយនោះពេញមួយសប្តាហ៍

យើងអាចរៀនបណ្តុះទម្លាប់ នឹងការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរ បានដោយស្តាប់សេចក្តីអធិប្បាយពេញមួយសប្តាហ៍ ហើយប្រព្រឹត្តិតាមសេចក្តីអធិប្បាយនោះ។ សូមកុំឲ្យសេចក្តីអធិប្បាយនៅថ្ងៃអាទិត្យក្លាយទៅជាព្រឹត្តិការណ៍ដែលបាត់ពីការចងចាំរបស់លោកអ្នក នៅពេលដែលគ្រូអធិប្បាយ

9Marks Online PDF

បានអធិប្បាយចប់ភ្លាមឡើយ (យ៉ាកុប ១:២២-២៥)។ យើងអាចជ្រើសរើសយកការអនុវត្តជាក់លាក់មួយ ឬពីរចេញពីបទគម្ពីរដែលបានអធិប្បាយនោះ ហើយដោយសេចក្តីអធិស្ឋាន ចូរអនុវត្តតាមនៅក្នុងការប្រព្រឹត្តិរបស់យើងនៅក្នុងសប្តាហ៍បន្ទាប់ចុះ។ ប្រសិនបើពួកជំនុំរបស់លោកអ្នកមានប្រព័ន្ធផ្សាយជាសម្លេង ឬវែបសាយដែលដាក់សេចក្តីអធិប្បាយទាំងនោះនៅកន្លែងណាមួយ ចូរយើងទាញយកអត្ថប្រយោជន៍ដោយគ្រាន់តែចូលទៅស្តាប់ ឬក៏អាន ដើម្បីឲ្យចំណីដល់ព្រលឹងរបស់យើង។ ដោយមានការគាំទ្រពីគ្រូគង្វាលរបស់លោកអ្នក ចូរបង្កើតក្រុមតូច ដើម្បីរម្លឹកឡើងវិញ និងអនុវត្តសេចក្តីអធិប្បាយ។ ឬក៏លោកអ្នកអាចប្រើប្រាស់សេចក្តីអធិប្បាយ និងការកត់ត្រារបស់លោកអ្នកជាធនធានសិក្សាសម្រាប់ទំនាក់ទំនងបង្កើតសិស្សមួយទល់នឹងមួយក៏បានដែរ។ ខ្ញុំស្គាល់គ្រួសារមួយចំនួនដែលមានការប្រជុំគ្នាទៀងទាត់ នៅល្ងាចថ្ងៃអាទិត្យ ដើម្បីរម្លឹកសេចក្តីអធិប្បាយឡើងវិញ ក្នុងការថ្វាយបង្គំជាលក្ខណៈគ្រួសារ។ មានរាប់រយរបៀប ក្នុងការរក្សាសេចក្តីអធិប្បាយឲ្យមានជីវិតនៅក្នុងជីវិតខាងឯព្រលឹងវិញ្ញាណរបស់លោកអ្នក ដោយការរម្លឹកឡើងវិញនូវព្រះបន្ទូលព្រះពេញមួយសប្តាហ៍។ ចូរឲ្យយើងមានគំនិតច្នៃប្រឌិត។ ការមានផែនការច្បាស់លាស់គឺស័ក្តិសមណាស់។

## ៥) ចូរអភិវឌ្ឍន៍ទម្លាប់រកចម្លើយ សម្រាប់សំណួរអំពីអត្ថបទនៅក្នុងគម្ពីរនោះ

លោក ចនណាសិន អ៊ែតវើត (Jonathan Edwards) បានប្តេជ្ញាថា គាត់នឹងមិនអនុញ្ញាតឲ្យថ្ងៃណាមួយកន្លងផុតទៅទេ មុនគាត់បានឆ្លើយនឹងសំណួរនានា ដែលគាត់ឆ្ងល់នៅពេលគាត់កំពុងសិក្សាព្រះបន្ទូលរបស់

ព្រះ។[២] តើពួកជំនុំរបស់យើងនឹងមានសុខភាពល្អយ៉ាងណាហ្ន៎ ប្រសិនបើសមាជិកពួកជំនុំម្នាក់ៗប្ដេជ្ញាចិត្តក្នុងការសិក្សាព្រះបន្ទាល់ដោយការប្រឹងប្រែង ហើយតាំងចិត្តបែបនេះនោះ? របៀបមួយដែលលោកអ្នកអាចចាប់ផ្ដើមបានគឺស្វែងយល់អំពីសំណួររឿងធ្ងល់ដែលទាក់ទងនឹងអត្ថបទនេះជាមួយនឹងគ្រូគង្វាល ពួកចាស់ទុំ និងគ្រូបង្រៀនដទៃទៀតនៅក្នុងពួកជំនុំ។ លើសពីនេះទៅទៀត សូមកុំអសកម្មនៅក្នុងការសិក្សាផ្ទាល់ខ្លួនឲ្យសោះ ចូរស្វែងរកចម្លើយដោយការស្រាវជ្រាវព្រះបន្ទាល់ដោយខ្លួនឯង ហើយដោយជជែកជាមួយនឹងដៃគូរដែលជួយមើលខុសត្រូវលើលោកអ្នក ឬក៏ក្នុងក្រុមតូច។ ប៉ុន្តែ កុំភ្លេចថា គ្រូគង្វាលទំនងជាបានចំណាយពេលច្រើនជាងមនុស្សភាគច្រើននៅក្នុងការគិតអំពីព្រះបទគម្ពីរនោះ ហើយតួនាទីគាត់គឺ ដើម្បីផ្ដល់ចំណីដែលជាព្រះបន្ទូលដល់លោកអ្នក។ ចូរស្វែងយល់សេចក្ដីអធិប្បាយដោយមានសំណួរ និងមតិដែលអាចនឹងជាការលើកទឹកចិត្តដល់គ្រូគង្វាលរបស់លោកអ្នក និងជាព្រះពរដល់ព្រលឹងរបស់លោកអ្នកផងដែរ។

## ៦) ចូរបណ្ដុះការបន្ទាបខ្លួន

ខណៈពេលដែលលោកអ្នកជីកកកាយនៅក្នុងព្រះបន្ទូលរបស់ព្រះជាម្ចាស់ និងស្ដាប់ព្រះសូរសៀងរបស់ទ្រង់ នោះលោកអ្នកនឹងច្បាស់

---

២ កាលលោក ចនណាសិន អ៊ែតវើត (Jonathan Edwards) មានអាយុ១៩ឆ្នាំ គាត់ក៏បានសរសេរការប្ដេជ្ញាចិត្តនេះដូចតទៅ៖ «ការប្ដេជ្ញាចិត្ត៖ នៅពេលដែលខ្ញុំមានចម្ងល់អ្វីមួយទាក់ទងទៅនឹងព្រះជាម្ចាស់ ដែលខ្ញុំត្រូវរកចម្លើយ ភ្លាមនោះខ្ញុំនឹងព្យាយាមធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ដើម្បីរកចម្លើយលើសំណួរ ប្រសិនបើកាលៈទេសៈមិនរារាំងខ្ញុំក្នុងការធ្វើបែបនោះ»។ The Works of Jonathan Edwards, ភាគ១ (Peabody, MA: Hendrickson), ទំព័រ៦២។

9Marks Online PDF

ជារីកចម្រើនឡើង ហើយក៏នឹងរកឃើញកំណប់ទ្រព្យដ៏អស្ចារ្យជាច្រើនជាមិនខាន។ ប៉ុន្តែ នៅពេលដែលលោកអ្នករីកចម្រើន ចូរកុំធ្វើជា «អ្នកស្តាប់ការអធិប្បាយបែបអាជីព» ដែលតែងតែស្តាប់បាន ប៉ុន្តែមិនចេះអ្វីសោះ។ ចូរប្រុងប្រយ័ត្នជាមួយនឹងចំណេះដឹងក្លែងក្លាយដែល «អួតបំប៉ោង» (១កូរិនថូស ១:៨; កូឡុស ២:១៨) ដែលទំនោរចង់បង្កឲ្យមានការឈ្លោះប្រកែក និងការបែកបាក់គ្នា។ សូមសម្លាប់ទំនោរដែលអាចនាំឲ្យមានអំនួតការថ្កោលទោសអ្នកដទៃ និងការរិះគន់រឿងដែលមិនសំខាន់ជាដើម។ ផ្ទុយទៅវិញ ចូរព្យាយាមឲ្យបានជួបព្រះយេស៊ូវរៀងរាល់ពេលដែលអ្នកអានព្រះបន្ទូលវិញ។ ចូរប្រមូលប្រេងឥន្ធនៈពីព្រះបន្ទូលសម្រាប់បញ្ឆេះការថ្វាយបង្គំអស់មួយជីវិតវិញ។ ជំនួសឲ្យការសរសើរខ្លួនឯង ចូរយើងចងចាំប្រសាសន៍របស់សាវ័ក ពេត្រុស «ចូរឲ្យអ្នករាល់គ្នាបន្ទាបខ្លួន នៅក្រោមព្រះហស្តដ៏ពូកែរបស់ព្រះចុះ ដើម្បីឲ្យទ្រង់បានតម្កើងអ្នករាល់គ្នាឡើង នៅវេលាកំណត់» (១ពេត្រុស ៥:៦)។

## *សេចក្តីសន្និដ្ឋាន*

គឺការឮព្រះបន្ទូលរបស់ព្រះនោះហើយដែលនាំឲ្យមានសេចក្តីជំនឿដែលនឹងនាំឲ្យមានសេចក្តីសង្គ្រោះ (រ៉ូម ១០:១៧)។ សមាជិកពួកជំនុំនឹងមានសុខភាពល្អ នៅពេលដែលពួកគាត់អនុញ្ញាតឲ្យខ្លួនឯងឮព្រះបន្ទូលទុកជាវិន័យទៀងទាត់របស់ខ្លួន។ ប្រាកដណាស់ ការស្តាប់តាមអត្ថន័យនៃព្រះគម្ពីរនឹងនាំឲ្យមានសុខភាពសម្រាប់សមាជិកពួកជំនុំម្នាក់ៗ និងពួកជំនុំទាំងមូល។

## *ការសញ្ជឹងគិតបន្ថែម*

១. តើលោកអ្នកដាក់ពិន្ទុឲ្យសមត្ថភាពស្តាប់របស់ខ្លួន ក្នុងការរកអត្ថន័យ

ព្រះបន្ទូលយ៉ាងដូចម្ដេច នៅពេលសិក្សាផ្ទាល់ខ្លួន និងនៅពេលកំពុងស្ដាប់សេចក្ដីអធិប្បាយ?

២. តើលោកអ្នកមានគម្រោងពង្រឹងសមត្ថភាពស្ដាប់របស់ខ្លួនដោយរបៀបណា? សម្រាប់ការសញ្ជឹងគិតបន្ថែម សូមជ្រើសរើសក្រុមជាមួយមិត្តភក្តិ និងសមាជិកក្នុងពួកជំនុំ ហើយពិចារណា និងពិភាក្សាសំណួរដែលបានសួរនៅទំព័រទី ៧៧-៧៨។

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

សូមជ្រើសរើសក្រុមជាមួយមិត្តភក្តិ និងសមាជិកក្នុងពួកជំនុំ ហើយពិចារណា និងពិភាក្សាសំណួរដែលបានសួរនៅទំព័រទី ៧៧-៧៨។

សញ្ញាសម្គាល់ទី២

# សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ

**«ការមិនស្គាល់អំពីព្រះ**—ការមិនស្គាល់អំពីផ្លូវរបស់ទ្រង់ និង អំពីការប្រកបគ្នា ជាមួយទ្រង់—គឺជាឫសគល់នៃសេចក្តីកម្សោយរបស់ពួកជំនុំនៅក្នុងសម័យនេះ»។ មូលហេតុនេះហើយបានជាលោក ជេ. អាយ. ភែកខ័រ (J. I. Packer) បានចាប់ផ្តើមបុព្វកថានៅក្នុងសៀវភៅរបស់គាត់មួយ នៅឆ្នាំ១៩៧៣ដែលមានចំណងជើងថា ការស្គាល់ព្រះជាម្ចាស់ ("Knowing God")។ លោក ភែកខ័រ បានពិចារណាឃើញថា មានការនិយមមួយដែលបង្កើតឲ្យមានការមិនស្គាល់អំពីព្រះ និងសេចក្តីកម្សោយនៅក្នុងពួកជំនុំ៖ «គំនិតរបស់គ្រីស្ទបរិស័ទបានគ្រាប់តាមវិញ្ញាណនៅសម័យទំនើបនេះ—ហើយវិញ្ញាណនោះបានបង្កើតជាគំនិតធំៗឲ្យមនុស្ស ហើយទុកចន្លោះដ៏តូចបំផុតសម្រាប់គិតអំពីព្រះជាម្ចាស់ទៅវិញ»។[៣]

---

៣ លោក J. I. Packer, Knowing God, ២0th Anniversary Edition (Downers Grove, IL: Inter Varsity ឆ្នាំ១៩៩៣) ទំព័រ១២។

9Marks Online PDF

គួរឲ្យសោកស្ដាយណាស់ ជាងបីទសវត្សរ៍ក្រោយមក ការសង្កេតរបស់លោក តែកខ័រ ក៏នៅតែជាការពិតដដែល។ ការមិនស្គាល់អំពីផ្លូវរបស់ព្រះ និងអំពីការប្រកបគ្នាជាមួយទ្រង់គឺជាការរីករាលដាលនៅក្នុងស្ថានភាពជាច្រើន។ នៅមានសមាជិកនៃពួកជំនុំគ្រីស្ទបរិស័ទជាច្រើនដែលនៅតែបន្តគិតដោយមានគំនិតតូចៗអំពីព្រះ ហើយមានគំនិតគិតធំៗអំពីមនុស្សវិញ។ ស្ថានភាពនេះបង្ហាញថា មានគ្រីស្ទបរិស័ទច្រើនណាស់ដែលបានធ្វេសប្រហែសនឹងការត្រាស់ហៅដ៏ធំទីមួយរបស់ខ្លួន គឺការត្រាស់ហៅ ដើម្បីឲ្យបានស្គាល់ព្រះជាម្ចាស់។ គ្រីស្ទបរិស័ទគ្រប់រូបត្រូវធ្វើជាទេវវិទូព្រះគម្ពីរដ៏ល្អ ហើយជិតស្និទ្ធបំផុតជាមួយនឹងព្រះបន្ទូល។ ប្រសិនបើពួកជំនុំចង់រីកចម្រើនឡើងក្នុងការមានសុខភាពល្អ នោះសមាជិកពួកជំនុំត្រូវតែប្ដេជ្ញាចិត្តធ្វើជាទេវវិទូព្រះគម្ពីរតាមអត្ថន័យព្រះគម្ពីរ ទៅតាមសមត្ថភាពដែលពួកគាត់អាចធ្វើបាន។ នេះឯងគឺជាសញ្ញាសម្គាល់ទីពីរនៃសមាជិកពួកជំនុំដែលមានសុខភាពល្អ។

## *តើអ្វីទៅជាការសិក្សាទេវវិទ្យាតាមព្រះគម្ពីរសម្រាប់សមាជិកពួកជំនុំ?*

ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរគឺជាការស្គាល់ព្រះជាម្ចាស់ផ្ទាល់។ ខ្ញុំប្រើពាក្យថា “ការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ” ដោយមានសេចក្ដីពីរយ៉ាងនៅក្នុងចិត្តគំនិតរបស់ខ្ញុំ។ ទីមួយ យើងត្រូវតែចងចាំថា ព្រះគម្ពីរគឺជាការបើកសម្ដែងផ្ទាល់អំពីព្រះជាម្ចាស់។ ព្រះគម្ពីរគឺជាប្រភពសិក្សាសម្រាប់បង្កើតគំនិតធំៗអំពីព្រះ។ គ្រីស្ទបរិស័ទដែលចង់ស្គាល់ព្រះរបស់ខ្លួនគឺជាគ្រីស្ទបរិស័ទដែលចង់ដឹងអំពីអ្វីដែលព្រះជាម្ចាស់បានមានបន្ទូលអំពីទ្រង់ផ្ទាល់នៅក្នុងព្រះគម្ពីរ។ គ្រីស្ទបរិស័ទបែបនោះនឹង

9Marks Online PDF

មិនចាប់ផ្ដើមការនិយាយរបស់គាត់ដូចជា “ខ្ញុំចូលចិត្តគិតអំពីព្រះជាម្ចាស់ថា...” នោះទេ។ គ្រីស្ទបរិស័ទបែបនោះនឹងមិនលាយឡំបញ្ចូលសេចក្ដីបែបសម័យថ្មីបន្តិច ឬជំនឿសាសនាហិណ្ឌូបន្តិចជាមួយនឹងជំនឿគ្រីស្ទបរិស័ទ ដើម្បីឲ្យបានក្លាយទៅជាព្រះដែលត្រូវចិត្តខ្លួននោះទេ។ អត់ទេ! សមាជិកពួកជំនុំគ្រីស្ទបរិស័ទដែលយកចិត្តទុកដាក់ក្នុងការស្គាល់ព្រះជាម្ចាស់គឺជាសមាជិកដែលប្ដេជ្ញាចិត្តដឹងអំពីអ្វីដែលព្រះគម្ពីរបានថែងអំពីព្រះជាម្ចាស់ ពីព្រោះព្រះគម្ពីរគឺជាកន្លែងដែលព្រះជាម្ចាស់បានមានបន្ទូលប្រាប់យើងអំពីទ្រង់ផ្ទាល់។

ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ គឺស្គាល់ដំណើររឿងធំៗអំពីសេចក្ដីប្រោសលោះរបស់ព្រះជាម្ចាស់។ ទីពីរ ទេវវិទូព្រះគម្ពីរគឺជាបុគ្គលដែលប្ដេជ្ញាចិត្ត ដើម្បីឲ្យបានយល់ប្រវត្តិសាស្ត្រនៃការបើកសម្ដែងខ្លឹមសារធំៗ និងគោលលទ្ធិព្រះគម្ពីរ ព្រមទាំងអំពីរបៀបផ្សេងៗដែលវាស៊ុចង្វាក់គ្នា។ បើនិយាយម៉្យាងវិញទៀត សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាបុគ្គលដែលមានការប្ដេជ្ញាចិត្ត ដើម្បីឲ្យបានយល់អំពីសេចក្ដីរួបរួមនិងដំណាក់កាលនៃដំណើររឿងក្នុងព្រះគម្ពីរទាំងមូល—មានន័យថា គាត់មិនមែនអានតែផ្នែកខ្លះៗ ឬអត្ថបទខ្លះដែលយើងចូលចិត្តប៉ុណ្ណោះនោះទេ។ ពួកគាត់អានព្រះគម្ពីរដោយដឹងថា ពួកគាត់កំពុងអានអំពីដំណើររឿងដ៏អស្ចារ្យមួយរបស់ព្រះជាម្ចាស់ ដែលទ្រង់កំពុងតែប្រោសលោះមនុស្សសម្រាប់ទ្រង់ និងសិរីល្អរបស់ទ្រង់។ ហើយនៅក្នុងដំណើររឿងនោះ ពួកគាត់បានឃើញថា ព្រះទ្រង់ជាព្រះអាទិករ ជាព្រះដ៏បរិសុទ្ធ ជាព្រះដ៏ស្មោះត្រង់ ជាព្រះដែលមានពេញដោយសេចក្ដីស្រឡាញ់ ហើយជាព្រះដែលពេញដោយអធិបតេយ្យភាពខណៈពេលដែលទ្រង់សន្យា និងរក្សាសេចក្ដីសន្យានានារបស់ទ្រង់ជាមួយនឹងរាស្ត្ររបស់ព្រះអង្គ គឺបានចាប់ផ្ដើមតាំង

ពីពេលលោកអ័ដាម និងនាង អេវ៉ា ព្រមទាំងបន្តរហូតដល់ការសម្រេចចប់សព្វគ្រប់ចុងក្រោយនៃការទាំងអស់។[១]

## *តើការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរមានដំណើរការយ៉ាងដូចម្តេច ដើម្បីលើកកម្ពស់ដល់សុខភាពនៅក្នុងសមាជិកពួកជំនុំ?*

នៅក្នុងសៀវភៅ*ការសិក្សាស្រាវជ្រាវ ទេវវិទ្យាតាមព្រះគម្ពីរជាប្រព័ន្ធ (“Systematic Theology”)* ដ៏មានប្រជាប្រិយភាព លោក វ៉េន គ្រូដិម (Wayne Grudem) បានសរសេរជាគ្រោងៗអំពីអត្ថប្រយោជន៍ជាច្រើនក្នុងការសិក្សាព្រះគម្ពីរជាប្រព័ន្ធ។ អត្ថប្រយោជន៍ភាគច្រើនទាំងនោះ ក៏មានភ្ជាប់មក ជាមួយនឹងការអនុវត្តការសិក្សាទេវវិទ្យាតាមព្រះគម្ពីរផងដែរ។ ខ្ញុំសូមសង្ខេបអំពីអត្ថប្រយោជន៍ដែលលោក គ្រូដិម បានស្នើឡើងនៅទីនេះ។[២]

ទីមួយ *ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរជួយយើងឲ្យរីកចម្រើនឡើង នៅក្នុងការចេះគោរពកោតខ្លាចដល់ព្រះជាម្ចាស់*។ នៅពេលដែលយើងជួបព្រះជាម្ចាស់នៃព្រះគម្ពីរដែលទ្រង់បង្កើតហើយរក្សាសេចក្តីសន្យារបស់ទ្រង់ជាមួយនឹងរាស្ត្រព្រះអង្គ នោះយើង នឹងឃើញអំពីអ្វីម៉្យាងនៃសេចក្តីដ៏រុងរឿងរបស់ទ្រង់ជាមិនខាន។ គ្រប់កិច្ចការ

---

១ លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books, ឆ្នាំ២០០៤)។ សូមអានជំពូកទី២។

២ លោក Wayne Grudem, Systematic Theology (Grand Rapids, MI: Zondervan, ឆ្នាំ១៩៩៤), ទំព័រ២៦-៣០។

9Marks Online PDF

ដែលផ្ទុំគ្នាសម្រាប់ជាសេចក្ដីល្អរបស់ទ្រង់នឹងបង្ហាញឲ្យយើងឃើញកាន់តែច្បាស់ គឺចាប់តាំងពីសេចក្ដីសន្យារបស់ទ្រង់ដល់ស្ត្រីថា ពូជរបស់នាងនឹងកិនក្បាលសត្វពស់ (លោកុប្បត្តិ ៣:១៥) ដល់សេចក្ដីសន្យារបស់ទ្រង់ថា នឹងបើកពោះស្ត្រីអារ ដើម្បីឲ្យពូជនោះត្រូវបានថែរក្សាបន្ត (លោកុប្បត្តិ ១៧:១៥-១៩; ២១:១-២; ២៩:៣១; ៣០:២២; អេសាយ ៧:១៤) រហូតដល់កំណើតពិតប្រាកដនៃពូជនោះបានមកដល់ (ម៉ាថាយ ១:២០-២៣)។ នៅពេលដែលយើងឃើញថា ព្រះជាម្ចាស់ជា តែងតែ និងនៅតែជាព្រះអាទិករ ព្រះដ៏បរិសុទ្ធ ព្រះដ៏ស្មោះត្រង់ មានពេញដោយសេចក្ដីស្រឡាញ់ ព្រមទាំងមានពេញដោយអធិបតេយ្យភាពសម្រាប់យើងរាល់គ្នា ដូចដែលទ្រង់មានដល់អ្នកដទៃ នោះយើងនឹងកាន់តែមានសេចក្ដីជំនឿ និងសេចក្ដីអស្ចារ្យនៅក្នុងទ្រង់ខ្លាំងថែមទៀត។ ប្រសិនបើយើងពិតជាចង់ស្គាល់ និងគោរពកោតខ្លាចដល់ព្រះជាម្ចាស់ដោយពិតត្រង់មែន នោះយើងនឹងប្ដេជ្ញាចិត្ត ដើម្បីឲ្យក្លាយជាទេវវិទូព្រះគម្ពីរ ដែលយល់អំពីដំណើររឿង និងខ្លឹមសារធំៗនៃព្រះគម្ពីរ។

ទីពីរ *ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរជួយយើងឲ្យយកឈ្នះលើគំនិតខុសឆ្គងរបស់យើង*។ យើងរាល់គ្នាសុទ្ធតែបានជួបនឹងសេចក្ដីបង្រៀនផ្សេងៗនៅក្នុងព្រះគម្ពីរដែលធ្វើឲ្យយើងពិបាកយល់ មានការងាយយល់ច្រឡំ ឬធ្វើឲ្យយើងមានប្រតិកម្ម។ ជាទូទៅ យើងបដិសេធមិនទទួលយកសេចក្ដីបង្រៀនទាំងនេះ ពីព្រោះយើងមានភាពស្រអាប់ និងអំពើបាបនៅក្នុងចិត្តរបស់យើង។ យើងអាចគេចចេញពីខគម្ពីរមួយនៅទីនេះ ឬទីនោះដែលធ្វើឲ្យយើងមិនសប្បាយចិត្ត ឬបន្ទោសដល់យើង។ ប៉ុន្តែ នៅពេលដែលយើងព្យាយាមយល់ពីវិសាលភាពដ៏ធំធេងនៃការបើកសម្ដែងតាមព្រះគម្ពីរ និងទម្ងន់ទាំងស្រុងនៃការបង្រៀនរបស់

ព្រះបន្ទូលលើប្រធានបទជាក់លាក់ណាមួយ នោះមានន័យថា យើងនឹងកាន់តែដឹងប្រាកដអំពីគំនិតខុសឆ្គងរបស់យើងជាមិនខាន។ ការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរជួយយើងឲ្យឃើញអំពីរបៀបដែលព្រះបានមានបន្ទូលមកយើងនូវព្រះរាជសារតែមួយដូចៗគ្នា ទៅកាន់រាស្ត្ររបស់ទ្រង់នៅក្នុងទីកន្លែងនានា និងរបៀបផ្សេងៗពីគ្នា (ហេព្រើរ ១:១) គឺជាព្រះរាជសារដែលនឹងមានថ្ងៃមួយធ្វើឲ្យគ្រប់គ្នាឱនក្រាប ហើយទទួលយក (អេសាយ ៤៥:២២-២៤; រ៉ូម ១៤:១០-១២; ភីលីព ២:៩-១១)។ ខណៈពេលដែលយើងសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរដោយមានដោយសេចក្តីអធិស្ឋាន នោះយើងនឹងចេះចុះចូលចំពោះព្រះជាម្ចាស់ដោយអំណរ ហើយបោះបង់ចោលគំនិតខុសឆ្គងរបស់យើងអំពីទ្រង់។

ទីបី *ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរជួយការពារពួកជំនុំប្រឆាំងនឹងជម្លោះអំពីគោលលទ្ធិ*។ ប្រវត្តិសាស្ត្រពួកជំនុំមានពេញទៅដោយជម្លោះជាច្រើនដែលកើតឡើងរវាងសមាជិកពួកជំនុំមួយ និង សមាជិកពួកជំនុំមួយទៀត។ ពួកជំនុំដែលអាចយកឈ្នះ ហើយដោះស្រាយបានល្អចំពោះជម្លោះបែបនេះដែលប្រកបដោយប្រសិទ្ធភាព គឺជាពួកជំនុំដែលរក្សាការយល់ដឹងអំពីការសិក្សាទេវវិទ្យាតាមព្រះគម្ពីរ តាមលក្ខណៈជាប្រព័ន្ធ និងតាមប្រវត្តិសាស្ត្រទេវវិទ្យា។ ចំណុចនេះជាការពិតពីព្រោះអ្វីក៏ដោយដែលព្រះគម្ពីរបានចែងអំពីចំណុចណាមួយ គឺសុទ្ធតែទាក់ទងទៅនឹងអ្វីៗផ្សេងទៀតដែលព្រះគម្ពីរបានចែងរួចហើយដែរ។ ការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរជួយឲ្យមានការបន្ត និងភាពទៀងទាត់នៃការបង្រៀនរបស់ព្រះគម្ពីរ។ ការសិក្សាព្រះគម្ពីរគឺប្រៀបដូចជាការលេងល្បែងតម្រៀបផ្គុំរូបមួយ។ នៅពេលដែលបំណែកណាមួយនៃរូបផ្គុំហាក់ដូចជាមិនដឹងថាត្រូវដាក់នៅត្រង់ណា គឺយើងអាចស្វែងរកកន្លែងដែលត្រឹមត្រូវ

របស់វាបាន ដោយពិនិត្យមើលរូបធំរបស់វានៅលើប្រអប់នៃបន្ទះតម្រៀបរូបផ្គុំនោះ។ កាលណាយើងផ្គុំបំណែកទាំងនោះបានកាន់តែច្រើន នោះយើងក៏នឹងកាន់តែងាយស្រួលក្នុងការដឹងថា បំណែកថ្មីៗដទៃទៀតត្រូវដាក់នៅត្រង់ណា ហើយយើងក៏នឹងមិនងាយដាក់បំណែកផ្គុំថ្មីខុសនោះដែរ។ ការសិក្សាព្រះគម្ពីរ គឺប្រៀបដូចជាការរៀបផ្គុំរូបយ៉ាងដូច្នេះដែរ ពោលគឺវាជួយឲ្យយើងទទួល ឬបដិសេធចំពោះចំណុចខុសឆ្គងនៃបំណែកនានានៃសិក្សាព្រះគម្ពីររបស់យើង ដោយសារយើងបានយល់អំពីរូបភាពធំនៃការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីររួចជាស្រេចហើយ។ ព្រះគម្ពីរគឺ "បានកត់ទុក សម្រាប់ជាសេចក្ដីទូន្មានប្រដៅ ដល់យើងរាល់គ្នា ដែលយើងនៅគ្រាចុងបំផុតនៃអស់ទាំងកល្ប" (១កូរិនថូស ១០:១១) ហើយការមានចំណេះដឹងលើព្រះបន្ទូលនឹងការពារពួកជំនុំពីរឿងល្បែងរបស់ស្រីចាស់ៗ និងការឈ្លោះប្រកែកគ្នាមិនចេះចប់ (១ធីម៉ូថេ ៤:៧)។

ទីបួន *ការអនុវត្តការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរគឺចាំបាច់ណាស់ចំពោះការបំពេញមហាបេសកកម្ម។* ព្រះយេស៊ូវបានបង្គាប់យើងឲ្យបង្រៀនដល់អ្នកជឿទាំងអស់ ឲ្យធ្វើតាមនូវអ្វីៗទាំងអស់ទ្រង់បញ្ជាឲ្យធ្វើ (ម៉ាថាយ ២៨:១៩-២០)។ ប្រសិនបើគ្មានការយល់ដឹងអំពីទេវវិទ្យាឲ្យបានច្បាស់លាស់ (រួមទាំងមានការយល់ដឹងត្រឹមត្រូវនៃរបៀបដែលយើងត្រូវយល់ការបង្គាប់របស់ព្រះនៅក្នុងដំណាក់កាល និងបរិបទខាងប្រវត្តិសាស្ត្រ) នោះយើងពិតជាពិបាកក្នុងការស្ដាប់បង្គាប់តាមការបង្គាប់របស់ព្រះអម្ចាស់ ដើម្បីបង្រៀនដល់អ្នកដទៃឲ្យចេះស្ដាប់បង្គាប់ដែរ។ តើយើងនឹងបង្រៀនអំពីអ្វី? តើយើងនឹងស្ដាប់បង្គាប់តាមអ្វី? តើយើងអាចដឹងអំពីអ្វីដែលយើងត្រូវអនុវត្តនៅក្នុងជីវិតរបស់យើងដោយរបៀបណា? យើងនឹងទទួលបានចម្លើយល្អៗលើសំណួរទាំងនេះ នៅពេលយើងមាន

9Marks Online PDF

ការយល់ដឹងទូលំទូលាយអំពីការសិក្សាស្រាវជ្រាវតាមព្រះគម្ពីរ ហើយស្គាល់ព្រះរបស់ខ្លួន។

ប៉ុន្តែ អត្ថប្រយោជន៍ដ៏ល្អបំផុតទាក់ទងនឹងការសិក្សាស្រាវជ្រាវទេវវិទ្យាតាមគម្ពីរនោះគឺថា *វាធ្វើឲ្យការយល់ដឹងរបស់យើងកាន់តែស៊ីជម្រៅ និងរៀនកាន់តែងាយស្រួលជាមួយដំណឹងល្អ*។ ព្រះយេស៊ូវ និងពួកសាវ័កមិនត្រូវការព្រះគម្ពីរសញ្ញាថ្មី ដើម្បីប្រកាសដំណឹងល្អនោះទេ។ ពួកគាត់ពឹងលើព្រះគម្ពីរសញ្ញាចាស់ ហើយបានយល់ដឹងថាព្រះគម្ពីរសញ្ញាចាស់ចង្អុលបង្ហាញអំពីព្រះយេស៊ូវ (លូកា ២៤:២៧, ៤៤-៤៥)។ ទេវវិទូព្រះគម្ពីរត្រូវតែគ្រាប់តាមរបៀបរបស់ព្រះយេស៊ូវ និងពួកសាវ័ក ដោយស្គាល់ច្បាស់អំពីភាពស៊ីចង្វាក់គ្នានៅក្នុងព្រះបន្ទូល ក៏ដូចជាឃើញអំពីព្រះគ្រីស្ទ និងដំណឹងល្អពាសពេញព្រះបន្ទូល។

## *របៀបក្លាយជាសមាជិកពួកជំនុំដែលមានសុខភាពល្អ ដោយក្លាយជាទេវវិទូព្រះគម្ពីរ*

តើគ្រីស្ទបរិស័ទអាចក្លាយជាសមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់ ដោយស្គាល់ប្រធានបទធំៗ នៃការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ ដោយរបៀបណា? មានរបៀបមួយចំនួនដែលអាចជាប្រយោជន៍។

## សូមអានសៀវភៅល្អៗអំពីការសិក្សាទេវវិទ្យាតាមព្រះគម្ពីរ

មានរបៀបងាយមួយ ដើម្បីឲ្យអាចក្លាយជាទេវវិទូព្រះគម្ពីរ គឺយើងអានសៀវភៅល្អៗអំពីការសិក្សាទេវវិទ្យាតាមបទគម្ពីរ។ មានសៀវភៅជាច្រើនបានបង្ហាញពីអត្ថប្រយោជន៍របស់វាជាច្រើនឆ្នាំកន្លងមក។ សម្រាប់ជា

9Marks Online PDF

ឯកសារយោង លោកអ្នកអានគួរតែសាកល្បងមើល «សារនៃព្រះគម្ពីរ»[៣] (The Message of the Bible)។ សម្រាប់ជាការចាប់ផ្តើមដំបូងៗដែលមានប្រយោជន៍ លោកអ្នកគួរសាកអានសៀវភៅទាំងនេះ៖[៤]

- លោក ហ្វិល ក្រូត័រ (Phil Crowter) ការអធិប្បាយអំពីផែនការដ៏អស្ចារ្យរបស់ព្រះជាម្ចាស់៖ គម្រោងអធិប្បាយព្រះគម្ពីរដោយសង្ខេប (Preaching God's Big Story: Talk Outlines for a Bible Overview)
- លោកស្រី ម៉ារី ដាប៊ឹលយូ. ជេ. ធេ (Mary W.J. Tay), របៀបអានព្រះគម្ពីរ (How to Read the Bible)
- លោក ភីតធើ ចេនសិន, នៅឯបេះដូងនៃចក្រវាឡ៖ អ្វីដែលពួកគ្រីស្ទបរិស័ទជឿ (Peter Jensen, At the Heart of the Universe: What Christians Believe)
- លោក វ៉ន រ៉ប៊ឺត (Vaughn Roberts), ផែនការព្រះ (God's Big Design)
- លោក ជេ. អាយ. ភែកខ័រ (J.I. Packer) ទេវសាស្ត្រសង្ខេប (Concise Theology)

---

៣ លោកអ្នកអាចទាញយកសៀវភៅនេះដោយមានគិតថ្លៃនៅក្នុងគេហទំព័រ៖ cambodianchristianresources.com

៤ សូមទំនាក់ទំនងទៅកាន់រោងពុម្ពប្រភពប្រាជ្ញា ឬក៏ចូលទៅកាន់គេហទំព័រ៖ www.fountofwisdomph.com ដើម្បីជាវសៀវភៅទាំងនេះ។

9Marks Online PDF

សៀវភៅ «សេចក្ដីបង្រៀននៃព្រះគម្ពីរ»[៥] (What the Bible Teaches) និពន្ធដោយលោក (William MacDonal) បោះពុម្ពផ្សាយដោយ អេម៉ាសន កម្ពុជា ដើម្បីជួយឲ្យលោកអ្នកយល់នូវអ្វីដែលព្រះគម្ពីរបានបង្រៀនអំពីប្រធានបទដ៏សំខាន់ៗ ជាច្រើនដែលមានសារៈសំខាន់អស់កល្បជានិច្ច។ សៀវភៅទាំងនេះផ្ដល់នូវការសង្ខេបដ៏រឹងមាំ និងងាយអានអំពីការស៊ីចង្វាក់គ្នា និងភាពសម្បូរបែបនៃបទគម្ពីរ។ ហើយសម្រាប់អ្នកអានកម្រិតខ្ពស់ជាងនេះគឺ អាចអានសៀវភៅរបស់លោក វ៉ន រ៉ប៊ឺត (Vaughn Roberts) វិសាលភាព៖ គម្រោងព្រះជាម្ចាស់ (God’s Big Picture: Tracing the Storyline of the Bible) បោះពុម្ពដោយប្រភពប្រាជ្ញា។[៦] ទាំងនេះគឺជាសៀវភៅដែលនៅតែគេនិយមអាន ទាក់ទងនឹងប្រធានបទនេះ។ ចូរប្រើសៀវភៅទាំងនេះសម្រាប់ការចំណាយពេលជាមួយព្រះ ឬក៏អាននៅពេលទំនេររបស់លោកអ្នក។ សូមស្នើដល់អ្នកដឹកនាំក្រុមតូចរបស់លោកអ្នក ឲ្យអានសៀវភៅបែបនេះជាក្រុម។

## សិក្សាព្រះបន្ទូលតាមប្រធានបទ

សូមញែកពេលខ្លះៗរបស់លោកអ្នកក្នុងការចំណាយពេលជាមួយព្រះ ដើម្បីសិក្សាព្រះបន្ទូលតាមប្រធានបទ។ ការសិក្សាកណ្ឌគម្ពីរម្ដងមួយខៗ នៅក្នុងបរិបទប្រវត្តិសាស្ត្រនៃការប្រោសលោះក្នុងកណ្ឌគម្ពីរទាំងនីមួយៗ

---

៥ លោកអ្នកអាចទាញយកសៀវភៅនេះដោយមានគិតថ្លៃនៅក្នុងគេហទំព័រ៖ cambodianchristianresources.com/books/what-the-bible-teaches

៦ សូមទំនាក់ទំនងទៅកាន់រោងពុម្ពប្រភពប្រាជ្ញា ឬក៏ចូលទៅកាន់គេហទំព័រ៖ www.fountofwisdomph.com ដើម្បីជាវសៀវភៅទាំងនេះ។

9Marks Online PDF

គឺជារបបអាហារដ៏សំខាន់នៃការទទួលយកក្នុងការសិក្សាព្រះគម្ពីរ។ ហើយសូមបន្ថែមពីលើរបបអាហារដ៏សំខាន់នេះ ដោយការសិក្សាលើប្រធានបទធំៗ ដែលមាននៅក្នុងព្រះគម្ពីរទាំងមូល។ សូមញែកពេលខ្លះ ដើម្បីសញ្ជឹងគិតពីការបើកសម្ដែងអំពីលក្ខណសម្បត្តិរបស់ព្រះជាម្ចាស់ ការរួបរួម និងភាពចម្រុះគ្នានៃការតាំងសេចក្ដីសញ្ញារបស់ព្រះជាមួយជាមួយរាស្ត្ររបស់ទ្រង់ ភាពជាហោរា ភាពជាសង្ឃ និងភាពជាស្ដេចរបស់ព្រះគ្រីស្ទ និងអំពីនគរព្រះ ទាំងនៅក្នុងព្រះគម្ពីរសញ្ញាចាស់ និងក្នុងព្រះគម្ពីរសញ្ញាថ្មី។ សូមស្វែងយល់អំពីប្រធានបទទាំងនេះនៅក្នុងព្រះគម្ពីរទាំងមូល ហើយកត់ចំណាំអំពីការបន្ត និងការបញ្ឈប់ក្នុងដំណាក់កាលនានាក្នុងប្រវត្តិសាស្ត្រនៃការប្រោសលោះ។ នៅពេលលោកអ្នកធ្វើដូច្នេះ នោះសេចក្ដីល្អរបស់ព្រះជាម្ចាស់ និងសិរីល្អនៃការប្រោសលោះនឹងមានក្នុងគំនិតរបស់លោកអ្នកនៅក្នុងរបៀបមួយដែលកាន់តែភ្លឺច្បាស់ និងលម្អិតជាងមុនជាមិនខាន។

## ចូរដាក់លក្ខណៈនៃព្រះគម្ពីរសញ្ញាថ្មីលើព្រះគម្ពីរសញ្ញាចាស់

ដូចជាយើងបានរៀបរាប់ពីមុន ព្រះគម្ពីរគឺជាដំណើររឿងតែមួយអំពីការប្រោសលោះរាស្ត្រដ៏ពិសេសមួយក្រុមសម្រាប់ទ្រង់ផ្ទាល់។ នៅពេលលោកអ្នកសិក្សាព្រះគម្ពីរសញ្ញាថ្មី សូមបង្ហាត់បង្រៀនខ្លួនឯង ឲ្យចេះភ្ជាប់អ្វីដែលបានរៀនទៅនឹងព្រះគម្ពីរសញ្ញាចាស់។ សូមសួរសំណួរដូចខាងក្រោមនេះ៖

- តើអត្ថបទនេះបានសម្រេចអ្វីមួយដែលបានសន្យានៅក្នុងព្រះគម្ពីរសញ្ញាចាស់ដោយរបៀបណា?
- តើគំនិតនៅក្នុងព្រះគម្ពីរសញ្ញាថ្មីនេះខុសគ្នា ឬស្រដៀងគ្នាទៅនឹងការបង្រៀននៅក្នុងព្រះគម្ពីរសញ្ញាចាស់ដោយរបៀបណា?

9Marks Online PDF

- តើនៅក្នុងរបៀបណាមួយដែលអត្ថបទព្រះគម្ពីរសញ្ញាថ្មីបញ្ជាក់ឲ្យច្បាស់ បើកសម្តែង ឬពន្យល់បន្ថែមអំពីអ្វីមួយទៀតចេញពីព្រះគម្ពីរសញ្ញាចាស់?

ការសួរសំណួរទាំងនេះនឹងជួយផ្តោតសំខាន់អំពីការរួបរួម និងភាពផ្សេងគ្នានៃព្រះគម្ពីរ និងសេចក្តីបង្រៀនរបស់ព្រះគម្ពីរជាដើម។ កណ្ឌគម្ពីរហេព្រើរគឺជាកណ្ឌដ៏ល្អមួយក្នុងការសិក្សាខណៈ ពេលដែលលោកអ្នកព្យាយាមឆ្លើយសំណួរទាំងនេះ។ សូមសិក្សាកណ្ឌគម្ពីរហេព្រើរ នោះលោកអ្នកនឹងមានសេចក្តីស្ញប់ស្ញែងក្នុងចិត្ត ចំពោះសេចក្តីដ៏ធំក្រៃលែងរបស់ព្រះយេស៊ូវគ្រីស្ទ ដែលមានបង្ហាញនៅក្នុងព្រះគម្ពីរសញ្ញាចាស់ជាមិនខាន។

## សិក្សាព្រះគម្ពីរសញ្ញាចាស់ដោយគិតអំពីព្រះយេស៊ូវ និងការមើលទ្រង់ឃើញនៅក្នុងព្រះគម្ពីរសញ្ញាថ្មី

នៅពេលដែលលោកអ្នកបានអាន និងសិក្សាព្រះគម្ពីរសញ្ញាចាស់ សូមសួរខ្លួនឯងថា តើការនោះមានភាពស៊ីគ្នាជាមួយនឹងការបើកសម្តែងនៃព្រះគម្ពីរសញ្ញាថ្មីយ៉ាងដូចម្តេច? ឧទាហរណ៍៖

- តើនៅកន្លែងណាដែលបទគម្ពីរនេះត្រូវគ្នានឹងពេលវេលានៃប្រវត្តិសាស្ត្រនៃការប្រោសលោះ?
- តើបទគម្ពីរនេះចង្អុលបង្ហាញប្រាប់យើងអំពីព្រះយេស៊ូវដោយរបៀបណា?
- តើសេចក្តីពិតអំពីសាសន៍អ៊ីស្រាអែលមានទាក់ទងគ្នាទៅនឹងគំនិតដែលមាននៅក្នុងព្រះគម្ពីរសញ្ញាថ្មីអំពីពួកជំនុំយ៉ាងដូចម្តេចខ្លះ?
- តើបទគម្ពីរនេះមានសារៈសំខាន់យ៉ាងដូចម្តេច សម្រាប់ការយល់ដឹងអំពីជំនឿគ្រីស្ទបរិស័ទនៅសម័យព្រះសញ្ញាថ្មីនេះ?

9Marks Online PDF

- តើគំនិត ឬក៏ការបង្រៀននៅក្នុងព្រះគម្ពីរសញ្ញាចាស់នេះបន្ត ឬមិនបន្តនៅក្នុងព្រះគម្ពីរសញ្ញាថ្មីដោយរបៀបណា?
- តើខគម្ពីរសញ្ញាថ្មីណាខ្លះដែលឆ្លើយតបនឹងសំណួរទាំងនេះ?

ចំពោះសិស្ស ដែលសិក្សាទេវវិទ្យាតាមព្រះគម្ពីរម្នាក់ដែលចេះច្រើន គឺគាត់យល់អំពីការបន្តសាច់រឿងនៅក្នុងព្រះបន្ទូល នៅពេលដែលគាត់សិក្សា។

## ចូរសិក្សាកណ្ឌគម្ពីរទំនាយនៅក្នុងព្រះគម្ពីរសញ្ញាចាស់

ទំនងមនុស្សជាច្រើន  មានការធ្វេសប្រហែសក្នុងការសិក្សាកណ្ឌគម្ពីរទំនាយនៃព្រះគម្ពីរសញ្ញាចាស់ ជាពិសេសកណ្ឌគម្ពីរនានាដែលគេដាក់ឈ្មោះឲ្យថា «គម្ពីរហោរាតូច»។ កណ្ឌគម្ពីរហោរាមានសេចក្ដីបង្រៀនដ៏មានតម្លៃមួយចំនួននៅក្នុងព្រះបន្ទូលអំពីជីវិត ព័ន្ធកិច្ច និងភាពឧត្ដុង្គឧត្ដមរបស់ព្រះយេស៊ូវគ្រីស្ទ។ ឧទាហរណ៍៖ នៅពេលលោកអ្នកសិក្សាកណ្ឌគម្ពីរអេសាយ ឬកណ្ឌគម្ពីរសាការី ចូរចងចាំថា ទំនាយនៅក្នុងកណ្ឌគម្ពីរទាំងនោះអាចសម្រេចឡើងរបៀបជាច្រើន។ ទំនាយណាក៏ដោយក៏អាចនឹងសម្រេចនៅក្នុងផ្នែកណាមួយបាន អាចថានៅក្នុងសម័យហោរានោះផ្ទាល់។ ហើយទំនាយដដែលនោះក៏អាចនឹងបំពេញសម្រេច «ក្នុងព្រះយេស៊ូវគ្រីស្ទ»។ ហើយវាក៏អាចនឹងសម្រេច «នៅគ្រានៃថ្ងៃចុងក្រោយបំផុតនៃផែនដីនេះ» ដែលនេះមានន័យថា វានឹងកើតឡើងនៅគ្រាចុងបញ្ចប់នៃពេលវេលានៅពេលដែលអ្វីៗគ្រប់យ៉ាងបានសម្រេចជាស្រេច។ ការសិក្សានិងការយល់ដឹងអំពីទំនាយនៅក្នុងរបៀបនេះនឹងជួយឲ្យយើងយកចិត្តទុកដាក់ផ្ដោតសំខាន់លើរូបភាពធំនៃព្រះគម្ពីរ និងធ្វើឲ្យចំណេះដឹងរបស់យើងអំពីព្រះជាម្ចាស់កាន់តែស៊ីជម្រៅជាងមុន។

## សូមស្គាល់ និងឯកភាពដោយគាំទ្រលើគោលជំនឿរបស់

9Marks Online PDF

## ពួកជំនុំរបស់លោកអ្នក

នៅពេលយើងចូលរួមនៅក្នុងពួកជំនុំណាមួយ យើងគួរតែដឹងថា តើពួកជំនុំនោះជឿលើអ្វីខ្លះ ហើយថា តើយើងឯកភាពជាមួយនឹងការបង្រៀននោះដែរឬទេ។ ដូច្នេះ សូមប្ដេជ្ញាចិត្តក្នុងការសិក្សាគោលជំនឿរបស់ពួកជំនុំនោះ។ តើគោលជំនឿនោះមានគោលលទ្ធិត្រឹមត្រូវដែរឬទេ? តើវាជាគោលជំនឿមួយដែលមានប្រវត្តិសាស្ត្រពិសេសនៅក្នុងពួកជំនុំតាមតំបន់នោះឬ? តើគោលជំនឿនោះឯកភាពជាមួយ ឬក៏ចាកចេញពីទំនៀមទម្លាប់របស់គ្រីស្ទបរិស័ទទូទៅ? តើលោកអ្នកយល់គោលជំនឿនោះដែរឬទេ? មានពួកជំនុំមួយចំនួនមានការអនុវត្ត ដែលមានសុខភាពល្អ ក្នុងការតម្រូវការឲ្យសមាជិកថ្មីចុះហត្ថលេខាលើគោលជំនឿរបស់ពួកជំនុំនោះ ទុកជាការបង្ហាញអំពីការឯកភាពរបស់ខ្លួន និងការស្ម័គ្រចិត្តការពារសេចក្ដីពិតដែលមាននៅក្នុងនោះ។ តើលោកអ្នកអាចនឹងចុះហត្ថលេខាលើគោលជំនឿរបស់ពួកជំនុំរបស់លោកអ្នក ដោយមានបញ្ញាចិត្តល្អបានដែរឬទេ? ប្រសិនជាអាច ចូរប្ដេជ្ញាចិត្តក្នុងការទ្រទ្រង់ភាពស្មោះត្រង់នៃគោលលទ្ធិពួកជំនុំរបស់លោកអ្នកចុះ។

## សូមស្វែងរកការរួបរួមខាងគោលលទ្ធិ ហើយជៀសវាងពីការមានជម្លោះឥតប្រយោជន៍

ពេលខ្លះ ការយល់ដឹងខុសគ្នាលើគោលលទ្ធិនឹងកើតឡើងនៅក្នុងពួកជំនុំតាមតំបន់។ សំណួរគន្លឹះសម្រាប់សមាជិកគឺថា “តើលោកអ្នកនឹងចូលរួមរកដំណោះស្រាយលើការយល់ដឹងខុសគ្នានោះដោយរបៀបណា?” មានពាក្យស្លោកបុរាណដែលមានប្រយោជន៍ណាស់ ដែលបានពោលថា “នៅក្នុងគ្រប់ការសំខាន់ ចូរមានការរួបរួម នៅក្នុងគ្រប់ការដែលមិនសំខាន់ ចូរ

9Marks Online PDF

មានសេរីភាព ហើយនៅក្នុងគ្រប់ការទាំងអស់ ចូរមានសេចក្ដីស្រឡាញ់»។ សមាជិកពួកជំនុំដែលមានសុខភាពល្អ ដែលបានប្ដេជ្ញាចិត្តធ្វើជាអ្នកសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ គាត់នឹងខំសង្វាតយល់ភាពខុសគ្នារវាងសេចក្ដីជំនឿដែលមានសំខាន់ចំពោះជំនឿគ្រីស្ទបរិស័ទតាមព្រះគម្ពីរ និងជំនឿដែលមិនសំខាន់ចំពោះការស្មោះត្រង់ ព្រមទាំងការបន្ដជំនឿទៅមុខទៀត។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងប្ដេជ្ញាចិត្តក្នុងការការពារសេចក្ដីដ៏សំខាន់នៃដំណឹងល្អ (ភីលីព ១:២៧; យូដាស ១:៣) ខណៈពេលដែលកំពុងជៀសវាងពីជម្លោះ និងការមិនឯកភាពគ្នាអំពីការដែលមិនសំខាន់ចំពោះដំណឹងល្អ។ ការណែនាំរបស់សាវ័ក ប៉ុល ដល់លោកធីម៉ូថេ មានភាពសមរម្យណាស់៖

> «ចូររម្លឹកគេពីសេចក្ដីទាំងនេះ ហើយហាមប្រាមគេដោយដាច់ខាតនៅចំពោះព្រះអម្ចាស់ថា កុំឲ្យជជែកគ្នាពីន័យពាក្យ ដែលជាការឥតប្រយោជន៍ ហើយក៏នាំពួកអ្នកដែលស្ដាប់ ឲ្យវង្វេងផងនោះឡើយ។ ចូរខំប្រឹងនឹងថ្វាយខ្លួនដល់ព្រះ ទុកជាមនុស្សដែលបានល្បងលជាប់ហើយ ជាអ្នកធ្វើការ ដែលមិនត្រូវខ្មាសឡើយ ដោយកាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ។ តែត្រូវចៀសចេញពីពាក្យសម្ដីឡេះឡោះឥតប្រយោជន៍ ដ្បិតពាក្យយ៉ាងនោះ នឹងនាំឲ្យចម្រើនសេចក្ដីទមិលល្មើស កាន់តែច្រើនឡើងទេ។ ហើយសម្ដីគេនឹងស៊ីរូងដូចជាដំបៅក្លាយ» (២ធីម៉ូថេ ២:១៤-១៧)។

ម្យ៉ាងវិញទៀត យើងគួរជាអ្នកមានជំនាញក្នុងការកាត់ស្រាយព្រះបន្ទូលនៃសេចក្ដីពិតយ៉ាងត្រឹមត្រូវ ប៉ុន្ដែយើងក៏គួរតែគ្មានកំហុសក្នុងការបង្កឲ្យមានជម្លោះលើរឿងឥតប្រយោជន៍។ ការឈ្លោះគ្នាដោយសាររឿង

9Marks Online PDF

កំបិុកកំប៉ុក និងការឥតប្រយោជន៍ «នាំពួកអ្នកដែលស្តាប់ ឲ្យវង្វេង» ហើយប្រៀបដូចជាដំបៅក្លាយ វានាំឲ្យចម្រើនសេចក្តីទមិលល្មើសឡើង។ ចូរយើងខំឲ្យបានភាពរួបរួមនៅក្នុងសេចក្តីជំនឿ និងសេចក្តីសុខសាន្តនៅក្នុងពួកជំនុំរបស់យើង ដោយចងចាំថា «អ្នកណាដែលមិនព្រមបៀតខ្លួន ក្នុងការឈ្លោះប្រកែកគ្នា នោះជាកិត្តិសព្ទដល់ខ្លួនហើយ ប៉ុន្តែគ្រប់ទាំងមនុស្សល្ងីល្ងើគេចេះតែរករឿងវិញ» (សុភាសិត ២០:៣)។

## *សេចក្តីសន្និដ្ឋាន*

លោក ជេ. អាយ. ភែកឌ័រ បានលើកឡើងថា ការស្គាល់ព្រះជាម្ចាស់ចាប់ផ្តើមពីការស្គាល់អំពីទ្រង់ និងអំពីលក្ខណសម្បត្តិរបស់ទ្រង់។ វាក៏ពាក់ព័ន្ធទៅនឹងការថ្វាយខ្លួនទៅព្រះជាម្ចាស់ ដោយផ្អែកលើសេចក្តីសន្យារបស់ទ្រង់ គឺឲ្យទ្រង់ធ្វើជាព្រះអង្គរបស់លោកអ្នកតាមរយៈការប្រែចិត្ត និងសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទ ដែលជាព្រះរាជបុត្រារបស់ទ្រង់ផងដែរ។ ជាលទ្ធផល ការស្គាល់ព្រះមានន័យថា យើងត្រូវដើរតាមព្រះយេស៊ូវក្នុងនាមជាសិស្សរបស់ទ្រង់។ ហើយលើសពីនេះទៅទៀត ការស្គាល់ព្រះធ្វើឲ្យយើង «លើសជាងអ្នកដែលមានជ័យជំនះទៅទៀត» ដោយមានសេចក្តីអំណរនៅក្នុងភាពគ្រប់គ្រាន់របស់ព្រះជាម្ចាស់ ក្នុងគ្រប់ការទាំងអស់។ យើងអាចទទួលបានចំណេះដឹងអំពីព្រះបែបនេះ ដោយក្រេបជញ្ជក់ព្រះរាជសារដ៏ជ្រាលជ្រៅនៃព្រះគម្ពីរ ដែលមានគ្រប់ទាំងប្រធានបទដែលមានតម្លៃ។ ហើយចំណេះដឹងអំពីព្រះបែបនេះគឺជាកម្មសិទ្ធិពិសេសរបស់សមាជិកពួកជំនុំគ្រីស្ទបរិស័ទដែលបានប្តេជ្ញាចិត្តធ្វើជាទេវវិទូតាមព្រះគម្ពីរតែប៉ុណ្ណោះ។

9Marks Online PDF

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. តើលោកអ្នកចេះសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរដល់កម្រិតណា? តើលោកអ្នកគិតថា ខ្លួនមានការយល់ដឹងគ្រប់គ្រាន់អំពីប្រធានបទសំខាន់ៗ និងដំណើររឿងនៃព្រះគម្ពីរដែរឬទេ? តើលោកអ្នកអាចពន្យល់ដល់គ្រីស្ទបរិស័ទថ្មីណាម្នាក់ ឬអ្នកមិនទាន់ជឿអំពីរបៀបដែលព្រះគម្ពីរទាំងមូលមានការស៊ីចង្វាក់គ្នាជាព្រះគម្ពីរតែមួយបានដែរឬទេ?

២. តើលោកអ្នកមានផែនការជាក់លាក់អ្វីខ្លះ ដើម្បីពង្រឹងចំណេះដឹងនៃការសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីររបស់ខ្លួន

9Marks Online PDF

សញ្ញាសម្គាល់ទី៣

# សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកជ្រាបជោគនៅក្នុងដំណឹងល្អ

**សេចក្ដីត្រូវការដ៏ធំបំផុត** នៅក្នុងពិភពលោកបច្ចុប្បន្ននេះ គឺ ដំណឹងល្អ។ នេះជាសេចក្ដីត្រូវការដ៏ធំបំផុតរបស់ពិភពលោក ពីព្រោះទាំងបុរស និងស្ត្រី ព្រមទាំងកុមារាកុមារីកំពុងតែវិនាសដោយមិនបានស្គាល់នូវចំណេះដឹងដែលមានសារៈសំខាន់បំផុតអំពីព្រះជាម្ចាស់ តាមរយៈដំណឹងល្អនៃព្រះអង្គសង្គ្រោះរបស់យើង និងព្រះយេស៊ូវដ៏ជាព្រះរាជបុត្រានៃព្រះ។

សេចក្ដីត្រូវការដ៏ធំបំផុតនៅក្នុងពួកជំនុំបច្ចុប្បន្ននេះគឺ ដំណឹងល្អ។ ដំណឹងល្អមិនមែនគ្រាន់តែជាដំណឹងសម្រាប់លោកីយ៍ ដែលកំពុងតែវិនាសតែមួយប៉ុណ្ណោះទេ ប៉ុន្តែវាក៏ជារាជសារដែលបង្កើត ទ្រទ្រង់ជីវិត និងជាកម្លាំងដល់ពួកជំនុំផងដែរ។ បើគ្មានដំណឹងល្អទេ នោះពួកជំនុំក៏គ្មានអ្វីដែលត្រូវនិយាយបានដែរ—នេះមានន័យថា គ្មានអ្វីដែលត្រូវនិយាយបានដោយក្រុមការងារមនុស្សធម៌ផ្សេងទៀតបានធ្វើហើយនោះទេ។ ដំណឹងល្អធ្វើឲ្យពួកជំនុំមានភាពខុសគ្នាពីលោកីយ៍នេះ ដំណឹងល្អពណ៌នាអំពីព្រះ

9Marks Online PDF

រាជសារ និងបេសកកម្មនៅក្នុងលោកីយ៍នេះ ហើយដំណឹងល្អរៀបចំពួកជំនុំ ដើម្បីប្រឆាំងនឹងព្រួញភ្លើងនៃសេចក្ដីអាក្រក់ និងការដែលគួរឲ្យចង់បានដែលក្លែងក្លាយពីអំពើបាប។ ដំណឹងល្អគឺសំខាន់ខ្លាំងណាស់ ដើម្បីឲ្យមានភាពរស់រវើក អំណរ ការតស៊ូ សេចក្ដីសង្ឃឹម និងគ្រីស្ទបរិស័ទ និងក្រុមជំនុំដែលមានសុខភាពល្អ។ ដំណឹងល្អពិតជាមានសារៈសំខាន់ណាស់ សំខាន់រហូតដល់តម្រូវឲ្យគ្រីស្ទបរិស័ទ ត្រូវជ្រមុជក្នុងនោះដើម្បីឲ្យអាចក្លាយសមាជិកដែលមានសុខភាពល្អបាន។

## ការក្លាយជាអ្នកដែលជ្រាបជោគនៅក្នុងដំណឹងល្អ

អញ្ចឹង! តើយើងជ្រមុជជោគនៅក្នុងដំណឹងល្អបានដោយរបៀបណា? តើផ្លូវណាអាចនឹងនាំយើងទៅកាន់សុខភាពដ៏ល្អខាងឯព្រលឹងវិញ្ញាណបាន?

## ស្គាល់អំពីដំណឹងល្អ

លំដាប់លំដោយទីមួយនៃការងារនេះ យើងត្រូវស្គាល់ដំណឹងល្អ។ នេះហាក់ដូចជាច្បាស់លាស់ពេកហើយ ដល់ថ្នាក់ថាការនិយាយបែបនេះស្ដាប់ទៅហាក់ដូចជាគួរឲ្យអស់សំណើច។ ប៉ុន្តែ ការពិតនោះគឺថា អ្នកដែលមានជំនឿ និងអស់អ្នកដែលប្រកាសថា ខ្លួនជាគ្រីស្ទបរិស័ទជាច្រើនមានការយល់ដឹងមិនស៊ីជម្រៅអំពីដំណឹងល្អទេ ទោះជាពួកគាត់ធ្លាប់បានឮ «ការចែកចាយដំណឹងល្អ» ខ្លីៗដែលបានដាក់ចូលនៅខាងចុងនៃសេចក្ដីអធិប្បាយ ជាច្រើនឆ្នាំហើយក៏ដោយ។ ហើយក៏នៅមានអ្នកខ្លះទៀត ដែលបានស្គាល់អំពីព្រះរាជសារអំពីព្រះគ្រីស្ទជាច្រើនឆ្នាំហើយក៏នៅតែគិតថាខ្លួនឯងឆ្គងៗ ហើយមិនមានសមត្ថភាពក្នុងការចែកចាយដំណឹងល្អនោះឲ្យបានច្បាស់ជាមួយគ្រួសារ និងមិត្តភក្ដិផងដែរ។ ការឈានជំហាន ដើម្បីឲ្យបានប្រាកដថា យើងពិតជាស្គាល់ដំណឹងល្អច្បាស់ និងស៊ីជម្រៅមែន

គឺជាការចាំបាច់ណាស់។

ជាការដែលមានប្រយោជន៍ក្នុងការដកចោលគំនិតមួយចំនួនដែលជាញឹកញាប់ត្រូវបានគេប្រកាសថា ជាដំណឹងល្អ។ ដំណឹងល្អមិនមែនគ្រាន់តែថា៖ ក) យើងមិនអីទេ ខ) ព្រះជាម្ចាស់ជាសេចក្ដីស្រឡាញ់ គ) ព្រះយេស៊ូវចង់ធ្វើជាមិត្តជាមួយយើង ឃ) ឬក៏ថាយើងគួរតែរស់នៅដោយត្រឹមត្រូវប៉ុណ្ណោះនោះទេ។[១] ដំណឹងល្អមិនមែនគ្រាន់តែជាការនិយាយថា គ្រប់បញ្ហាទាំងអស់របស់យើងនឹងត្រូវបានដោះស្រាយ ប្រសិនបើយើងដើរតាមព្រះយេស៊ូវ ឬក៏ថាព្រះជាម្ចាស់សព្វព្រះហឫទ័យចង់ឲ្យយើងមានសុខភាពល្អ មានទ្រព្យសម្បត្តិ និងមានប្រាជ្ញាទេ។ គំនិតទាំងអស់នេះអាចជាការពិតក្នុងករណីខ្លះៗ ប៉ុន្តែគ្រាន់តែក្នុងគំនិតមួយចំនួនតែប៉ុណ្ណោះ ហើយក៏មិនមែនជាការលើកឡើងគ្រប់គ្រាន់ទាំងស្រុងណាដែលពិពណ៌នាថា នេះហើយជាដំណឹងល្អនោះដែរ។

ដំណឹងនេះអំពីព្រះយេស៊ូវគ្រីស្ទគឺជា «ជាដំណឹងល្អ»។ ក្នុងលក្ខណៈជា*ដំណឹង* វាមានពាក្យពេចន៍នៃការពិត និងសេចក្ដីពិតដែលមកពីការពិតទាំងអស់នោះ។ ដំណឹង*ល្អ*ផ្ទុកនូវសេចក្ដីសង្ឃឹមដែលមានមូលដ្ឋានលើសេចក្ដីសន្យារបស់ព្រះជាម្ចាស់ ហើយបានចាក់ឫសនៅក្នុងការពិត និងសេចក្ដីពិតនៃប្រវត្តិសាស្ត្រដែលបង្ហាញជាភស្តុតាងថា សេចក្ដីសន្យាទាំងនោះគឺពិតត្រង់មែន។

ដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទគឺថា ព្រះជាម្ចាស់ដ៏ជាព្រះវរបិតាទ្រង់បរិសុទ្ធ ហើយសុចរិតនៅគ្រប់ចំណុចរបស់ទ្រង់ ព្រះអង្គមានសេចក្ដីក្រោធ

---

១ លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books), សូមអានជំពូក៣។

9Marks Online PDF

ជាមួយនឹងមនុស្សមានបាប ហើយនឹងដាក់ទោសដល់អំពើបាប។ មនុស្សដែលមិនបានស្តាប់បង្គាប់តាម ព្រះជាម្ចាស់ក៏បានដាច់ចេញពីសេចក្តីស្រឡាញ់របស់ព្រះអង្គ ហើយក៏កំពុងតែស្ថិតនៅក្នុងសេចក្តីក្រោធនៃការថ្កោលទោសដ៏ឈឺចាប់ និងអស់កល្បក្រោមព្រះហស្តរបស់ព្រះជាម្ចាស់ដែរ។ ប៉ុន្តែ ព្រះជាម្ចាស់ដែលទ្រង់មានពេញដោយសេចក្តីមេត្តាករុណាដោយសារសេចក្តីស្រឡាញ់ដ៏អស្ចារ្យរបស់ទ្រង់ នោះព្រះអង្គបានចាត់ព្រះរាជបុត្រាដ៏អស់កល្បរបស់ទ្រង់ឲ្យមកយកកំណើតនៅស្ត្រីព្រហ្មចារីគឺនាងម៉ារា ដើម្បីឲ្យទ្រង់សុគតទុកជាថ្លៃលោះ និងជាអ្នកជំនួសសម្រាប់អំពើបាបនៃពួកមនុស្សបះបោរ។ ហើយឥឡូវនេះ តាមរយៈការស្តាប់បង្គាប់ដ៏គ្រប់លក្ខណ៍របស់ព្រះរាជបុត្រានៃទ្រង់ និងការសុគតដ៏ស្ម័គ្រព្រះទ័យនៅលើឈើឆ្កាងទុកជាថ្លៃសងសម្រាប់អំពើបាបរបស់យើង នោះអស់អ្នកដែលកែប្រែចិត្ត ហើយជឿលើព្រះយេស៊ូវគ្រីស្ទ ដោយដើរតាមទ្រង់ថាជាព្រះអង្គសង្គ្រោះ និងជាព្រះអម្ចាស់ នោះពួកគាត់នឹងបានទទួលសេចក្តីសង្គ្រោះឲ្យរួចពីសេចក្តីក្រោធរបស់ព្រះដែលនឹងត្រូវមក។ ព្រះអង្គនឹងរាប់ពួកគាត់ថាសុចរិតនៅចំពោះព្រះជាម្ចាស់។ ពួកគាត់នឹងមានជីវិតអស់កល្បជានិច្ច។ ពួកគាត់នឹងទទួលបានព្រះវិញ្ញាណនៃព្រះ ទុកភ្លក់ជាមុននៃសិរីល្អនៅនគរស្ថានសួគ៌ជាមួយនឹងព្រះជាម្ចាស់ផ្ទាល់។

នេះជាការនិយាយយ៉ាងខ្លី៖ យើងត្រូវតែក្រេបយក ហើយរីករាយក្នុងដំណឹងល្អនេះ ប្រសិនបើយើងក្លាយជាសមាជិកពួកជំនុំដែលមានសុខភាពល្អ។

9Marks Online PDF

## ចូរមានចិត្តចង់ឮដំណឹងល្អ និងប្រកាសដំណឹងល្អទៅកាន់ខ្លួនឯង

យើងត្រូវតែបណ្តុះបណ្តាល ឲ្យមានការស្រេកឃ្លានខ្លាំងលើព្រះរាជសារនេះ។ ការស្តាប់ និងការព្យាយាមយល់ឲ្យបានទៀងទាត់អំពីជម្រៅនៃដំណឹងល្អនឹងចម្រើនចំណេះដឹងនៃព្រះរាជសារនេះ ចម្រើនសេចក្តីស្រឡាញ់របស់យើងចំពោះព្រះអង្គសង្គ្រោះ និងចម្រើនជំនាញរបស់យើងក្នុងការចែកចាយព្រះរាជសារនេះផងដែរ។

ដូច្នេះ យើងគួរតែស្តាប់ដោយសកម្ម ហើយយកចិត្តទុកដាក់ចំពោះដំណឹងល្អ និងការនិយាយសំដៅទៅកាន់ដំណឹងល្អ នៅក្នុងសេចក្តីអធិប្បាយ។ សូមកុំបិទត្រចៀករបស់លោកអ្នកឲ្យសោះ នៅពេលដែលគ្រូគង្វាលចាប់ផ្តើមប្រកាសព្រះរាជសារនៃដំណឹងល្អ ដល់អស់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទនៅឡើយ។ ចូរស្តាប់ទុកដូចជារឿងថ្មី។ ចូរបញ្ជាក់សេចក្តីជំនឿរបស់លោកអ្នកឡើងវិញ នៅក្នុងសេចក្តីពិត សេចក្តីសន្យា និងព្រះចេស្តានៅក្នុងដំណឹងល្អនោះ ក្នុងជីវិតរបស់អ្នកចុះ។ ចូរយកដំណឹងល្អនោះទុកជារបស់ខ្លួនឯងសម្រាប់កម្ចាត់អំពើបាបទាំងឡាយណា ដែលលោកអ្នកដឹងតាមរយៈសេចក្តីអធិប្បាយ និងក៏តាមការពិនិត្យមើលខ្លួនឯង។ នៅពេលដែលលោកអ្នកឮអំពីដំណឹងល្អ ចូរយល់ថាអំពើបាប*របស់លោកអ្នក*បានជាប់នៅលើឈើឆ្កាង។ ចូរពិចារណាថា តើមានសេចក្តីសន្យាថ្មីណាខ្លះទៀត ឬផ្នែកណាទៀតដែលមាននៅក្នុងដំណឹងល្អ តាមរយៈសេចក្តីអធិប្បាយនោះ។ តើលោកអ្នកនឹងកាន់ខ្ជាប់ទៅនឹងសេចក្តីពិតទាំងនោះដោយរបៀបណា?

ចូរស្តាប់ដោយសកម្ម ហើយមានចិត្តចង់បានដំណឹងនេះ រហូតដល់ថ្នាក់ថាវាធ្វើឲ្យលោកអ្នកមានអារម្មណ៍ថា ខ្លួនក្រីក្រ ហើយខ្វះជីវជាតិ

9Marks Online PDF

អាហារនៅពេលណាមិនបានឮដំណឹងនេះនៅក្នុងសេចក្ដីអធិប្បាយ។ ហើយនៅពេលណាដែលលោកអ្នកមានអារម្មណ៍ថា ខ្លួនមិនបានឆ្អែត ឬនៅមានតម្រូវការ នោះចូរប្រកាសដំណឹងល្អនេះទៅកាន់ខ្លួនឯងចុះ។ នេះជាព្រះរាជសារដែលផ្ញើមកកាន់លោកអ្នក ហើយសម្រាប់អ្នកផងដែរ។ ចូរយកដំណឹងល្អនេះចុះ។ ជាជាងគ្រាន់តែស្ដាប់អ្នកដទៃ ឬស្ដាប់សម្លេងដែលធ្វើឲ្យអ្នកមានសេចក្ដីសង្ស័យ សេចក្ដីខ្វល់ខ្វាយ ភាពភ័យខ្លាច ចូរស្ដាប់ព្រះសូរសៀងរបស់ព្រះនៅក្នុងដំណឹងល្អដោយការប្រកាសដំណឹងល្អនោះដល់ខ្លួនឯង នៅពេលមានសេចក្ដីត្រូវការចុះ។ នៅក្នុងសៀវភៅដ៏ល្អ និងមានប្រយោជន៍របស់លោក ស៊ី. ចេ. ម៉ាហានី (C.J. Mahaney) ដែលមានចំណងជើងថា ការរស់ក្នុងជីវិតដែលយកឈើឆ្កាងជាធំ៖ ការថែរក្សាដំណឹងល្អជារបស់សំខាន់ (Living the Cross Centered Life: Keeping the Gospel the Main Thing) គាត់បានស្នើឲ្យយើងទន្ទេញដំណឹងល្អ អធិស្ឋានដំណឹងល្អ ច្រៀងអំពីដំណឹងល្អ រម្លឹកអំពីរបៀបដែលដំណឹងល្អបានផ្លាស់ប្រែយើង និងបន្តសិក្សាដំណឹងល្អទៀតផង។

## ចូរយកដំណឹងល្អទៅដល់សេចក្ដីសន្និដ្ឋាន

នៅពេលលោកអ្នកជញ្ជឹងគិតអំពីព្រឹត្តិការ និងសេចក្ដីសន្យានានានៃដំណឹងល្អ ចូរខំប្រឹងទៅឯសេចក្ដីសន្និដ្ឋាននៃដំណឹងល្អចុះ។ លោកគ្រូ ចន ផាយភ័រ (John Piper) បានរម្លឹកយើងថា ព្រះគឺជាដំណឹងល្អ ដែលថាដំណឹងល្អនោះគឺជាព្រះរាជសារអំពីព្រះ ដែលបានថ្វាយអង្គទ្រង់ដល់យើងដោយសេចក្ដីស្រឡាញ់៖

> **លោកអ្នក មិនបានឱបដំណឹងល្អនៃព្រះជាម្ចាស់នៅឡើយទេ ប្រសិន**

9Marks Online PDF

> បើព្រឹត្តិការដំណឹងល្អនៃបុណ្យថ្ងៃសុក្រដ៏ល្អ (Good Friday) និងបុណ្យព្រះអង្គមានព្រះជន្មរស់ (Easter) ព្រមទាំងសេចក្តីសន្យារបស់ដំណឹងល្អនៃការរាប់ជាសុចរិត និងជីវិតអស់កល្បជានិច្ចមិនបាននាំឲ្យលោកអ្នកមើលឃើញ ហើយឱបក្រសោបព្រះជាម្ចាស់ផ្ទាល់ថាជាសេចក្តីអំណរដ៏ខ្ពស់បំផុតរបស់លោកអ្នកទេ។ លោកអ្នកបានឱបអំណោយទានតែមួយចំនួនរបស់ទ្រង់ប៉ុណ្ណោះ។ លោកអ្នកបានមានសេចក្តីរីករាយចំពោះរង្វាន់មួយចំនួន ដែលទ្រង់ប្រទានឲ្យតែប៉ុណ្ណោះ។លោកអ្នកគ្រាន់តែមានសេចក្តីអស្ចារ្យចំពោះការអស្ចារ្យមួយចំនួនរបស់ទ្រង់ទេ។ ប៉ុន្តែ លោកអ្នកមិនទាន់បានភ្ញាក់ ដោយដឹងអំពីមូលហេតុដែលអំណោយទាន រង្វាន់ និងការអស្ចារ្យទាំងនោះបានមកនៅឡើយទេ។ ទាំងអស់នោះបានមកសម្រាប់ហេតុផលដ៏ធំមួយ គឺ ដើម្បីឲ្យលោកអ្នកសម្លឹងមើលសិរីល្អនៃព្រះជាម្ចាស់នៅក្នុងព្រះគ្រីស្ទជារៀងរហូត ហើយតាមរយៈការសម្លឹងមើល នោះលោកអ្នកបានក្លាយជាប្រភេទមនុស្ស ដែលរីករាយនៅក្នុងព្រះជាម្ចាស់លើសគ្រប់អ្វីៗទាំងអស់។ ហើយតាមរយៈការរីករាយ នោះលោកអ្នកនឹងបង្ហាញអំពីសេចក្តីលម្អដ៏លើសលប់ និងតម្លៃដ៏អស្ចារ្យនៃដែលពន្លឺចែងចាំង និងមានសុភមង្គលដ៏គ្រប់លក្ខណ៍ជារៀងរហូត។[២]

## ចូររៀបចំលំដាប់លំដោយជីវិតរបស់លោកអ្នកជុំវិញដំណឹងល្អ

ក្នុងនាមជាសមាជិកពួកជំនុំ គោលបំណងរបស់យើងគឺ ដើម្បីយល់អំពីដំណឹងល្អឲ្យបានស៊ីជម្រៅ ឲ្យបានជិតស្និតដល់ថ្នាក់ថាវាផ្តល់កម្លាំង និង

---

២ លោកគ្រូ John Piper, God Is the Gospel: Meditations on God’s Love as the Gift of Himself (Wheaton, IL: Crossway Books, ឆ្នាំ២០០៥), ទំព័រ៣៨។ អក្សរដិតមាននៅក្នុងការបោះពុម្ពដើម។

ជីវិតដល់គ្រប់ផ្នែកនៃជីវិតរស់នៅរបស់យើង។ យើងត្រូវការឲ្យដំណឹងល្អជាចំណុចស្នូលក្នុងទំនាក់ទំនងរបស់យើងជាមួយអ្នកដទៃទៀត ជាចំណុចស្នូលចំពោះរបៀបដែលយើងលើកទឹកចិត្ត និងកែតម្រង់ ជាចំណុចស្នូលចំពោះគ្រប់ការងារ និងសេចក្ដីសម្រេចចិត្តផ្នែកទំនាក់ទំនងគ្នា ជាចំណុចស្នូលចំពោះការសម្រេចចិត្តនានា ដែលធ្វើឡើងរួមគ្នា និងជាចំណុចស្នូលក្នុងគ្រប់ទាំងទម្លាប់នៃជីវិតរបស់យើង។ យើងត្រូវការដំណឹងល្អ (ព្រះជាម្ចាស់នៃដំណឹងល្អ) ក្លាយជាការជ្រើសរើសអាទិភាពចម្បងនៅក្នុងគ្រប់ទាំងផ្នែកនៃជីវិតយើង។ សមាជិកពួកជំនុំ ដែលជ្រាបជោគនៅក្នុងដំណឹងល្អគួរតែពិចារណាអំពីយុទ្ធសាស្ត្រនានា ដើម្បីរៀបចំជីវិតរបស់ខ្លួនជុំវិញដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទដូចជា៖

- ការទៅកន្លែងលក់ដូរជាក់លាក់ណាមួយដដែល ឲ្យបានញឹក ញាប់ (កន្លែងអ្នកបោកសម្អាត អ្នកធ្វើការនៅភោជនីយដ្ឋាន...។ល។) ដោយមានគោលបំណង ដើម្បីកសាងទំនាក់ទំនង និងឲ្យស្គាល់គ្នាជាមួយបុគ្គលិកនៅទីនោះដោយសង្ឃឹមថាខ្លួននឹងបានសន្ទនាជាមួយគ្នាអំពីដំណឹងល្អ។
- ការប្រើប្រាស់វិស្សមកាលសម្រាប់ចុះបេសកកម្មខ្លី។
- ការស្ម័គ្រចិត្តចូលរួមនៅក្នុងអង្គការសហគមន៍ ដើម្បីជះឥទ្ធិពលសម្រាប់ដំណឹងល្អ។
- ការផ្ដើមឲ្យមានការពិភាក្សានៅផ្ទះខ្លួនអំពីសាសនា និងទស្សនវិជ្ជា។
- ការអញ្ជើញអ្នកជិតខាងមកញ៉ាំអាហារ ឬក៏ជប់លៀងនៅថ្ងៃសម្រាក ហើយនិយាយជាមួយពួកគេអំពីព្រះគ្រីស្ទ។
- ការផ្ដើមឲ្យមានការសិក្សាព្រះគម្ពីរនៅកន្លែងធ្វើការ។
- ការចូលរួមក្នុងក្លឹបសហគមន៍ (ក្លឹបសួនច្បារ ក្លឹបជិះកង់...ល។) ដើម្បី

កសាងទំនាក់ទំនង និងឲ្យមានឱកាសក្នុងការចែកចាយដំណឹងល្អនៅពេលអនាគត។

- ការអញ្ជើញមិត្តភក្តិមកព្រះវិហារនិងមកកម្មវិធីផ្សេងៗរបស់ពួកជំនុំដែលមានការផ្សាយដំណឹងល្អ។

យើងត្រូវចាំថា ពុំមានហានិភ័យអ្វីទាំងអស់ក្នុងការចែកចាយដំណឹងល្អមានតែរង្វាន់នៃការស្មោះត្រង់តែប៉ុណ្ណោះ។ យើងចង់ «ប្រុងខ្លួនជាស្រេច» ក្នុងការប្រកាសព្រះបន្ទូលនៃជីវិត។

## ចូរចែកចាយដំណឹងល្អជាមួយអ្នកដទៃ

ជួនកាល គ្រីស្ទបរិស័ទមួយចំនួនហាក់ដូចជាជឿថា គោលបំណងគឺប្រកាសដំណឹងល្អទៅគ្រប់មនុស្សទាំងអស់ រហូតដល់តែដំណឹងល្អនោះបានមកដល់ពួកគេ ហើយបន្ទាប់មកពួកគេត្រូវតែទុកដំណឹងល្អនោះចោល នៅក្នុងទូរសុវត្ថិភាពនៃប្រវត្តិសាស្រ្តផ្ទាល់ខ្លួនរបស់គេ ទុកឲ្យឆ្ងាយពីមនុស្សម្នាទៅវិញ។ គ្រីស្ទបរិស័ទមួយចំនួនបានគិតថា បើគ្រាន់តែចែកចាយទីបន្ទាល់ ឬរស់នៅជាជីវិតគ្រីស្ទបរិស័ទឲ្យបានល្អ នោះមានប្រសិទ្ធភាពដូចជាការប្រកាសដំណឹងល្អអញ្ចឹងដែរហើយ។ មិនមានការសង្ស័យអ្វីទេត្រង់ថា ជីវិតបែបនោះគឺជាបន្ទាល់មួយមែន។ ប៉ុន្តែ តើនេះជាទីបន្ទាល់អំពីឈើឆ្កាងនៃព្រះយេស៊ូវគ្រីស្ទដែរឬទេ? តើ «ការធ្វើទីបន្ទាល់» តាមរយៈការរស់នៅ និងទង្វើល្អផ្ទាល់របស់យើងចង្អុលបង្ហាញអំពីឈើឆ្កាង និងព្រះអង្គសង្គ្រោះក្នុងរបៀបដែលមានប្រសិទ្ធភាពគ្រប់គ្រាន់ដែរទេ?

មានករណីជាច្រើនណាស់ដែលការព្យាយាមបែបនេះបានគ្រាន់តែទុកឲ្យមានតែចំណាប់អារម្មណ៍ មិនច្បាស់លាស់នៃសេចក្តីឧស្សាហ៍ខាងសាសនាប៉ុណ្ណោះ ហើយមិនមែនជាការសម្តែងឲ្យឃើញដ៏ឆ្លាតវៃអំពីសិរីល្អ

9Marks Online PDF

របស់ព្រះជាម្ចាស់ នៅក្នុងការប្រោសលោះដល់មនុស្សមានបាបតាមរយៈយញ្ញបូជានៃព្រះរាជបុត្រាទ្រង់ទេ។ ប្រសិនបើយើងចង់រួមចំណែកនៅក្នុងការធ្វើឲ្យពួកជំនុំមានសុខភាពល្អ នោះយើងត្រូវប្តេជ្ញាចិត្ត ដោយមិនគ្រាន់តែដើម្បីប្រមូលផលដំណឹងល្អសម្រាប់ខ្លួនឯងប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងដឹកជញ្ជូនដំណឹងល្អនោះទៅកាន់អ្នកដទៃទៀតផងដែរ។ យើងត្រូវតែធ្វើការជាអ្នកផ្សាយដំណឹងល្អ។ ដោយមានភាពបន្ទាន់ យើងត្រូវតែប្រាប់អ្នកដែលមិនមែនជាគ្រីស្ទបរិស័ទនៅក្នុងចំណោមយើង ឲ្យប្រែចិត្តចេញពីអំពើបាបរបស់ខ្លួន ហើយជឿដល់ព្រះយេស៊ូវគ្រីស្ទ។ យើងត្រូវតែប្រាប់ដល់ពួកគេថាការបែរទៅរកព្រះជាម្ចាស់ នឹងមិនធ្វើឲ្យពួកគេមានជីវិតដ៏ងាយស្រួលមួយនោះទេ ប៉ុន្តែការសម្រេចចិត្តនោះវាមានតម្លៃណាស់។ មានតែក្នុងតួអង្គនៃព្រះយេស៊ូវគ្រីស្ទតែមួយប៉ុណ្ណោះដែលពួកគេអាចទទួលបានការអត់ទោសបាប និងភាពស្កប់ចិត្តដែលព្រលឹងរបស់ខ្លួនបាន។

យើងមានឱកាស ដើម្បីធ្វើឲ្យការងាររបស់គ្រូគង្វាលរបស់យើងរីកចម្រើនឡើង ដោយការដាំ និងស្រោចទឹកដល់គ្រាប់ពូជដំណឹងល្អ ដែលគាត់បានដាំ និងស្រោចតាមរយៈការអធិប្បាយរបស់គាត់។ យើងអាចស្វាគមន៍ និងនិយាយលេងជាមួយភ្ញៀវ ដែលបានចូលរួមក្នុងព្រះវិហារយើង ហើយអញ្ជើញគ្រួសារ និងមិត្តភក្តិដែលមិនមែនជាអ្នកជឿឲ្យមកព្រះវិហារដែរ។ យើងគួរតែប្រើប្រាស់ឱកាសនៃការមកលេងរបស់ពួកគេ ដើម្បីពិភាក្សាអំពីរឿងខាងឯវិញ្ញាណ ជាពិសេសទាក់ទងទៅនឹងការយល់ដឹងរបស់ពួកគេអំពីដំណឹងល្អ និងការទទួលយក ឬក៏ការបដិសេធរបស់ពួកគេចំពោះដំណឹងល្អ។ យើងក៏អាចជួបជុំជាមួយគ្រីស្ទបរិស័ទដទៃទៀតផងដែរ ដើម្បីរៀបគម្រោង ហើយអធិស្ឋានឲ្យមានឱកាសក្នុងការផ្សាយដំណឹងល្អ។ ជីវិតដែលជ្រាបជោគនៅក្នុងដំណឹងល្អគឺជាជីវិតដែលបាច

9Marks Online PDF

សាចដល់អ្នកដទៃដោយដំណឹងល្អ។ ពួកជំនុំមានសុខភាពល្អគឺបានសង់ឡើងដោយ (ក្នុងផ្នែកមួយចំនួន) សមាជិកដែលទទួលបានការជំរុញទឹកចិត្តដោយដំណឹងល្អ។

## ចូរការពារដំណឹងល្អ

ជាចុងក្រោយ សមាជិកពួកជំនុំដែលមានសុខភាពល្អក៏ចេះទទួលខុសត្រូវ ដោយម៉ឺងម៉ាត់ក្នុងការការពារដំណឹងល្អពីសេចក្ដីពុករលួយ និងការបោះបង់ចោលដែរ។ ព្រះគម្ពីរសញ្ញាថ្មីហាក់ដូចជាដាក់ការទទួលខុសត្រូវនេះលើពួកជំនុំធ្ងន់ជាងដាក់លើគ្រូគង្វាលតែម្នាក់ឯង។ នៅពេលពួកជំនុំកាឡាទី មានភាពមិនច្បាស់លាស់ដោយសារមានគ្រូក្លែងក្លាយបានតែព្យាយាមបន្ថែមការកាត់ស្បែក លើសពីសេចក្ដីត្រូវការនៃដំណឹងល្អ នោះសាវ័ក ប៉ុល ក៏បានសរសេរសំបុត្រទៅកាន់ពួកចាស់ទុំ មិនមែនតែទៅកាន់តែគ្រូគង្វាលប៉ុណ្ណោះទេ។ ប៉ុន្តែ គឺផ្ញើទៅកាន់ពួកជំនុំផ្ទាល់តែម្ដង។ គាត់បានផ្ញើទៅកាន់អស់អ្នកដែលជាសមាជិក ហើយឲ្យពួកគេការពារដំណឹងល្អដែលគាត់បានប្រកាសដល់ពួកគេកាលពីមុន។ ការណែនាំរបស់គាត់គឺម៉ឺងម៉ាត់ខ្លាំងណាស់៖

> «ប៉ុន្តែ បើយើងខ្ញុំ ឬទេវតាពីស្ថានសួគ៌ នឹងប្រាប់ដំណឹងណាមកអ្នករាល់គ្នា ខុសពីដំណឹងល្អ ដែលយើងខ្ញុំបានប្រាប់ហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ។ ឯសេចក្ដីដែលខ្ញុំទើប នឹងនិយាយអម្បាញ់មិញនេះ នោះខ្ញុំនិយាយម្ដងទៀតថា បើអ្នកណាប្រាប់ដំណឹងណា ខុសអំពីដំណឹងល្អ ដែលអ្នករាល់គ្នាបានទទួលហើយ នោះឲ្យគេត្រូវបណ្ដាសាចុះ» (កាឡាទី ១:៨-៩)។

9Marks Online PDF

ពួកជំនុំកាឡាទី (គឺគ្រប់គ្រីស្ទបរិស័ទដែលជាសមាជិក) ត្រូវតែមានការប្រុងប្រយ័ត្នអំពីអ្វី ដែលពួកគេស្តាប់នៅក្នុងការប្រកាសដំណឹងល្អ។ សាវ័ក យ៉ូហាន បានដាស់តឿនដល់អ្នកអានរបស់គាត់ថា «បើអ្នកណាមកឯអ្នករាល់គ្នា តែមិនបង្រៀនចំពោះសេចក្តីនេះ នោះកុំឲ្យទទួលអ្នកនោះ នៅក្នុងផ្ទះឡើយ កុំឲ្យទាំងជម្រាបសួរដល់អ្នកនោះផង ដ្បិតបើអ្នកណាជម្រាបសួរ នោះក៏តែងមានសេចក្តីប្រកបគ្នា ក្នុងការអាក្រក់របស់អ្នកនោះដែរ» (២យ៉ូហាន ១:១០-១១)។ សាវ័ក ពេត្រុស បានរម្លឹកដល់អ្នកអានរបស់គាត់ថា អស់អ្នកណាដែលដើរ «ទៅតាមផ្លូវវិនាស» របស់គ្រូក្លែងក្លាយ នោះនឹងធ្វើឲ្យ «ផ្លូវពិតនឹងត្រូវសេចក្តីប្រមាថមើលងាយ» ជាមិនខាន (២ពេត្រុស ២:២)។ ហេតុដូច្នេះហើយបានជាយើងអាចយល់បានថា លោក យូដាស ខំព្យាយាមលើកទឹកចិត្តដល់អ្នកអានរបស់គាត់ឲ្យ «*ការពារ* សេចក្តីជំនឿ ដែលបានប្រគល់មកពួកបរិសុទ្ធ» (យូដាស ១:៣)។ ពួកជំនុំ និងសមាជិកពួកជំនុំដែលមានសុខភាពល្អច្បាំង ដើម្បីការពារដំណឹងល្អរបស់ពួកសាវ័កដែលបានចែកចាយ និងថែទាំនៅក្នុងទំព័រនៃព្រះគម្ពីរ។ នៅពេលដែលយើងមិនទទួលយកទំនួលខុសត្រូវនោះ ហើយបានមិនយកចិត្តទុកដាក់ក្នុងការយល់ដឹងពីដំណឹងល្អ ហើយអនុវត្តតាមដំណឹងល្អ នោះមានន័យថា យើងបានទុកចោលឲ្យដំណឹងល្អរងនូវសេចក្តីពុករលួយ រងការបំពាន និងបោះបង់ចោលដោយគ្រូមិនស្មោះត្រង់ និងអំណាចនៃអារក្សសាតាំងហើយ។

## *សេចក្តីសន្និដ្ឋាន*

នៅក្នុងដំណឹងល្អរបស់ព្រះយេស៊ូវគ្រីស្ទ ព្រះជាម្ចាស់បានប្រទានអង្គទ្រង់ផ្ទាល់*សម្រាប់*មនុស្សមានបាប និង*ដល់*មនុស្សមានបាប។ គឺដំណឹងល្អ

ហើយដែលធ្វើឲ្យយើងដឹងអំពីសេចក្ដីស្រឡាញ់របស់ព្រះ ហើយឲ្យយើងដឹងអំពីភាពអាក្រក់របស់យើង ដែលមិនអាចផ្គាប់ព្រះហឫទ័យដល់ព្រះជាម្ចាស់បាន ហើយនិងតម្រូវការនៃសេចក្ដីប្រោសលោះ ព្រមទាំងឲ្យយើងដឹងអំពីសេចក្ដីអំណរដ៏នៅអស់កល្បតាមរយៈការថ្វាយបង្គំព្រះជាម្ចាស់។ ដំណឹងល្អដដែលនេះ និងការយល់ដឹងដ៏ត្រឹមត្រូវអំពីវា ដែលនឹងបង្កើតឲ្យមានសុខភាពល្អ និងផ្ដល់កម្លាំងទៅដល់សមាជិកនៃពួកជំនុំគ្រីស្ទបរិស័ទ។ ចូរឲ្យយើងជ្រាបជោគនៅក្នុងដំណឹងល្អនេះចុះ!

## *ការពិចារណាបន្ថែម*

តើមានយុទ្ធសាស្ត្រអ្វីខ្លះដែលលោកអ្នកនឹងយកមកអនុវត្តផ្ទាល់ ដើម្បីធ្វើឲ្យលោកអ្នកគិតអំពី រស់នៅតាម និងចែកចាយដំណឹងល្អ?

## *សម្រាប់ការអានបន្ថែម*

“តើដំណឹងល្អជាអ្វី?” និពន្ធដោយលោក Bryan Chapell (https://plovpit.com/gospel-bryan/)។

“ការលះបង់របស់ព្រះគ្រីស្ទ” និពន្ធដោយលោក Stephen Charnock (https://www.fountofwisdomph.com/product/christ-crucified/)។

“តើព្រះយេស៊ូវពិតជាចង់មានន័យដូចម្ដេចនៅពេលដែលទ្រង់មានបន្ទូលថា “ចូរមកតាមខ្ញុំ”” និពន្ធដោយលោក David Platt (https://www.fountofwisdomph.com/product/follow-me/)។ “អង្គបម្រើ” និពន្ធដោយលោក T.D. Alexander (https://www.fountofwisdomph.com/product/the-servant-king/)។

9Marks Online PDF

សញ្ញាសម្គាល់ទី៤

# សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ

**មិត្តខ្ញុំម្នាក់ឈ្មោះ សិលា** គាត់មានសេចក្តីអំណរគ្រីស្ទបរិស័ទដែលឆ្លងដល់អ្នកដទៃ។ គាត់ស្រឡាញ់ព្រះអម្ចាស់ណាស់ ហើយក៏ឧស្សាហ៍ក្នុងការប្រកាសដំណឹងល្អដែរ។ សេចក្តីឧស្សាហ៍របស់ប្អូន សិលា ត្រូវបានគេសម្គាល់ជាការស្ម័គ្រចិត្តមួយ "ធ្វើអ្វីៗគ្រប់បែបយ៉ាង" ដើម្បីឲ្យគេ "ប្រកាសពីជំនឿនៅក្នុងព្រះគ្រីស្ទ"។

ថ្ងៃមួយប្អូន សិលា (ដោយមានសេចក្តីអំណរដូចសព្វដង) បានប្រាប់ខ្ញុំអំពីមិត្តរបស់គាត់ម្នាក់ឈ្មោះ រ៉ូ ដែល "បានកើតជាថ្មី"។ ខ្ញុំបានភ្ញាក់ផ្អើលយ៉ាងខ្លាំងដោយសម្តីរបស់ប្អូន សិលា។ ដោយមើលរំលងការរំភើបរបស់គាត់ ខ្ញុំក៏បានសួរគាត់ថា "តើប្អូនដឹងដោយរបៀបណាថា គាត់បានកើតជាថ្មីហើយនោះ?"

ប្អូន សិលា បានដកខ្លួនបន្តិច ងើយក្បាលឡើងលើដោយការងឿងឆ្ងល់ដែលជួនកាលសម្តែងនូវអាកប្បកិរិយាមិនប្រក្រតី ហើយសួរខ្ញុំវិញ

9Marks Online PDF

ថា «តើបងចង់មានន័យថាម៉េច?»។

«ខ្ញុំចង់សួរថា តើប្អូនប្រាកដចិត្តដោយរបៀបណាដែលថា កំណើតថ្មីនោះបានកើតឡើងមែន?»

បន្ទាប់មក ទឹកមុខ និងស្នារបស់ប្អូន សិលា បង្ហាញពីភាពធូរស្រាល ហើយគាត់ឆ្លើយថា «អូ ស្រួលណាស់។ គាត់បានឡើងទៅថ្វាយខ្លួននៅមុខអាសនា ដោយអធិស្ឋាន ដើម្បីទទួលព្រះគ្រីស្ទ—ដែលនោះជារបៀបដែលមនុស្សជាច្រើនបានទទួលសេចក្ដីសង្គ្រោះដែរ»។

ក្រោយពីការសន្ទនារបស់ខ្ញុំជាមួយ ប្អូន សិលា មួយឆ្នាំក្រោយមក គាត់បានទូរស័ព្ទមកខ្ញុំថា គាត់មានសេចក្ដីព្រួយបារម្ភ។ បញ្ហាដែលបានធ្វើឲ្យគាត់បាត់បង់សេចក្ដីកម្សាន្តចិត្តកំពុងតែបានកើតឡើង ជាថ្មីម្ដងទៀត គឺអំពីមិត្តរបស់គាត់ឈ្មោះ រ៉ូ។ ប្អូន សិលា បានប្រាប់ខ្ញុំអំពីរបៀបដែល រ៉ូ បានចាប់ផ្ដើមការរត់ប្រណាំងជាគ្រីស្ទបរិស័ទបានយ៉ាងល្អ៖ ការចូលរួមបម្រើជាសាធារណៈ ការអធិស្ឋានដោយការគោរពកោតខ្លាច ការចេញទៅជាមួយក្រុមផ្សាយដំណឹងល្អ ហើយជួនកាលគាត់ក៏បានបង្ហាញអំពីអារម្មណ៍ឆេះឆួល នៅពេលថ្វាយបង្គំជាសាធារណៈផងដែរ។ ប្អូន សិលា បានរៀបរាប់ថា «ឆ្នាំទីមួយល្អមែនទែន»។ «ប៉ុន្តែ បន្ទាប់មក» គាត់និយាយខ្សឹបៗថា «រ៉ូ បានទាសចេញឆ្ងាយហើយ ហាក់បីដូចជាគាត់ខ្សោយទៅៗ ដូចជាសាវ័ក ពេត្រុស...ហើយឥឡូវនេះ គាត់កំពុងតែមានបញ្ហាគ្រួសារ ហើយគិតថា នឹងចាកចេញពីសេចក្ដីជំនឿ»។

ពេលនោះ ការសន្ទនាក៏ស្ងាត់តាមទូរស័ព្ទមួយសន្ទុះ។ បន្ទាប់មកប្អូន សិលា ក៏បានសួរថា «តើបងគិតថា រ៉ូ ពិតជាបានសង្គ្រោះមែនដែរឬទេ? តើយើងអាចដឹងថា បុគ្គលណាម្នាក់បានកើតជាថ្មី ដោយរបៀបណា?»។

## *ការយល់អំពីការផ្លាស់ប្រែចិត្តដ៏ត្រឹមត្រូវ*

នៅពេលយើងកំពុងគិតអំពីបញ្ជីមួយចំនួននៃការ ដែលសមាជិកពួកជំនុំដែលមានសុខភាពល្អត្រូវតែមាន ករណីល្អមួយដែលអាចធ្វើឡើងសម្រាប់ការចាប់ផ្តើមគឺ នៅត្រង់នេះ—សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់ត្រូវតែមានការផ្លាស់ប្រែចិត្តដ៏ពិតប្រាកដដែរ។ សមាជិកពួកជំនុំ ដែលមានសុខភាពល្អ—សមាជិកពួកជំនុំ ដ៏ពិតប្រាកដមែន—ត្រូវតែស្គាល់អំពីកិច្ចការនៃព្រះគុណរបស់ព្រះជាម្ចាស់ នៅក្នុងព្រលឹងវិញ្ញាណរបស់ខ្លួន។ យើងផ្ទាល់ត្រូវតែទទួលបាននូវការផ្លាស់ប្រែចិត្ត។ ការនេះពេលស្តាប់ទៅអាចនឹងច្បាស់ពេកហើយ ប៉ុន្តែមានប្រហែលជា ៤០% នៃអស់អ្នកដែលខ្ញុំសម្ភាសន៍សម្រាប់ចូលសមាជិកភាពនៅពួកជំនុំតាមតំបន់យើង គឺពួកគាត់បានប្រាប់ខ្ញុំអំពីពេលវេលាដែលពួកគាត់ជាសមាជិកពួកជំនុំ ប៉ុន្តែពួកគាត់មិនបានយល់អំពីដំណឹងល្អ ហើយតាមការសន្មតរបស់ខ្លួនក៏មិនមែនជាអ្នកដែលពិតជាបានផ្លាស់ប្រែចិត្តមែនដែរ។ បទពិសោធន៍នេះកើតនៅគ្រប់ទីកន្លែង សូម្បីតែគ្រីស្ទបរិស័ទល្បីៗដូចជាលោក ចន វេស្លី (John Wesley) ក៏បានប្រាប់ពីរឿងរ៉ាវយ៉ាងដូច្នេះដែរ។

## *ការយល់អំពីការផ្លាស់ប្រែចិត្តតាមព្រះគម្ពីរ*

ប្រាកដណាស់ ហេតុផលមួយនៃហេតុផលជាច្រើនមានគ្រីស្ទបរិស័ទតែឈ្មោះជាច្រើន នៅក្នុងប្រវត្តិសាស្រ្តពួកជំនុំគ្រីស្ទបរិស័ទគឺដោយសារពួកជំនុំបានបរាជ័យក្នុងការឱបក្រសោប និងបង្រៀនអំពីការយល់ដឹងនៃការផ្លាស់ប្រែចិត្តតាមព្រះគម្ពីរ។ ប្រសិនបើយើងចង់យល់ពីការផ្លាស់ប្រែចិត្តឲ្យបានត្រឹមត្រូវ គឺយើងត្រូវតែចាប់ផ្តើមជាមួយនឹងការធ្វើការវិនិច្ឆ័យរបស់ព្រះគម្ពីរលើមនុស្ស ដែលបានធ្លាក់ក្នុងអំពីបាបជាមុនសិន។ យើងត្រូវតែ

ស្គាល់ជំងឺជាមុនសិន ដើម្បីឲ្យយើងអាចផ្តល់នូវការព្យាបាលត្រឹមត្រូវបាន។

មនុស្សទាំងអស់សុទ្ធតែឈឺចាប់ដោយសារអំពើបាប ដែលជាជំងឺ។ មនុស្សយើងមិនត្រឹមតែធ្វើបាបប៉ុណ្ណោះទេ តែថែមទាំងមាននិស្ស័យបាបតាំងពីកំណើតមកម្ល៉េះ (អេភេសូរ ២:១-៣)។ នៅក្នុងឫសគល់ ក្នុងចំណុចស្នូល និងចិត្តគំនិត គឺមនុស្សបានដាច់ចេញពីព្រះជាម្ចាស់ ហើយបានត្រឡប់ជាខ្មាំងសត្រូវជាមួយនឹងព្រះអង្គវិញ។ មនុស្សយើងចូលចិត្តបំពេញសេចក្តីស្រេកឃ្លានខាងឯអំពើបាប និងសេចក្តីប៉ងប្រាថ្នារបស់ខ្លួន ជាជាងការគោរពប្រតិបត្តិ និងថ្វាយបង្គំព្រះជាម្ចាស់—យ៉ាងនោះហើយបានជាមនុស្សក្លាយជាទាសករនៃអំពើបាប។

> ពីព្រោះអស់អ្នកណាដែលតាមសាច់ឈាម នោះគិតតែខាងសាច់ឈាម តែអស់អ្នកណាដែលគិតតាមព្រះវិញ្ញាណ នោះគិតតែខាងវិញ្ញាណវិញ ដ្បិតគំនិតខាងសាច់ឈាម នោះជាសេចក្តីស្លាប់ទទេ។ ឯគំនិតនៃព្រះវិញ្ញាណ នោះទើបជាជីវិត និងសេចក្តីសុខសាន្តវិញ ព្រោះគំនិតខាងសាច់ឈាម នោះរមែងទាស់ទទឹងនឹងព្រះ ដ្បិតមិនចុះចូលនឹងក្រឹត្យវិន័យរបស់ព្រះទេ ក៏ពុំអាចនឹងចុះចូលបានផង។ ពួកអ្នកដែលនៅខាងសាច់ឈាម នោះពុំអាចនឹងគាប់ព្រះហឫទ័យដល់ព្រះបានឡើយ (រ៉ូម ៨:៥-៨)។

ដោយព្រោះតែមនុស្សមាននិស្ស័យបាបតាំងពីកំណើតមក នោះហើយបានជាមនុស្សមានទោសនៅចំពោះព្រះជាម្ចាស់ ហើយសមនឹងទទួលទណ្ឌកម្មដែលព្រះជាម្ចាស់បានសន្យាថានឹងដាក់។ ប្រសិនបើមិនមានការផ្លាស់ប្រែចិត្តទាំងស្រុង នៅក្នុងស្ថានភាពខាងឯព្រលឹងវិញ្ញាណរបស់គាត់ទេ នោះមនុស្សនឹងត្រូវវិនាសក្នុងការជំនុំជម្រះជាមិនខាន។ ដោយ

9Marks Online PDF

មានគំនិតតែខាងការអាក្រក់ មនុស្សមិនអាច ហើយក៏មិនមានសូម្បីតែសេចក្ដីប្រាថ្នាចង់ផ្គាប់ព្រះហឫទ័យព្រះផង។ មនុស្សត្រូវតែផ្លាស់ប្រែជាដាច់ខាត។ មនុស្សត្រូវការមានចិត្តថ្មីមួយទៀត។

ការផ្លាស់ប្ដូរទាំងស្រុងនេះគឺជាអ្វីដែលទេវវិទ្យាគ្រីស្ទបរិស័ទហៅថា "ការផ្លាស់ប្រែចិត្ត"។ ការផ្លាស់ប្រែចិត្តទាំងស្រុងគឺជាការចេញពីជីវិតនៃភាពជាទាសករនៃការដេញតាមអំពើបាប មកឯជីវិតដែលមានសេរីភាពនៃការដេញតាម និងការថ្វាយបង្គំព្រះជាម្ចាស់វិញ។ ការផ្លាស់ប្រែចិត្តគឺជាការផ្លាស់ប្ដូរជីវិត មិនត្រឹមតែជាការសម្រេចចិត្តនោះទេ។ ការផ្លាស់ប្ដូរនេះមិនមែនអំពីសុជីវធម៌ ការចេះជួយខ្លួនឯង ឬក៏គ្រាន់តែជាការកែប្រែអាកប្បកិរិយានោះទេ។ ការផ្លាស់ប្ដូរនេះមិនកើតឡើងដោយសារការសម្ដែងនៅពីក្រៅ ឬការគោរពតាមសាសនាតែខាងក្រៅដូចជាការ "ឡើងទៅថ្វាយខ្លួននៅមុខអាសនា" នោះទេ។ ហើយវាក៏មិនអាចកើតមកដោយសារការខិតខំប្រឹងប្រែងរបស់មនុស្សនោះដែរ តែដោយសារអំណាចព្រះចេស្ដានៃព្រះជាម្ចាស់តែប៉ុណ្ណោះ។

ការផ្លាស់ប្រែចិត្តគឺជាការផ្លាស់ប្ដូរមួយដ៏ខ្លាំង នេះបានជាការនេះតម្រូវឲ្យមានការអន្តរាគមន៍ពីព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធ។ នៅក្នុងការផ្លាស់ប្រែចិត្តនោះ ព្រះវិញ្ញាណនៃព្រះប្រទានព្រះគុណជាទ្វេដង គឺការប្រែចិត្ត និងការមានជំនឿដល់មនុស្សមានបាបដែលបែរចេញពីអំពើបាប ហើយបែរទៅរកព្រះអង្គតាមរយៈសេចក្ដីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទវិញ។[៣] អត្ថបទទី៨នៃគោលលទ្ធិ នូហាមសើរ (The New Hampshire Confession of

---

៣ ឧទាហរណ៍៖ យ៉ូហាន ១:១២-១៣; ៣:៣-៨; ៦:៤៤; ១៥:១៦; កិច្ចការ ១១:១៨; អេភេសូរ ១:១៣-១៤; ២:១-៩; ១ពេត្រុស ១:២៣; និង១យ៉ូហាន ៤:១០។

Faith's eighth) បានពិពណ៌នាអំពីការផ្លាស់ប្រែចិត្តតាមបទគម្ពីរបានយ៉ាងល្អ៖

> យើងជឿថា ការប្រែចិត្ត និងការមានជំនឿជាកាតព្វកិច្ចបរិសុទ្ធ ហើយក៏ជាព្រះគុណដែលមិនអាចបំបែកគ្នាបាន ដែលបានចូលមកក្នុងព្រលឹងរបស់យើងដោយព្រះវិញ្ញាណនៃព្រះ ដែលធ្វើឲ្យមានការកើតជាថ្មី។ ដោយព្រះគុណ នោះយើងស្គាល់យ៉ាងច្បាស់អំពីទោសរបស់យើង អំពីគ្រោះថ្នាក់ និងអំពីភាពតែលតោលឥតទីពឹងរបស់យើង ព្រមទាំងស្គាល់អំពីផ្លូវនៃសេចក្តីសង្គ្រោះដោយសារព្រះគ្រីស្ទ នោះយើងក៏បែរទៅរកព្រះជាម្ចាស់ដោយស្មោះត្រង់ ឥតពុតត្បុត ដោយការសារភាពទោសកំហុស ហើយដោយការអង្វរសូមសេចក្តីមេត្តាករុណាពីទ្រង់។ នៅពេលដំណាលគ្នានោះ យើងក៏ទទួលព្រះអម្ចាស់យេស៊ូវគ្រីស្ទដោយអស់ពីចិត្តថា ទ្រង់ជាហោរា ជាសង្ឃ និងជាស្តេចរបស់យើង ហើយពឹងអាងដល់ទ្រង់ជាព្រះអង្គសង្គ្រោះតែមួយគត់ និងគ្រប់គ្រាន់សម្រាប់ការទាំងអស់។

ដូច្នេះ ការផ្លាស់ប្រែចិត្តតម្រូវឲ្យមានការដឹងដ៏ពិតប្រាកដអំពីអំពើបាបដែលនាំទៅរកការបែរចេញ (ការប្រែចិត្ត) ហើយពឹងអាងដល់ព្រះអម្ចាស់យេស៊ូវគ្រីស្ទតែមួយគត់ប៉ុណ្ណោះ ដើម្បីឲ្យបានសេចក្តីសង្គ្រោះ (ការមានជំនឿ)។

## *ការស្គាល់វិញ្ញាណរបស់យើងផ្ទាល់*

បើអញ្ចឹង តើការយល់ដឹងអំពីការផ្លាស់ប្រែចិត្តតាមព្រះគម្ពីរនឹងមានឥទ្ធិពលលើអ្វីដែលយើងកំពុងធ្វើជាក់ស្តែងនៅក្នុងពួកជំនុំរបស់យើងយ៉ាងដូចម្តេច? វាពិតជាសំខាន់ណាស់ក្នុងការដែលយើងគិតអំពីការអនុវត្តខាង

9Marks Online PDF

ក្នុង និងការអនុវត្តខាងក្រៅផងដែរ។

ដូច្នេះ ចូរចាប់ផ្តើមដោយការមើលពីខាងក្នុងសិន។ យើងត្រូវតែសួរខ្លួនឯងថា តើយើងទទួលបានចិត្តដែលផ្លាស់ប្រែដោយព្រះគុណរបស់ព្រះ តាមរយៈសេចក្តីជំនឿនៅក្នុងព្រះយេស៊ូវគ្រីស្ទហើយឬនៅ។ ការពិនិត្យមើលខ្លួនឯងរបៀបនេះគឺជាការដែលត្រូវធ្វើឲ្យមានសុខភាពល្អខាងឯព្រលឹងវិញ្ញាណ។ តាមពិតទៅ នេះគឺជាអ្វីដែលពួកសាវ័កឧស្សាហ៍លើកទឹកចិត្តដល់អ្នកអានឲ្យធ្វើ (២កូរិនថូស ១៣:៥; ភីលីព ២:១២; ២ពេត្រុស ១:៥-១១)។ លំដាប់លំដោយដំបូងនោះគឺយើងត្រូវស្គាល់អំពីព្រលឹងខ្លួនឯងជាមុនសិន។ តើយើងកំពុងទុកចិត្តនៅក្នុងកិច្ចការដែលព្រះគ្រីស្ទបានធ្វើសម្រេចតែមួយសម្រាប់សេចក្តីសង្គ្រោះរបស់យើងដែរឬទេ? តើមានភស្តុតាងនៃព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងជីវិតរបស់យើងដែរឬទេ? តើយើងកំពុងតែរីកចម្រើនឡើងនៅក្នុងព្រះគុណ និងចំណេះដឹងអំពីព្រះយេស៊ូវគ្រីស្ទ នៅក្នុងផលផ្លែនៃព្រះវិញ្ញាណ (កាឡាទី ៥:២២-២៤) ហើយនិងនៅក្នុងចរិតលក្ខណៈដែលបានចែងនៅក្នុងការបង្រៀនរបស់ព្រះគ្រីស្ទដែរឬទេ? (ម៉ាថាយ ៥:៣-១២)។

កណ្ឌគម្ពីរយ៉ូហានខ្សែទី១ គឺជាកណ្ឌដែលមានប្រយោជន៍ណាស់ក្នុងការសិក្សាទាក់ទងទៅនឹងការពិនិត្យមើលកិច្ចការរបស់ព្រះជាម្ចាស់នៅក្នុងព្រលឹងវិញ្ញាណរបស់យើង។ សាវ័ក យ៉ូហាន បានផ្តល់នូវការពិនិត្យមើលជាច្រើន ដើម្បីជួយគ្រីស្ទបរិស័ទឲ្យបានដឹងថា តើពួកគាត់ទទួលបានសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ ដោយសេចក្តីសង្គ្រោះហើយឬនៅ? ក្នុងការខំប្រឹងប្រែងស្គាល់អំពីសណ្ឋានភាពនៃព្រលឹងវិញ្ញាណរបស់យើងនៅចំពោះព្រះជាម្ចាស់ គឺយើងអាចពិនិត្យខ្លួនឯងដោយមើលភស្តុតាងដូចខាងក្រោមនេះ។

9Marks Online PDF

## តើយើងដើរនៅក្នុងពន្លឺ ឬក៏នៅក្នុងសេចក្ដីងងឹត?

“បើសិនជាយើងរាល់គ្នាថា យើងមានសេចក្ដីប្រកបនឹងទ្រង់ តែដើរក្នុងសេចក្ដីងងឹតវិញ នោះឈ្មោះថាយើងកុហក ហើយមិនប្រព្រឹត្តតាមសេចក្ដីពិតទេ។ តែបើយើងរាល់គ្នា ដើរក្នុងពន្លឺវិញ ដូចជាទ្រង់ក៏គង់ក្នុងពន្លឺដែរ នោះយើងមានសេចក្ដីប្រកបនឹងគ្នាទៅវិញទៅមក ហើយព្រះលោហិតនៃព្រះយេស៊ូវគ្រីស្ទ ជាព្រះរាជបុត្រានៃទ្រង់ ក៏សម្អាតយើងរាល់គ្នាពីគ្រប់អំពើបាបទាំងអស់” (១យ៉ូហាន ១:៦-៧)។ អស់អ្នកដែលបានផ្លាស់ប្រែចិត្ត ទៅឯព្រះគ្រីស្ទនឹងពិតប្រាកដជាមានការព្រួយចិត្តអំពីអំពើបាបរបស់ខ្លួន។ ពួកគាត់ស្អប់អំពើបាបរបស់ខ្លួន ពួកគាត់ចង់បានពន្លឺនៃជីវិតនៅក្នុងព្រះគ្រីស្ទ ពោលគឺពួកគាត់ចង់បាន និងចង់ដើរដោយស្មោះត្រង់ និងសុចរិតផងដែរ។ អស់អ្នកដែលបន្តរស់នៅតាមទម្លាប់ដដែលៗ ហើយមិនប្រែចិត្ត ហើយបដិសេធថា ខ្លួនឯងមិនមែនជាមនុស្សមានបាបទេ (ខ ៨-១០) គឺអ្នកនោះមិនមែនជាអ្នកដែលបានផ្លាស់ប្រែចិត្តដ៏ពិតប្រាកដទេ។ “ឯអស់អ្នកណាដែលនៅជាប់ក្នុងទ្រង់ នោះមិនដែលធ្វើបាបទេ តែពួកអ្នកដែលធ្វើបាបវិញ គេមិនបានឃើញទ្រង់ឡើយ ក៏មិនស្គាល់ទ្រង់ផង” (១យ៉ូហាន ៣:៥)។

## តើយើងស្រឡាញ់ព្រះវរបិតាដែរឬទេ?

មនុស្សមួយចំនួនហាក់ដូចជាស្រឡាញ់ “ភាពស្លូតត្រង់” របស់ព្រះយេស៊ូវ ប៉ុន្តែមិនបង្ហាញសេចក្ដីស្រឡាញ់ដល់ព្រះវរបិតាទេ ដោយសារពួកគាត់ស្មានថា នៅសម័យសញ្ញាចាស់ ទ្រង់ជាព្រះដែលមិនមានសេចក្ដី

ស្រឡាញ់ទេ។ ការគិតថា ព្រះយេស៊ូវជាព្រះនៃសេចក្ដីស្រឡាញ់ និងពេញដោយការអត់ធ្មត់បាននាំឲ្យមនុស្សមួយចំនួនជឿថា ព្រះនឹងមិនកាត់ទោសអំពើបាប ឬក៏ផ្ដន្ទាទោសដល់អស់អ្នកដែលមានបាបនោះទេ។ ពួកគេគិតថា ព្រះវរបិតាជាព្រះផ្ដាច់ការនៃសម័យសញ្ញាចាស់ ហើយពួកគេក៏បានបដិសេធការបង្រៀនរបស់ព្រះគម្ពីរអំពីព្រះជាម្ចាស់ ពីព្រោះពួកគេគិតថាការបង្រៀននោះហួសសម័យ ដែលមិនពេញចិត្តខ្លួនឯង និងគួរឲ្យស្អប់ខ្ពើមផងដែរ។ ប៉ុន្តែ សាវ័ក យ៉ូហាន បានរាប់ការស្រឡាញ់ដល់ព្រះវរបិតាថាជាភស្តុតាងមួយ ដើម្បីឲ្យដឹងអំពីសេចក្ដីជំនឿពិតប្រាកដ។ «កុំឲ្យស្រឡាញ់លោកីយ៍ ឬរបស់អ្វីដែលនៅក្នុងលោកីយ៍នេះឲ្យសោះ បើអ្នកណាស្រឡាញ់លោកីយ៍ អ្នកនោះគ្មានសេចក្ដីស្រឡាញ់របស់ព្រះវរបិតានៅក្នុងខ្លួនឡើយ» (១យ៉ូហាន ២:១៥)។ «តើអ្នកណាជាអ្នកកុហក បើមិនមែនជាអ្នកដែលប្រកែកថា ព្រះយេស៊ូវមិនមែនជាព្រះគ្រីស្ទនោះទេ អ្នកណាដែលមិនព្រមទទួលស្គាល់ទាំងព្រះវរបិតា និងព្រះរាជបុត្រាផង អ្នកនោះហើយជាអ្នកដែលទទឹងនឹងព្រះគ្រីស្ទ។ ឯអស់អ្នកដែលមិនព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏គ្មានព្រះវរបិតាដែរ តែអ្នកណាដែលព្រមទទួលស្គាល់ព្រះរាជបុត្រា នោះក៏មានទាំងព្រះវរបិតាផង» (១យ៉ូហាន ២:២២-២៣)។ មានព្រះតែមួយប៉ុណ្ណោះ—ព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ហើយគ្មានផ្លូវដែលយើងអាចស្រឡាញ់លោកីយ៍ផង និងព្រះវរបិតាផងបានដែរ។ ហើយក៏គ្មានផ្លូវដែលយើងអាចឱបព្រះគ្រីស្ទ ដោយមិនឱបយកព្រះវរបិតាបានដែរ ឬក៏ការចូលទៅឯព្រះវរបិតាដោយមិនបានជឿដល់ព្រះគ្រីស្ទដែរ។ ការស្រឡាញ់ដល់ព្រះវរបិតាគឺជាភស្តុតាងមួយ ដើម្បីឲ្យដឹងអំពីការផ្លាស់ប្រែចិត្តដ៏ពិតប្រាកដរបស់យើង។

## តើយើងស្រឡាញ់ដល់គ្រីស្ទបរិស័ទដទៃទៀតដែរឬទេ?

មនុស្សជាច្រើន ហាក់ដូចជារស់នៅដោយគ្មានសេចក្តីស្រឡាញ់ ឬការឈឺឆ្អាលដ៏ពិតប្រាកដ ចំពោះគ្រីស្ទបរិស័ទដទៃទៀតសោះ។ ពួកគាត់គិតថា ជីវិតជាគ្រីស្ទបរិស័ទគឺជា «ការលេងកីឡាតែម្នាក់»។ ប៉ុន្តែ «អស់អ្នកណាដែលជឿថា ព្រះយេស៊ូវជាព្រះគ្រីស្ទ អ្នកនោះបានកើតពីព្រះមក ហើយអស់ទាំងអ្នកណាដែលស្រឡាញ់ព្រះដ៏បង្កើតខ្លួនមក នោះក៏រមែងស្រឡាញ់ដល់អស់អ្នកឯទៀត ដែលកើតពីទ្រង់មកដែរ» (១យ៉ូហាន ៥:១)។ «ឯអ្នកណាដែលមិនស្រឡាញ់បងប្អូន អ្នកនោះជាអ្នកនៅជាប់ក្នុងសេចក្តីស្លាប់នៅឡើយ។ អ្នកណាដែលមានចិត្ត ស្អប់ដល់បងប្អូននោះឈ្មោះថា ជាអ្នកសម្លាប់គេ ហើយអ្នករាល់គ្នាដឹងហើយថា គ្មានអ្នកណាសម្លាប់គេណាមួយ ដែលមានជីវិតដ៏រស់អស់កល្បជានិច្ចនៅក្នុងខ្លួនឡើយ» (១យ៉ូហាន ៣:១៤ខ-១៥)។ «ពួកកូនតូចៗអើយ យើងមិនត្រូវស្រឡាញ់ ដោយពាក្យសម្តី ឬដោយបបូរមាត់ប៉ុណ្ណោះឡើយ គឺដោយការប្រព្រឹត្ត និងសេចក្តីពិតវិញ គឺយ៉ាងនោះឯងដែលយើងនឹងដឹងថា យើងកើតមកពីសេចក្តីពិត ហើយយើងនឹងបានកំឡាចិត្ត នៅចំពោះទ្រង់ផង» (១យ៉ូហាន ៣:១៨-១៩)។ សាវ័ក យ៉ូហាន បានបង្រៀនថា បញ្ញត្តិនោះគឺត្រូវឲ្យយើងជឿនៅក្នុងព្រះនាមនៃព្រះយេស៊ូវគ្រីស្ទ ហើយត្រូវស្រឡាញ់គ្នាទៅវិញទៅមក។ ប្រសិនបើសេចក្តីស្រឡាញ់របស់អ្នកចំពោះគ្រីស្ទបរិស័ទដទៃទៀត មានសភាពត្រជាក់ គឺយើងត្រូវតែពិនិត្យមើលថា តើយើងបានជឿដល់ព្រះគ្រីស្ទយេស៊ូវជាព្រះរាជបុត្រានៃព្រះ ដើម្បីឲ្យបានសង្គ្រោះហើយឬទេ។

## តើយើងមានទីបន្ទាល់ពីព្រះវិញ្ញាណដែលថា យើងជាកូន

## របស់ព្រះជាម្ចាស់ដែរឬទេ?

«អ្នកណាដែលកាន់តាមបញ្ញត្តទ្រង់ នោះឈ្មោះថានៅជាប់ក្នុងទ្រង់ ហើយទ្រង់ក៏គង់នៅក្នុងអ្នកនោះដែរ យើងដឹងថា ទ្រង់គង់នៅក្នុងយើង ដោយសារព្រះវិញ្ញាណដែលទ្រង់ប្រទានមក» (១យ៉ូហាន ៣:២៤)។ ព្រះវរបិតាមិនបានទុកយើងចោលដោយគ្មានទីបន្ទាល់នៃសេចក្តីស្រឡាញ់របស់ទ្រង់ទេ។ យើងអាចនឹងប្រាកដអំពីការ ដែលទ្រង់បានទទួលយើងយកមកចិញ្ចឹមនៅក្នុងគ្រួសាររបស់ទ្រង់ ដោយព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធផ្ទាល់ ដោយទ្រង់បានបញ្ជាក់ឲ្យយើងដឹងច្បាស់ថា «ដោយព្រោះអ្នករាល់គ្នាជាកូន បានជាព្រះទ្រង់ចាត់ព្រះវិញ្ញាណនៃព្រះរាជបុត្រាទ្រង់ ឲ្យមកក្នុងចិត្តអ្នករាល់គ្នា ឲ្យបន្លឺឡើងថា អ័ប្បា ព្រះវរបិតាអើយ» (កាឡាទី ៤:៦ ហើយសូមអានកណ្ឌគម្ពីរ រ៉ូម ៨:១៥ ផងដែរ)។ «ហើយព្រះវិញ្ញាណទ្រង់ក៏ធ្វើបន្ទាល់នឹងវិញ្ញាណយើងថា យើងជាកូនរបស់ព្រះ» (រ៉ូម ៨:១៦)។ យើងដឹងថា យើងរស់នៅក្នុងព្រះ ហើយព្រះគង់នៅក្នុងយើង ពីព្រោះយើងបានទទួលព្រះវិញ្ញាណបរិសុទ្ធនៅពេលយើងជឿលើដំណឹងល្អ (១យ៉ូហាន ៤:១៣-១៤)។

## តើយើងកំពុងខ្ជាប់ខ្ជួននៅក្នុងសេចក្តីជំនឿដែរឬទេ?

«ពីព្រោះគ្រប់ទាំងអស់ដែលកើតពីព្រះមក នោះបានឈ្នះលោកីយ៍ ហើយ ឯជ័យជម្នះដែលឈ្នះលោកីយ៍ នោះគឺជាសេចក្តីជំនឿរបស់យើង។ តើអ្នកណាជាអ្នកឈ្នះលោកីយ៍ បើមិនមែនជាអ្នកដែលជឿថា ព្រះយេស៊ូវជាព្រះរាជបុត្រានៃព្រះ» (១យ៉ូហាន ៥:៤-៥)។ អស់អ្នកណាដែលជឿ ហើយនៅតែបន្តក្នុងសេចក្តីជំនឿ គឺជាពួកអ្នកដែលឈ្នះលើលោកីយ៍ ដោយសេចក្តីជំនឿនៅក្នុងព្រះគ្រីស្ទ។ សេចក្តីជំនឿពិតប្រាកដ គឺជាសេចក្តី

9Marks Online PDF

ជំនឿដែលមានសេចក្ដីខ្ជាប់ខ្ជួន។ នេះមិនមែនមានន័យថា ជួនកាលការលំបាកនៅក្នុងជីវិតយើងមិនធ្វើឲ្យយើងមានការសង្ស័យ ឬក៏ការមានទុក្ខព្រួយនោះទេ។ ប៉ុន្តែ វាមានន័យថា គ្រីស្ទបរិស័ទពិតប្រាកដនឹងមមុលទៅមុខក្នុងសេចក្ដីជំនឿ ដោយទុកចិត្តដល់ព្រះជាម្ចាស់ និងផែនការទ្រង់ ព្រមទាំងបំណងព្រះហឫទ័យរបស់ទ្រង់ផងដែរ។ ពិតមែនហើយ ព្រះវិញ្ញាណដដែល ដែលអ្នកជឿពិតប្រាកដបានទទួលនោះក៏បានដៅចំណាំ ហើយរក្សាអ្នកជឿទាំងនោះរហូតដល់ថ្ងៃនោះផងដែរ (អេភេសូរ ១:១៣-១៤; ១ពេត្រុស ១:៣-៥)។

ការសួរសំណួរទាំងអស់នេះគឺជាការសួរយ៉ាងល្អបំផុតបើកើតឡើងនៅក្នុងការប្រកបគ្នានៃពួកជំនុំតាមតំបន់ ក្នុងចំណោមគ្រីស្ទបរិស័ទដែលប្ដេជ្ញាចិត្ត និងកំពុងតែរីកចម្រើនឡើង ដែលអាចជួយយើងឲ្យឃើញអំពីខ្លួនឯងបានយ៉ាងត្រឹមត្រូវ។ មានមនុស្សមួយចំនួនងាយធ្លាក់ក្នុង «ការជឿស្រួលនិយម» ដែលប្រឆាំងនឹងការថែរក្សាដ៏ប្រុងប្រយ័ត្នដល់ព្រលឹងរបស់ខ្លួនផ្ទាល់ រីឯអ្នកខ្លះទៀតក៏ងាយបណ្ដោយខ្លួនឲ្យទទួលសេចក្ដីល្បួងដោយងាយស្រួលពេកដល់ការសង្ស័យ និងការអស់សង្ឃឹម។ នៅក្នុងវប្បធម៌ពួកជំនុំ យើងអាចស្រឡាញ់គ្នាទៅវិញទៅមកបាន ដោយការចង្អុលបង្ហាញភស្តុតាងនៃព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងជីវិតគ្នាទៅវិញទៅមក និងដោយការសួរសំណួរពិបាកៗអំពីការប្រកាសសេចក្ដីជំនឿ និងដំណើររបស់យើងជាមួយព្រះ។ តាមរយៈការធ្វើការទាំងពីរនេះ នោះយើងអាចជួយគ្នាទៅវិញទៅមកក្នុងការជៀសវាងពីការអស់សង្ឃឹមខ្លាំង និងការមិនខ្វល់អំពីដំណើរខ្លួនឯង។ ហើយតាមរយៈការធ្វើការបែបនោះ យើងក៏លើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យឃើញពីខ្លួនឯងថា ព្រលឹងខ្លួនកំពុងនៅក្នុងពន្លឺនៃ

9Marks Online PDF

កិច្ចការសង្គ្រោះរបស់ព្រះជាម្ចាស់ដែរ។

## *ការអនុវត្តសម្រាប់ដំណឹងល្អ*

ក្រៅពីមើលតែទៅខាងក្នុង (និងការជួយអ្នកដទៃឲ្យធ្វើដូចគ្នាដែរ) យើងក៏ចង់ឲ្យមើលទៅឯខាងក្រៅ ដោយមានការយល់ដឹងរបស់យើងអំពីការផ្លាស់ប្រែចិត្ត និងអំពីរបៀបដែលការនោះមានឥទ្ធិពលដល់វិធីសាស្ត្ររបស់ពួកជំនុំយើង ក្នុងការប្រកាសដំណឹងល្អដែរ។ ទាក់ទងទៅនឹងការប្រកាសដំណឹងល្អ សមាជិកពួកជំនុំដែលមានសុខភាពល្អត្រូវតែយល់ឲ្យបានត្រឹមត្រូវថា តើនរណាជាអង្គដ៏ពិតដែលបំផ្លាស់បំប្រែចិត្តមនុស្សមានបាបនោះ—គឺព្រះវិញ្ញាណបរិសុទ្ធ។ ហើយសមាជិកពួកជំនុំដែលមានសុខភាពល្អក៏ត្រូវតែទទួលស្គាល់ថា ការប្រកាសដំណឹងល្អមិនមែនជាវិធីវៃឆ្លាតនោះទេ ប៉ុន្តែគឺជាការពឹងដល់ព្រះវិញ្ញាណនព្រះក្នុងការប្រទានពរដល់ព្រះបន្ទូលរបស់ទ្រង់ ដើម្បីធ្វើឲ្យមានលទ្ធផលជាកំណើតថ្មីខាងឯវិញ្ញាណ និងការផ្លាស់ប្តូរទាំងស្រុងវិញ។ យើងនឹងពិចារណាអំពីការប្រកាសដំណឹងល្អតាមព្រះគម្ពីរបន្តទៀតនៅជំពូកបន្ទាប់នេះ។

## *សេចក្តីសន្និដ្ឋាន*

ខ្ញុំបានបាត់ទំនាក់ទំនងជាមួយនឹងលោក រ៉ូ ជាច្រើនឆ្នាំមកហើយ។ ខ្ញុំមិនដឹងថា តើគាត់នៅតែរស់នៅក្នុងជីវិតជាគ្រីស្ទបរិស័ទ ឬក៏ថាគាត់បានបែរចេញពីសេចក្តីពិត ហើយត្រឡប់ទៅរកលោកីយ៍វិញហើយ ឬយ៉ាងណាដែរ។ ខ្ញុំដឹងថា វាសំខាន់ណាស់ដែលគាត់ត្រូវពិនិត្យមើលខ្លួនឯង ដើម្បីឲ្យដឹងថា តើគាត់នៅក្នុងសេចក្តីជំនឿ ឬយ៉ាងណា។ ហើយខ្ញុំដឹងថា ការពិនិត្យមើលនោះនឹងបានផ្លែផ្កា លុះត្រាតែគាត់ស្វែងរកភស្តុតាងនៃការផ្លាស់ប្រែចិត្តពិត ដែលព្រះជាម្ចាស់បានពន្យល់យ៉ាងច្បាស់នៅក្នុងព្រះ

9Marks Online PDF

បន្ទូលរបស់ទ្រង់។

## *សម្រាប់ការពិចារណាបន្ថែម*

ចូរប្រើសំណួរដូចខាងក្រោម ដើម្បីពិចារណា ហើយសម្គាល់រកភស្តុតាងនៃព្រះគុណរបស់ព្រះ ក្នុងចំណោមអ្នករាល់គ្នាជាមួយនឹងសមាជិកពួកជំនុំគ្រីស្ទបរិស័ទ និងមិត្តភក្តិដែលពេញវ័យខាងឯវិញ្ញាណ ហើយប្រសិនបើចាំបាច់ ចូរលើកឡើងអំពីកន្លែងណាខ្លះនៅក្នុងជីវិតយើងដែលនៅត្រូវការព្រះគុណ។

១. តើយើងអ្នកដើរនៅក្នុងពន្លឺ ឬនៅក្នុងសេចក្ដីងងឹត (១យ៉ូហាន ១:៦-៧)?

២. តើយើងស្រឡាញ់ព្រះវរបិតា ឬក៏ស្រឡាញ់លោកីយ៍នេះ (១យ៉ូហាន ២:១៥)។

៣. តើយើងស្រឡាញ់ដល់គ្រីស្ទបរិស័ទដទៃទៀតដែរឬទេ (១យ៉ូហាន ៣:១៤-១៥, ១៨-១៩; ៥:១)?

៤. តើយើងមានទីបន្ទាល់នៃព្រះវិញ្ញាណបរិសុទ្ធដែលថា យើងជាកូនរបស់ព្រះជាម្ចាស់ដែរឬទេ (រ៉ូម ៨:១៥-១៦; កាឡាទី ៤:៦; ១យ៉ូហាន ៣:២៤)?

៥. តើយើងកំពុងតែនៅខ្ជាប់ខ្ជួនក្នុងសេចក្ដីជំនឿដែរឬទេ (១យ៉ូហាន ៥:៤-៥)?

## *សម្រាប់ការអានបន្ថែម*

ធនធានក្នុងគេហទំព័រផ្លូវពិត៖

9Marks Online PDF

“ប្រែចិត្តដោយមិនផ្លាស់ប្ដូរ?”
(https://plovpit.com/you-repent-without-changing/)

“ការលន់តួអំពើបាប”
(https://plovpit.com/why-continue-repent/)

“របៀប៥យ៉ាងដើម្បីឲ្យដឹងថា តើការប្រែចិត្តនោះជាការពិតឬក៏មិនពិត?”
(https://plovpit.com/true-repentance/)

## ***ធនធានពីប្រភពប្រាជ្ញា៖***

“ការបញ្ចប់យ៉ាងល្អ៖ ការបញ្ចប់រឿងដ៏សំខាន់រាប់ជំពូកក្នុងជីវិត”
និពន្ធដោយ៖ លោក ដាវីឌ ដាប់បិលយូ. អេហ្វ. រ៉ុង។

“ជីវិតថ្មីក្នុងព្រះគ្រីស្ទ៖ សេចក្តីពិតដ៏សំខាន់ក្នុងជំនឿគ្រីស្ទបរិស័ទ”
និពន្ធដោយ៖ លោក ជច អ៊ីហ្គើ។

9Marks Online PDF

សញ្ញាសម្គាល់ទី៥

# សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកដែលប្រកាសដំណឹងល្អតាមព្រះគម្ពីរ

**នៅក្នុងជំពូកមុននេះ** យើងបានពិភាក្សារួចហើយអំពីគោលលទ្ធិដ៏សំខាន់នៃការផ្លាស់ប្រែចិត្ត។ យើងបានចាប់ផ្តើមជំពូកនោះដោយរៀបរាប់អំពីរឿងរ៉ាវរបស់លោក រ៉ូ ជាមិត្តភក្តិម្នាក់ដែល «បានប្រកាសអំពីសេចក្តីជំនឿ» ប៉ុន្តែក្រោយមកបានបែរចេញពីព្រះគ្រីស្ទ។

អ្វីដែលជាការបង្ហាញដ៏ច្បាស់លាស់ និងគួរឲ្យឈឺចាប់ចំពោះមិត្តសម្លាញ់របស់ខ្ញុំ សិលា និងខ្ញុំនៅបច្ចុប្បន្ននេះគឺថា «ការបង្ហាញអំពីដំណឹងល្អ» ដែលលោក រ៉ូ បានឮកាលពីប៉ុន្មានឆ្នាំមុនទៅនោះគឺជាព្រះរាជសារដែលរាក់ជាងគេបំផុត។ អ្វីដែលគាត់បានឮនោះមិនមែនជាការប្រកាសអំពីសេចក្តីជំនឿ ដោយស្មោះត្រង់តាមព្រះគម្ពីរទេ។ នោះមិនមែនជាការប្រកាសអំពី (១) សេចក្តីបរិសុទ្ធ និងសេចក្តីសុចរិតនៃព្រះដែលមានពេញទៅដោយអធិបតេយ្យភាព ដែលបានបង្កើតរបស់សព្វសារពើទាំងអស់ (២) អំពីភាពពោរពេញដោយអំពើបាបរបស់មនុស្ស និងការជំនុំជម្រះលើ

9Marks Online PDF

ពួកគេ ដោយសារការបះបោរប្រឆាំងនឹងព្រះអង្គ (៣) អំពីសេចក្តីត្រូវការជាចាំបាច់របស់មនុស្ស ដើម្បីឲ្យមានការផ្លាស់ប្តូរទាំងស្រុង ប្រយោជន៍ឲ្យមានចិត្តថ្មីមួយ និងសេចក្តីសុចរិតដ៏គ្រប់លក្ខណ៍ (៤) អំពីការពិតដែលថាមានតែព្រះយេស៊ូវគ្រីស្ទតែមួយប៉ុណ្ណោះ ដែលបានប្រទានសេចក្តីសុចរិតដែលយើងត្រូវការ ហើយទ្រង់ក៏បានធ្វើឲ្យមានសេចក្តីធួននឹងបាបរបស់យើងបានជាការសព្វព្រះទ័យដល់ព្រះវរបិតា (៥) និងអំពីសេចក្តីត្រូវការជាចាំបាច់របស់លោក រ៉ូ ថាគាត់ត្រូវបង្កើតផលផ្លែឲ្យសំណាំនឹងការប្រែចិត្ត ហើយពឹងទាំងស្រុងលើព្រះគ្រីស្ទយេស៊ូវ។

ខ្ញុំប្រាកដណាស់ថា អ្នកចែកចាយក៏ពិតជាបានបង្ហាញការមួយចំនួនខាងលើនោះដល់លោក រ៉ូ មែនដែរ។ ប៉ុន្តែ ខ្ញុំក៏ប្រាកដច្បាស់ផងដែរថា សេចក្តីស្មោះត្រង់តាមព្រះគម្ពីរក៏នៅទាមទារលើសពីអ្វីដែលលោក សិលា បានចែកចាយ ហើយលើសពីអ្វីដែលលោក រ៉ូ បានសួរលោក សិលា ផងដែរ។ វាគួរឲ្យខ្លាចណាស់ នៅពេលដែលខ្ញុំគិតអំពីមនុស្សមួយចំនួនដែលមិនបានភ្លក់រសជាតិនៃសេចក្តីល្អរបស់ព្រះជាម្ចាស់ និងសេចក្តីសង្គ្រោះរបស់ទ្រង់ នោះមិនមែនដោយសារគ្រីស្ទបរិស័ទមិនមានឱកាសចែកចាយនោះទេ ប៉ុន្តែគឺដោយសារអ្វីដែលយើងបានចែកចាយនោះវាមិនមានភាពស៊ីជម្រៅសោះ។ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់នឹងប្រាកដថា គាត់ជាអ្នកដែលបានទទួលការផ្លាស់ប្រែចិត្តពិតមែន ប៉ុន្តែគាត់ក៏ប្រាកដផងដែរថា គាត់ត្រូវខិតខំប្រឹងប្រែងក្នុងការផ្សាយដំណឹងល្អថា គាត់បានទទួលព័ត៌មានដោយការយល់ដឹងតាមព្រះគម្ពីរអំពីការផ្លាស់ប្រែចិត្តដែរ។

## *ការយល់ដឹងអំពីការផ្សាយដំណឹងល្អតាមព្រះគម្ពីរ*

បើគ្មានការយល់ដឹងអំពីការផ្លាស់ប្រែចិត្ត និងការផ្សាយដំណឹងល្អតាមព្រះ

9Marks Online PDF

គម្ពីរទេ នោះសមាជិកពួកជំនុំនឹងស្ទើរតែមិនអាចបំពេញបេសកកម្មរបស់ពួកជំនុំក្នុងការបង្កើតសិស្សបានទេ។ ប៉ុន្តែ ដោយសារបច្ចុប្បន្ននេះ ពួកជំនុំចាប់អារម្មណ៍លើវិធីសាស្ត្រ របៀបធ្វើ និងបច្ចេកទេសតាមកាលៈទេសៈ («ប្រសិនបើវាដំណើរការ ចាំធ្វើ») នោះវាងាយស្រួលធ្វើឲ្យសមាជិកពួកជំនុំវង្វេងទៅក្នុងទិសដៅដែលមិនមានសុខភាពល្អ ប្រសិនបើពួកគេមិនបានយល់អំពីការផ្លាស់ប្រែចិត្ត និងការផ្សាយដំណឹងល្អទេ។ «នៅទីបញ្ចប់ របៀបតាមកាលៈទេសៈដែលគ្មានគោលការណ៍ក៏មិនគ្រាន់តែជារបៀបមិនស្មោះត្រង់ប៉ុណ្ណោះទេ វាថែមទាំងមិនទៅតាមកាលៈ ទេសៈទៀតផង»។[៤]

ដំណឹងដែលលើកទឹកចិត្តនោះគឺថា នៅពេលយើងមានការយល់ដឹងល្អអំពីការផ្លាស់ប្រែចិត្តពិត នោះយើងនឹងដឹងថា ការផ្សាយដំណឹងល្អមិនពឹងលើសមត្ថភាពសំនួនវោហារ ការប្រើប្រាស់ភ្លើងក្នុងបរិយាកាសត្រឹមត្រូវ ការប្រើប្រាស់បទចម្រៀង និងរឿងរ៉ាវដែលស៊ីអារម្មណ៍ ឬក៏ការបញ្ចុះបញ្ចូលដែលមានការសន្យាច្រើនឡើយ។ យើងគ្រាន់តែត្រូវទុកចិត្តដល់ព្រះជាម្ចាស់ និងទុកចិត្តលើអំណាចនៃដំណឹងល្អប៉ុណ្ណោះ ដើម្បីបង្កើតផលផ្លែដែលទ្រង់សព្វព្រះហឫទ័យ (រ៉ូម ១:១៧)។ យើងដឹងថា ទោះបីជាយើងជាទូតតំណាងព្រះគ្រីស្ទក្នុងការអង្វរឲ្យមនុស្សបានផ្សះផ្សាជាមួយព្រះជាម្ចាស់ក៏ដោយ ក៏ប៉ុន្តែគឺព្រះជាម្ចាស់ផ្ទាល់ទេដែលទ្រង់ធ្វើការតាមរយៈយើង ដែលយើងជាអ្នកធ្វើការជាមួយនឹងទ្រង់ទេតើ (១កូរិនថូស ៣:៩; ២កូរិនថូស ៥:២០; ៦:១) ហើយព្រះវិញ្ញាណរបស់ទ្រង់ដែលធានាថា ព្រះបន្ទូលរបស់ទ្រង់នឹងមិនត្រឡប់មកឯទ្រង់វិញជាអាសាឥតការទេ

៤ លោក Phillip D. Jensen និងលោក Tony Payne, "Church/Campus Connections: Model ១," in Telling the Truth: Evangelizing Postmoderns, កែសម្រួលដោយលោក D. A. Carson (Grand Rapids, MI: Zondervan), ទំព័រ១៩៥។

9Marks Online PDF

(អេសាយ ៥៥:១១)។ យើងត្រូវតែដាំ ហើយស្រោចទឹកដោយស្មោះត្រង់ ដោយជឿជាក់ថា ព្រះជាម្ចាស់នឹងប្រទានឲ្យមានការចម្រើនឡើង (១កូរិនថូស ៣:៧)។

ដូច្នេះ ការផ្សាយដំណឹងល្អតាមព្រះគម្ពីរតម្រូវឲ្យយើងមានការមួយដែលសំខាន់បំផុតគឺ៖ យើងត្រូវតែស្មោះត្រង់ក្នុងការចែកចាយដំណឹងល្អអំពីព្រះយេស៊ូវគ្រីស្ទជាមួយមនុស្ស ដែលព្រះជាម្ចាស់បានដាក់ឲ្យមានទំនាក់ទំនងជាមួយនឹងយើង (១កូរិនថូស ៤:១-២)។ បើនិយាយឲ្យកាន់តែជាក់លាក់ទៅ៖ ការផ្សាយដំណឹងល្អដែលមានភាពស្មោះត្រង់ត្រូវតែ (១) មានការរៀបរាប់ដែលជាក់លាក់ ដោយប្រកាសសេចក្តីពិតអំពីថា "តើព្រះជាម្ចាស់ជានរណា តើមនុស្សជាអ្នកណា តើអំពើបាបជាអ្វី តើព្រះយេស៊ូវជានរណា តើព្រះយេស៊ូវបានធ្វើអ្វីចំពោះអំពើបាប ហើយថាតើយើងត្រូវតែធ្វើដូចម្តេចចំពោះការដែលព្រះគ្រីស្ទបានសម្រេចនោះ" (២) "រួមបញ្ចូលទាំងគំនិតដែលថាព្រះគ្រីស្ទគឺជាផ្លូវតែមួយគត់នៃសេចក្តីសង្គ្រោះ" ដោយការពារមិនឲ្យគំនិតដែលថា មានផ្លូវច្រើនដែលអាចនាំមនុស្សទៅកាន់ព្រះជាម្ចាស់បាន (យ៉ូហាន ១៤:៦; កិច្ចការ ៤:១២) ព្រមទាំង (៣) ការត្រាស់ហៅអ្នកដែលឮឲ្យប្រែចិត្ត និងជឿដល់ព្រះគ្រីស្ទ។[៥]

ការផ្សាយដំណឹងល្អតាមព្រះគម្ពីរ តម្រូវឲ្យមានការចែកចាយដំណឹងដ៏អស្ចារ្យដែលថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សមានបាប ហើយបន្ទាប់មកអង្វរឲ្យអ្នកដែលឮប្រែចិត្ត ហើយទទួលជឿ។ លោក យ៉ូហាន-បាទីស្ទ បានប្រកាសអំពីព្រះរាជសារនេះ (ម៉ាថាយ ៣:១-២)។ ព្រះយេស៊ូវ

---

៥ លោក Michael P. Andrus, "Turning to God: Conversion beyond Mere Religious Preference," in Telling the Truth; see pp. ទំព័រ១៥៥-៦១។

9Marks Online PDF

ក៏បានប្រកាសអំពីដំណឹងល្អដូចគ្នានេះដែរ (ម៉ាថាយ ៤:១៧)។ ហើយនៅឯពិធីបុណ្យថ្ងៃទី៥០សាវ័ក ពេត្រុស ក៏បានប្រកាសអំពីដំណឹងល្អដដែលនេះដែរ (កិច្ចការ ២:៣៨)។ សមាជិកពួកជំនុំដែលមានសុខភាពល្អ នឹងយកដំណឹងល្អនេះជាចំណុចស្នូល ខណៈពេលដែលពួកគាត់ព្យាយាមធ្វើឲ្យក្លាយជាអ្នកប្រកាសដំណឹងល្អដែលស្មោះត្រង់ ស្របតាមព្រះគម្ពីរ។

## *ចូរឲ្យអ្នកធ្វើការជាគ្រូផ្សាយដំណឹងល្អចុះ*

មានអ្នកនិពន្ធជាច្រើនបានសរសេរ ដើម្បីជួយយើងឲ្យធ្វើការប្រកាសដំណឹងល្អដោយស្មោះត្រង់អំពីព្រះយេស៊ូវគ្រីស្ទ។ អ្នកនិពន្ធមួយចំនួនបានផ្ដល់នូវការលើកឡើងដែលមានប្រយោជន៍ និងមានប្រសិទ្ធភាពក្នុងការអនុវត្ត។ លោកគ្រូ ម៉ាក ដិវើរ (Mark Dever) បានសរសេរ៦ចំណុចដែលសមាជិកពួកជំនុំគួរចាំក្នុងចិត្ត ពេលប្រកាសដំណឹងល្អ។[៦]

១) សូមប្រាប់ដល់ពួកគេដោយស្មោះត្រង់ថា ប្រសិនបើពួកគេប្រែចិត្ត ហើយទទួលជឿ នោះពួកគេនឹងទទួលបានសេចក្ដីសង្គ្រោះ—ប៉ុន្តែ ពួកគេត្រូវតែមានការលះបង់ខ្លាំងណាស់។

២) សូមប្រាប់ពួកគេជាបន្ទាន់ថា ប្រសិនបើពួកគេប្រែចិត្ត ហើយទទួលជឿ នោះពួកគេនឹងទទួលបានសេចក្ដីសង្គ្រោះ—ប៉ុន្តែពួកគេត្រូវតែសម្រេចចិត្តឥឡូវនេះភ្លាម។

៣) សូមប្រាប់ពួកគេដោយសេចក្ដីអំណរថា ប្រសិនបើពួកគេប្រែចិត្ត ហើយទទួលជឿដំណឹងល្អ នោះពួកគេនឹងទទួលបានសេចក្ដីសង្គ្រោះ ទោះបើវាអាចនឹងលំបាកក៏ដោយ ក៏ប៉ុន្តែវាមានតម្លៃ

---

៦ លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books, ឆ្នាំ២០០៤), ទំព័រ១២៤-៣០។

9Marks Online PDF

ណាស់!

៤) សូមប្រើប្រាស់ព្រះគម្ពីរ។

៥) សូមចងចាំថា ជីវិតរបស់គ្រីស្ទបរិស័ទម្នាក់ៗ និងជីវិតក្រុមជំនុំជារួម គឺជាផ្នែកដ៏សំខាន់នៃការប្រកាសដំណឹងល្អ។ របៀបរស់នៅទាំងពីរគួរតែផ្តល់ការសមរម្យមួយដល់ដំណឹងល្អដែលយើងប្រកាស។

៦) សូមកុំភ្លេចអធិស្ឋាន។

លោក ម៉ៃខល ភី. អែនដ្រោស (Michael P. Andrus) ក៏បានផ្តល់ការទូន្មានដ៏មានប្រយោជន៍មួយចំនួនថែមទៀតដែរ។ គាត់បានលើកឡើងថា ដើម្បីរក្សាគំនិតដែលមានសុខភាពល្អអំពីការផ្លាស់ប្រែចិត្តនៅក្នុងគំនិតយើង ទាក់ទងនឹងការខិតខំប្រឹងប្រែងរបស់យើងក្នុងការផ្សាយដំណឹងល្អ៖

១) សូមផ្តល់ប្រឹក្សាដល់អ្នកដែលស្វែងយល់នៅក្នុងរបៀបមួយដែលផ្តោតទៅលើទង្វើ មិនមែនគ្រាន់តែលើពាក្យសម្តី ផ្តោតលើការផ្លាស់ប្តូរជីវិត មិនមែនគ្រាន់តែផ្លាស់ប្តូរជំនឿតែប៉ុណ្ណោះទេ។ ចំណុចចុងក្រោយដែលយើងគួរប្រាប់គឺថា ដោយគ្រាន់តែនិយាយថា “បាទ/ចាស” ទៅកាន់ការបកស្រាយ នោះពួកគេអាចទទួលបានការធានាថាមានជីវិតអស់កល្បជានិច្ចហើយ។

២) សូមផ្តោតលើភាពធ្ងន់ធ្ងរនៃអំពើបាប និងទណ្ឌកម្មនៃអំពើបាបតាមអត្ថន័យព្រះគម្ពីរ។

៣) សូមបង្រៀនព្រះគម្ពីរ និងគោលលទ្ធិគ្រីស្ទបរិស័ទ ដើម្បីឲ្យអ្នកដែលកំពុងស្វែងយល់ដែលហៀបនឹងប្រែចិត្តជឿអាចយល់អំពីផែនការនៃសេចក្តីសង្គ្រោះថាជាការព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនមែនជាប្រាជ្ញារបស់មនុស្សទេ។

9Marks Online PDF

៤) សូមបោះបង់ភាសាងាយៗចោលដែលផ្ដោតលើការសម្រេចចិត្ត (ដូចជា «គ្រាន់តែជឿ» «ចូរអធិស្ឋាន ដើម្បីទទួលយក» ឬក៏ «សូមយាងព្រះយេស៊ូវមកគង់ក្នុងចិត្តរបស់លោកអ្នកចុះ») ប៉ុន្តែ ចូរប្រើភាសាដែលប្រុងប្រយ័ត្នវិញដោយផ្ដោតលើការផ្លាស់ប្រែចិត្ត (ដូចជា «សូមចុះចូលចំពោះការដឹកនាំព្រះយេស៊ូវគ្រីស្ទចុះ» ឬក៏ «សូមបែរចេញពីអំពើបាប ហើយចូរទទួលយកការអត់ទោសដែលព្រះយេស៊ូវបានទិញមកតាមរយៈការសុគតរបស់ទ្រង់ ហើយបន្ទាប់មកសូមរស់នៅក្នុងជីវិតមួយដែលស្ដាប់បង្គាប់តាមទ្រង់ចុះ»)។[៧]

## *ការផ្សាយដំណឹងល្អតាមរយៈពួកជំនុំតាមតំបន់*

លើសពីការផ្ដល់គំនិតដ៏ល្អៗទាំងអស់នេះ សមាជិកពួកជំនុំគួរកត់សម្គាល់លើចំណុចស្នូល និងអត្ថប្រយោជន៍របស់ពួកជំនុំតាមតំបន់ ក្នុងការងារផ្សាយដំណឹងល្អ។ នៅកន្លែងដែលយើងចូលរួមក្នុងពួកជំនុំដែលមានការផ្សាយដំណឹងល្អ នោះដោយព្រះគុណរបស់ព្រះជាម្ចាស់ ដំណឹងល្អក៏នឹងត្រូវបានប្រកាសក្នុងការជួបជុំគ្នារាល់ថ្ងៃព្រះអម្ចាស់ដែរ។ ការអញ្ជើញមិត្តភក្តិ ដែលមិនមែនជាអ្នកជឿ ឲ្យមកចូលរួមកម្មវិធីថ្វាយបង្គំនៅឯពួកជំនុំ គឺជារបៀបដ៏ប្រសើរមួយក្នុងការពង្រឹងការសន្ទនាដែលលោកអ្នកមានជាមួយនឹងពួកគេអំពីដំណឹងល្អ។

ហើយវាក៏ជាឱកាសមួយសម្រាប់ពួកគេឃើញពី «បង្ហាញ» ដំណឹងល្អនៅក្នុងជីវិតជាក់ស្ដែងរបស់ពួកជំនុំនៃពួកអ្នកជឿផងដែរ។ នៅក្នុងពួកជំនុំ អ្នកមិនមែនជាគ្រីស្ទបរិស័ទគួរតែអាចមើលឃើញការរួបរួមគ្នា និង

---

៧ លោក Michael Andrus, "Turning to God," ទំព័រ១៦១-៦២។

9Marks Online PDF

សេចក្តីស្រឡាញ់ដែលបង្ហាញអំពីទីបន្ទាល់នៃសេចក្តីពិត ព្រះចេស្តានៃដំណឹងល្អ និងសេចក្តីស្រឡាញ់របស់ព្រះជាម្ចាស់ (យ៉ូហាន ១៣:៣៤-៣៥; ១៧:២០-២១)។ មិត្តភក្តិរបស់យើងនឹងឃើញដំណឹងល្អដោយភ្នែករបស់ពួកគេផ្ទាល់ នៅពេលពួកគេឃើញគ្រីស្ទបរិស័ទធ្វើពិធីបុណ្យជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។ ទាំងក្នុងរបៀបដែលយើងរស់នៅជាមួយគ្នាក្នុងពួកជំនុំ និងទាំងនៅក្នុងពិធីផ្សេងៗរបស់ពួកជំនុំ នោះយើងបង្ហាញឲ្យឃើញអំពីដំណឹងល្អនៅក្នុងរបៀបដែលបំពេញដល់ការ ដែលពួកជំនុំអធិប្បាយព្រះបន្ទូលនៃដំណឹងល្អ។

លើសពីនេះទៅទៀត ការឲ្យគ្រួសារ និងមិត្តភក្តិរបស់យើងដែលជាអ្នកមិនជឿមានចំណែកនៅក្នុងជីវិតពួកជំនុំ គឺជាការមើលទៅមុខដ៏មានប្រយោជន៍មួយទាក់ទងនឹងជីវិតដែលពួកគេនឹងទទួលបានការត្រាស់ហៅឲ្យរស់នៅដូចនោះដែរ ប្រសិនបើព្រះអង្គនាំពួកគេឲ្យប្រែចិត្ត និងមានសេចក្តីជំនឿដែលនឹងទទួលបានសង្គ្រោះ។ ការយកពួកជំនុំតាមតំបន់ជាចំណុចស្នូលនៃការខិតខំប្រឹងប្រែងខាងឯការប្រកាសដំណឹងល្អរបស់យើងនឹងជួយកាត់ឫសនៃវប្បធម៌បុគ្គលនិយមខាងឯវិញ្ញាណចេញ នៅពេលពួកគេចាប់ផ្តើមដើរក្នុងជីវិតជាគ្រីស្ទបរិស័ទ។

ចុងក្រោយ នៅក្នុងពួកជំនុំតាមតំបន់របស់យើង យើងមានសម្ព័ន្ធមិត្តរាប់រយនាក់ដែលជាគ្រីស្ទបរិស័ទដូចយើងដែរ ហើយម្នាក់ៗមានបទពិសោធន៍ក្នុងការផ្លាស់ប្រែចិត្តក្នុងដំណើររឿងខុសៗគ្នា និងធនធានរៀងៗខ្លួន ដែលពួកគេអាចកសាងទំនាក់ទំនងជាមួយក្រុមគ្រួសារ និងមិត្តភក្តិរបស់យើងបានដែរ។ ជាញឹកញាប់ ព្រះអម្ចាស់សព្វព្រះហឫទ័យក្នុងការប្រើប្រាស់សមាជិករួមជំនឿរបស់យើង ក្នុងការចែករំលែកពាក្យសម្តីដែលមានប្រយោជន៍ ឬក៏ការរស់នៅដែលជាគំរូដ៏គួរឲ្យចាប់អារម្មណ៍ដល់អ្នក

9Marks Online PDF

ដទៃទៀត ដែលអាចនាំឲ្យបុគ្គលនោះមកឯជំនឿដែលនាំឲ្យបានសេចក្តីសង្គ្រោះបានដែរ។ សូមកុំបោះបង់ពួកជំនុំតាមតំបន់ចោល ខណៈពេលដែលលោកអ្នកព្យាយាមផ្សាយដំណឹងល្អដល់មនុស្សបាត់បង់។

## *សេចក្តីសន្និដ្ឋាន*

មានពេលមួយ ខ្ញុំបានចូលរួមសន្និបាតដំណឹងល្អដែលធ្វើឡើងដោយពួកជំនុំតាមតំបន់មួយ។ គ្រូអធិប្បាយច្បងនៅក្នុងសន្និបាតនោះបានសួរទៅកាន់អ្នកចូលរួមថា តើអ្វីទៅជាហេតុផលចម្បងដែលគ្រីស្ទបរិស័ទមិនចង់អ្នកធ្វើការជាអ្នកផ្សាយដំណឹងល្អ? អ្នកចូលរួមបានផ្តល់ចម្លើយល្អៗជាច្រើនដូចជា ការភ័យខ្លាច ការខ្វះចំណេះដឹង និងការមិនមានចិត្តចង់ជាដើម។ គ្រូអធិប្បាយនោះបានធ្វើឲ្យអ្នកចូលរួមមានការភ្ញាក់ផ្អើល នៅពេលដែលគាត់បានលើកឡើងថា ប្រាកដណាស់ទាំងអស់នោះជាបញ្ហា ប៉ុន្តែអ្វីដែលជាបញ្ហាចម្បងនោះគឺថា គ្រីស្ទបរិស័ទជាច្រើនមិនជឿលើកណ្ឌគម្ពីររ៉ូម ១:១៦ ទេ។ ពួកគេមិនបានជឿថា ដំណឹងល្អ គឺជាព្រះចេស្តារបស់ព្រះជាម្ចាស់សម្រាប់សេចក្តីសង្គ្រោះទេ។ ពួកគេខ្វះទំនុកចិត្តលើដំណឹងល្អ។

ចុះចំណែកលោកអ្នកវិញ? តើលោកអ្នកជឿថា ដំណឹងល្អគឺជាព្រះចេស្តានៃព្រះ ដើម្បីឲ្យបានសេចក្តីសង្គ្រោះដែរឬទេ? តើការធ្វើការជាអ្នកផ្សាយដំណឹងល្អរបស់លោកអ្នកបានបង្ហាញអំពីទំនុកចិត្តបែបនេះដែរឬទេ? ខ្ញុំអធិស្ឋានសូមឲ្យលោកអ្នកទាំងអស់គ្នាអាចឆ្លើយនឹងសំណួរនេះថា “បាទ/ចាស” បាន។

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. តើលោកអ្នកបានបញ្ចូលគ្រប់ទាំងចំណុចសំខាន់នៃដំណឹងល្អនៅពេលដែលលោកអ្នកនិយាយទៅកាន់អ្នកដទៃផ្សេងទៀតអំពីព្រះយេស៊ូវដែរឬទេ?

២. តើលោកអ្នកបានបង្ហាញអំពីទំនុកចិត្តនៅក្នុងព្រះរាជសារនៃដំណឹងល្អថា ជាព្រះចេស្តានៃព្រះ ដើម្បីឲ្យបានសេចក្តីសង្គ្រោះ នៅពេលដែលលោកអ្នកនិយាយទៅកាន់អ្នកដទៃផ្សេងទៀតអំពីព្រះយេស៊ូវដែរឬទេ?

៣. តើពួកជំនុំដែលសមាជិកទាំងអស់បានប្តេជ្ញាយ៉ាងជ្រាលជ្រៅចំពោះគ្នាទៅវិញទៅមកនឹងផ្លាស់ប្តូរការយល់ឃើញពីអ្នកក្រៅលើពួកជំនុំនោះដោយរបៀបណា?

សញ្ញាសម្គាល់ទី៦

# សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាសមាជិកដែលមានការប្តេជ្ញាចិត្ត

**មនុស្សជាច្រើនគិតថា** ពួកជំនុំ (ជាពិសេសសមាជិកភាពពួកជំនុំដែលនោះមានន័យថា អ្នកដែលបានចុះបញ្ជី និងការចូលរួមជាមួយគ្នា) គឺជាតួនាទីខាងឯវិញ្ញាណមួយដែលសម្រាប់តែសម័យមុន ហើយហួសសម័យនៅសម័យនេះ ដែលពួកជំនុំបានតាំងឡើង ដើម្បីរាំងដល់សេរីភាព និងការបង្កើតផលផ្លែខាងឯវិញ្ញាណ។

មានហេតុផលច្រើនណាស់ ទាក់ទងនឹងទស្សនៈនៃការយល់ឃើញអំពីសមាជិកភាពក្នុងពួកជំនុំបែបនេះ។ គ្រីស្ទបរិស័ទខ្លះ*មិនចាប់អារម្មណ៍តែម្តង*ចំពោះការធ្វើជាសមាជិកនៅក្នុងពួកជំនុំណាមួយឡើយ។ ពួកគាត់អាចធ្វើជាសមាជិកក៏បាន ហើយមិនធ្វើក៏បាន។ ពួកគាត់មិនរំភើប ហើយក៏មិនមានគំនិតអវិជ្ជមានអ្វីទាំងអស់ចំពោះពួកជំនុំ។ ចំពោះពួកគាត់ វាមិនសំខាន់អ្វីទាំងអស់។

មនុស្សមួយចំនួនទៀត*មិនដឹងអ្វីទាំងអស់*។ ពួកគាត់ខ្វះការយល់ដឹងត្រឹមត្រូវ។ ពួកគាត់មិនដែលពិចារណាអំពីគំនិតរបស់ព្រះគម្ពីរ ដែលនិយាយអំពីពួកជំនុំតាមតំបន់ទេ។

9Marks Online PDF

រីឯមនុស្សមួយចំនួនទៀត *មិនចេះធ្វើការសម្រេចចិត្តទេ*។ ពួកគាត់មិនអាចធ្វើការសម្រេចចិត្តក្នុងការចូលរួមសោះ។ ប្រហែលជាពួកគាត់ជាប្រភេទមនុស្សដែលមិនដែលធ្វើការសម្រេចចិត្ត ហើយការសម្រេចចិត្តនោះទំនងជាកើតឡើងដល់ពួកគាត់ដោយឯងៗ។

ហើយក៏នៅមានប្រភេទមនុស្សមួយចំនួនទៀតដែល *ឯករាជ្យ* ផងដែរ។ ពួកគាត់ជា «គ្រីស្ទបរិស័ទដែលមិនចូលក្នុងក្រុម» ដែលមិនចង់មានបន្ទុកដោយការធ្វើជាសមាជិកពួកជំនុំទេ។ ពួកគាត់មិនចង់ឲ្យអ្នកដទៃទៀត «ជ្រៀតជ្រែកក្នុងកិច្ចការរបស់ពួកគាត់ទេ»។ ពួកគាត់គ្រាន់តែចង់ចូលមកឯពួកជំនុំមួយ ចង់យកអ្វីដែលពួកគាត់ចង់បាន ហើយចង់ចាកចេញដោយមិនជាប់ដៃ។

ប្រភេទមនុស្សចុងក្រោយនេះ ជាប្រភេទមនុស្សដែលយឺតក្នុងការប្ដេជ្ញាចិត្តចំពោះពួកជំនុំតាមតំបន់ ពីព្រោះពួកគាត់មានសេចក្ដីស្រឡាញ់ *បញ្ច្រាស*។ ពួកគាត់មានទំនាក់ទំនងដ៏រឹងមាំជាមួយ «ពួកជំនុំដើម» នៅក្នុងកន្លែងដែលពួកគាត់បានធំធាត់ឡើង ប៉ុន្តែរូបកាយរបស់ពួកគាត់នៅឆ្ងាយរាប់រយគីឡូម៉ែត្រ។ ពួកគាត់មិនអាចភ្ជាប់ខ្លួនទៅនឹងពួកជំនុំដែលពួកគាត់នៅជាមួយសព្វថ្ងៃនេះបានទេ ពីព្រោះអារម្មណ៍របស់ពួកគាត់ មិនដែលចាកចេញពីពួកជំនុំចាស់របស់នៅឡើយ។

ជាឫសគល់ គ្រប់ទាំងទស្សនៈអំពីពួកជំនុំនៅក្នុងតំបន់ទាំងអស់នេះ គឺបានដុះចេញពីបញ្ហាដូចគ្នាមួយ៖ ការមិនយល់ ឬការមិនយកចិត្តទុកដាក់ចំពោះបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ថា ទ្រង់សព្វព្រះទ័យចង់ឲ្យពួកជំនុំតាមតំបន់ក្លាយជាចំណុចស្នូលក្នុងជីវិតរបស់រាស្ត្រទ្រង់។ ពួកគាត់មិនបានក្លាយសមាជិកពួកជំនុំដែលមានការប្ដេជ្ញាចិត្តបានទេ (ដែលជាលទ្ធផលក៏មិនបានក្លាយជាគ្រីស្ទបរិស័ទដែលមានសុខភាព

ល្អ) ពីព្រោះពួកគាត់មិនយល់ថា ការប្តេជ្ញាចិត្តបែបនោះគឺជាការត្រឹមត្រូវមួយ ដែលព្រះសព្វព្រះហឫទ័យចង់ឲ្យរាស្ត្រទ្រង់រស់នៅ ដើម្បីបង្ហាញពីសេចក្តីជំនឿ ហើយទទួលបទពិសោធន៍អំពីសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទផងដែរ។

## *តើ «សមាជិកភាពពួកជំនុំ» ជាគំនិតតាមព្រះគម្ពីរមួយដែរឬទេ?*

នៅពេលអ្នក ដែលជួបប្រទះជាលើកដំបូងលើគំនិតដែលថា សមាជិកភាពពួកជំនុំមានភាពចាំបាច់ និងមានសារៈសំខាន់ជាច្រើនអ្នកចង់ដឹងថា "តើគំនិតស្តីអំពីសមាជិកភាពពួកជំនុំមានសារៈសំខាន់ដែរឬទេ? តើខ្ញុំអាចរកឃើញគំនិតនេះនៅត្រង់កន្លែងណាក្នុងព្រះគម្ពីរ?"។

ដូចជាការជាច្រើនទៀតដែរ លោកអ្នកមិនអាចបើកព្រះគម្ពីរទៅ "កណ្ឌគម្ពីរសមាជិកភាពពួកជំនុំ" បានទេ ឬក៏បើកទៅកាន់ជំពូកណាមួយដែលមានដាក់ចំណងជើងដោយឆោងពុម្ពថា "ការក្លាយជាសមាជិកភាពពួកជំនុំ" នោះដែរ។ ព័ត៌មាននៅក្នុងព្រះគម្ពីរមិនមែនងាយរកងាយយល់បែបនោះទេ ប៉ុន្តែគំនិតអំពីសមាជិកភាពគឺស្ទើរតែមាននៅគ្រប់ទីកន្លែងនៅក្នុងព្រះគម្ពីរ។

តើលោកអ្នកធ្លាប់ពិចារណាដែរឬទេថា តើមានការអនុវត្ត និងការបង្គាប់ប៉ុន្មាន ដែលព្រះជាម្ចាស់បានប្រទានមកពួកជំនុំសញ្ញាថ្មី ដែលនឹងបាត់បង់រាល់អត្ថន័យរបស់វា ប្រសិនបើមិនមានការអនុវត្តសមាជិកភាពពួកជំនុំ ដែលអាចធ្វើការកត់សម្គាល់លើបាន និងមានសារៈសំខាន់? ទាំងនេះជាការសំខាន់មួយចំនួនដែលព្រះគម្ពីរបានបង្គាប់មក សម្រាប់ពួកជំនុំតាមតំបន់ដែលអាចនឹងបាត់បង់អត្ថន័យ បើគ្មានគំនិតនៃការអនុវត្ត

9Marks Online PDF

សមាជិកភាពពួកជំនុំទាំងនោះ។[៨]

## ភាពជាអ្នកដឹកនាំពួកជំនុំ

មានខគម្ពីរពីរ ដែលបានបង្ហាញអំពីលក្ខណសម្បត្តិជាដែលអ្នកដឹកនាំពួកជំនុំត្រូវតែមាន (១ធីម៉ូថេ ៣:១-១៣; ទីតុស ១:៥-៩)។ លើសពីលក្ខណសម្បត្តិទាំងអស់នេះ ក៏នៅមានការបង្គាប់ត្រង់ៗផ្សេងទៀតសម្រាប់អ្នកដឹកនាំក្នុងការឃ្វាលហ្វូងចៀម និងសម្រាប់គ្រីស្ទបរិស័ទក្នុងការចុះចូលចំពោះអ្នកដឹកនាំផងដែរ (ហេព្រើរ ១៣:១៧)។ ប៉ុន្តែ ប្រសិនបើគ្មានសមាជិកទេ នោះអ្នកដឹកនាំក៏មិនមានអ្នកណាអាចដឹកនាំបានដែរ។ ការតម្រូវឲ្យមានការចុះចូលចំពោះអ្នកដឹកនាំដូចមាននៅក្នុងកណ្ឌគម្ពីរ ហេព្រើរ ១៣:១៧ ក៏នឹងក្លាយជាការឥតប្រយោជន៍ដែរ ប្រសិនបើអ្នកដឹកនាំមិនមានការទទួលខុសត្រូវចំពោះក្រុមជាក់លាក់ណាមួយ ហើយក្រុមនោះក៏មិនមានទំនួលខុសត្រូវជាមួយនឹងពួកគេផងដែរ។

## ការដាក់វិន័យពួកជំនុំ

នៅក្នុងកណ្ឌគម្ពីរកូរិនថូសខ្សែទី១ជំពូក៥សាវ័ក ប៉ុល បានបង្រៀនដល់អ្នកជឿនៅក្នុងទីក្រុងកូរិនថូសឲ្យ «ដកម្នាក់ចេញពីការប្រកបគ្នារបស់ពួកគេ» ពីព្រោះបុរសម្នាក់នោះបានប្រព្រឹត្តិការកំផិត។ ព្រះអម្ចាស់យេស៊ូវក៏បានបង្គាប់ការស្រដៀងគ្នានេះនៅក្នុងកណ្ឌគម្ពីរ ម៉ាថាយ ១៨:១៥-១៧ ផងដែរ។ មូលហេតុដែលព្រះគម្ពីរបង្គាប់ឲ្យមានការដាក់វិន័យពួកជំនុំគឺ ដើម្បីរក្សាភាពផ្សេងគ្នារវាងរាស្ត្ររបស់ព្រះដែលជាពួកជំនុំ និងលោកីយ៍ដែលនៅ

---

៨ លោក Mark Dever and លោកPaul Alexander, The Deliberate Church: Building Your Ministry on the Gospel (Wheaton, IL: Crossway, ឆ្នាំ២០០៥), ទំព័រ៦០-៦១។

9Marks Online PDF

ជុំវិញពួកគាត់ (១កូរិនថូស ៥:៩-១៣)។ ប្រសិនបើមិនមានរបៀបជាក់ស្ដែងក្នុងការកំណត់ថា តើនរណាជារបស់ពួកជំនុំ ហើយនរណាជារបស់លោកីយ៍ទេ នោះភាពខុសគ្នា និងកិច្ចការនេះក្នុងការ "ដកអ្នកណាម្នាក់ចេញពីការប្រកបគ្នា" មិនអាចទៅរួចបានឡើយ ពីព្រោះមិនមានរបៀបពិតប្រាកដណាមួយក្នុងការប្រកបគ្នាឡើយ។

## ការរក្សាបញ្ជី និងការបោះឆ្នោត

មានភស្ដុតាង ដែលពួកជំនុំនៅសម័យមុនពិតជាបានកត់បញ្ជីមួយចំនួនទាក់ទងនឹងសមាជិកពួកជំនុំ។ ឧទាហរណ៍៖ មានបញ្ជីស្ត្រីមេម៉ាយដែលពួកគាត់បានកត់ទុក (១ធីម៉ូថេ ៥:៩)។ ហើយពួកជំនុំតាមតំបន់ ក៏បានបោះឆ្នោតក្នុងការសម្រេចសកម្មភាពផ្សេងៗផងដែរ។ នេះគឺជា "[អ្នក]ច្រើនគ្នា" ដែលបានបោះឆ្នោតក្នុងការដកបុរសនោះចេញពីសមាជិកភាពនៅក្នុងពួកជំនុំនៅទីក្រុងកូរិនថូស (២កូរិនថូស ២:៦)។

ការជ្រើសរើសអ្នកដឹកនាំ ការចុះចូលចំពោះពួកគាត់ ការកំណត់ច្បាប់សមាជិកភាព ការមានបញ្ជីឈ្មោះ និងការបោះឆ្នោតមានភាពសមហេតុសមផល លុះត្រាណាតែពួកគាត់ស្គាល់អ្នកដែលមានអត្តសញ្ញាណច្បាស់លាស់ និងមានភាពខុសពីគេ។ ដូច្នេះ ទោះបីជាព្រះគម្ពីរ មិនបានផ្ដល់ឲ្យយើងនូវប្រធានបទជាក់លាក់អំពីសមាជិកភាពពួកជំនុំចំៗក៏ដោយ ក៏យើងនៅមានភស្ដុតាងគ្រប់គ្រាន់នៅក្នុងព្រះគម្ពីរដែលព្រះវិញ្ញាណបណ្ដាលឲ្យតែងនេះដែលលើកឡើងថា ពិតជាមានទម្រង់ខ្លះៗអំពីសមាជិកភាពដែលពួកគាត់បានអនុវត្តមែន ហើយវាមានភាពចាំបាច់នៅក្នុងដំណើរការរបស់ពួកជំនុំដែរ។ នៅសម័យនេះ សមាជិកភាពពួកជំនុំនៅតែមានសារៈសំខាន់ដែរ។

9Marks Online PDF

## *ភាពសំខាន់បំផុតនៃសមាជិកភាព៖ ការមានសេចក្ដីស្រឡាញ់ដែលមានការប្ដេជ្ញាចិត្ត*

ព្រះអម្ចាស់យេស៊ូវនៃយើង បានបញ្ជាក់អំពីសញ្ញាសម្គាល់មួយសម្រាប់សិស្សរបស់ទ្រង់។ ពិតណាស់ មានសញ្ញាសម្គាល់ជាច្រើនទៀតអំពីភាពជាសិស្សដ៏ពិតប្រាកដ ប៉ុន្តែមានសញ្ញាសម្គាល់មួយដែលព្រះអង្គបានលើកឡើង ដើម្បីបង្ហាញដល់លោកីយ៍ដែលកំពុងតែមើលនេះថា *យើងជារបស់ព្រះគ្រីស្ទមែន៖*

> ខ្ញុំឲ្យសេចក្ដីបញ្ញត្ត១ថ្មីដល់អ្នករាល់គ្នា គឺឲ្យអ្នករាល់គ្នាស្រឡាញ់គ្នាទៅវិញទៅមក ត្រូវឲ្យស្រឡាញ់គ្នា ដូចជាខ្ញុំបានស្រឡាញ់អ្នករាល់គ្នាដែរ។ គេនឹងដឹងថា អ្នករាល់គ្នាជាសិស្សរបស់ខ្ញុំ ដោយសារសេចក្ដីនេះឯង គឺដោយអ្នករាល់គ្នាមានសេចក្ដីស្រឡាញ់ដល់គ្នាទៅវិញទៅមក (យ៉ូហាន ១៣:៣៤-៣៥)។

សញ្ញាសម្គាល់នៃភាពជាសិស្សរបស់គ្រីស្ទបរិស័ទគឺ ការមានសេចក្ដីស្រឡាញ់—ជាប្រភេទនៃសេចក្ដីស្រឡាញ់ដែលព្រះយេស៊ូវបានមានចំពោះអ្នកដើរតាមទ្រង់ ពោលគឺការមានសេចក្ដីស្រឡាញ់ដែលបង្ហាញឲ្យឃើញច្បាស់គ្រប់គ្រាន់ដែលគេនឹងអាចកត់សម្គាល់បានថា សេចក្ដីស្រឡាញ់នោះជារបស់អស់អ្នកដែលដើរតាមព្រះយេស៊ូវ។

ដូច្នេះ វាមិនមែនជាការភ្ញាក់ផ្អើលទេ ដែលគ្រីស្ទបរិស័ទដែលមានសុខភាពល្អគឺជាបុគ្គលម្នាក់ដែលបានប្ដេជ្ញាចិត្តក្នុងការបង្ហាញសេចក្ដីស្រឡាញ់នោះដល់គ្រីស្ទបរិស័ទដទៃទៀត។ ហើយកន្លែងដ៏ល្អបំផុតសម្រាប់គ្រីស្ទបរិស័ទឲ្យអាចស្រឡាញ់យ៉ាងនេះបាន គឺនៅក្នុងការប្រជុំនៃរាស្ត្ររបស់ព្រះដែលហៅថា ពួកជំនុំតាមតំបន់។ តើវាមិនមានភាពច្បាស់

ណាស់ទេឬ ដែលបន្ទាន់មកអ្នកសរសេរកណ្ឌគម្ពីរហេព្រើរបានបង្រៀនដល់យើងឲ្យ «ពិចារណាមើលគ្នាទៅវិញទៅមកដែរ ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ ហើយឲ្យប្រព្រឹត្តការល្អផង»។ ហើយភ្លាមនោះក៏សរសេរទៀតថាឲ្យ «ឥតលែងប្រជុំគ្នា ដូចជាអ្នកខ្លះធ្លាប់នោះឡើយ ត្រូវឲ្យកំឡាចិត្តគ្នាវិញ ឲ្យកាន់តែខ្លាំងឡើងផង តាមដែលឃើញថា ថ្ងៃនោះជិតមកដល់ហើយ?» (ហេព្រើរ ១០:២៤-២៥)។ ការទៅព្រះវិហារឲ្យបានទៀងទាត់ មានការទាក់ទងយ៉ាងជិតស្និទ្ធទៅនឹងការកំឡាចិត្តគ្នាទៅវិញទៅមក ដើម្បីនឹងបណ្ដាលឲ្យមានសេចក្ដីស្រឡាញ់ និងឲ្យប្រព្រឹត្តិការល្អ។ ពួកជំនុំតាមតំបន់គឺជាកន្លែងដែលគេអាចឃើញអំពីសេចក្ដីស្រឡាញ់ច្រើនជាងគេបំផុត និងគួរឲ្យចាប់អារម្មណ៍ក្នុងចំណោមរាស្ត្ររបស់ព្រះជាម្ចាស់។ ពួកជំនុំតាមតំបន់គឺជាកន្លែងដែល «រូបកាយរបស់ព្រះគ្រីស្ទ» ត្រូវបានបង្ហាញយ៉ាងច្បាស់បំផុតទៅដល់លោកីយ៍នេះ។

## *តើសមាជិកពួកជំនុំដែលបានប្ដេជ្ញាចិត្តមានលក្ខណៈយ៉ាងដូចម្ដេច?*

នៅក្នុងរបៀបជាក់លាក់មួយ សំណួរដែលសួរថា «តើសមាជិកពួកជំនុំដែលបានប្ដេជ្ញាចិត្តមានលក្ខណៈយ៉ាងដូចម្ដេច?» វាគឺជាអ្វីដែលសៀវភៅនេះទាំងមូលចង់បង្រៀន។ ប៉ុន្តែ នៅទីនេះ យើងចង់រុករកសំណួរនេះដោយមានទំនាក់ទំនងទៅនឹងការបង្គាប់ និងសញ្ញាសម្គាល់ដ៏សំខាន់នៃការស្រឡាញ់។ ខាងក្រោមនេះគឺជាអ្វីដែលសមាជិកភាពដែលមានការប្ដេជ្ញាចិត្តម្នាក់ត្រូវបង្ហាញ។

## ចូលរួមយ៉ាងទៀងទាត់

នេះគឺជាព័ន្ធកិច្ចដំបូង និងសំខាន់បំផុតរបស់គ្រីស្ទបរិស័ទនៅក្នុងពួកជំនុំ

តាមតំបន់គ្រប់ៗរូប។ ការដែលមានវត្តមាន ការដែលគេស្គាល់ និងការសកម្មគឺជារបៀបដែលអាចធ្វើឲ្យមានសេចក្តីស្រឡាញ់របស់គ្រីស្ទបរិស័ទកើតមានឡើងបាន (ហេព្រើរ ១០:២៤-២៥)។

## ស្វែងរកមេត្រីភាព

សមាជិកពួកជំនុំ ដែលមានការប្តេជ្ញាចិត្តគឺជាអ្នកប្តេជ្ញាក្នុងការរក្សាសន្តិភាពនៅក្នុងពួកជំនុំ។ «ហេតុដូច្នេះ ត្រូវឲ្យយើងដេញតាមអស់ទាំងសេចក្តី ដែលនាំឲ្យមេត្រីគ្នា និងសេចក្តីទាំងប៉ុន្មាន ដែលជួយស្អាងចិត្តគ្នាទៅវិញទៅមកវិញ» (រ៉ូម ១៤:១៩)។ «រីឯផលនៃសេចក្តីសុចរិត នោះបានព្រោះចុះដោយសេចក្តីមេត្រី សម្រាប់ពួកអ្នកដែលរកសេចក្តីមេត្រីនោះឯង» (យ៉ាកុប ៣:១៨)។

## ស្អាងចិត្តគ្នា

គោលបំណងជាក់លាក់មួយ ឬគោលដៅនៃការប្រជុំគ្នាជាសាធារណៈរបស់ពួកជំនុំគឺការស្អាងចិត្តគ្នាទៅវិញទៅមក ការស្អាងគ្នាឡើងក្នុងជំនឿ (១កូរិនថូស ១២, ១៤; អេភេសូរ ៤:១១-១៦)។ សមាជិកដែលមានការប្តេជ្ញាចិត្ត ហើយមានសុខភាពល្អនឹងមកបម្រើ ដូចជាព្រះយេស៊ូវដែរ មិនមែនមកឲ្យអ្នកផ្សេងបម្រើនោះទេ (ម៉ាកុស ១០:៤៥) គឺមកដើម្បីផ្តល់ឲ្យ មិនគ្រាន់តែមកដើម្បីយកពីដទៃនោះទេ។

## ព្រមាន និងដាស់តឿនគ្នា

យើងនឹងពិភាក្សាចំណុចនេះដោយស៊ីជម្រៅនៅក្នុងជំពូក៧ «អ្នកដែលស្វែងរកការដាក់វិន័យ»។ សមាជិកដែលមានការប្តេជ្ញាចិត្តគឺជាអ្នកប្តេជ្ញាចិត្តក្នុងការនិយាយអំពីសេចក្តីពិត ដោយមានសេចក្តីស្រឡាញ់ចំពោះបងប្អូនរួមជំនឿ ដើម្បីជួយពួកគាត់ឲ្យរួចពីការធ្លាក់ជង្ហុក ហើយមិនតែប៉ុណ្ណោះ

9Marks Online PDF

គាត់ក៏នឹងលើកទឹកចិត្តបងប្អូនរួមជំនឿឲ្យរស់នៅក្នុងសេចក្ដីបរិសុទ្ធ និងសេចក្ដីអំណររបស់គ្រីស្ទបរិស័ទផងដែរ។ សមាជិកដែលមានការប្ដេជ្ញាចិត្តក៏នឹងមិនជ្រៀតជ្រែកដល់ជីវិតអ្នកដទៃដែរ—ជាមនុស្សបេះបួយ—ប៉ុន្តែគាត់ក៏មិន «នៅដៃទំនេរ» ដែរ នៅពេលគាត់ត្រូវយកចិត្តទុកដាក់ និងផ្ដល់ប្រឹក្សាដល់អ្នកដទៃ (១ធីម៉ូថេ ៥:១៣)។

## ប្រដេញតាមការផ្សះផ្សាគ្នា

គ្រីស្ទបរិស័ទ គឺជាមនុស្សដែលបានទទួលការផ្សះផ្សាជាមួយនឹងព្រះជាម្ចាស់ តាមរយៈព្រះគ្រីស្ទ។ ជាលទ្ធផល ទ្រង់បានប្រទានឲ្យយើងមាន «ការងារផ្សះផ្សានេះ» (២កូរិនថូស ៥:១៨-២១)។ ដូច្នេះ សមាជិកដែលមានការប្ដេជ្ញាចិត្តនឹងខំព្យាយាម ដើម្បីផ្សះផ្សាជម្លោះ ឲ្យបានឆាប់បំផុតតាមដែលអាចធ្វើបាន មុនពេលបន្តក្នុងការថ្វាយបង្គំជាសាធារណៈជាមួយគ្នាផង (ម៉ាថាយ ៥:២៣-២៤)។

## ទ្រាំទ្រនឹងគ្នា

អ្នកធ្វើព័ន្ធកិច្ចក្នុងការផ្សះផ្សាគ្នាត្រូវតែមានការអត់ធ្មត់ ហើយការស៊ូទ្រាំ។ ពួកគាត់ត្រូវតែមានសេចក្ដីសម្លូត ដោយពួកគាត់មិនគិតខ្ពស់អំពីខ្លួនឯងពេកនោះទេ (ម៉ាថាយ ៥:៥)។ ពួកគាត់ត្រូវតែទ្រាំនៅក្រោមទម្ងន់នៃការខកចិត្ត ការខឹងសម្បារ ការបាត់បង់ ការវាយប្រហារ ការនិយាយបង្កូច និងការធ្វើខុសពីអ្នកដទៃ (ម៉ាថាយ ១៨:២១-២២; រ៉ូម ១៥:១)។ ដោយការទទួលបន្ទុកគ្នា នោះយើងអាចបំពេញបញ្ញត្តិរបស់ព្រះគ្រីស្ទឲ្យបានសម្រេច (កាឡាទី ៦:២)។

9Marks Online PDF

## រៀបចំសម្រាប់ពិធីបង្ហូរព្រះគុណ

ឯកសិទ្ធិមួយរបស់សមាជិកភាពពួកជំនុំគឺ យើងអាចចូលរួមនៅក្នុងពិធីនានាដែលព្រះគ្រីស្ទបានបង្គាប់—ដូចជាពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់។ លើសពីនេះទៅទៀត ឯកសិទ្ធិទាំងអស់នេះផ្ដល់ឲ្យយើងមាននូវការប្រកាសអំពីដំណឹងល្អ ដោយមើលឃើញថា ព្រះគ្រីស្ទបានសុគតសម្រាប់មនុស្សមានបាប ហើយក៏បានមានព្រះជន្មរស់ឡើងវិញ ដោយមានព្រះជន្មគង់នៅអស់កល្បជានិច្ចផងដែរ។ ដូច្នេះ វាជាសោកនាដកម្មដែលគ្រីស្ទបរិស័ទជាច្រើនបានធ្វេសប្រហែសនឹងពិធីទាំងនេះ ដែលព្រះគ្រីស្ទផ្ទាល់បានតាំងឡើងកាលពីជាង២០០០ឆ្នាំមុន។ សមាជិកដែលមានការប្ដេជ្ញាចិត្តនឹងមានសេចក្ដីរីករាយចំពោះពិធីជ្រមុជទឹកដល់អ្នកដែលជឿថ្មី ហើយគាត់ក៏នឹងពិនិត្យមើលចិត្តខ្លួនឯង នៅក្នុងការរៀបចំខ្លួនសម្រាប់ការចូលរួមក្នុងគ្រួសាររបស់ព្រះនៅឯតុរបស់ព្រះជាម្ចាស់ដែរ—ពិធីលៀងព្រះអម្ចាស់។ គាត់នឹងទទួលនូវការអនុវត្តខាងឯវិញ្ញាណទាំងអស់នេះដែលជាមធ្យោបាយនៃព្រះគុណ គឺជាមធ្យោបាយដែលផ្ដល់នូវទីបន្ទាល់ដែលមើលឃើញ ដល់ដំណឹងល្អក្នុងជីវិតរបស់គាត់ និងជីវិតនៃពួកជំនុំដែលជួបជុំគ្នា។

## ឧបត្ថម្ភគាំទ្រដល់ព័ន្ធកិច្ច

សមាជិកដែលមានការប្ដេជ្ញាចិត្តផ្ដល់ធនធាន ពេលវេលា និងអំណោយទានដល់ការរីកចម្រើននៃដំណឹងល្អ នៅក្នុងពួកជំនុំតាមតំបន់។ គាត់រស់នៅដោយស្របតាមការត្រាស់ហៅពីព្រះគម្ពីរ ឲ្យមកធ្វើជារូបកាយរបស់ព្រះគ្រីស្ទ។ “ដូច្នេះ ដែលមានអំណោយទានផ្សេងពីគ្នា តាមព្រះគុណដែលផ្ដល់មកយើង ទោះបើជាសេចក្ដីទំនាយ នោះក៏ត្រូវទាយតាមខ្នាតនៃសេចក្ដីជំនឿ ឬបើជាការបម្រើ នោះចូរបម្រើចុះ ឬជាការបង្រៀន ចូរ

9Marks Online PDF

បង្រៀនទៅ ឬជាការទូន្មាន ចូរទូន្មានទៅ ឬជាការចែកទាន ចូរចែកដោយចិត្តស្មោះ ឬជាការនាំមុខ ចូរធ្វើដោយឧស្សាហ៍ ឬការមេត្តាករុណា ក៏ចូរធ្វើដោយរីករាយចុះ» (រ៉ូម ១២:៦-៨)។ សមាជិកដែលមានការប្តេជ្ញា ហើយមានសុខភាពល្អនឹងទទួល ក៏ដូចជាអនុវត្តព្រះគុណរបស់ព្រះជាម្ចាស់ ដោយឧបត្ថម្ភគាំទ្រដល់ព័ន្ធកិច្ចនៃពួកជំនុំនៅតាមតំបន់ ហើយពូកែខាងផ្តល់នូវអ្វីដែលគាត់បានទទួលពីព្រះជាម្ចាស់ដល់ព័ន្ធកិច្ចដំណឹងល្អ។ គាត់គួរតែដើរតាមគំរូរបស់ពួកអ្នកស្រុកម៉ាសេដូន ដែលបានប្តេជ្ញាចិត្តផ្តល់ហិរញ្ញវត្ថុដោយមានការលះបង់ ដោយមានសេចក្តីសប្បុរស ហើយក៏កាន់តែបង្កើនច្រើនឡើងៗ និងព្រមទាំងចម្រើនឡើងដោយសេចក្តីជំនឿនៅក្នុងព្រះជាម្ចាស់ ទោះបីជាស្ថានភាពបច្ចុប្បន្នយ៉ាងណាក៏ដោយ (២កូរិនថូស ៨-៩)។ តើយើងមានអ្វីខ្លះដែលយើងមាន ដែលព្រះជាម្ចាស់មិនបានប្រទានមកយើងជាមុនសិន? តើយើងមានអ្វីខ្លះដែលយើងមាន ដែលយើងមិនគួរថ្វាយដល់ទ្រង់វិញ ក្នុងការថ្វាយបង្គំ?

## ***សេចក្តីសន្និដ្ឋាន***

ការបរាជ័យក្នុងការរាប់ខ្លួនយើងដោយមានភាពយូរអង្វែង និងស្មោះត្រង់ជាមួយនឹងព្រះសិរសានៃពួកជំនុំ ដោយការចូលរួមក្នុងរូបកាយរបស់ទ្រង់ គឺជាសញ្ញាសម្គាល់មួយនៃភាពរមិលគុណ មិនថាការនោះកើតមកពីការមិនយល់ដឹង ឬក៏ពីការមានចិត្តសោះអង្គើយនោះឡើយ។ ពួកយើងដែលមានឯកសិទ្ធិរស់នៅក្នុងប្រទេសដែលយើងអាចចូលរួមជាមួយពួកជំនុំតាមតំបន់ដោយសេរីបាន យើងគួរតែចងចាំការរម្លឹកដាស់តឿនមួយនៅក្នុងចិត្តពីលោក ដេទ្រិខ ប៊ុនហូហ្វ័រ (Dietrich Bonhoeffer) ថា៖

ពួកជំនុំមួយ ត្រូវបានអនុញ្ញាតឲ្យចូលរួមគ្នានៅក្នុងលោកីយ៍នេះ ដើម្បីចែកចាយព្រះបន្ទូល និងពិធីបង្ហូរព្រះគុណរបស់ព្រះជាម្ចាស់ ដោយសារព្រះគុណ។ មិនមែនគ្រីស្ទបរិស័ទទាំងអស់សុទ្ធតែទទួលបានព្រះពរនេះទេ។ អ្នកជាប់គុក អ្នកមានជំងឺ អ្នកខ្ចាត់ខ្ចាយឯកោ អ្នកប្រកាសដំណឹងល្អនៅលើទឹកដីដែលគ្មានអ្នកជឿ គឺពួកគាត់នៅតែម្នាក់ឯង។ ពួកគាត់ដឹងថា ការប្រកបគ្នាគឺជាព្រះពរមួយ ដែលអាចមើលឃើញបាន។ ពួកគាត់ចងចាំ (ដូចជាអ្នកសរសេរកណ្ឌគម្ពីរទំនុកតម្កើងបានចងចាំដែរ) អំពីរបៀបដែលពួកគាត់ទៅ «...ដោយសម្លេងអរសប្បាយ និងសេចក្តីសរសើរ គឺជាពួកកកកុញ ដែលកំពុងតែកាន់ថ្ងៃបរិសុទ្ធ» (ទំនុកតម្កើង ៤២:៤)។ ដូច្នេះ ចូរឲ្យអ្នកដែលមានឯកសិទ្ធិក្នុងការរស់នៅក្នុងជីវិតគ្រីស្ទបរិស័ទទូទៅជាមួយនឹងគ្រីស្ទបរិស័ទដទៃទៀតរហូតមកដល់សព្វថ្ងៃនេះ បានសរសើរព្រះគុណរបស់ព្រះជាម្ចាស់ដោយអស់ពីចិត្តរបស់គាត់ចុះ។ សូមឲ្យពួកគាត់បានលុតជង្គង់ ហើយអរព្រះគុណដល់ព្រះ ដោយប្រកាសថា៖ គឺដោយសារព្រះគុណ គ្មានអ្វីផ្សេងទៀតក្រៅពីព្រះគុណទេ ដែលព្រះបានអនុញ្ញាតឲ្យយើងរាល់គ្នារស់នៅក្នុងសហគមន៍ជាមួយបងប្អូនគ្រីស្ទបរិស័ទផ្សេងទៀត។ [៩]

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. ពី១ដល់១០ តើការប្តេជ្ញាចិត្តរបស់លោកអ្នកអំពីសមាជិកភាពនៅក្នុងពួកជំនុំក្នុងតំបន់ស្ថិតនៅចំណុចលេខប៉ុន្មាន? ប្រសិនបើមិនស្ថិតនៅចំណុចលេខ១០ទេ តើមកពីមូលហេតុអ្វី?

២. ជាទូទៅ តើពួកជំនុំតាមតំបន់របស់លោកអ្នកយកចិត្តទុកដាក់

---

៩ លោក Dietrich Bonhoeffer, Life Together (New York: Harper and Row, ឆ្នាំ១៩៥៤)។

9Marks Online PDF

ចំពោះសមាជិកភាពក្នុងពួកជំនុំដែរឬទេ? តើលោកអ្នកអាចដកស្រង់ខគម្ពីរខ្លះៗ ដើម្បីគាំទ្រចម្លើយរបស់ខ្លួនបានដែរឬទេ?

៣. តើពួកជំនុំ ដែលមានសមាជិកដែលមានការប្ដេជ្ញាចិត្តជ្រាលជ្រៅចំពោះគ្នាទៅវិញទៅមកអាចនឹងផ្លាស់ប្ដូររបៀបគិតពីអ្នកក្រៅដោយរបៀបណា?

សញ្ញាសម្គាល់ទី៧

# សមាជិកពួកជំនុំដែលមានសុខភាពល្អគឺ ជាអ្នកដែលស្វែងរកការដាក់វិន័យ

**ជីវិតត្រូវតែមានការរៀបរៀង និងលំដាប់លំដោយ។** នោះគឺជាសេចក្តីពិតដែលគេច្រើនភ្លេច ឬមើលរំលង។ ដើម្បីឲ្យអាចចម្រើនធំធាត់ឡើងបាន គឺគ្រប់ចំណុចទាំងអស់នៃជីវិតសុទ្ធតែត្រូវការមានលំដាប់លំដោយ។

ភាពរឹករររគឺជាខ្មាំងសត្រូវនៃការរីកចម្រើន។ ជាទូទៅ ការដែលមិនមានរបៀបរៀបរយ ការធ្វេសប្រហែស និងការមិនផ្តោតដោយយកចិត្តទុកដាក់គឺជាដើមចមនៃអស្ថិរភាព ដែលនាំឲ្យចុះខ្សោយ ជាជាងផ្តល់កម្លាំង។ កន្លែងណាដែលមិនមានលំដាប់លំដោយ កន្លែងនោះនឹងមានស្ថិរភាព និងមានការរីកចម្រើនតិចតួចតែប៉ុណ្ណោះ។ ជីវិតត្រូវតែមានការរៀបរៀង និងលំដាប់លំដោយ។ អ្នករៀបការថ្មីថ្មោងដឹងអំពីការនេះនៅពេលព្រះបានប្រទានកូនដល់ពួកគាត់។ ជីវិតរបស់ពួកគាត់រហូតមកដល់ត្រង់ចំណុចនេះបង្ហាញនូវឥរិយាបថមួយដែលហៅថា “មានសេរីភាព ហើយគ្មានអ្នកត្រួត” ប៉ុន្តែមិនយូរប៉ុន្មានពួកគាត់ក៏ចាប់ផ្តើមដឹងថា ដើម្បីថែរក្សា និងចិញ្ចឹមបីបាច់កូនម្នាក់ឲ្យបានត្រឹមត្រូវ នោះ

ពួកគាត់ត្រូវរក្សាកម្រិតជាក់លាក់មួយនៃការមានលំដាប់លំដោយ។ ពួកគាត់ត្រូវតែបង្កើតទម្លាប់នៃការដេក និងការបញ្ចុកបាយកូន។ ពួកគាត់ត្រូវតែដកយកនូវរបស់របរតូចៗ និងមានគ្រោះថ្នាក់ចេញ។ ពួកគាត់ត្រូវតែបិទកន្លែងព្រីភ្លើងឲ្យជិត។ ពួកគាត់ត្រូវតែផ្តល់ឲ្យតាមពេលត្រឹមត្រូវទាក់ទងនឹងការប្តូរខោរទឹកនោម ការងូតទឹក និងសម្លៀកបំពាក់ស្អាត។ ប្រសិនបើចង់បានការរីកចម្រើន នោះដាច់ខាតត្រូវតែមានលំដាប់លំដោយ។ វាគឺជាការពិតនៃជីវិត។

ជាការពិតណាស់ ការមានលំដាប់លំដោយក៏មានភាពចាំបាច់ផងដែរនៅក្នុងសេចក្តីខាងឯព្រលឹងវិញ្ញាណ។ បើគ្មានការបង្កើតឲ្យមានទម្លាប់ដែនកំណត់ និងគំរូត្រឹមត្រូវទេ នោះការរីកចម្រើនខាងឯព្រលឹងវិញ្ញាណក៏ពុំអាចកើតឡើងបានដែរ ឬនឹងក្លាយទៅជាការគ្មានគម្រោងច្បាស់លាស់តែម្តង។ ពាក្យមួយទៀតសម្រាប់ពាក្យការមានលំដាប់លំដោយ ដើម្បីឲ្យមានការរីកចម្រើនខាងឯវិញ្ញាណបាន គឺការដាក់វិន័យ។

## ***តើការដាក់វិន័យជាអ្វី?***

បច្ចុប្បន្ននេះ នៅពេលគេឮពាក្យ *ការដាក់វិន័យ* គេច្រើនគិតអំពីទម្រង់អវិជ្ជមាននៃការដាក់ទណ្ឌកម្ម ដូចជាការវាយកូនដែលរឹងរូសជាដើម។ មនុស្សជាច្រើនគិតថា *ការដាក់វិន័យ* ហាក់ដូចជាការអាក្រក់ ជាអ្វីម្យ៉ាងដែលត្រូវជៀសវាង ឬថាជាអ្វីមួយដែលមនុស្សចិត្តអាក្រក់ ឬចិត្តឃោរឃៅច្រើនធ្វើ។ សម្រាប់មនុស្សមួយចំនួនទៀត ពួកគាត់គិតថា វាជាការដាក់កម្រិតលើសេរីភាព និងការអរសប្បាយ។ បើនិយាយឲ្យប្រាកដទៅ ការដាក់វិន័យមិនមែនជាបទពិសោធន៏រីករាយ គ្រប់ពេលនោះទេ។ អ្នកនិពន្ធកណ្ឌគម្ពីរហេព្រើរបានសរសេរថា "កាលណាយើងត្រូវសេចក្តីផ្ចាញ់ផ្ចាល

9Marks Online PDF

(ការដាក់វិន័យ) នោះមើលទៅដូចជាព្រួយណាស់ មិនមែនសប្បាយទេ» (ហេព្រើរ ១២:១១)។

ប៉ុន្តែ តាមពិតទៅពាក្យថា *ការដាក់វិន័យ* មានអត្ថន័យទូលំទូលាយ និងវិជ្ជមានជាងពាក្យថា «ការដាក់ទារុណកម្មដែលមិនសប្បាយ»។ ពាក្យថា *ការដាក់វិន័យ* (Discipline) និងពាក្យ សិស្ស (Disciple) មានពាក្យឫសពីភាសាឡាតាំងដូចគ្នា ដែលមានទំនាក់ទំនងយ៉ាងជិតស្និទ្ធចំពោះគំនិតអំពីការអប់រំ និងការមានសណ្តាប់ធ្នាប់។ ពួកសាវ័កពីដំបូងគឺជាសិស្សដែលចូលរួមក្នុងការអនុវត្តការដាក់វិន័យជាក់លាក់ណាមួយ ជាអ្នកដែលរៀនពីអាជីពវិជ្ជាជីវៈមួយ ឬក៏ជាអ្នកចេះដឹងច្រើនលើប្រធានបទណាមួយ។ គាត់គឺជាបុគ្គលដែលបានរៀបចំជីវិតរបស់គាត់ឲ្យមានលំដាប់លំដោយក្រោម ឬឲ្យមានរបៀបរៀបរយក្រោមច្បាប់នៃការណែនាំណាមួយ។ ដូចដែលកីឡាករអាជីពម្នាក់ប្រកាន់ខ្ជាប់នឹងច្បាប់កីឡារបស់ពួកគេ។ សាស្ត្រាចារ្យចិត្តវិទ្យាមានការប្តេជ្ញាតោងជាប់នឹងគំនិតសាលានេះ ឬគំនិតសាលានោះ។ វេជ្ជបណ្ឌិត ប្រកាន់ខ្ជាប់នឹងគោលការណ៍ពីមណ្ឌលស្ថានរៀនសូត្ររបស់ពួកគាត់។ អ្នកទាំងអស់នេះគឺជាសិស្សនៃមុខជំនាញទាំងអស់នោះ ហើយស្ថិតនៅក្រោមវិន័យគោលការណ៍នៃមុខជំនាញរបស់ពួកគេដែរ។

ការនេះគឺដូចគ្នាទៅនឹងពួកជំនុំដែរ។ ពួកជំនុំគឺជាកន្លែងមួយនៃបណ្តុំក្នុងការបម្រើគ្រប់យ៉ាងដែលគួរ «ត្រូវតែធ្វើការទាំងអស់តាមបែបគួរសម ហើយដោយលំដាប់លំដោយផង» (១កូរិនថូស ១៤:៤០)។ លំដាប់លំដោយនោះចាំបាច់ណាស់សម្រាប់ការស្អាងចិត្តគ្នា។

ហើយការដាក់វិន័យ ក៏មានភាពចាំបាច់នៅក្នុងជីវិតរបស់អ្នកជឿម្នាក់ៗផងដែរ។[១០] លោក ចេ អាដាម (Jay Adams) បាននិយាយសង្ខេបយ៉ាងល្អ អំពីទំនាក់ទំនងរវាងការដាក់វិន័យដ៏មានលំដាប់លំដោយ ការរៀនសូត្រ និងជីវិតគ្រីស្ទបរិស័ទថា «នៅពេលយើងទទួលពិធីជ្រមុជទឹកនៅក្នុងពួកជំនុំ នោះពួកជំនុំបានក្លាយជាកន្លែង ដែលយើងចុះឈ្មោះចូលរៀននៅក្នុងសាលារបស់ព្រះគ្រីស្ទ។ បន្ទាប់មក ជីវិតដែលសេសសល់របស់យើងនៅផែនដីនេះ គឺយើងត្រូវតែរៀនសូត្រ (មិនត្រឹមសេចក្តីពិតតែមួយប៉ុណ្ណោះទេ ប៉ុន្តែ) និងព្រមទាំងស្តាប់បង្គាប់តាមបញ្ញត្តិរបស់ព្រះគ្រីស្ទផងដែរ។ នេះជាការអប់រំដែលបូករួមទាំងការបង្ហំផងដែរ។ វាជាការអប់រំដែលមានវិន័យសណ្តាប់ធ្នាប់យ៉ាងឆ្អឹងខ្នង ដែលនោះគឺជាការចាំបាច់ ដើម្បីឲ្យបានលទ្ធផលនៃការសិក្សារៀនសូត្រ»។[១១]

ដូច្នេះ ការដាក់វិន័យគឺសម្រាប់ការអប់រំ និងការរៀនសូត្រ ការមានលំដាប់លំដោយ និងការរីកចម្រើនឡើង។ វិន័យក្នុងជីវិតនៃការរស់នៅក្នុងពួកជំនុំ និងសមាជិកពួកជំនុំដែលមានសុខភាពល្អនឹងផ្តល់ឲ្យមានបរិយាកាសមួយសម្រាប់ការរីកចម្រើន និងការអភិវឌ្ឍន៍។ វានាំទៅកាន់ការមានលក្ខណៈពិសេសដ៏កម្រមាន ទាក់ទងនឹងការមានលក្ខណសម្បត្តិដូចជាព្រះគ្រីស្ទ។

---

១០ ឧទាហរណ៍៖ ១ថែស្សាឡូនិច ៤:២២ និង២ថែស្សាឡូនិច ៣:៦, ១១។

១១ លោក Jay Adams, Handbook on Church Discipline: A Right and Privilege of Every Church Member (Grand Rapids, MI: Zondervan, ឆ្នាំ១៩៧៤), ទំព័រ១៦។

9Marks Online PDF

## *តើការដាក់វិន័យនៅក្នុងជីវិតរបស់សមាជិកដែលមានសុខភាពល្អមានលក្ខណៈយ៉ាងដូចម្ដេច?*

ការដាក់វិន័យមានពីរទម្រង់ដែលកើតឡើងនៅក្នុងជីវិតពួកជំនុំ និងសមាជិកពួកជំនុំដែលមានសុខភាពល្អ។ ទម្រង់នៃការដាក់វិន័យទាំងពីរនេះមានប្រភពចេញពីព្រះបន្ទូល ហើយតាមពិតទៅរបៀបទាំងពីរមានការយល់អំពីបំណងព្រះហឫទ័យ និងលទ្ធផលនៃព្រះបន្ទូលរបស់ព្រះនៅក្នុងជីវិតនៃរាស្ត្ររបស់ទ្រង់ផងដែរ។

សាវ័ក ប៉ុល បានសរសេរនៅក្នុងកណ្ឌគម្ពីរ ២ធីម៉ូថេ ៣:១៦៖ «គ្រប់ទាំងបទគម្ពីរ គឺជាព្រះទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែងទេ ក៏មានប្រយោជន៍សម្រាប់ការបង្រៀន ការរម្លឹកឲ្យដឹងខ្លួន ការប្រដៅតម្រង់ និងការបង្ហាត់ខាងឯសេចក្ដីសុចរិត»។

យើងអាចនិយាយម្យ៉ាងទៀតថា ព្រះបន្ទូលដែល «ទ្រង់បានបញ្ចេញព្រះវិញ្ញាណបណ្ដាលឲ្យតែង» ឬដែលបណ្ដាលមកពីព្រះជាម្ចាស់មានគោលបំណងទូទៅពីរគឺ *ការដាក់វិន័យសម្រាប់បង្ហាត់បង្រៀន* និង*ការដាក់វិន័យសម្រាប់កែតម្រង់*។ នៅពេលសាវ័ក ប៉ុល បានសរសេរថា ព្រះបន្ទូល «មានប្រយោជន៍សម្រាប់ការបង្រៀន» និង «សម្រាប់ការបង្ហាត់ខាងឯសេចក្ដីសុចរិត» គឺគាត់កំពុងតែពណ៌នាអំពី*ការដាក់វិន័យបែបវិជ្ជមាន* ឬក៏*ការដាក់វិន័យសម្រាប់បង្ហាត់បង្រៀន*។ ការដាក់វិន័យសម្រាប់ការបង្ហាត់បង្រៀនគឺ សំដៅលើរបៀបដែលព្រះគម្ពីរឆ្នៃ និងបង្កើតគ្រីស្ទបរិស័ទទៅតាមសេចក្ដីបង្រៀន និងការហ្វឹកហាត់នៅក្នុងការរស់នៅសម្រាប់ព្រះអង្គ។ ដូចដែលវេជ្ជបណ្ឌិតគោរពតាមការគ្រប់គ្រងដោយស្តង់ដារ និងការសច្ចាប្រណិធានក្នុងវិជ្ជាជីវៈរបស់គាត់យ៉ាងណា នោះគ្រីស្ទបរិស័ទក៏ត្រូវឆ្នៃឡើង ហើយគ្រប់គ្រងដោយព្រះបន្ទូលរបស់ព្រះយ៉ាងដូច្នោះដែរ។

9Marks Online PDF

ដូចគ្នាផងដែរ នៅពេលសាវ័ក ប៉ុល បានមានប្រសាសន៍ថា បទគម្ពីរមានប្រយោជន៍សម្រាប់ «ការរម្លឹកឲ្យដឹងខ្លួន ការប្រដៅតម្រង់» គឺគាត់កំពុងតែសំដៅលើរបៀបដែលព្រះបន្ទូលរបស់ព្រះព្រមានយើងអំពីកំហុស ហើយបង្វែរយើងចេញពីកំហុសនោះឲ្យទៅឯសេចក្តីសុចរិតវិញ។ នេះហើយជាការដាក់វិន័យបែបកែតម្រង់។

ភាគច្រើន ការដាក់វិន័យនៅក្នុងពួកជំនុំគឺជាវិន័យសម្រាប់បង្ហាត់បង្រៀន ឬវិន័យវិជ្ជមាន ការនោះនឹងកើតឡើងនៅពេលដែលពួកជំនុំរីកចម្រើនឡើងដោយសារការអធិប្បាយព្រះបន្ទូល នៅពេលពួកគេសិក្សាបទគម្ពីរផ្ទាល់ខ្លួន និងនៅពេលពួកគេត្រូវបានទទួលការកំឡាចិត្តដោយការប្រកបគ្នា និងការលើកទឹកចិត្តគ្នាពីបងប្អូនដទៃទៀត នៅក្នុងព្រះគ្រីស្ទ។ ប៉ុន្តែ ពេលខ្លះក៏នឹងមានបងប្អូនដែលបណ្តោយខ្លួនទៅក្នុងអំពើបាប ហើយត្រូវការការកែតម្រង់ដោយសេចក្តីស្រឡាញ់ពីសមាជិកនៃពួកជំនុំដែលប្តេជ្ញាចិត្តចំពោះសុខមាលភាពនៃព្រលឹងរបស់គាត់ឡើងវិញដែរ។ លើសពីនេះទៅទៀត បទគម្ពីរក៏បានចង្អុលបង្ហាញអំពីស្ថានភាពផ្សេងៗ ដែលតម្រូវឲ្យមានការកែតម្រង់ផងដែរ។ ព្រះអម្ចាស់យេស៊ូវនៃយើង ទ្រង់បានគូសបង្ហាញអំពីដំណើរការមួយសម្រាប់ការដាក់វិន័យក្នុងការកែតម្រង់ ក្នុងករណីដែលបងប្អូនណាម្នាក់បានធ្វើបាបនឹងម្នាក់ទៀត (ម៉ាថាយ ១៨:១៥-១៧)។ សាវ័ក ប៉ុល បានលើកទឹកចិត្តពួកជំនុំកូរិនថូសឲ្យប្រាប់ពីកំហុស ហើយឲ្យបណ្តេញចេញបុគ្គលម្នាក់ពីសមាជិកភាព ដោយព្រោះអំពើកំផិតដ៏គួរឲ្យស្អប់ខ្ពើម (១កូរិនថូស ៥)។ ការកែតម្រង់របស់ពួកជំនុំមិនគ្រាន់តែចាំបាច់សម្រាប់អំពើបាប «ដ៏អាក្រក់» ដូចជាការកំផិតដ៏អសីលធម៌ប៉ុណ្ណោះនោះទេ ប៉ុន្តែសូម្បីតែអំពើបាបខុសរបៀបដែលមើលទៅហាក់ដូចជារឿងធម្មតាដូចជាភាពខ្ជិលច្រអូស និងសេចក្តីបង្រៀនខុសឆ្គងក៏ត្រូវតែមាន

9Marks Online PDF

ការកែតម្រង់ផងដែរ (២ថែស្សាឡូនីច ៣:៦, ១១; ទីតុស ៣:១០)។

គ្មានអ្នកណាម្នាក់រស់នៅ ពេញមួយជីវិតនេះ ដោយមិនត្រូវការការដាក់វិន័យឡើយ មិនថា វិន័យសម្រាប់បង្ហាត់បង្រៀន ឬវិន័យសម្រាប់ការកែតម្រង់នោះទេ។ ដូច្នេះ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងតែងតែឱបក្រសោបការដាក់វិន័យទុកជាមធ្យោបាយនៃព្រះគុណ នៅក្នុងជីវិតជាគ្រីស្ទបរិស័ទរបស់ខ្លួន។

## *តើយើងស្វែងរកការដាក់វិន័យ ដោយមានអំណរដោយរបៀបណា?*

ប្រធានបទនៃការដាក់វិន័យពួកជំនុំអាចជាប្រធានបទថ្មីមួយចំពោះលោកអ្នក ឬក៏ថាមិនមែនជាប្រធានបទថ្មី ប៉ុន្តែការអនុវត្តការដាក់វិន័យនៅក្នុងពួកជំនុំតាមតំបន់អាចជាប្រធានបទថ្មី ឬក៏មិនដែលមានផងដែរ។ មនុស្សមួយចំនួននឹងរីកចម្រើនដំណាលគ្នា ទាំងការយល់ដឹងអំពីប្រធានបទនេះ ទាំងការហ៊ានប្រឈមនឹងការភ័យខ្លាច ឬការយល់ខុស និងទាំងការរួមចំណែកក្នុងការធ្វើឲ្យពួកជំនុំរបស់ខ្លួនមានសុខភាពល្អផងដែរ។ ខាងក្រោមនេះគឺជាការលើកឡើងមួយចំនួន ដែលជាបំណងប្រាថ្នា ដែលចង់បណ្តុះការដាក់វិន័យសម្រាប់បង្ហាត់បង្រៀន និងការដាក់វិន័យសម្រាប់ការកែតម្រង់ ដើម្បីឲ្យយើងអាចក្លាយជាសមាជិកពួកជំនុំដែលមានសុខភាពល្អនៅក្នុងពួកជំនុំរបស់យើង។

## ចូរទទួលព្រះបន្ទូលនៃព្រះដោយចិត្តសុភាព

លោក យ៉ាកុប បានហៅឲ្យគ្រីស្ទបរិស័ទថេះ «លះចោលអស់ទាំងសេចក្តីស្មោកគ្រោកចេញ និងសេចក្តីគម្រក់ដ៏មានច្រើនម្លេះចេញផង ដ្បិតព្រះបន្ទូលនោះ អាចនឹងជួយសង្គ្រោះព្រលឹងអ្នករាល់គ្នាបាន» (យ៉ាកុប

១:២១)។ នៅក្នុងការណែនាំរបស់លោក យ៉ាកុប គឺគាត់ចង់សំដៅលើភាពខុសគ្នារវាងជីវិត ដែលមិនកោតខ្លាចព្រះនៅក្នុងសេចក្ដីស្មោកគ្រោក និងសេចក្ដីគម្រក់ និងជីវិតដែលមានការបន្ទាបខ្លួន មានចិត្តសុភាព ដែលមានលក្ខណៈដូចព្រះគ្រីស្ទ។ គ្រីស្ទបរិស័ទគួរតែទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយមានការបន្ទាបខ្លួន។ នេះមានន័យថា នៅក្នុងការអធិប្បាយព្រះបន្ទូលរបស់ព្រះ ហើយនៅក្នុងការសិក្សាព្រះគម្ពីរ គឺគ្រីស្ទបរិស័ទគួរតែមានការបន្ទាបខ្លួន និងចិត្តសុភាពជានិច្ចនៅចំពោះព្រះគម្ពីរ ដោយទទួលស្គាល់ថា ព្រះគម្ពីរគឺជាប្រភពនៃសេចក្ដីសង្គ្រោះ និងការណែនាំឲ្យរស់នៅក្នុងជីវិតដែលចេះកោតខ្លាចព្រះ។ នៅពេលយើងចូលមកឯព្រះគម្ពីរ គឺយើងត្រូវតែដឹងថា យើងជាមនុស្សដែលមាននិស្ស័យដែលពោរពេញដោយអំពីបាប ភាពកម្សត់ខាងព្រលឹងវិញ្ញាណរបស់ខ្លួននៅចំពោះព្រះ ហើយនិងតម្រូវការរបស់យើងសម្រាប់ឥទ្ធិពលនៃការកែច្នៃពីព្រះ ដែលមកពីព្រះបន្ទូលរបស់ព្រះអង្គ។

តើយើងអាចដឹងបានដោយរបៀបណាថា យើងកំពុងទទួលព្រះបន្ទូលរបស់ព្រះជាម្ចាស់ដោយចិត្តសុភាព? ទំនងសំណួរខាងក្រោមនេះអាចនឹងជួយដល់លោកអ្នកឲ្យដឹងបាន៖

- នៅពេលយើងអានព្រះគម្ពីរ តើយើងកំពុងអាន ដើម្បីឲ្យបានតែព័ត៌មាន ឬក៏អានដោយជំនឿដែលថា ជាព្រះជាម្ចាស់មានបន្ទូលជាក់ស្ដែងតាមរយៈព្រះបន្ទូលទ្រង់?
- នៅពេលដែលយើងឮការអធិប្បាយព្រះបន្ទូល ជាទូទៅ តើយើងស្វែងរកឲ្យមានការបំពេញសេចក្ដីត្រូវការមួយណាដែរឬទេ (ឧទាហរណ៍៖ ស្ដាប់ទុកជាការកម្សាន្ត ឬជាការប្រមូលទុកដំបូន្មានសម្រាប់ការប្រើប្រាស់ជាក់ស្ដែង) ឬក៏យើងចង់ដឹងចង់យល់អំពីអត្ថន័យដើមនៃ

ព្រះគម្ពីរនោះ ហើយអនុវត្តនៅក្នុងជីវិតរស់នៅរបស់យើង?

- តើចំណាប់អារម្មណ៍ដំបូងរបស់យើងចំពោះព្រះគម្ពីរគឺថា «តើព្រះគម្ពីរនេះធ្វើឲ្យខ្ញុំមានអារម្មណ៍យ៉ាងដូចម្ដេច?» ឬក៏ថា «តើខ្ញុំទទួលព្រះគម្ពីរនេះជាសេចក្ដីពិតឬទេ?»។ តើយើងអនុញ្ញាតឲ្យអារម្មណ៍របស់យើងកំណត់អ្វីមួយជាសេចក្ដីពិត ឬក៏យើងអនុញ្ញាតឲ្យព្រះគម្ពីរកំណត់អារម្មណ៍របស់យើង? [១២]
- តើការស្ដាប់របស់យើងក្នុងកំឡុងពេលអធិប្បាយ ឬការអានព្រះគម្ពីរ យើងមានចិត្តចង់ការពារខ្លួន ឬមានចិត្តចង់វាយប្រហារ ក្នុងឥរិយាបថបែបដែលទាមទារឲ្យអ្នកណាម្នាក់មក «បង្ហាញភស្តុតាងដល់យើង?»[១៣]
- តើយើងមានទំនោរវិនិច្ឆ័យទស្សនៈវិជ្ជា ឬគំនិតនានាដោយយកព្រះគម្ពីរជាគោល ឬក៏យើងវិនិច្ឆ័យព្រះគម្ពីរដោយទស្សនៈវិទ្យា ឬគំនិតនានាដទៃទៀត?

ការទទួលយកព្រះបន្ទូលរបស់ព្រះជាម្ចាស់ ដោយមានចិត្តសុភាពមានន័យថា យើងទទួលព្រះគម្ពីរដោយសេចក្ដីជំនឿ ដោយចិត្តរីករាយ និងចេះចុះចូល ព្រមទាំងដោយទីបន្ទាល់នៃព្រះវិញ្ញាណរបស់ព្រះផង។ ជាពិសេស យើងត្រូវទទួលស្គាល់អំពីការពិតដែលថា ព្រះគម្ពីរគឺជាសេចក្ដីពិត

---

១២ លោក C. J. Mahaney, Living the Cross Centered Life: Keeping the Gospel the Main Thing (Sisters, OR: Multnomah, ឆ្នាំ២០០៦)។ សូមអានជំពូក២។

១៣ នេះគឺជាអាកប្បកិរិយារបស់មនុស្សដែលមិនកោតខ្លាចព្រះនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៨, ២១ «ដែលបង្ខាំងសេចក្ដីពិត» ហើយ «មិនបានតម្កើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ»។

9Marks Online PDF

ដែលមានអំណាចគ្រប់គ្រាន់សម្រាប់ប៉ាន់ថ្មៃសូនជីវិតរបស់យើង ហើយថាព្រះគម្ពីរត្រូវតែគ្រប់គ្រងអារម្មណ៍ និងការគិតរបស់យើង។ តាមរយៈការធ្វើបែបនោះ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងរៀបចំខ្លួនក្នុងការទទួលការដាក់វិន័យ បែបកែតម្រង់ ពីពួកជំនុំរបស់ព្រះគ្រីស្ទ។

## ចូរទទួលយកការកែតម្រង់ពីអ្នកដទៃទៀតដោយបន្ទាប់ខ្លួន

សមាជិកពួកជំនុំ ដែលមានសុខភាពល្អមិនត្រឹមតែទទួលយកការវាយប្រដៅរបស់ព្រះប៉ុណ្ណោះទេ ប៉ុន្តែក៏ថែមទាំងទទួលយកការកែតម្រង់ពីអ្នកដទៃដោយបន្ទាបខ្លួនផងដែរ។ ពួកគាត់ទទួលស្គាល់ថា ជាញឹកញាប់ការកែតម្រង់របស់ព្រះគឺកើតឡើងតាមរយៈសមាជិកដទៃទៀតនៅក្នុងពួកជំនុំជាពួកបរិសុទ្ធដែលយកចិត្តទុកដាក់គ្រប់គ្រាន់ មិនត្រឹមតែលើកទឹកចិត្តនៅក្នុងពេលវេលាល្អៗនោះទេ ប៉ុន្តែប្រាប់អំពីកំហុស និងកែតម្រង់នៅពេលដែលចាំបាច់ផងដែរ។ សមាជិកពួកជំនុំដែលមានសុខភាពល្អយល់ស្របថា «ការដែលបន្ទោសនៅកណ្តាលជំនុំ នោះវិសេសជាងសេចក្តីស្រឡាញ់លាក់កំបាំង។ របួសដែលមិត្តសម្លាញ់ធ្វើដល់យើង នោះតែធ្វើដោយស្មោះត្រង់ទេ» (សុភាសិត ២៧:៥-៦)។

ពួកជំនុំជាច្រើនដែលម៉ឺងម៉ាត់ជាមួយសមាជិកភាពតែងតែសុំឲ្យសមាជិកថ្មីៗពិនិត្យមើលឡើងវិញ គាំទ្រ ហើយជូនកាលចុះហត្ថលេខាលើកិច្ចសន្យារបស់ពួកជំនុំទៀតផង។ កិច្ចសន្យារបស់ពួកជំនុំគឺជាឯកសារមួយដែលសង្ខេបការប្តេជ្ញាចិត្តដែលសមាជិកពួកជំនុំធ្វើឡើងនៅចំពោះព្រះអម្ចាស់ ហើយចំពោះគ្នាទៅវិញទៅមក ដើម្បីរស់នៅដោយស្របតាមសេចក្តីជំនឿគ្រីស្ទបរិស័ទ ក្នុងឥរិយាបថមួយដែលធ្វើតាមការបង្គាប់របស់

9Marks Online PDF

ព្រះគម្ពីរ។

កថាខណ្ឌ ដែលខ្ញុំចូលចិត្តមួយនៅក្នុងកិច្ចសន្យាទូទៅរបស់ពួកជំនុំដែលបានសរសេរអំពីរឿងសំខាន់នៃការទទួលយកសេចក្តីស្រឡាញ់ និងការកែតម្រង់ពីអ្នកដទៃគឺថា៖

> **យើងនឹងដើររួមគ្នានៅក្នុងសេចក្តីស្រឡាញ់ជាបងប្អូន ខណៈដែលយើងក្លាយជាសមាជិកនៃពួកជំនុំគ្រីស្ទបរិស័ទ។ យើងនឹង អនុវត្តការយកចិត្តទុកដាក់ដោយសេចក្តីស្រឡាញ់ និងការប្រុងប្រយ័ត្នសម្រាប់គ្នាទៅវិញទៅមក ហើយដាស់តឿនដោយស្មោះត្រង់ និងអង្វរគ្នាទៅវិញទៅមកនៅពេលចាំបាច់ផងដែរ។**[១៤]

“មនុស្សឥតបើគិត គេមើលងាយប្រាជ្ញា និងសេចក្តីប្រៀនប្រដៅវិញ” (សុភាសិត ១:៧) ប៉ុន្តែវាជានិស្ស័យពិតនៃការចេះកោតខ្លាចព្រះ មានភាពចាស់ទុំ និងសុខភាពនៅក្នុងសមាជិកពួកជំនុំក្នុងការទទួលយកការណែនាំ និងការបន្ទោសដែលមានសេចក្តីស្រឡាញ់ពីបងប្អូនដទៃទៀតផងដែរ។

## ចូរទទួលខុសត្រូវដោយម៉ឺងម៉ាត់ចំពោះការដាក់វិន័យដល់អ្នកដទៃ

របៀបទី៤ ដែលយើងអាចនឹងបណ្តុះសេចក្តីប្រាថ្នាដែលមានសុខភាពល្អសម្រាប់ការដាក់វិន័យ ដែលកោតខ្លាចដល់ព្រះឲ្យបានដុះឡើង គឺយើងត្រូវទទួលខុសត្រូវដោយម៉ឺងម៉ាត់ ក្នុងការយកចិត្តទុកដាក់ដល់អ្នកដទៃនៅក្នុងរបៀបនេះ។ នេះជាឃ្លាមួយទៀតក្នុងកិច្ចសន្យាទូទៅនៃពួកជំនុំដែល

---

១៤ សូមមើលក្នុងជំពូកឧបសម្ពន្ធ៖ សេចក្តីសញ្ញាសាមញ្ញមួយនៃពួកជំនុំដែលមានសុខភាពល្អ សម្រាប់ជាគំរូ។

9Marks Online PDF

សរសេរអំពីទំនួលខុសត្រូវបែបនេះ “យើងនឹងធ្វើការជាមួយគ្នាសម្រាប់បន្តព័ន្ធកិច្ចដំណឹងល្អដ៏ស្មោះត្រង់មួយនៅក្នុងពួកជំនុំនេះ ខណៈពេលដែលយើងទ្រទ្រង់ឲ្យមានការថ្វាយបង្គំ ពិធីបង្ហូរព្រះគុណ ការដាក់វិន័យ និងគោលលទ្ធិផងដែរ”។ វាជាទំនួលខុសត្រូវមូលដ្ឋានមួយ និងជាឯកសិទ្ធិរបស់សមាជិកគ្រប់ៗរូប ក្នុងការជួយទ្រទ្រង់ការដាក់វិន័យនៅក្នុងពួកជំនុំតាមតំបន់។ នេះជាមូលហេតុដែលព្រះបន្ទូលដូចជានៅក្នុងកណ្ឌគម្ពីរម៉ាថាយជំពូក១៨ និងកូរិនថូស ខ្សែទី២ ជំពូក៥ បានលើកឡើងអំពីការដោះស្រាយអំពើបាបដែលមិនមានការប្រែចិត្ត ដោយឲ្យការសម្រេចចិត្តចុងក្រោយដល់ពួកជំនុំ។[១៥] ប៉ុន្តែ ការកែតម្រង់មិនគ្រាន់តែជាកម្មសិទ្ធិរបស់ពួកជំនុំទាំងមូលប៉ុណ្ណោះទេ វាក៏ជាការចាប់ផ្តើមពីបុគ្គលម្នាក់ៗ ដោយសកម្មក្នុងស្រឡាញ់ ហើយស្វែងរកការផ្សះផ្សាដល់អស់អ្នកដែលជាប់នៅក្នុងអំពើបាបឲ្យបានត្រឡប់មកវិញផងដែរ។[១៦]

## កុំភ្លេចមានអំណរ

វាអាចនឹងងាយក្នុងការគិតអំពីការដាក់វិន័យពួកជំនុំដោយគ្រាន់តែផ្តោតលើទុក្ខព្រួយ និងការសោកសង្រេង ដែលមកជាមួយនឹងអំពើបាប និងការបាត់បង់បងប្អូនណាម្នាក់។ ហើយទុក្ខព្រួយបែបនេះក៏មានកន្លែងរបស់វាដែរ (ម៉ាថាយ ៥:៤, ១កូរិនថូស ៥:២)។ ប៉ុន្តែ ដំណើរការទាំងមូលនៃការដាក់វិន័យ ពីកិច្ចការនៃការដាក់វិន័យសម្រាប់ការបង្ហាត់បង្រៀនព្រះបន្ទូល រហូតដល់កិច្ចការនៃការដាក់វិន័យសម្រាប់កែតម្រង់ពីពួកជំនុំ ក្នុង

---

១៥ សូមអាន ម៉ាថាយ ១៨:១៧ និង១កូរិនថូស ៥:៤-៥។

១៦ ឧទាហរណ៍៖ ម៉ាថាយ ១៨:១៥ និងកាឡាទី ៦:១។

9Marks Online PDF

ការដកសមាជិកណាម្នាក់ចេញដែលមិនបានប្រែចិត្ត គឺយើងគួរតែធ្វើឡើង ដោយមានសេចក្តីសង្ឃឹម និងគោលដៅនៃការផ្លាស់ប្រែដែលនាំទៅរកការ មានអំណរ និងការកម្សាន្តចិត្តផងដែរ (២កូរិនថូស ២:៦)។ យើងកំពុង តែព្យាយាមឲ្យបានឈ្នះ ដើម្បីឲ្យបងប្អូនយើងបានត្រឡប់មកឯសេចក្តី ពិតវិញ (យ៉ាកុប ៥:១៩-២០) ហើយនៅពេលដែលការនោះកើតឡើង គឺ យើងនឹងមានអំណរជាមួយពួកទេវតា នៅនគរឋានសួគ៌ដែរ។ ប្រហែលជា គ្មានអ្វីដែលផ្អែមល្ហែមជាងការដែលយើងកំពុងឃើញបុគ្គលណាម្នាក់ដែល ទទួលបានការបោកបញ្ឆោត ហើយកំពុងត្រូវបានបំផ្លាញចោលដោយអំពើ បាប តែបុគ្គលនេះបានមានសេរីភាពពីភាពឃុំឃាំងដ៏ឃោរឃៅរបស់អំពើ បាប ហើយគាត់បានរកឃើញសេរីភាពជាថ្មី និងការអត់ទោសរបស់ព្រះ អង្គសង្គ្រោះដ៏ពោរពេញ ដោយសេចក្តីមេត្តារបស់យើងនោះទេ។ ក្នុងនាម ជាសមាជិកពួកជំនុំដែលមានសុខភាពល្អ ដែលកំពុងតែព្យាយាមពង្រឹង ពួកជំនុំរបស់យើង គឺយើងអាចចូលរួមក្នុងការដាក់វិន័យពីពួកជំនុំដោយ មានអំណរ និងជំនឿ ដោយដឹងថាព្រះវរបិតាដ៏មានពេញដោយសេចក្តី ស្រឡាញ់ ទ្រង់កែតម្រង់អស់អ្នកដែលទ្រង់ស្រឡាញ់ ដោយព្រះហឫទ័យ ទន់សន្តោស និងស្មោះត្រង់។ នោះគឺជាសេចក្តីអំណររបស់យើងដែលមើល ឃើញពីស្នាព្រះហស្តដែលទ្រង់សម្តែងឲ្យឃើញនៅក្នុងការរីកចម្រើនឡើង ការប្រែចិត្ត និងការស្តារឡើងវិញដល់អស់អ្នកដែលទទួលបានព្រះគុណ នៃការដាក់វិន័យ។

## *សេចក្តីសន្និដ្ឋាន*

វាមិនអាចទៅរួចបានទេ ដែលសមាជិកពួកជំនុំអាចយកចិត្តទុកដាក់ចំពោះ គ្នាទៅវិញទៅមកដែលប្រកបដោយប្រសិទ្ធភាព ប្រសិនបើមានតែពីរទៅបី

នាក់ដែលមានទំនួលខុសត្រូវក្នុងការកែតម្រង់ ឬការណែនាំបងប្អូនដែលត្រូវការការដាក់វិន័យនោះ។ ប្រសិនបើសមាជិកមិនឲ្យខ្លួនឯងបានបម្រើដល់អ្នកដទៃទៀត ដោយបង្រៀនព្រះបន្ទូលនៅថ្នាក់ថ្ងៃអាទិត្យ ឬដឹកនាំក្រុមតូច ឬក៏ប្រសិនបើសមាជិកផ្តាច់ខ្លួន ដោយនៅឆ្ងាយ ហើយមិនចង់ស្គាល់គ្នាទៅវិញទៅមក ដែលការធ្វើបែបនោះនឹងនាំឲ្យមិនមានបរិបទសម្រាប់ការប្រកបគ្នាដ៏ពោរពេញដោយអត្ថន័យនោះទេ នោះជាលទ្ធផលក៏នឹងមិនមានការដាក់វិន័យសម្រាប់បង្ហាត់បង្រៀន ឬក៏ការដាក់វិន័យសម្រាប់កែតម្រង់បានឡើយ។ ព្រះដំណាក់របស់ព្រះនឹងមិនមានលំដាប់លំដោយគ្រប់គ្រាន់ទេ កូនៗរបស់ព្រះអង្គក៏នឹងទទួលបានការរៀនសូត្រតិចតួច ហើយទីបន្ទាល់នៃពួកជំនុំក៏នឹងមានភាពផុយស្រួយដោយអំពើបាប ដែលមិនបានប្រែចិត្ត និងមិនបានកែតម្រង់ផងដែរ។

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

សូមជ្រើសរើសក្រុមជាមួយមិត្តភក្តិ និងសមាជិកក្នុងពួកជំនុំ ហើយពិចារណា និងពិភាក្សាសំណួរដែលបានសួរនៅទំព័រទី ៧៧-៧៨។

## *សម្រាប់គ្រូគង្វាល*

“គ្រូគង្វាលអើយ ចូរប្រយ័ត្ន” និពន្ធដោយ៖ Nathan Wells បងប្អូនអាចទាញយកសៀវភៅនេះ ដើម្បីអានដោយឥតគិតថ្លៃនៅក្នុងគេហទំព័រ https://cambodianchristianresources.com/books/pastors-beware/

9Marks Online PDF

សញ្ញាសម្គាល់ទី៨

# សមាជិកពួកជំនុំដែលមានសុខភាពល្អគឺ ជាអ្នកដែលលូតលាស់ខាង ឯភាពជាសិស្ស

**សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជា** សមាជិកដែលកំពុងមានការរីកលូតលាស់។

វាមិនអាចទៅរួចបានទេ ក្នុងការញែកសុខភាពនៃពួកជំនុំតាមតំបន់ចេញពីសុខភាពនៃសមាជិកក្នុងពួកជំនុំនោះ។ ហើយវាក៏មិនអាចទៅរួចថែមទៀតបានដែរក្នុងការបែងចែកសុខភាពនៃសមាជិកពួកជំនុំ ចេញពីការរីកចម្រើនខាងឯវិញ្ញាណ និងភាពជាសិស្សរបស់គាត់ផងដែរ។

## *នៅពេលគ្រីស្ទបរិស័ទមិនរីកចម្រើន*

នេះគឺជាការស្មានរបស់ខ្ញុំ ប៉ុន្តែវាអាចនឹងជាករណីបញ្ហារ៉ាំរ៉ៃបំផុតដែលពួកជំនុំ និងគ្រីស្ទបរិស័ទកំពុងប្រឈម គឺការមិនការរីកចម្រើនខាងឯវិញ្ញាណជាទៀងទាត់ក្នុងភាពជាសិស្ស។ យើងទាំងអស់គ្នាស្គាល់គ្រីស្ទបរិស័ទដែលប្រកាសអំពីសេចក្ដីជំនឿរបស់ខ្លួន និងការប្រែចិត្ត ប៉ុន្តែគួរឲ្យសោកស្ដាយណាស់ព្រោះអស់អ្នកដែលប្រកាសនោះបានសារភាពថា ពួក

គាត់មិនមានការរីកចម្រើន នៅក្នុងរយៈពេលណាមួយដែរ។ ស្ថានភាពនេះមានពីរផ្សេងៗគ្នា។ មានស្ថានភាពនៅនឹងថេរបណ្ដោះអាសន្ន ឬការនៅក្នុងការជាប់ផុងខាងឯវិញ្ញាណដែលគ្រីស្ទបរិស័ទគ្រប់រូបធ្លាប់ជួបប្រទះ ហើយជាច្រើននាក់បានយកឈ្នះម្ដងហើយម្ដងទៀត។ នេះជាស្ថានភាពធម្មតា ហើយមិនធ្វើឲ្យមានសញ្ញាគ្រោះថ្នាក់ខ្លាំងទេ។ ប្រហែលត្រូវមានការផ្លាស់ប្ដូរទម្លាប់ ឬការផ្ដោតលើការកែជាថ្មី ប៉ុន្តែបញ្ហានេះមិនទាន់មានភាពរ៉ាំរ៉ៃនៅឡើយទេ។

ប៉ុន្តែ បន្ទាប់មកក៏មានស្ថានភាពដែលរ៉ាំរ៉ៃមួយដែរ។ នៅចំណុចនេះ បុគ្គលនោះអាចនឹងមិនដឹងអំពីការរីកចម្រើននៅរយៈពេលដ៏វែងមួយ។ គាត់បានធ្លាក់នៅក្នុងអ្វីមួយដែលជ្រៅជាងការជាប់ផុងមួយនោះទៀត។ ពួកគាត់មិនគ្រាន់តែនៅ "ជាប់ផុង" ហើយកំពុងខំរើឲ្យរួចប៉ុណ្ណោះទេ ប៉ុន្តែពួកគាត់បានធ្លាក់ចូលភាពងោកងុយខាងឯវិញ្ញាណមួយទៀតផងដែរ។ ប្រសិនបើពួកគាត់បានធ្លាក់ក្នុងស្ថានភាពនេះអស់រយៈពេលយូរ នោះប្រហែលជាពួកគាត់ជឿថា មិនបាច់មានការរីកចម្រើនថែមទៀតបានទេ ឬក៏ថា ការដើរតាមព្រះគ្រីស្ទគឺជារឿងរាក់ៗ ហើយមានប្រហោងក្នុងទៅវិញ។ ដូច្នេះ ពួកគាត់បានបោះបង់ការរំពឹងទុកក្នុងការរីកចម្រើនចោល។ អំនួតអាចនឹងនិយាយថា "ខ្ញុំបានទៅដល់ចំណុចកំពូលខាងឯវិញ្ញាណហើយ ហើយខ្ញុំក៏មិនចាំបាច់ត្រូវឲ្យមានការរីកចម្រើនថែមទៀតដែរ"។

កាលណាដែលការនេះកើតឡើង នោះនឹងមានសញ្ញាគ្រោះថ្នាក់ដ៏ធំដែរហើយ! នៅក្នុងពិភពបុគ្គលនិយម ឯកជននិយមខាងឯវិញ្ញាណដ៏ធំធេងរបស់យើង បញ្ហាបែបនោះគេអាចនឹងមិនកត់សម្គាល់លើទេ មិនបានលើកយកមកនិយាយ និងមិនបានកែតម្រង់អស់រយៈពេលណាមួយដែរ។

ការរីកចម្រើនខាងឯចំណេះដឹង និងលក្ខណៈដូចជាព្រះគ្រីស្ទ ពោល

គឺភាពចាស់ទុំ និងការរីកចម្រើនខាងឯព្រលឹងវិញ្ញាណ គួរជារឿងធម្មតាសម្រាប់គ្រីស្ទបរិស័ទ។ ដូច្នេះហើយបានជាកណ្ឌគម្ពីរហេព្រើរបានលើកទឹកចិត្តថា៖ "ចូរឲ្យយើងឈប់ ខាងឯសេចក្ដីបឋមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ ហើយខំឲ្យបានជឿនទៅមុខ" (ហេព្រើរ ៦:១)។ អ្នកសរសេរកណ្ឌគម្ពីរនេះបានគិតថា គ្រីស្ទបរិស័ទគួរតែមានការរីកចម្រើន "គួរឲ្យអ្នករាល់គ្នាបានធ្វើជាគ្រូ ដោយព្រោះជឿជាយូរមកហើយ" ប្ដូរពីការទទួលទាន "ទឹកដោះ" សម្រាប់កូនក្មេងដែលមិនប្រសប់មកឯ "អាហាររឹង នោះសម្រាប់តែមនុស្សធំ" វិញ (ហេព្រើរ ៥:១១-១៣)។

> ដោយនិយាយអំពីខ្លួនគាត់សាវ័ក ប៉ុល ក៏បានធ្វើជាគំរូនៃរបៀបដែលត្រូវរក្សាការបន្ទាបខ្លួន ទាក់ទងទៅនឹងការរីកចម្រើនខាងឯវិញ្ញាណ៖ មិនមែនថា ខ្ញុំបានទទួល ឬថា «ខ្ញុំបានគ្រប់លក្ខណ៍ហើយនោះទេ តែខ្ញុំកំពុងតែដេញតាម សង្ឃាតនឹងចាប់ឲ្យបានសេចក្ដីដែលព្រះគ្រីស្ទយេស៊ូវបានចាប់ខ្ញុំឲ្យបាននោះដែរ»។ បងប្អូនអើយ ខ្ញុំមិនរាប់ថា ខ្លួនខ្ញុំចាប់បានហើយនោះទេ តែមានសេចក្ដីនេះ១គឺថា «ខ្ញុំភ្លេចសេចក្ដីទាំងប៉ុន្មានដែលកន្លងទៅហើយ ក៏ខំមមុលឈោងទៅឯសេចក្ដីខាងមុខទៀត ទាំងរត់តម្រង់ទៅឯទី ដើម្បីឲ្យបានរង្វាន់នៃការងារដ៏ខ្ពស់របស់ព្រះ ក្នុងព្រះគ្រីស្ទយេស៊ូ» (ភីលីព ៣:១២-១៤)។

បន្ទាប់មក គាត់បានផ្ដល់ការលើកទឹកចិត្តនេះដល់អ្នកអានរបស់គាត់ថា "ដូច្នេះ យើងទាំងអស់គ្នាដែលគ្រប់លក្ខណ៍ហើយ យើងត្រូវមានគំនិតយ៉ាងនោះឯង" (ខ១៥)។

វាជារឿងធម្មតាដែលគ្រីស្ទបរិស័ទត្រូវតែរីកចម្រើនឡើង ត្រូវតែខិតខំប្រឹងប្រែង ដើម្បីឲ្យមានការរីកចម្រើន ហើយត្រូវរំពឹងពីការរីកចម្រើននៃភាព

9Marks Online PDF

ចាស់ទុំខាងឯវិញ្ញាណផងដែរ។ អស់អ្នកដែលធ្វើបែបនោះ គឺជាសមាជិកពួកជំនុំដែលមានសុខភាពល្អ។

## *បញ្ហានៃការគិតរបស់យើងអំពីការរីកចម្រើន*

ប៉ុន្តែ ការដែលនិយាយថា គ្រីស្ទបរិស័ទគួរតែរំពឹង ខិតខំប្រឹងប្រែង និងទទួលបានបទពិសោធន៍នៃការរីកចម្រើនឡើង មិនមែនជាចុងបញ្ចប់នៃបញ្ហាទេ។ ដើម្បីឲ្យគ្រីស្ទបរិស័ទអាចរីកចម្រើននៅក្នុងរបៀបដែលមានសុខភាពមួយ គឺយើងត្រូវតែប្រាកដឲ្យច្បាស់ថា តើការរីកចម្រើន និងការមិនមែនរីកចម្រើនជាអ្វី។ វប្បធម៌មិនស៊ីជម្រៅមួយរបស់យើងផ្តោតទៅលើសញ្ញាសម្គាល់ខាងក្រៅ ហើយធ្វេសប្រហែសនឹងភាពពិតខាងក្នុង។ យើងបារម្ភដោយសុខចិត្តទទួលយកគ្រោះថ្នាក់ ដោយគ្រាន់តែឲ្យអ្នកដទៃគិតថាយើងមានភាពចាស់ទុំ ជាជាងខំឲ្យខ្លួនពិតជាមានភាពចាស់ទុំមែន។

ការបង្រៀនរបស់ព្រះយេស៊ូវនៅក្នុងកណ្ឌគម្ពីរលូកាជំពូក៨បានជួយឲ្យយើងកំណត់បានយ៉ាងហោចណាស់នូវឥរិយាបថពីរយ៉ាង ដែលរារាំងការរីកចម្រើនដ៏រឹងមាំតាមបទគម្ពីរ និងអំពីភាពជាសិស្ស៖

ឯពួកអ្នកខ្លះដែលទុកចិត្តនឹងខ្លួនគេថា គេសុចរិត ហើយក៏មើលងាយដល់មនុស្សឯទៀតផង នោះទ្រង់មានព្រះបន្ទូលជាពាក្យប្រៀបប្រដូចនេះថា មានបុរស២នាក់ឡើងទៅអធិស្ឋានក្នុងព្រះវិហារ មួយជាពួកផារិស៊ី មួយទៀតជាអ្នកយកពន្ធ អ្នកផារិស៊ីក៏ឈរតាំងអធិស្ឋានតែម្នាក់ឯងដូច្នេះថា ឱព្រះអង្គអើយ ទូលបង្គំអរព្រះគុណដល់ទ្រង់ ព្រោះទូលបង្គំមិនដូចជាមនុស្សឯទៀត ដែលជាមនុស្សប្លន់ ទុច្ចរិត ហើយកំផិត ឬដូចជាអ្នកយកពន្ធនេះទេ ទូលបង្គំតមក្នុង១អាទិត្យ២ដង ហើយក៏ថ្វាយ១ភាគក្នុង១០ពីរបស់ទាំងអម្បាលម៉ានដែលទូលបង្គំបានចំណេញផង ឯអ្នកយកពន្ធ

9Marks Online PDF

គាត់ឈរនៅទីឆ្ងាយ មិនទាំងងើបមើលទៅលើមេឃផង ក៏គក់ដើមទ្រូង ទូលថា ឱព្រះអង្គអើយ សូមទ្រង់មេត្តាអត់ទោសដល់ទូលបង្គំ ដែលជាអ្នកមានបាបផង ខ្ញុំប្រាប់អ្នករាល់គ្នាថា កាលចុះទៅដល់ផ្ទះ អ្នកនេះបានរាប់ជាសុចរិត ជាជាងអ្នក១នោះ ដ្បិតអស់អ្នកណាដែលតម្កើងខ្លួន នោះនឹងត្រូវបន្ទាបវិញ ហើយអ្នកណាដែលបន្ទាបខ្លួន នោះនឹងបានតម្កើងឡើង (លូកា ១៨:៩-១៤)។

មានបញ្ហាបីយ៉ាងក្នុងការគិតរបស់ពួកផារិស៊ី ដែលរារាំងមិនឲ្យពួកគាត់រីកចម្រើនឡើង នៅក្នុងការកោតខ្លាចដល់ព្រះ។

១) *អន្ទាក់នៃការកំណត់តម្លៃតាមរយៈស្នាដៃ*។ នៅក្នុងកីឡាធំៗទាំងអស់ គេបានកត់ត្រាស្ថិតិសម្រាប់ការលេងរបស់កីឡាករ អត្រាដណ្តើមគូប្រកួត អត្រាបញ្ជូន អត្រាវាយចូល អត្រាទាត់បញ្ចូលទី....ជាដើម។ ជាញឹកញាប់ តម្លៃខ្លួនរបស់កីឡាករត្រូវបានកំណត់ដោយស្ថិតិទាំងនេះ។ ហើយអស់អ្នកណាដែលអាច “បំបែកស្ថិតិ” ដោយមានចំនួនច្រើន នោះគេនឹងសាទរ ហើយកត់សម្គាល់ថាជា “កីឡាករឆ្នើម” ហើយក៏ទទួលបានពានរង្វាន់ទៀតផង។

គំនិតរបស់យើងអំពីការរីកចម្រើនក្នុងភាពជាគ្រីស្ទបរិស័ទអាចរងឥទ្ធិពលដោយផ្នត់គំនិតនៃការ “បំបែកស្ថិតិ”។ សូមកត់សម្គាល់អំពីពួកផារិស៊ីដែលបាននិយាយជាមួយព្រះអំពីខ្លួនគាត់ ហើយនិងអំពីអ្វីដែលគាត់បានធ្វើ។ គាត់បានវាស់ការរីកចម្រើនដោយគោលដៅ និងគោលបំណងដែលអាចសង្កេតបានដូចជា ការតមអាហារពីរដងក្នុងមួយសប្តាហ៍ ហើយការដាក់ដង្វាយមួយភាគដប់ពីអ្វីដែលគាត់ទទួលបាន។ យើងក៏អាចមានទំនោរធ្វើដូច្នេះដែរ។ យើងផ្តោតលើចំនួនដងដែលយើងបានបំពេញក្នុង “ការចំណាយពេលស្ងៀមស្ងាត់ជាមួយព្រះ” នៅសប្តាហ៍នេះ ចំនួនដង

ដែលបានចែកចាយចំណេះដឹងគ្រីស្ទបរិស័ទដល់អ្នកដទៃទៀត ឬក៏ថាចំនួនដងដែលយើងបានផ្សាយដំណឹងល្អ។ យើងក៏អាចធ្លាក់ចូលទៅក្នុងអន្ទាក់ដែលកំណត់តម្លៃតាមរយៈស្នាដៃនោះដោយគិតថា ការលូតលាស់ខាងឯព្រលឹងវិញ្ញាណ និងភាពជាសិស្ស មើលទៅប្រៀបដូចជាការប្រព្រឹត្តដ៏ល្អៗ និងភាពជោគជ័យអញ្ចឹង។ នៅពេលការនេះកើតឡើង នោះគំនិតនៃការរីកចម្រើន និងតម្លៃរបស់យើងត្រឡប់ជាចងជាប់នឹង «ស្ថិតិ» ដែលមិនត្រឹមត្រូវវិញ។

២) ការវិនិច្ឆ័យដោយប្រើប្រាស់ខ្នាតមិនត្រឹមត្រូវ។ រឿងមួយទៀតដែលជាញឹកញាប់នាំឲ្យគ្រីស្ទបរិស័ទដើរផ្លូវខុស នៅពេលនិយាយអំពីការរីកចម្រើនឡើង នោះគឺទំនោរក្នុងការវិនិច្ឆ័យដោយប្រើប្រាស់ការប្រៀបធៀបសុខភាពរបស់យើងជាមួយនឹងអ្នកដទៃ។ គ្រីស្ទបរិស័ទជាច្រើនគឺជាមនុស្សចូលចិត្តប្រៀបធៀបនៅក្នុងរបៀបនេះឯង។ ពួកផារិស៊ីមានអំនួតនៅចំពោះព្រះថាដោយគាត់បានពោលថា «ព្រោះទូលបង្គំមិនដូចជាមនុស្សឯទៀត ដែលជាមនុស្សប្លន់ ទុច្ចរិត ហើយកំផិត ឬដូចជាអ្នកយកពន្ធនេះទេ»។ ចូរស្រមៃអំពីការនេះ! ខណៈពេលដែលកំពុងតែលុតជង្គង់អធិស្ឋាននៅចំពោះព្រះ ហើយពេលដំណាលគ្នានោះ គាត់ក៏ថ្កោលទោសហើយបរិហារបុរសដែលកំពុងអធិស្ឋាននៅក្បែរគាត់នោះ! ការប្ដេជ្ញាចិត្តទីប្រាំបីរបស់លោក ចនណាថាន អ៊ែដវើដ (Jonathan Edwards) គឺជាវិធីល្អប្រសើរជាង។ គាត់បានសរសេរថា៖

> **ខ្ញុំប្ដេជ្ញាចិត្តគ្រប់បែបយ៉ាងក្នុងការប្រព្រឹត្ត និងនិយាយ និងធ្វើប្រៀបដូចជាគ្មានអ្នកណាម្នាក់អាក្រក់ដូចជាខ្ញុំទេ ហើយដូចជាខ្ញុំបានប្រព្រឹត្តអំពើបាបដូចគ្នាដែរ ឬក៏មានភាពទន់ខ្សោយ ឬបរាជ័យដូចអ្នកដទៃ**

9Marks Online PDF

**ដែរ។ ហើយថា ខ្ញុំនឹងអនុញ្ញាតឲ្យចំណេះដឹងអំពីភាពបរាជ័យរបស់ពួកគេជំរុញឲ្យគ្មានអ្វីក្រៅពីការធ្វើឲ្យខ្ញុំខ្មាសអៀននៅក្នុងខ្លួនខ្ញុំវិញ ហើយបង្ហាញឲ្យឃើញតែឱកាសនៃការលន់តួអំពើបាបរបស់ខ្ញុំ និងទុក្ខវេទនារបស់ខ្ញុំចំពោះព្រះប៉ុណ្ណោះ។[១៧]**

ប្រសិនបើយើងផ្តោតលើអ្នកដទៃ ដើម្បីព្យាយាមរាប់ខ្លួនឯងជាសុចរិតនៅចំពោះព្រះ ឬក៏ដើម្បី «លើកតម្កើងខ្លួនឯងឡើង» ទុកជា «មនុស្សដែលមានសេចក្តីជំនឿរឹងមាំ» នោះយើងនឹងមិនត្រឹមតែមិនបានលូតលាស់រីកចម្រើនប៉ុណ្ណោះទេ តែយើងនឹងថែមទាំងបញ្ឆោតខ្លួនឯងឲ្យគិតថា យើងកំពុងតែគិតថា យើងកំពុងធ្វើល្អ ជាងអ្វីដែលយើងកំពុងមានទៀតផង។ ហើយយើងអាចនឹងប្រាកដថា ព្រះនឹងទម្លាក់យើងចុះជាមិនខាន។ ដូច្នេះវាជាការប្រសើរជាងដែលយើងត្រូវតែបន្ទាបខ្លួន ហើយទុកចិត្តក្នុងព្រះគុណព្រះ ជាជាងឲ្យព្រះតតាំងនឹងយើងដោយសារសេចក្តីអំនួតនោះវិញ (យ៉ាកុប ៤:៦; ១ពេត្រុស ៥:៥)។

៣) ការពឹងផ្អែកលើកម្លាំង ឬការខិតខំផ្ទាល់ខ្លួនក្នុងការរីកចម្រើនខាងឯវិញ្ញាណ។ នេះគឺជាកំហុសមួយទៀតរបស់ពួកផារិស៊ី។ ពួកគេផ្តោតតែលើការគិតថា អ្វីដែលជាការសរសើរនៅចំពោះព្រះគឺលទ្ធផលនៃការខិតខំ និងសមត្ថភាពរបស់ខ្លួន។ ប៉ុន្តែ ការខិតខំផ្ទាល់ខ្លួនមិនមែនជាប្រភពនៃការរីកចម្រើនខាងឯវិញ្ញាណដ៏ពិតប្រាកដនោះទេ។ បន្ទាប់ពីអ្នកសរសេរកណ្ឌគម្ពីរហេព្រើរលើកទឹកចិត្ត «ចូរឲ្យយើងឈប់ ខាងឯសេចក្តីបឋមសិក្សានៃព្រះបន្ទូលព្រះគ្រីស្ទ ហើយខំឲ្យបានជឿនទៅមុខ ដរាបដល់

---

១៧ The Works of Jonathan Edwards, ភាគ១ (Peabody, MA: Hendrickson, ឆ្នាំ១៩៩៨), ទំព័រ៦២។

9Marks Online PDF

ពេញខ្នាតចុះ» នោះគាត់ក៏បានបន្ថែមទៀតថា “ប្រសិនបើព្រះអង្គទ្រង់អនុញ្ញាតឲ្យ នោះយើងរាល់គ្នានឹងធ្វើការនោះឯង» (ហេព្រើរ ៦:១, ៣)។ ព្រះគម្ពីរបរិសុទ្ធបានប្រាប់យើងថា ការរីកចម្រើនរបស់យើងនៅក្នុងភាពជាសិស្ស និងភាពចាស់ទុំខាងឯព្រលឹងវិញ្ញាណគឺអាស្រ័យលើព្រះគុណ និងបំណងព្រះហឫទ័យរបស់ព្រះជាម្ចាស់ មិនមែនអាស្រ័យលើការខិតខំ និងកម្លាំងផ្ទាល់ខ្លួនរបស់យើងឡើយ។ នេះជាមូលហេតុដែលសាវ័កប៉ុល បានសរសើរតម្កើងដល់ព្រះជាម្ចាស់សម្រាប់ការរីកចម្រើនរបស់គ្រីស្ទបរិស័ទ (២ថែស្សាឡូនីច ១:៣) ហើយបានអធិស្ឋានដល់ព្រះអង្គសម្រាប់ការរីកចម្រើនដែលកំពុងបន្តទៅមុខទៀត (១ថែស្សាឡូនីច ៣:១១-១៣; កូឡុស ១:១០)។ ព្រះបានបង្គាប់ឲ្យយើងមានការរីកចម្រើនឡើង ហើយបណ្ដុះឲ្យមានភាពចាស់ទុំ និងការគោរពប្រតិបត្តិដល់ទ្រង់ (២ពេត្រុស ១:៥-៨, ៣:១៨) ប៉ុន្តែរាល់ការខិតខំរបស់យើងត្រូវបានអនុវត្តឡើងដោយពឹងផ្អែកលើព្រះជាម្ចាស់ ហើយដោយសេចក្ដីជំនឿលើទ្រង់សម្រាប់ការរីកចម្រើនដែលយើងកំពុងស្វែងរក។

ដូច្នេះ យើងមិនគួរមានការភាន់ច្រឡំអំពីការរីកចម្រើនតាមព្រះគម្ពីរជាមួយនឹងការប្រព្រឹត្តខាងក្រៅប៉ុណ្ណោះទេ ហើយយើងក៏មិនត្រូវវាស់វែងដោយប្រើប្រាស់អ្នកដទៃជាខ្នាតរបស់យើងដែរ ក្នុងភាពចាស់ទុំ។ ហើយចុងក្រោយ វាក៏មិនបានពឹងលើការខិតខំផ្ទាល់ខ្លួន និងការសម្រេចជោគជ័យរបស់យើងដែរ។ បើអញ្ចឹង តើអ្វីទៅជាការរីកចម្រើន? ហើយតើសមាជិកពួកជំនុំដែលមានសុខភាពល្អត្រូវប្រដេញតាមវាដោយរបៀបណា?

## *ការរីកចម្រើនដែលយើងចង់ឃើញ*

សមាជិកពួកជំនុំដែលមានសុខភាពល្អមានការព្រួយបារម្ភអំពីការរីកចម្រើនផ្ទាល់ខ្លួន និងការរីកចម្រើនរបស់អ្នកដទៃទៀតនៅក្នុងពួកជំនុំរបស់គាត់ដែរ។ លោក ម៉ាក ដិវើរ (Mark Dever) បានសរសេរយ៉ាងត្រឹមត្រូវថា "ការធ្វើការ ដើម្បីលើកកម្ពស់ភាពជាសិស្ស និងការរីកចម្រើនរបស់គ្រីស្ទបរិស័ទគឺជាការកំពុងធ្វើឡើងមិនមែន ដើម្បីនាំសិរីល្អសម្រាប់ខ្លួនឯងឡើយ ប៉ុន្តែសម្រាប់ព្រះវិញ។ នេះជារបៀបដែលព្រះជាម្ចាស់នឹងបង្ហាញអង្គទ្រង់ឲ្យពិភពលោកនេះស្គាល់"។[១៨] ដោយសារការព្រួយបារម្ភ ដើម្បីថ្វាយសិរីល្អដល់ព្រះគួរតែជាអ្វីដែលសំខាន់បំផុតនៅក្នុងជីវិតរបស់យើងដែលជាអ្នកជឿ នោះការរីកចម្រើនក៏គួរជាការព្រួយបារម្ភរបស់យើងដូចគ្នាដែរ។

មានខគម្ពីរជាច្រើនបានបង្ហាញដល់យើងអំពីការរីកចម្រើន ដែលសមាជិកពួកជំនុំដែលមានសុខភាពល្អគួរសង្ឃឹមចង់ឃើញនៅក្នុងពួកគាត់ និងអ្នកដទៃ។ ឧទាហរណ៍៖ កណ្ឌគម្ពីរ កាឡាទី ៥:២២-២៥ បានរាយចុះអំពីបញ្ជីផលផ្លែនៃព្រះវិញ្ញាណសម្រាប់យើង ដែលនោះជាគុណធម៌ និងចរិតលក្ខណៈដែលបង្កើតឡើងដោយព្រះវិញ្ញាណ។ ការនេះជាការដែលសម្គាល់ថា ពួកគាត់រស់នៅដោយមិនពឹងលើកម្លាំងខ្លួនឯង និងនិស្ស័យបាបរបស់ខ្លួននោះទេ ប៉ុន្តែពឹងលើព្រះវិញ្ញាណវិញ។ យើងត្រូវតែ "ចម្រើនឡើងក្នុងព្រះគុណ ហើយក្នុងការស្គាល់ដល់ព្រះយេស៊ូវគ្រីស្ទជាព្រះអម្ចាស់ជាព្រះអង្គសង្គ្រោះនៃយើងរាល់គ្នា សូមឲ្យទ្រង់បានសិរីល្អនៅជាន់ឥឡូវនេះ" (២ពេត្រុស ៣:១៨)។

---

១៨ លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books, ឆ្នាំ២០០៤), ទំព័រ២១៤។

9Marks Online PDF

កណ្ឌគម្ពីរ អេភេសូរ ៤:១១-១៣ បានរម្លឹកដល់យើងថា ព្រះអម្ចាស់ប្រទានមនុស្សដែលមានអំណោយទានមកពួកជំនុំក្នុងគោលបំណង ដើម្បីឲ្យមានការរីកចម្រើន «ហើយនឹងស្អាងរូបកាយព្រះគ្រីស្ទឡើង ទាល់តែយើងរាល់គ្នាបានរួបរួម ខាងឯសេចក្ដីជំនឿរួចជាស្រេច ហើយបានស្គាល់ព្រះរាជបុត្រានៃព្រះ ដូចគ្នាទាំងអស់ គឺដល់បានពេញជាមនុស្ស ហើយដល់ខ្នាតកម្ពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ»។

យើងអាចសង្ខេបជារូបភាព និងការលើកទឹកចិត្តទាំងអស់នេះមកពាក្យថាជា «ការគោរពកោតខ្លាចព្រះ» ឬក៏ «ភាពបរិសុទ្ធ»។ ការរីកចម្រើនដែលយើងចង់ឃើញ (ការរីកចម្រើនដែលមិនគ្រាន់តែខាងក្រៅ ឬរាក់ៗ) គឺជាការរីកចម្រើនក្នុងការគោរពកោតខ្លាចដល់ព្រះជាម្ចាស់ ឬក្នុងភាពបរិសុទ្ធដែលជាការរីកចម្រើនក្នុង «ខ្នាតកម្ពស់នៃសេចក្ដីពោរពេញផងព្រះគ្រីស្ទ»។ សមាជិកពួកជំនុំដែលកំពុងតែរីកចម្រើនគឺជាបុគ្គលម្នាក់ដែលមើលទៅកាន់តែមានលក្ខណៈដូចជាព្រះគ្រីស្ទនៅក្នុងឥរិយាបថនៃចិត្ត គំនិត ពាក្យសម្ដី និងសកម្មភាព។ នោះជាអ្វីដែលយើងចង់ឲ្យខ្លួនយើងក្លាយទៅជា និងពួកជំនុំរបស់យើងបានក្លាយជាបែបនោះដែរ។

## *ការរីកចម្រើនឲ្យមានលក្ខណៈដូចព្រះយេស៊ូវ*

តើសមាជិកពួកជំនុំដែលមានសុខភាពល្អបណ្ដុះការរីកចម្រើនបែបនេះបានដោយរបៀបណា? ខាងក្រោមនេះជាយោបល់សម្រាប់បន្តអភិវឌ្ឍន៍ក្នុងការគោរពកោតខ្លាចដល់ព្រះ និងភាពបរិសុទ្ធនៅក្នុងជីវិត។

9Marks Online PDF

## ចូរនៅជាប់ជាមួយព្រះគ្រីស្ទ

ព្រះយេស៊ូវបានមានបន្ទូលថា៖

> ខ្ញុំជាគល់ អ្នករាល់គ្នាជាខ្នែង អ្នកណាដែលនៅជាប់នឹងខ្ញុំ ហើយខ្ញុំជាប់នឹងអ្នកនោះ នោះទើបនឹងបង្កើតផលឡើងជាច្រើន ដ្បិតបើដាច់ពីខ្ញុំចេញ នោះអ្នករាល់គ្នាពុំអាចនឹងធ្វើអ្វីបានទេ បើអ្នកណាមិននៅជាប់នឹងខ្ញុំ អ្នកនោះត្រូវបោះចោលទៅខាងក្រៅ ហើយក៏ក្រៀមទៅដូចជាខ្នែងដែរ រួចគេប្រមូលបោះទៅក្នុងភ្លើងឆេះអស់ទៅ បើអ្នករាល់គ្នានៅជាប់នឹងខ្ញុំ ហើយពាក្យខ្ញុំនៅជាប់ក្នុងអ្នករាល់គ្នា នោះចូរសូមអ្វីតាមតែប្រាថ្នាចុះ សេចក្តីនោះនឹងបានសម្រេចដល់អ្នករាល់គ្នាជាមិនខាន ព្រះវរបិតាខ្ញុំបានតម្កើងឡើង ដោយសេចក្តីនេះឯង គឺដោយអ្នករាល់គ្នាបង្កើតផលជាច្រើន យ៉ាងនោះអ្នករាល់គ្នានឹងធ្វើជាសិស្សខ្ញុំមែន (យ៉ូហាន ១៥:៥-៨)។

ការកំពុងតែនៅជាប់នឹងដើមទំពាំងបាយជូរដ៏ពិតដែលជាព្រះគ្រីស្ទយេស៊ូវ គឺជាគន្លឹះ ដើម្បីរីកចម្រើននៅក្នុងការគោរពកោតខ្លាចព្រះ។ នៅចំណុចនេះ ការជាប់នៅក្នុងព្រះគ្រីស្ទ និងការបង្កើតផលផ្លែគឺ «គ្មានអ្វីក្រៅពីលទ្ធផលនៃការរក្សាការពឹងផ្អែកលើដើមទំពាំងបាយជូរដែលជំរុញដោយសេចក្តីជំនឿ ហើយឱបជាប់នូវគ្រប់ចំណុចទាំងអស់នៃជីវិតរបស់អ្នកជឿ និងលទ្ធផលនៃទីបន្ទាល់របស់គាត់»។១៩ ហើយការបង្កើតផលផ្លែនេះកើតចេញមកពីព្រះបន្ទូលនៃព្រះអម្ចាស់ដែលនៅជាប់នឹងសិស្សនោះ។ «ព្រះបន្ទូលទាំង

---

១៩ លោក Don Carson, The Gospel of John: An Introduction and Commentary, Pillar New Testament Commentary Series (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៩១), ទំព័រ៥១៧។

9Marks Online PDF

នោះត្រូវតែស្ថិតនៅក្នុងគំនិត និងចិត្តរបស់សិស្សនោះ។ គំនិត និងចិត្ត ដែលត្រាប់តាមព្រះគ្រីស្ទ និងស្ដាប់បង្គាប់តាមព្រះគ្រីស្ទ។ នេះគឺជារឿងដ៏ធម្មជាតិបំផុត (អធិធម្មជាតិ?) នៅក្នុងពិភពលោកនេះ»។២០ ការនៅជាប់នឹងព្រះគ្រីស្ទ ការនៅជាប់នៅក្នុងព្រះបន្ទូលរបស់ទ្រង់ គឺសំខាន់ណាស់ចំពោះភាពសំណាំជាសិស្ស និងការរីកចម្រើនរបស់គ្រីស្ទបរិស័ទ។

## ចូរប្រើប្រាស់មធ្យោបាយធម្មតានៃព្រះគុណ

មានគ្រីស្ទបរិស័ទជាច្រើនហាក់ដូចជាជឿថា ការរីកចម្រើននៅក្នុងភាពចាស់ទុំពេញវ័យខាងឯវិញ្ញាណត្រូវតែកើតឡើងដោយមានបទពិសោធន៍ពិសេសណាមួយ ឬក៏ដោយ «របកគំហើញណាមួយ»។ សម្រាប់ពួកគាត់ ការរីកចម្រើនអាចកើតឡើងបានដោយសារតែបទពិសោធន៍ពិសេសណាមួយ។ ប៉ុន្តែ ដូចដែលយើងបានឃើញស្រាប់ហើយនៅក្នុងកណ្ឌគម្ពីរយ៉ូហានជំពូក១៥បានចែងថា វាជាមធ្យោបាយធម្មតាៗនៃព្រះគុណទេ ដែលជាធម្មតានឹងបង្កើតឲ្យមានការរីកចម្រើន និងភាពចាស់ទុំ។ តាមពិតទៅ ជាញឹកញាប់អារម្មណ៍រំជើបរំជួល និងភាពមិនធម្មតាបែបនោះ នាំឲ្យមនុស្សវង្វេង តែការបង្រៀន និងការយល់ព្រះបន្ទូលត្រឹមត្រូវនឹងមិនដែលនាំឲ្យនរណាវង្វេងឡើយ។ «មធ្យោបាយធម្មតានៃព្រះគុណ» រួមមានទាំងការសិក្សាព្រះបន្ទូលព្រះ ចូលរួមនៅក្នុងពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ជាមួយនឹងពួកជំនុំ និងការអធិស្ឋានជាដើម។ ទាំងនេះជារបៀបធម្មតាដែលព្រះគុណនៃព្រះត្រូវបានប្រកាសប្រាប់ បង្ហាញឲ្យឃើញ និងប្រើប្រាស់នៅក្នុងជីវិតគ្រីស្ទបរិស័ទ។ តាមរយៈព្រះបន្ទូលព្រះជាម្ចាស់

---

២០ ក្នុងសៀវភៅដូចគ្នា។

9Marks Online PDF

នោះយើងឮអំពីការដែលព្រះគ្រីស្ទត្រូវបានបើកសម្តែង និងទទួលបានសិរីល្អ ហើយនៅទីនោះឯងដែលយើង «រៀនអំពីព្រះគ្រីស្ទ» បានយ៉ាងច្បាស់បំផុត។ ប៉ុន្តែ នៅក្នុងពិធីជ្រមុជទឹក និងពិធីលៀងព្រះអម្ចាស់ នោះយើងឃើញព្រះគ្រីស្ទ និងដំណឹងល្អនៅពេលយើងស្រមៃឃើញអំពីការសុគត ការបញ្ចុះក្នុងផ្នូរ និងការមានព្រះជន្មរស់ឡើងវិញសម្រាប់យើង និងសម្រាប់សេចក្តីសង្គ្រោះរបស់យើង។

គ្រីស្ទបរិស័ទដែលមានសុខភាពល្អនឹងមិនធ្វេសប្រហែសចំពោះពិធី និងមធ្យោបាយនៃព្រះគុណទាំងអស់នេះឡើយ ប៉ុន្តែមានសេចក្តីអំណរត្រៀមខ្លួនជាស្រេចសម្រាប់ការទាំងអស់នោះវិញ ព្រមទាំងទទួលបានការរម្លឹកតាមរយៈការគិតអំពីសិរីល្អរបស់ព្រះគ្រីស្ទ ជាព្រះអង្គសង្គ្រោះរបស់យើងផងដែរ។ គាត់នឹងចងចាំអំពីព្រះគុណនោះដែល «បង្ហាត់បង្រៀនយើងរាល់គ្នាឲ្យលះចោលសេចក្តីទមិលល្មើស និងសេចក្តីប៉ងប្រាថ្នាក្នុងលោកីយ៍នេះ ហើយឲ្យរស់នៅក្នុងសម័យនេះ ដោយសេចក្តីធូន់ធ្ងរ សេចក្តីសុចរិត ហើយដោយគោរពប្រតិបត្តិដល់ព្រះវិញ» (ទីតុស ២:១១-១២)។ គ្រីស្ទបរិស័ទដែលមានសុខភាពល្អពឹងផ្អែកលើព្រះគុណព្រះជាម្ចាស់កាន់តែច្រើនឡើងៗ នៅពេលដែលព្រះបន្ទូលបានបង្ហាញអំពីព្រះគុណនោះ និងពិធីទាំងនោះ។

## ចូលរួមនៅក្នុងពួកជំនុំតាមតំបន់

កណ្ឌគម្ពីរហេព្រើរ ១០:២៥ បានណែនាំយើងមិនឲ្យធ្វេសប្រហែសនឹងការប្រជុំគ្នានៃពួកបរិសុទ្ធឡើយ។ ផ្ទុយទៅវិញ យើងត្រូវតែជួបជុំគ្នា និងលើកទឹកចិត្តគ្នាទៅវិញទៅមកឲ្យកាន់តែច្រើនថែមទៀត ខណៈពេលដែលយើងកំពុងរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ។ ការប្រជុំជា

9Marks Online PDF

សាធារណៈគឺមានបំណង ដើម្បីស្អាងចិត្តគ្នា ការលើកទឹកចិត្ត និងការរីកចម្រើនឡើងក្នុងភាពជាគ្រីស្ទបរិស័ទ។ ការប្រហែសក្នុងការមិនចូលរួមនៅក្នុងជីវិតរួមគ្នានៃពួកជំនុំ ឬក៏មិនបម្រើអ្នកផ្សេងដោយសកម្ម និងមិនឲ្យអ្នកផ្សេងបម្រើយើង គឺជាផ្លូវដែលនឹងដាក់កំណត់ដល់ការរីកចម្រើនរបស់យើងហើយ។ កណ្ឌគម្ពីរ អេភេសូរ ៤:១១-១៦ បានផ្តល់នូវការវែកញែកដ៏ខ្លាំងក្លាមួយដែលថា ការចូលរួមនៅក្នុងរូបកាយព្រះគ្រីស្ទគឺជារបៀបដ៏សំខាន់ដែលព្រះអង្គចម្រើនកម្លាំង និងធ្វើឲ្យយើងមានភាពចាស់ទុំបាន។ នៅពេលយើងបម្រើអ្នកដទៃនៅក្នុងពួកជំនុំ ស៊ូទ្រាំជាមួយគ្នាទៅវិញទៅមក ស្រឡាញ់គ្នាទៅវិញទៅមក កែតម្រង់គ្នាទៅវិញទៅមក លើកទឹកចិត្តគ្នាទៅវិញទៅមក នោះមានន័យថាយើងចូលរួមនៅក្នុង “សហប្រតិបត្តិការពិសេស ដើម្បីភាពរីកចម្រើនខាងព្រលឹងវិញ្ញាណមួយ” ដែលជាកន្លែងស្តុកទុក និងជាកន្លែងផ្គត់ផ្គង់ដែលកាន់តែចម្រើនទ្វេគុណឡើង។ លទ្ធផលចុងក្រោយដែលការនោះបង្កើតបានគឺ ការរីកចម្រើន និងភាពជាសិស្ស។

## ចូរទន្ទឹងចាំមើលការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ

ជាចុងក្រោយ យើងរីកចម្រើនឡើងក្នុងភាពបរិសុទ្ធដោយសញ្ជឹងគិត និងទន្ទឹងរង់ចាំការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវ។ ការនិយាយសំដៅភាគច្រើននៃព្រះគម្ពីរសញ្ញាថ្មីអំពីការយាងត្រឡប់មកវិញរបស់ព្រះយេស៊ូវត្រូវបានភ្ជាប់មកជាមួយនូវការលើកទឹកចិត្តឲ្យមានភាពបរិសុទ្ធ និងភាពស្អាតស្អំ។ ឧទាហរណ៍៖ នៅក្នុងកណ្ឌគម្ពីរម៉ាថាយជំពូក២៥ នៅពេលព្រះយេស៊ូវបានបញ្ចប់ការបង្រៀនដល់ពួកសិស្សទ្រង់អំពីការយាងមកជាលើកទី២ នោះទ្រង់ក៏រួមបញ្ចូលការលើកទឹកចិត្តសាមញ្ញមួយ គឺឲ្យយើង “ចាំយាម” ឬទន្ទឹងមើលការយាងត្រឡប់មកវិញរបស់ទ្រង់ ហើយឲ្យរស់

9Marks Online PDF

នៅក្នុងជីវិតមួយដែលសមរម្យនៅក្នុងពេលដំណាលគ្នានោះដែរ។ បន្ទាប់មក កណ្ឌគម្ពីរម៉ាថាយជំពូក២៥បានលើកឡើងនូវការប្រៀបប្រដូចបី ដែលសុទ្ធតែលើកទឹកចិត្តដល់អ្នកស្ដាប់ ដើម្បីឲ្យចាំយាម ហើយមានការស្មោះត្រង់រហូតដល់ទ្រង់យាងមកវិញ។ ព្រះអម្ចាស់បានបង្រៀនថា ការយាងមកជាលើកទី២របស់ទ្រង់គឺជាអ្វីដែលយើងត្រូវសញ្ជឹងគិតឥតឈប់ឈរ ហើយការសញ្ជឹងគិតនោះគួរនាំយើងឲ្យមានការប្រុងប្រយ័ត្នក្នុងជីវិត និងការរីកចម្រើនរបស់យើងផងដែរ។

កណ្ឌគម្ពីរ ទីតុស ២:១៣-១៤ បានសំដៅលើ «សេចក្ដីសង្ឃឹមដែលមានពរ គឺឲ្យបានឃើញដំណើរលេចមកនៃសិរីល្អរបស់ព្រះដ៏ជាធំ និងព្រះយេស៊ូវជាព្រះអង្គសង្គ្រោះរបស់យើង» ដោយការពន្យល់ពីបេសកកម្មរបស់ព្រះយេស៊ូវថា៖ «ទ្រង់បានថ្វាយព្រះអង្គទ្រង់ជំនួសយើងរាល់គ្នា ដើម្បីនឹងលោះយើងឲ្យរួចពីគ្រប់ទាំងសេចក្ដីទទឹងច្បាប់ ហើយនិងសម្អាតមនុស្ស១ពួក ទុកដាច់ជារាស្ត្ររបស់ផងទ្រង់ ដែលឧស្សាហ៍ធ្វើការល្អ»។ បើនិយាយឲ្យស្រួលស្ដាប់ទៅ យើងមើលទៅឈើឆ្កាង និងការយាងត្រឡប់មកវិញរបស់ព្រះគ្រីស្ទ ហើយចងចាំថា ព្រះគ្រីស្ទបានធ្វើគ្រប់យ៉ាងសម្រាប់ការប្រោសលោះ ភាពបរិសុទ្ធ និងសេចក្ដីឧស្សាហ៍របស់យើង ហើយនោះសំដៅលើសេចក្ដីបរិសុទ្ធរបស់យើង។ សាវ័ក យ៉ូហាន ក៏បានដាក់បញ្ចូលនូវការនិយាយស្រដៀងគ្នានេះ នៅក្នុងសំបុត្រមួយរបស់គាត់ដោយសរសេរថា៖

> ពួកស្ងួនភ្ងាអើយ ឥឡូវនេះ យើងរាល់គ្នាជាកូនព្រះហើយ តែដែលយើងរាល់គ្នានឹងបានទៅជាយ៉ាងណាទៀត នោះមិនទាន់សម្ដែងមកនៅឡើយ ប៉ុន្តែយើងដឹងថា កាលណាទ្រង់លេចមក នោះយើងនឹង

9Marks Online PDF

**បានដូចជាទ្រង់ ដ្បិតដែលទ្រង់យ៉ាងណា នោះយើងនឹងឃើញទ្រង់យ៉ាងនោះឯង។ អស់អ្នកណាដែលមានសេចក្តីសង្ឃឹមយ៉ាងនេះដល់ទ្រង់ នោះក៏តែងជម្រះសម្អាតចិត្តខ្លួន ឲ្យដូចទ្រង់ដែលស្អាតដែរ (១យ៉ូហាន ៣:២-៣)។**

ការប្រាថ្នាចង់នៅជាមួយ និងចង់ឃើញព្រះយេស៊ូវគឺមានបំណងចង់ធ្វើឲ្យយើងកាន់តែដូចព្រះយេស៊ូវនៅក្នុងភាពបរិសុទ្ធ។ ការសម្លឹងទន្ទឹងរង់ចាំព្រះគ្រីស្ទនឹងបង្កើតឲ្យមានការរីកចម្រើន នៅក្នុងសមាជិកពួកជំនុំដែលមានសុខភាពល្អ។

## *សេចក្តីសន្និដ្ឋាន*

សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាសមាជិកពួកជំនុំដែលកំពុងរីកចម្រើនឡើង។ បើនិយាយឲ្យជាក់លាក់ទៅ គាត់គឺជាសមាជិកក្រុមជំនុំដែលរីកចម្រើនក្នុងភាពដូចព្រះគ្រីស្ទ ក្នុងភាពបរិសុទ្ធ និងក្នុងភាពចាស់ទុំ។ ភាពចាស់ទុំ និងភាពបរិសុទ្ធនោះកើតមានឡើងដោយពឹងផ្អែកលើព្រះគ្រីស្ទ ព្រះបន្ទូលរបស់ទ្រង់ និងអ្នកផ្សេងទៀតនៅក្នុងពួកជំនុំតាមតំបន់។ ហើយអ្វីដែលអស្ចារ្យបំផុតនោះគឺថា យើងនឹងមិនឈប់រីកចម្រើនឡើយរហូតដល់យើងឈានដល់ភាពពេញលេញរបស់ព្រះគ្រីស្ទសិន!

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. តើមានរបៀបខុសឆ្គងណាខ្លះទេដែលអ្នកបានប្រើប្រាស់សម្រាប់វាស់វែង ឬគិតអំពីការរីកចម្រើន? បើមាន តើមានអ្វីខ្លះ? តើលោកអ្នកគិតថាមានអ្វីខ្លះ ដើម្បីផ្លាស់ប្តូរការគិតរបស់ខ្លួន? តើសមាជិកពួកជំនុំផ្តល់ជំនួយអ្វីខ្លះដល់លោកអ្នកលើបញ្ហានេះ?

9Marks Online PDF

២. សូមពិភាក្សាអំពីវិធីដែលលោកអ្នកទាំងអស់គ្នាបានរីកចម្រើននាពេលថ្មីៗនេះជាមួយក្រុមមិត្តភក្តិគ្រីស្ទបរិស័ទ និងសមាជិកពួកជំនុំ។ តើតាមរបៀបណាខ្លះដែលនាំឲ្យមានសេចក្តីប្រាថ្នា និងទម្លាប់បរិសុទ្ធរីកចម្រើនឡើងដោយព្រះគុណរបស់ព្រះ?

៣. នៅពេលនេះ តើមានយុទ្ធសាស្រ្តសម្រាប់ការរីកចម្រើនខាងឯវិញ្ញាណណាខ្លះដែលលោកអ្នកត្រូវការចាំបាច់បំផុត ក្នុងជីវិតរបស់លោកអ្នក? តើលោកអ្នកនឹងធ្វើតាមវិធានការទាំងនោះដោយរបៀបណា?

## *សម្រាប់ការអានបន្ថែម*

លោកគ្រូ John Piper "កុំឲ្យខ្ជះខ្ជាយជីវិតរបស់អ្នកឡើយ" បោះពុម្ពដោយអង្គការសកម្មភាពកម្ពុជា។

9Marks Online PDF

សញ្ញាសម្គាល់ទី៩

# សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នកដែលដើរតាមព្រះដោយចេះបន្ទាបខ្លួន

**សុខភាពរបស់**ពួកជំនុំតាមតំបន់អាចពឹងផ្អែកទាំងស្រុងទៅលើការឆ្លើយតបរបស់សមាជិកភាពចំពោះការដឹកនាំរបស់ពួកជំនុំ។ របៀបដែលក្រុមជំនុំទទួលយក ឬបដិសេធអ្នកដឹកនាំរបស់ខ្លួនមានឥទ្ធិពលផ្ទាល់ ទៅលើលទ្ធភាពនៃព័ន្ធកិច្ចដ៏ស្មោះត្រង់ និងសុខភាពរបស់ពួកជំនុំ។ តើពួកជំនុំពេញចិត្ត ហើយទទួលយកការអធិប្បាយព្រះបន្ទូលត្រឹមត្រូវដែរឬទេ? តើសមាជិកពួកជំនុំនឹងទុកចិត្ត ហើយដើរតាមអ្នកដឹកនាំ ទោះបីស្ថិតនៅក្នុងស្ថានភាពមិនច្បាស់លាស់ ឬលំបាកៗដែរឬទេ? តើពួកគេប្រមូលផ្តុំគ្នានៅពីក្រោយ ឬបំបាក់បំបែកភាពជាអ្នកដឹកនាំនៅពេលដែលផែនការ និងគំនិតនានាត្រូវបានបរាជ័យដែរឬទេ?

នៅក្នុងការវិភាគចុងក្រោយ ជាទូទៅ សមាជិកពួកជំនុំគឺជាមនុស្សដែលបង្កើត ឬបំបែកពួកជំនុំតាមតំបន់។ ហើយការបង្កើត ឬបំបែកពួកជំនុំនោះច្រើនតែទាក់ទងនឹងអាកប្បកិរិយា និងសកម្មភាពរបស់សមាជិកភាព

9Marks Online PDF

ចំពោះអ្នកដឹកនាំរបស់ខ្លួន។

ដូច្នេះ បើគ្មានការព្យាយាមកំណត់និយមន័យលើសមាជិកពួកជំនុំដែលមានសុខភាពល្អទេ ដែលនោះអាចនឹងមានការធ្វេសប្រហែសក្នុងការឆ្លុះបញ្ចាំងអំពីទំនាក់ទំនងរវាងសមាជិកក្រុមជំនុំ និងអ្នកដឹកនាំ។ ហើយមិនគួរឲ្យភ្ញាក់ផ្អើលទេ ព្រះបន្ទូលដែលបញ្ចេញដោយព្រះវិញ្ញាណនេះក៏បានផ្ដល់ការណែនាំយ៉ាងច្រើន ទាក់ទងនឹងអាកប្បកិរិយា និងសកម្មភាពរបស់សមាជិកដែលមានបំណងចូលរួមចំណែកដល់សុខភាពពួកជំនុំតាមតំបន់របស់ខ្លួន ដោយធ្វើតាមការដឹកនាំរបស់ពួកជំនុំ។

## *អាកប្បកិរិយារបស់សមាជិកពួកជំនុំដែលមានសុខភាពល្អចំពោះអ្នកដឹកនាំ*

មានយ៉ាងហោចណាស់ អាកប្បកិរិយាបីយ៉ាងដែលបង្ហាញអំពីលក្ខណៈរបស់សមាជិកក្រុមជំនុំដែលមានសុខភាពល្អ នៅពេលនិយាយអំពីការធ្វើតាមអ្នកដឹកនាំក្រុមជំនុំតាមតំបន់។

១) *គោរពអ្នកចាស់ទុំ។* មានបទគម្ពីរជាច្រើនបានណែនាំសមាជិកក្រុមជំនុំឲ្យគោរពអ្នកចាស់ទុំ និងអ្នកដឹកនាំក្រុមជំនុំ។ ឧទាហរណ៍៖ កណ្ឌគម្ពីរ ១ធីម៉ូថេ ៥:១៧ បានប្រាប់យើងថា “អ្នកចាស់ទុំណាដែលជាអ្នកនាំមុខយ៉ាងល្អ នោះត្រូវរាប់ជាគួរនឹងគោរពប្រតិបត្តិជាទ្វេគុណឡើង គឺមានពួកដែលខំផ្សាយព្រះបន្ទូល ហើយនិងពួកដែលបង្រៀនជាដើម”។ តើកិត្តិយសទ្វេដងនេះរួមបញ្ចូលអ្វីខ្លះ? សាវ័ក ប៉ុល បានទាញចំណាប់អារម្មណ៍ចំពោះរឿងពីរយ៉ាងនេះនៅក្នុងខគម្ពីរបន្តបន្ទាប់។ នៅក្នុងខ១៨ ការផ្ដល់កិត្តិយសដល់ពួកអ្នកចាស់ទុំរួមមានការមើលថែទាំងតម្រូវការផ្នែកហិរញ្ញវត្ថុ និងទាំងតម្រូវការខាងរូបកាយរបស់ពួកគាត់។ ពួកជំនុំ និង

9Marks Online PDF

សមាជិកដែលគោរពអ្នកដឹកនាំរបស់ខ្លួននឹងផ្ដល់ប្រាក់ឈ្នួលសមរម្យ ហើយគ្រប់គ្រាន់សម្រាប់អ្នកដឹកនាំរបស់ខ្លួន ជាពិសេសចំពោះអស់អ្នកដែលធ្វើការពេញម៉ោង ក្នុងព័ន្ធកិច្ចនេះ។

នៅក្នុងខ១៩ សាវ័ក ប៉ុល បានបង្ហាញថា ការគោរពអ្នកដឹកនាំរបស់យើងក៏រួមមានបញ្ចូលទាំងការការពារកេរ្ដិ៍ឈ្មោះរបស់ពួកគាត់ផងដែរ។ យើងមិនត្រូវ «ស្ដាប់សេចក្ដីចោទប្រកាន់នឹងអ្នកចាស់ទុំណាឡើយ លើកតែមានស្មរបន្ទាល់២ ឬ៣នាក់»។ សាវ័ក ប៉ុល បានយល់យ៉ាងច្បាស់ជាងអ្នកណាៗទាំងអស់ អំពីរបៀបដែលព័ន្ធកិច្ចងាយបើកចំហយ៉ាងណាដល់ការចោទប្រកាន់ ការរិះគន់ និងការត្អូញត្អែរពីខាងក្រៅ និងក្នុងក្រុមជំនុំ។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងជួយការពារគ្រូគង្វាលពីខ្សែដង្ហក់ និងគ្រាប់ព្រួញនានា។ ពាក្យចចាមអារ៉ាម និងការនិយាយដើមត្រូវតែស្លាប់នៅត្រឹមត្រចៀករបស់សមាជិកពួកជំនុំដែលមានសុខភាពល្អ ដែលមិនព្រមពិចារណាលើរឿងរ៉ាវដែលមិនមានការបញ្ជាក់ច្បាស់លាស់ ឬភស្ដុតាងនោះទេ។

សមាជិកពួកជំនុំដែលមានសុខភាពល្អគោរពដល់តួនាទីរបស់អ្នកចាស់ទុំ។ គាត់ឲ្យតម្លៃខ្ពស់លើតួនាទីនេះ គាត់ដឹងគុណ និងគោរពអស់អ្នកដែលបម្រើរាស្ត្ររបស់ព្រះអម្ចាស់ក្នុងនាមជាចាស់ទុំ។ យើងគោរពគ្រូគង្វាលរបស់យើង ពីព្រោះនៅថ្ងៃនៃព្រះអម្ចាស់ ពួកគាត់នឹងក្លាយជាទីអំនួតរបស់យើង (២កូរិនថូស ១:១៤)។

២) *សូមបង្ហាញសេចក្ដីស្រឡាញ់ដោយបើកចិត្តទូលាយចំពោះអ្នកដឹកនាំ។* ការគោរព និងកិត្តិយសដែលសមាជិកផ្ដល់ឲ្យអ្នកចាស់ទុំ មិនមែនជាកិត្តិយសដែលមានគម្លាត និងជាកិត្តិយសផ្លូវការ បែបដូចជាទាហានម្នាក់ផ្ដល់ឲ្យមេបញ្ជាការនោះទេ។ កិត្តិយសទ្វេដងដែលអ្នកគង្វាល

9Marks Online PDF

គួរទទួលនោះគឺសេចក្តីស្រឡាញ់ដែលបើកចិត្តទូលាយ។ ម្តងហើយម្តងទៀតសាវ័ក ប៉ុល បានប្រាប់ឲ្យក្រុមជំនុំនៅក្រុងកូរិនថូសបើកចិត្តដល់គាត់ក្នុងនាមជាអ្នកដែលមើលថែពួកគេខាងឯវិញ្ញាណៈ

> ឱពួកកូរិនថូសអើយ មាត់យើងខ្ញុំបើកចំពោះអ្នករាល់គ្នាហើយ ចិត្តយើងខ្ញុំបានទូលាយឡើង។ អ្នករាល់គ្នាមិនចង្អៀតក្នុងយើងខ្ញុំទេ គឺចង្អៀតតែក្នុងចិត្តរបស់អ្នករាល់គ្នាវិញ។ ខ្ញុំនិយាយនឹងអ្នករាល់គ្នាទុកដូចជាដល់កូនថា ចូរសងដូចគ្នាវិញ ដោយបើកចិត្តឲ្យទូលាយឡើងដូច្នោះដែរ (២កូរិនថូស ៦:១១-១៣)។

គួរតែមានការផ្តល់ឲ្យគ្នាទៅវិញទៅមកដ៏ផ្អែមល្ហែមនៃសេចក្តីស្រឡាញ់រវាងគ្រូគង្វាល និងពួកជំនុំ។ នៅពេលដែលពួកគាត់រស់នៅ រីកចម្រើន និងធ្វើការជាមួយគ្នា នោះដួងចិត្តរបស់ពួកគាត់ត្រូវតែបើកឲ្យកាន់តែទូលំទូលាយដល់គ្នាទៅវិញទៅមកថែមទៀត។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងមិន «ក្តាប់ជាប់» សេចក្តីស្រឡាញ់របស់គាត់ពីគ្រូគង្វាលទេ ផ្ទុយទៅវិញគាត់ផ្តល់សេចក្តីស្រឡាញ់នោះឲ្យដោយសេរី និងមិនបង្ខំឡើយ។

សមាជិកពួកជំនុំដែលមានសុខភាពល្អមិនចង់ឮគ្រូគង្វាលដ៏ស្មោះត្រង់របស់គាត់អង្វរគាត់ ដូចដែលសាវ័ក ប៉ុល បានធ្វើជាមួយពួកជំនុំនៅទីក្រុងកូរិនថូសទេ៖ «ចូរទទួលយើងខ្ញុំ យើងខ្ញុំមិនបានធ្វើខុសនឹងអ្នកណាក៏មិនបានបង្ខូចអ្នកណា ឬបំបាត់អ្នកណាសោះឡើយ។ ខ្ញុំនិយាយដូច្នេះមិនមែនចង់ប្រកាន់ទោសដល់អ្នកណាទេ ដ្បិតខ្ញុំបាននិយាយអំពីមុនរួចហើយថា អ្នករាល់គ្នានៅក្នុងចិត្តយើងខ្ញុំ ឲ្យបានស្លាប់ឬរស់ជាមួយគ្នា»

9Marks Online PDF

(២កូរិនថូស ៧:២-៣)។

ចំពោះសមាជិកពួកជំនុំដែលមានសុខភាពល្អ ដំបូងគាត់នឹងថ្វាយខ្លួនទៅព្រះអម្ចាស់ ហើយបន្ទាប់មក គាត់នឹងបម្រើព្រះអម្ចាស់ដោយដឹងថា នេះជាព្រះហឫទ័យរបស់ទ្រង់ (២កូរិនថូស ៨:៥)។ សមាជិកបែបនេះនឹងមើលឃើញអំពីរបៀបដែលគ្រូគង្វាលដ៏ស្មោះត្រង់នឹងចំណាយពេលរបស់គាត់សម្រាប់រូបកាយនោះ ដោយសេចក្ដីស្រឡាញ់។ ហើយគាត់នឹងមានសេចក្ដីខ្មាសអៀន នៅពេលឮគ្រូគង្វាលសួរថា «ថ្វីបើខ្ញុំស្រឡាញ់អ្នករាល់គ្នាកាន់តែខ្លាំងឡើងប៉ុណ្ណា នោះអ្នករាល់គ្នាស្រឡាញ់ខ្ញុំ ក៏កាន់តែថយចុះប៉ុណ្ណោះដែរ?» (២កូរិនថូស ១២:១៥)។ សេចក្ដីស្រឡាញ់តែម្ខាងបែបនេះស័ក្ដិសមតែសម្រាប់ល្ខោនសោកនាដកម្មរបស់សេកស្ពារ (Shakespearean tragedy) តែមិនមែនសម្រាប់ពួកជំនុំតាមតំបន់ទេ។ សេចក្ដីរីករាយ និងសេចក្ដីស្រឡាញ់របស់យើងចំពោះគ្រូគង្វាលរបស់យើងគួរតែ «លំហែចិត្ត [ពួកគាត់] ក្នុងព្រះគ្រីស្ទផង» (ភីលេម៉ូន ២០)។

៣. *អាចបង្រៀនបាន។* សមាជិកពួកជំនុំដែលមានសុខភាពល្អក៏គួរតែមានចិត្តដែលអាចទទួលការបង្រៀនបានដែរ។ ចិត្តដែលអាចទទួលការបង្រៀនបានបង្ហាញថាគាត់ជាមនុស្សរាបទាប និងបំណងប្រាថ្នា ដើម្បីរីកចម្រើនក្នុងព្រះគ្រីស្ទ។ បើគ្មានចិត្តបែបនោះទេ នោះមានន័យថា គេជាមនុស្សមានក្បាលរឹង ចចេសមានៈ និងមិនអាចកែបានឡើយ។

ការងាររបស់អ្នកដឹកនាំអាចនឹងត្រូវបានបង្រួមមកត្រឹមតែកិច្ចការមួយៈ ការបង្រៀន។ ប្រសិនបើសមាជិក ឬផ្នែកធំណាមួយនៃសមាជិកបង្ហាញថា មិនអាចទទួលការបង្រៀនបាន នោះកិច្ចការរបស់គ្រូគង្វាលនឹងក្លាយជាបន្ទុក ឬមិនអាចធ្វើបានផងក៏ថាបាន ព្រោះការដែលមានចិត្តមិនអាចទទួលការបង្រៀនបាននេះកំពុងតែប្រឆាំងនឹងគាត់ នៅចំណុចចម្បងបំផុត

9Marks Online PDF

នៃកិច្ចការរបស់គាត់។ ពេលសាវ័ក ប៉ុល បានសរសេរទៅកាន់លោក ធីម៉ូថេ ហើយគាត់ក៏បានផ្តល់នូវការណែនាំដ៏អស្ចារ្យសម្រាប់គ្រូគង្វាល ឲ្យមានការណែនាំដ៏ល្អសម្រាប់សមាជិកផងដែរ។ សាវ័ក ប៉ុល បានសរសេរអំពីតួនាទីរបស់ពួកចាស់ទុំថា៖

> **ក៏មិនគួរឲ្យបាវបម្រើនៃព្រះអម្ចាស់ឈ្លោះប្រកែកគ្នាឡើយ គួរឲ្យបានចិត្តសុភាពរាបសាដល់មនុស្សទាំងអស់វិញ ត្រូវ ប្រសប់ក្នុងការបង្រៀន ទាំងមានចិត្តអត់ធ្មត់ផង។ ត្រូវប្រដៅតម្រង់មនុស្សដែលទទឹងទទែង ដោយមានចិត្តសុភាព ក្រែងព្រះទ្រង់នឹង បណ្តាលឲ្យគេប្រែចិត្ត ឲ្យបានស្គាល់សេចក្តីពិតវិញ។ ហើយគេនឹងភ្ញាក់ដឹងខ្លួនឡើង ចេញផុតពីអន្ទាក់របស់អារក្ស ដែលវាបានចាប់គេប្រើតាមចិត្តនោះ**
>
> **(២ធីម៉ូថេ ២:២៤-២៦)។**

មានអត្ថប្រយោជន៍ជាច្រើនចេញពីបទគម្ពីរនេះសម្រាប់ឲ្យសមាជិកពួកជំនុំសង្កេតមើល ។ ទីមួយ គ្រូគង្វាលត្រូវតែមានការណែនាំបែបជាមនុស្សស្លូតបូត សប្បុរស និងដើម្បីជាប្រយោជន៍ដល់យើង។ យើងមិនគួរប្រើប្រាស់ការនេះដោយទាញយកប្រយោជន៍ពេញលេញពីអត្តចរិតដែលព្រះបានតែងតាំងនេះទេ។ ផ្ទុយទៅវិញ យើងគួរទទួលយកការណែនាំបែបនោះទុកជាការដាស់តឿន និងការត្រាស់ហៅឲ្យប្រែចិត្តវិញ។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងមិនច្រឡំសេចក្តីសប្បុរសដែលចេះកោតខ្លាចព្រះថាជាសេចក្តីកម្សោយនៅក្នុងគ្រូគង្វាលនោះទេ ប៉ុន្តែគាត់នឹងប្រើប្រាស់ឱកាសនេះ ដើម្បីពិនិត្យមើលដួងចិត្តខ្លួនឯងម្នាក់ៗផ្ទាល់ សម្រាប់ចំណុចដែលត្រូវមានការប្រែចិត្តវិញ។

ទីពីរ យើងគួរទទួលស្គាល់ថា វាងាយស្រួលណាស់ក្នុងការដែល

យើង “ប្រឆាំងនឹង” គ្រូគង្វាលនៅពេលគាត់ណែនាំយើង។ ជាផ្នែកមួយទូទៅនៃជីវិតខាងឯព្រលឹងវិញ្ញាណយើង យើងគួរសួរខ្លួនឯងថា “តើខ្ញុំមានការប្រឆាំងនឹងការបង្រៀនរបស់គ្រូគង្វាលក្នុងរបៀបណាមួយដែរឬទេ? ទីបី យើងគួរតែអធិស្ឋានសុំចំណេះដឹងអំពីសេចក្ដីពិត គំនិតច្បាស់លាស់ និងការការពារពីផែនការរបស់អារក្ស នៅពេលណាដែលយើងរកឃើញស្នូលនៃការប្រឆាំងដល់ការបង្រៀនរបស់គ្រូគង្វាល។ គ្រូគង្វាលមើលថែរក្សាព្រលឹងរបស់យើង គាត់ជាបុរសដែលត្រូវរៀបរាប់ប្រាប់ដល់ព្រះ។ ហេតុដូច្នេះហើយបានជាយើងគួរតែទុកចិត្ត និងទទួលយកការដឹកនាំរបស់ពួកគាត់ដោយអំណរ ទុកជាអំណោយមកពីព្រះជាម្ចាស់ សម្រាប់ជាប្រយោជន៍ដ៏អស់កល្បរបស់យើង។ យើងត្រូវចេះបើកចិត្តទទួលយកការបង្រៀនចុះ។

## *សកម្មភាពរបស់សមាជិកពួកជំនុំដែលមានសុខភាពល្អចំពោះការដឹកនាំ*

ក្រៅពីអត្តចរិត ឬអាកប្បកិរិយាជាមូលដ្ឋានទាំងនេះ ក៏នៅមានសកម្មភាពជាក់លាក់មួយចំនួនទៀតដែលសមាជិកពួកជំនុំដែលមានសុខភាពល្អនឹងប្រព្រឹត្ត ដើម្បីធ្វើតាមការដឹកនាំរបស់ពួកជំនុំតាមតំបន់ប្រកបដោយប្រសិទ្ធភាព។

## ចូលរួមដោយអត់ធ្មត់ក្នុងការជ្រើសរើសអ្នកដឹកនាំ

ការសម្រេចចិត្តដ៏សំខាន់បំផុតដែលពួកជំនុំធ្វើ (ឧបមាថា មានគោលការណ៍ពួកជំនុំ) ប្រហែលគឺជាការជ្រើសរើសអ្នកដឹកនាំរបស់ខ្លួន។ តាមរយៈការជ្រើសរើសអ្នកដឹកនាំ នោះពួកជំនុំនឹងកំណត់សម្លេងខាងឯវិញ្ញាណ និងទិសដៅខ្លួន ជូនកាលសម្រាប់រយៈពេលជាច្រើនជំនាន់ទៀត

9Marks Online PDF

ក៏ថាបាន។ ប្រហែលនេះហើយជាមូលហេតុដែលពួកសាវ័កបានណែនាំដល់ពួកជំនុំដំបូងឲ្យស្វែងរកគុណសម្បត្តិខាងឯវិញ្ញាណ និងភាពចាស់ទុំក្នុងអ្នកដឹកនាំខ្លួន (កិច្ចការ ៦:១-៦; ១ធីម៉ូថេ ៣)។ យើងត្រូវធ្វើការជ្រើសរើសអ្នកដឹកនាំឡើងដោយមានការអត់ធ្មត់ និងការពិចារណាដោយការអធិស្ឋាន។ សាវ័ក ប៉ុល បានណែនាំដល់លោក ធីម៉ូថេ ថាៈ «កុំឲ្យប្រញាប់ដាក់ដៃលើអ្នកណា» ឡើយ (១ធីម៉ូថេ ៥:២២ក)។ អ្នកជំនួយព្រះវិហារដំបូងត្រូវ «ពេញជាព្រះវិញ្ញាណបរិសុទ្ធ និងប្រាជ្ញា» (កិច្ចការ ៦:៣)។ ការយល់ដឹងអំពីគុណសម្បត្តិទាំងនេះតម្រូវឲ្យមានការអធិស្ឋាន ការសង្កេតមើល និងការអត់ធ្មត់។ ហើយប្រសិនបើពួកជំនុំរបស់ព្រះអម្ចាស់នឹងមានសុខភាពល្អ នោះសមាជិកត្រូវតែយក និងតែងតាំងអ្នកដឹកនាំដែលមានគំនិតខាងឯវិញ្ញាណ និងមានភាពចាស់ទុំនៅក្នុងព្រះគ្រីស្ទ។

សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងមិនមើលរំលងសារៈសំខាន់នៃកិច្ចការដ៏សំខាន់នេះទេ។ ពួកគាត់អាចអញ្ជើញអ្នកដឹកនាំអនាគត និងក្រុមគ្រួសាររបស់គាត់មកទទួលទានអាហារថ្ងៃត្រង់ ឬអាហារពេលល្ងាច ដើម្បីឲ្យស្គាល់គាត់កាន់តែច្បាស់ថែមទៀតផង។ ពួកគាត់នឹងចង់ឮបន្ថែមទៀតអំពីទីបន្ទាល់របស់បុរសនោះ អំពីបំណងប្រាថ្នារបស់គាត់ ក្នុងការបម្រើក្នុងសមត្ថភាពជាអ្នកដឹកនាំ និងអំពីការបម្រើពីមុនៗរបស់គាត់នៅក្នុងព្រះវិហារនានា។ ព្រះវិហារខ្លះទុកពេលពីរខែ រវាងការតែងតាំងបុរសម្នាក់សម្រាប់ការដឹកនាំ និងការបោះឆ្នោតពិតប្រាកដ ដើម្បីឲ្យសមាជិកចូលរួមយ៉ាងជាក់លាក់តាមវិធីមួយនេះបាន។

## ចូរស្ដាប់បង្គាប់ និងចុះចូលចំពោះអ្នកដឹកនាំ

នេះជាហេតុផលដ៏ល្អក្នុងការចូលរួមពេញដោយការអធិស្ឋាន និងដោយ

9Marks Online PDF

អត់ធ្មត់ ក្នុងការទទួលស្គាល់អ្នកដឹកនាំពួកជំនុំ៖ សមាជិកពួកជំនុំដែលមានសុខភាពល្អត្រូវតែស្តាប់តាម និងចុះចូលចំពោះអ្នកដឹកនាំរបស់ខ្លួន។ គេបានចាត់ទុកពាក្យ ស្តាប់បង្គាប់ និងចុះចូល មិនត្រឹមតែថាជា “ពាក្យអាក្រក់ៗ” នៅក្នុងពិធីមង្គលការប៉ុណ្ណោះទេ វាក៏ជាពាក្យពាក្យមិនល្អចំពោះសមាជិកពួកជំនុំជាច្រើនដែរ។ ប៉ុន្តែ ព្រះគម្ពីរមិនអាចបញ្ជាក់ច្បាស់ជាងនេះទៀតទេថា៖ “ចូរស្តាប់តាម ហើយចុះចូលនឹងពួកអ្នក ដែលនាំមុខអ្នករាល់គ្នាចុះ” (ហេព្រើរ ១៣:១៧)។ ការស្តាប់បង្គាប់របស់យើងគឺ ដើម្បីធ្វើឲ្យការងាររបស់ពួកគាត់មានអំណរ មិនមែនជាបន្ទុកឡើយ។ ហើយការស្តាប់បង្គាប់របស់យើងប្រគល់មកវិញនូវអត្ថប្រយោជន៍ដល់យើង ពីព្រោះវានឹងគ្មានប្រយោជន៍អ្វីសម្រាប់យើងទេ ក្នុងការហៅពួកគាត់ឲ្យធ្វើជាអ្នកដឹកនាំ ហើយបន្ទាប់មកមិនស្តាប់បង្គាប់តាមពួកគាត់នោះ។ សមាជិកពួកជំនុំដែលមានសុខភាពល្អដាក់ខ្លួនឯងនៅក្រោមអ្នកដឹកនាំពួកជំនុំដូចដែលទាហានម្នាក់ដាក់ឋានៈ និងការស្តាប់បង្គាប់របស់គាត់នៅក្រោមឧត្តមសេនីយ៍យោធាម្នាក់យ៉ាងដូច្នោះដែរ។ យើងត្រូវតែចុះចូលដោយអំណរយ៉ាងក្លៀវក្លា និងពេញទំហឹងចំពោះអ្នកដឹកនាំរបស់យើង ដើម្បីជាសេចក្តីល្អរបស់យើង សេចក្តីល្អរបស់ពួកគាត់ និងសេចក្តីល្អនៃរូបកាយទាំងមូលផងដែរ។

## ចូរយកគំរូតាមអ្នកដឹកនាំ

ហេតុផលមួយ ដែលព្រះអម្ចាស់តែងតាំងពួកបុរសៗឲ្យធ្វើជាអ្នកដឹកនាំក្នុងពួកជំនុំគឺ ដើម្បីផ្តល់ជាគំរូជាក់លាក់ ដែលពួកជំនុំអាចមើលឃើញបាន ក្នុងការរស់នៅប្រកបដោយភាពស្មោះត្រង់ និងគោរពកោតខ្លាចព្រះ។ អ្នកដឹកនាំរបស់យើងគឺប្រៀបដូចជា “រូបភាពចលនា” នៃការដើរតាមព្រះ

យេស៊ូវ។ ព្រះបានត្រាស់ហៅពួកគាត់ឲ្យធ្វើជាគំរូគ្រប់យ៉ាង (១ធីម៉ូថេ ៤:១២; ១ពេត្រុស ៥:៣)។ ហេតុដូច្នេះហើយបានជាសាវ័ក ប៉ុល លើកឡើងថា «បងប្អូនអើយ ចូរត្រាប់តាមខ្ញុំគ្រប់គ្នា ហើយពិចារណាមើលឲ្យស្គាល់ពួកអ្នក ដែលដើរដូចជាយើងខ្ញុំបានធ្វើក្បួនឲ្យអ្នករាល់គ្នាហើយ» (ភីលីព ៣:១៧)។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងយកគំរូតាមជីវិតរបស់អ្នកដឹកនាំ គឺតាមរបៀបរស់នៅរបស់ពួកចាស់ទុំដែលគោរពកោតខ្លាចព្រះក្នុងពួកជំនុំ។ យើងត្រូវយកគំរូតាមអ្នកដឹកនាំរបស់យើង ដោយរំពឹងថា យើងនឹងមានលក្ខណៈដូចព្រះគ្រីស្ទ។

សម្រាប់មនុស្សជាច្រើននៅជំនាន់របស់យើងនេះ គំនិតនៃការត្រាប់តាមនេះមានលក្ខណៈដូចជាការដើរតាមក្រុមខុសឆ្គង។ មនុស្សជាច្រើននៅសម័យនេះគិតថា ការត្រាប់តាមនេះ ស្តាប់ទៅដូចជាទំនៀមទម្លាប់ដែលគេត្រាប់តាមគ្រប់ទាំងសេចក្តីដែលគ្រូគង្វាលល្បីៗបែបជាបុគ្គលក្នុងការនិយាយ ឬធ្វើ។ វាជាការត្រឹមត្រូវហើយដែលយើងមានការព្រួយបារម្ភអំពីការត្រាប់តាមគំរូ និងការណែនាំដែលមិនត្រាប់តាមព្រះគម្ពីរបែបនេះ។ ប៉ុន្តែ រូបភាពរបស់ព្រះគម្ពីរនៃការយកគំរូតាមគ្រូគង្វាល ចង្អុលទៅកាន់ការគោរពកោតខ្លាចព្រះជាម្ចាស់ដ៏ពិតប្រាកដ «ដោយពាក្យសម្តី កិរិយាប្រព្រឹត្ត សេចក្តីស្រឡាញ់ សេចក្តីជំនឿ និងសេចក្តីបរិសុទ្ធ» (១ធីម៉ូថេ ៤:១២) ដោយធ្វើនូវអ្វីដែលល្អ (ទីតុស ២:៧)។ ព្រះជាម្ចាស់បានត្រាស់ហៅគ្រូគង្វាលឲ្យធ្វើជាគំរូបែបនេះ ហើយសមាជិកពួកជំនុំដែលមានសុខភាពល្អត្រូវយកគំរូតាមភាពបរិសុទ្ធរបស់ពួកគាត់ដោយប្រាជ្ញាដែរ។

## ចូរអធិស្ឋានសម្រាប់អ្នកដឹកនាំ

ដោយពិចារណាអំពីគ្រប់កិច្ចការទាំងអស់ ដែលអ្នកដឹកនាំត្រូវធ្វើ

9Marks Online PDF

ហើយតស៊ូជាមួយ តើលោកអ្នកអាចគិតអំពីរឿងសំខាន់មួយទៀត ដែលត្រូវធ្វើខ្លាំងជាងការអធិស្ឋានសម្រាប់ពួកគាត់បានដែរឬទេ? សូម្បីតែសាវ័កប៉ុល ក៏បានយល់អំពីតម្រូវការរបស់គាត់ផងដែរគឺការអធិស្ឋានដ៏ស្មោះត្រង់របស់ពួកបរិសុទ្ធ៖

> **ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន ទាំងចាំយាមក្នុងសេចក្តីនោះឯងដោយពាក្យអរព្រះគុណ ព្រមទាំងអធិស្ឋានឲ្យយើងខ្ញុំផង ដើម្បីឲ្យព្រះបានបើកទ្វារឲ្យយើងខ្ញុំផ្សាយព្រះបន្ទូល ជាសេចក្តីអាថ៌កំបាំងនៃព្រះគ្រីស្ទ ដែលខ្ញុំជាប់ចំណង ដោយព្រោះព្រះបន្ទូលនោះឯង ប្រយោជន៍ឲ្យខ្ញុំបានសម្តែងព្រះបន្ទូលតាមដែលគួរគប្បី (កូឡូស ៤:២-៤; សូមមើល អេភេសូរ ៦:១៩-២០ ផងដែរ)។**

យើងគួរអធិស្ឋានសុំភាពក្លាហាន ភាពច្បាស់លាស់ និងភាពស៊ីសង្វាក់គ្នាជាមួយនឹងព្រះរាជសារនៃដំណឹងល្អ សម្រាប់អ្នកដឹកនាំរបស់យើង និងអធិស្ឋានឲ្យពួកគាត់មានឱកាសក្នុងការប្រកាសអំពីព្រះគ្រីស្ទ។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងប្តេជ្ញាក្នុងការអធិស្ឋានឲ្យអ្នកដឹកនាំរបស់ខ្លួន។ ពួកគាត់ធ្វើតាមការដាស់តឿនរបស់ព្រះយេស៊ូវក្នុងការដែលត្រូវតែអធិស្ឋានជានិច្ច និងឥតរសាយចិត្តឡើយ (លូកា ១៨:១)។ ហើយពួកគាត់ធ្វើដូច្នេះជំនួសឲ្យគ្រូគង្វាលរបស់ខ្លួនផងដែរ។

នៅក្នុងពួកជំនុំតាមតំបន់របស់យើង សមាជិកដ៏ស្មោះត្រង់មួយក្រុមតែងតែជួបជុំគ្នារៀងរាល់យប់ថ្ងៃអង្គារ ក្នុងគោលបំណងអធិស្ឋានសម្រាប់អ្នកដឹកនាំ។ រាល់សប្តាហ៍ ពួកគាត់ស្នើសុំសំណូមពរអធិស្ឋាន និងការផ្តល់ព័ត៌មានលើសំណើអធិស្ឋានកាលពីលើកមុន។ ពេលពួកគាត់ជួបគ្នា ពួកគាត់អធិស្ឋានសម្រាប់គ្រប់បែបយ៉ាងទាក់ទងទៅនឹងជីវិតផ្ទាល់

9Marks Online PDF

ខ្លួន ជីវិតសាធារណៈ និងជីវិតព័ន្ធកិច្ចរបស់អ្នកចាស់ទុំ។ ព្រះជាម្ចាស់បានបង្កើតផលផ្លែដ៏អស្ចារ្យនៅក្នុងពួកជំនុំយើង តាមរយៈការអធិស្ឋានរបស់ពួកគាត់។

## ចូរគាំទ្រព័ន្ធកិច្ច និងទំនាក់ទំនងខាងក្រៅរបស់អ្នកដឹកនាំ

ប្រាកដណាស់ នេះប្រហែលជាការតូចបំផុតនៃសកម្មភាពដែលសមាជិកមានសុខភាពល្អនឹងទទួលយក ក្នុងការដើរតាមអ្នកដឹកនាំ។ សមាជិកងាយនឹងមានទំនោរចិត្តក្នុងការដែលយកគ្រូគង្វាលរបស់ខ្លួនធ្វើជាកម្មសិទ្ធិរបស់ខ្លួន—«គាត់ជាគ្រូគង្វាលរបស់យើង»។ មានទិដ្ឋភាពវិជ្ជមានចំពោះភាពជាកម្មសិទ្ធិបែបនេះ។ ឧទាហរណ៍៖ វាបង្ហាញអំពីការភ្ជាប់ចិត្តដែលបើកទូលាយចំពោះអ្នកគង្វាល។

ទោះជាយ៉ាងណាក៏ដោយ ក៏ភាពជាកម្មសិទ្ធិនេះអាចនឹងក្លាយជាភាពអាត្មានិយម ប្រសិនបើក្រុមជំនុំបដិសេធមិនគាំទ្រចំពោះការពាក់ព័ន្ធរបស់គ្រូគង្វាលក្នុងព័ន្ធកិច្ចក្រៅពីពួកជំនុំរបស់ខ្លួន។ គ្រូគង្វាល គឺជាមនុស្សដែលឈឺចាប់ញឹកញាប់បំផុតក្នុងភាពអាត្មា និយមបែបនេះ ព្រោះបើគ្មានការជំរុញពីខាងក្រៅ និងការទទួលភាពស្រស់ស្រាយពីគ្រូគង្វាល និងអ្នកដឹកនាំដទៃទៀតទេ នោះគាត់នឹងស្ងួត ព្រមទាំងក្រៀមស្រពោនដូចជាដើមទំពាំងបាយជូរមួយជាមិនខាន។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងរួមចំណែកដល់សុខភាព និងកម្លាំងរឹងមាំរបស់អ្នកដឹកនាំក្នុងព័ន្ធកិច្ច ដោយលើកទឹកចិត្តឲ្យគាត់ចូលរួមការសន្និបាតនៅខាងក្រៅ ទទួលឱកាសធ្វើជាអ្នកអធិប្បាយ និងការប្រកបជាមួយអ្នកដឹកនាំក្នុងពួកជំនុំដទៃទៀត លើកលែងតែជាមួយពួកខុសឆ្គង។

ព្រះគម្ពីរផ្ដល់នូវការបង្ហាញជាច្រើនអំពីការគាំទ្ររបស់ពួកជំនុំមួយដល់

9Marks Online PDF

ពួកជំនុំមួយទៀត។ កណ្ឌគម្ពីរ ២កូរិនថូស ៩:១៣ បានសរសើរសេចក្តីសប្បុរសរបស់ពួកជំនុំចំពោះពួកជំនុំផ្សេងទៀត។ ហើយយើងសង្ឃឹមថាសេចក្តីសប្បុរសបែបនេះ ដែលមានទម្រង់ជា «ការឲ្យខ្ចី» គ្រូគង្វាលក្នុងការធ្វើព័ន្ធកិច្ចដល់ពួកជំនុំដទៃនឹង ពង្រីកដំណឹងល្អតាមរយៈការប្រកាសនៅតាមតំបន់នានាផ្សេងទៀតដែរ (២កូរិនថូស ១០:១៥-១៦)។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងចង់ឃើញដំណឹងល្អកាន់តែរីកចម្រើនឡើង ហើយក៏នឹងចង់រួមចំណែកដល់សុខភាពពួកជំនុំផ្សេងទៀត បើអាចទៅរួចដែរ។ ការគាំទ្រព័ន្ធកិច្ចខាងក្រៅរបស់អ្នកដឹកនាំគឺជារបៀបមួយ ដើម្បីសម្រេចបាននូវបំណងប្រាថ្នានេះ។

## *សេចក្តីសន្និដ្ឋាន*

ព្រះជាម្ចាស់បានបង្កើតភាពជាអ្នកដឹកនាំនៅក្នុងពួកជំនុំតាមតំបន់សម្រាប់ការប្រទានពរដល់រាស្ត្ររបស់ទ្រង់។ ទោះជាយ៉ាងណាក៏ដោយ ដើម្បីឲ្យការដឹកនាំមានប្រសិទ្ធភាពបាន គឺចាំបាច់ត្រូវមានការលើកទឹកចិត្ត និងការគាំទ្រពីសមាជិកនៃពួកជំនុំនោះ។ មានគ្រូគង្វាលស្មោះត្រង់ជាច្រើនបានលិចចុះដោយបុកច្រាំងថ្មនៃសមាជិកដែលមិនអាចកែតម្រង់បាន ហើយចេះតែប្រឆាំងនឹងពួកគាត់។ នៅក្នុងចំណោមរាស្ត្ររបស់ព្រះ ការ បែប នេះ មិនគួរមានដូច្នេះទេ។ ផ្ទុយទៅវិញ សមាជិកពួកជំនុំដែលមានសុខភាពល្អតាមតំបន់គួរតែខិតខំ និងលើកទឹកចិត្តអ្នកផ្សេងទៀតឲ្យខិតខំធ្វើតាមអ្នកដឹកនាំរបស់ខ្លួន ដោយបើកចិត្តឲ្យទូលាយ ឲ្យគោរពប្រតិបត្តិយ៉ាងក្លៀវក្លា និងឲ្យចុះចូលដោយអំណរ។

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. សូមពិចារណាអំពីការណែនាំដល់សមាជិកពួកជំនុំនៅក្នុងកណ្ឌគម្ពីរ

ហេព្រើរ ជំពូក១៣។តើមានរបៀបណាខ្លះដែលការចុះចូលចំពោះអ្នកដឹកនាំបាននាំឲ្យលោកអ្នកទទួលបានអត្ថប្រយោជន៍ ឬព្រះពរ?

២. តើលោកអ្នកអាចអធិស្ឋានសម្រាប់អ្នកដឹកនាំរបស់ខ្លួនតាមរបៀបជាក់លាក់ណាខ្លះបាន?

៣. ខណៈពេលដែលពួកអ្នកដឹកនាំក្រុមជំនុំដើរតាមព្រះគ្រីស្ទ ហើយបង្រៀនព្រះបន្ទូល តើលោកអ្នកអាចលើកទឹកចិត្តសមាជិកផ្សេងទៀតឲ្យមានទំនុកចិត្តកាន់តែខ្លាំងលើអ្នកដឹកនាំទាំងនោះដោយរបៀបណា?

9Marks Online PDF

សញ្ញាសម្គាល់ទី១០

# សមាជិកពួកជំនុំដែលមានសុខភាពល្អគឺជាអ្នកចម្បាំងខាងសេចក្តីអធិស្ឋាន

**កាលខ្ញុំនៅក្មេង** យើងធ្លាប់ធ្វើពិធីខួបកំណើតឲ្យមិត្តភក្តិរបស់យើងដោយទះពួកគេ មួយដៃសម្រាប់មួយឆ្នាំនៃថ្ងៃកំណើតរបស់ពួកគេ។ ហើយបន្ទាប់មក យើងនឹងបញ្ចប់ដោយថែមមួយដៃទៀត ហើយនិយាយថា "...ហើយមួយនេះ ដើម្បីឲ្យរីកចម្រើនថែមទៀត"។ ខ្ញុំបានការរក្សាជំពូកទាំងប្រាំបួនដំបូងនៃសៀវភៅនេះឲ្យត្រូវគ្នាទៅនឹង សញ្ញាសម្គាល់ទាំងប្រាំបួននៅក្នុងភាគរបស់វា *សញ្ញាសម្គាល់ប្រាំបួនយ៉ាងនៃពួកជំនុំដែលមានសុខភាពល្អ* និង *ពួកជំនុំមានសុខភាពល្អ* ខណៈដែលជំពូកទី១០នេះគឺជាជំពូក "មួយ ដើម្បីឲ្យរីកចម្រើនថែមទៀត"។

ខ្ញុំមិនដែលជួបគ្រីស្ទបរិស័ទ សូម្បីតែម្នាក់ ដែលមិនជឿថា ការអធិស្ឋានមានសារៈសំខាន់ ហើយមិនត្រឹមតែសំខាន់ប៉ុណ្ណោះទេ ប៉ុន្តែជាផ្នែកដ៏សំខាន់បំផុតនៃជីវិតជាគ្រីស្ទបរិស័ទទៀតផង។ គ្រីស្ទបរិស័ទ ដែលព្យាយាមរស់នៅក្នុងជីវិតជាគ្រីស្ទបរិស័ទដោយគ្មានការអធិស្ឋាន គឺជាគ្រីស្ទបរិស័ទចម្លែកណាស់។

9Marks Online PDF

ប៉ុន្តែ ទោះបីជាមានការទទួលស្គាល់ជាសកលបែបនេះក៏ដោយ ក៏ការអធិស្ឋាននៅតែជាកិច្ចការដ៏លំបាកសម្រាប់គ្រីស្ទបរិស័ទជាច្រើនដែរ ដែលវាជាកាតព្វកិច្ចដែលគ្មានសេចក្តីអំណរ ហើយពេលខ្លះហាក់ដូចជាគ្មានប្រសិទ្ធភាពទៀតផង។ គ្រីស្ទបរិស័ទអាចនឹងរអើរវាយរវាងបង្គោលនៃការធ្វេសប្រហែស និងការខកចិត្ត នៅពេលនិយាយអំពីការអធិស្ឋាន។

ហេតុអ្វីបានជាវាដូច្នេះ? ហេតុអ្វីបានជាគ្រីស្ទបរិស័ទ និងសមាជិកពួកជំនុំដែលមានសុខភាពល្អមានអារម្មណ៍ថា ការអធិស្ឋានគឺជាលំហាត់ដ៏ពិបាកបែបនេះ?

## *សំណាក់នៃការអធិស្ឋានសម្រាប់មនុស្សទាំងអស់*

ភាពលំបាកក្នុងការអធិស្ឋាន នឹងកាន់តែមានការភាន់ច្រលំ នៅពេលដែលយើងដឹងថា ព្រះវិហារជាកន្លែងសម្រាប់អធិស្ឋាន។ ហោរ៉ា អេសាយ បានសរសេរអំពីគ្រាមួយដែលពួកមហាតលិក និងជនបរទេសនឹងស្វែងរកកន្លែងដែលស្វាគមន៍ក្នុងចំណោមប្រជាជននៃព្រះ។ អស់អ្នកដែលមកពីប្រទេសផ្សេងក្រៅពីអ៊ីស្រាអែល នឹងកាន់តាមសេចក្តីសញ្ញារបស់ព្រះ ហើយព្រះអម្ចាស់បានសន្យាចំពោះជនបរទេសទាំងនេះថា៖

> នោះអញនឹងនាំគេមកឯភ្នំបរិសុទ្ធរបស់អញ
> ហើយឲ្យគេបានអរសប្បាយ នៅក្នុងដំណាក់របស់អញ
> ដែលសម្រាប់ជាទីអធិស្ឋាន អញនឹងទទួលអស់ទាំងដង្វាយដុត
> នឹងយញ្ញបូជារបស់គេ នៅលើអាសនា
> ដ្បិតដំណាក់អញនឹងបានហៅជាទីអធិស្ឋាន
> សម្រាប់គ្រប់ទាំងសាសន៍ (អេសាយ ៥៦:៧)។

9Marks Online PDF

ព្រះអម្ចាស់យេស៊ូវបានលើកឡើងនូវសេចក្តីសន្យានេះនៅពេលដែល «ទ្រង់យាងចូលទៅក្នុងព្រះវិហារ ក៏បណ្តេញអស់ទាំងអ្នកដែលលក់ដូរក្នុងព្រះវិហារចេញ» ព្រះអង្គកំពុងតែបញ្ជាក់ថា ដំណាក់ព្រះមិនមែនជារោងចោរទេ តែជាទីសម្រាប់អធិស្ឋានវិញ (ម៉ាថាយ ២១:១៣; ម៉ាកុស ១១:១៧)។

នៅពេលយើងពិនិត្យមើលសកម្មភាពរបស់ពួកជំនុំដំបូង ដែលបានកត់ត្រាទុកសម្រាប់យើងនៅក្នុងព្រះគម្ពីរ នោះយើងនឹងឃើញថា ចំណុចដ៏សំខាន់មួយដែលសមាជិកក្រុមជំនុំដំបូងបានឱបជាប់គឺ ការអធិស្ឋាន។ នៅពេលពួកគាត់រង់ចាំសេចក្តីសន្យានៃព្រះវិញ្ញាណបរិសុទ្ធ នោះពួកគាត់បានប្រមូលផ្តុំគ្នានៅបន្ទប់ខាងលើ ហើយ «ពួកអ្នកទាំងនេះមានចិត្តព្រមព្រៀងគ្នា ដោយព្យាយាមក្នុងសេចក្តីអធិស្ឋាន» (កិច្ចការ ១:១៤)។ បន្ទាប់ពីថ្ងៃបុណ្យទី៥០ នៅពេលដែលព្រះបានបន្ថែមចំនួនពួកអ្នក ដែលកំពុងតែត្រូវបានទទួលសេចក្តីសង្គ្រោះ សមាជិកដំបូងបំផុតនៃក្រុមជំនុំគ្រីស្ទបរិស័ទបាន «ព្យាយាមប្តូរផ្តាច់» ចំពោះកិច្ចការបួនយ៉ាង៖ «ព្យាយាមក្នុងសេចក្តីបង្រៀនរបស់ពួកសាវ័ក ហើយក្នុងសេចក្តីប្រកបគ្នា ព្រមទាំងការកាច់នំបុ័ង និងសេចក្តីអធិស្ឋានផង» (កិច្ចការ ២:៤២)។ ការចូលរួមរបស់គ្រីស្ទបរិស័ទដំបូងបំផុត ក្នុងការអធិស្ឋានមានភាពសស្រាក់សស្រាំខ្លាំងនេះហើយបានជាគេហៅវាថា «ការប្តូរផ្តាច់»។

ការអធិស្ឋានជាការដាក់វិន័យខាងឯវិញ្ញាណដ៏សំខាន់មួយ ដែលវាជាការប្តូរផ្តាច់តែមួយគត់ ដែលបានផ្តល់ជាហេតុផលសម្រាប់ការរំខានដល់ការទំនាក់ទំនងអាពាហ៍ពិពាហ៍ធម្មតារវាងប្តី និងប្រពន្ធ (១កូរិនថូស ៧:៥)។ សូមស្រមៃមើលអំពីការរីកផុសផុលឡើង នៅក្នុងជីវិតខាងវិញ្ញាណ ប្រសិនបើបន្ទប់គេងរបស់គ្រីស្ទបរិស័ទដែលមានប្តី ឬប្រពន្ធ

9Marks Online PDF

និយាយថា “បង/អូនសម្លាញ់ មិនមែនពេលនេះទេ តែចូរយើងព្យាយាមនឹងសេចក្តីអធិស្ឋានសិន” ជំនួសឲ្យពាក្យថា “បង/អូនសម្លាញ់ មិនមែនពេលនេះទេ ព្រោះអូន/បងកំពុងឈឺក្បាល” ។ ចាប់តាំងពីផ្ទះរហូតដល់ព្រះវិហារ ការអធិស្ឋានគឺចាំបាច់ណាស់។

## *តើការអធិស្ឋានជាអ្វី?*

ប៉ុន្តែ ការគ្រាន់តែចង្អុលបង្ហាញពីសារៈសំខាន់ និងចំណុចស្នូលនៃការអធិស្ឋាននៅក្នុងក្រុមជំនុំដំបូងមិនធ្វើឲ្យយើងក្លាយជាមនុស្សឆ្នើមខាងសេចក្តីអធិស្ឋាននោះទេ។ មិនត្រឹមតែប៉ុណ្ណឹងទេ ជាញឹកញាប់យើងក៏ច្រើនតែមិនបានយល់ច្បាស់ថា តើការអធិស្ឋានជាអ្វីឲ្យពិតប្រាកដដែរ។ មានគំនិតខុសឆ្គងច្រើន ឧទាហរណ៍៖

- លុះត្រាតែយើងអធិស្ឋាន បើមិនដូច្នេះទេ នោះព្រះជាម្ចាស់មិនអាចធ្វើសកម្មភាពនៅក្នុងពិភពលោកនេះបានទេ។
- ព្រះជាម្ចាស់បានសម្រេចគ្រប់អ្វីៗទាំងអស់រួចទៅហើយ។ ទ្រង់មានពេញដោយអធិបតេយ្យភាព ដូច្នេះហេតុអ្វីបានជាយើងចាំបាច់អធិស្ឋាន?
- ព្រះអង្គរវល់ខ្លាំងពេកក្នុងការស្តាប់សេចក្តីអធិស្ឋានរបស់ខ្ញុំ។

ជាឫសគល់ ការយល់ខុសអំពីការអធិស្ឋាន ភាគច្រើនកើតចេញពីការយល់ខុសអំពីនិស្ស័យរបស់ព្រះជាម្ចាស់ និងអំពីទំនាក់ទំនងរបស់យើងជាមួយនឹងទ្រង់។ វាមានភាពងាយស្រួលណាស់ក្នុងការបង្វែរការអធិស្ឋានទៅជាការសម្តែងមួយដែលផ្តោតលើខ្លួនឯងជាធំ ជាកន្លែងដែលយើងបានផ្តោតយកចិត្តទុកដាក់ការទាមទារ និងសេចក្តីត្រូវការរបស់យើង ហើយយើងចាត់ទុកព្រះជាម្ចាស់ជាអ្នកបើកបិទវាំងននលើឆាក ដើម្បីផ្លាស់ប្តូរ

9Marks Online PDF

ទិដ្ឋភាពទៅតាមសំណើរបស់យើងវិញ។ ប៉ុន្តែ វាក៏ងាយស្រួលផងដែរក្នុងការធ្លាក់ចេញពីផ្នែកម្ខាងទៀតនៃផ្នត់គំនិត ដោយចាត់ទុកព្រះជាម្ចាស់ជាអ្នកលេងអុកដោយកំណត់ការផ្លាស់ប្តូរបំណែកទាំងអស់ ដោយមិនគិតពីសកម្មភាពរបស់រាស្ត្រទ្រង់។

អ្វីដែលយើងត្រូវការគឺការយល់ដឹងមួយដែលផ្តោតលើចំណុចស្នូលនៃដំណឹងល្អ នៅក្នុងសេចក្តីអធិស្ឋាន។ លោក ហ្គ្រាអែម ហ្គោលស្វឺឌី (Graeme Goldsworthy) ដែលជាទេវវិទូម្នាក់បានផ្តល់នូវការយល់ដឹងនេះដូចខាងក្រោម៖

> ដំណឹងល្អផ្តោតជាចម្បងលើកិច្ចការរបស់ព្រះរាជបុត្រា។ របៀបដែលយើងស្គាល់ព្រះរាជបុត្រានឹងកំណត់ អំពីរបៀបដែលយើងមានទស្សនៈ ចំពោះទំនាក់ទំនងរបស់យើងជាមួយព្រះវរបិតា ដែលមានបន្ទូលមកកាន់យើង តាមរយៈព្រះបន្ទូលរបស់ទ្រង់។ របៀបដែលយើងឲ្យតម្លៃ ឬក៏មិនឲ្យតម្លៃលើទំនាក់ទំនងនោះនឹងកំណត់ថា យើងមករកព្រះដោយរបៀបណាក្នុងការអធិស្ឋាន និងថាមានទំនុកចិត្តបែបណា។ ការអធិស្ឋាននឹងមិនមែនជាដំណើរកម្សាន្តបែបមនោសញ្ចេតនា ឬជាការវាយប្រហារដោយសភាវគតិនៃការភ័យស្លន់ស្លោឡើយ។ វាក៏មិនមែនជាការសន្មតនៃសិទ្ធិពីកំណើត ក្នុងការទាមទារការយកព្រះទ័យទុកដាក់ពីព្រះដែរ។ ប៉ុន្តែ ការអធិស្ឋានគឺជាការបង្ហាញអំពីការចូលទៅក្នុងទីបរិសុទ្ធនៃនគរស្ថានសួគ៌របស់ព្រះ ដែលត្រូវបានទទួលទុកសម្រាប់យើងដោយសម្តេចសង្ឃដ៏ខ្ពស់បំផុតរបស់យើង។[២១]

---

២១ លោក Graeme Goldsworthy, Prayer and the Knowledge of God: What the Whole Bible Teaches (Downers Grove, IL: Inter Varsity ឆ្នាំ២០០៣) ទំព័រ៥១។

9Marks Online PDF

ការជឿលើដំណឹងល្អ ផ្លាស់ប្តូរឋានៈរបស់យើងពីអ្នកក្រៅឲ្យទៅជាសមាជិកនៃគ្រួសាររបស់ព្រះជាម្ចាស់ ដែលជាកូនចិញ្ចឹមរបស់ព្រះតាមរយៈសេចក្តីជំនឿលើព្រះគ្រីស្ទ។ ដោយផ្អែកលើមូលដ្ឋាននេះ—ភាពជាកូនរបស់យើង តាមរយៈសេចក្តីជំនឿលើព្រះគ្រីស្ទ—នោះយើងអាចនិយាយទៅកាន់ព្រះក្នុងនាមជាកូនរបស់ទ្រង់ ដែលបានប្រោសលោះ។ «ការអធិស្ឋាន គឺជាការឆ្លើយតបរបស់យើងទៅកាន់ព្រះជាម្ចាស់ ដូចដែលទ្រង់បានមានបន្ទូលមកកាន់យើង»[២២] ទីមួយ គឺនៅក្នុងដំណឹងល្អរបស់ព្រះគ្រីស្ទ ហើយបន្ទាប់មកគឺនៅក្នុងព្រះបន្ទូលរបស់ទ្រង់។

ការអធិស្ឋានគឺ «មិនមែនជាការអង្វរ ដើម្បីបុព្វហេតុមួយនៅចំពោះព្រះមួយអង្គដែលមិនសព្វព្រះហឫទ័យនោះទេ»[២៣] ហើយការអធិស្ឋានក៏មិនមែនជាការដើរតួជំនួសសម្រាប់ព្រះអង្គណាមួយ ដែលគ្មានអំណាច ដើម្បីផ្លាស់ប្តូរអ្វីៗទាំងអស់ដោយគ្មានយើងនោះដែរ។ នៅក្នុងការអធិស្ឋាន ក្នុងនាមជាកូនដែលបានរួបរួមជាមួយនឹងព្រះគ្រីស្ទ ដែលទ្រង់បានធ្វើជាអ្នកជំនួស និងសម្តេចសង្ឃរបស់យើង ជាអ្នកទទួលមរតកនៃអ្វីៗទាំងអស់ នោះយើងឈរនៅចំពោះទ្រង់ដែលកំពុងតែទទួលការសណ្តាប់យ៉ាងពេញលេញ។ ដោយសារយើងនៅចំពោះព្រះនៅក្នុងព្រះគ្រីស្ទ នោះមិនមានពិដានណាមួយដែលនឹងរាំងការអធិស្ឋានរបស់យើងទេ ទោះបីជាយើងគិតថា មានក៏ដោយ។ ផ្ទុយទៅវិញ «យើងរួមចំណែកក្នុងកិច្ចការរបស់ព្រះជាមួយនឹងពិភពលោកនេះ» ដោយការអធិស្ឋាន «ឆ្ពោះទៅរកការសម្រេច

---

២២ ក្នុងសៀវភៅដូចគ្នា, ទំព័រ១៦។

២៣ ក្នុងសៀវភៅដូចគ្នា, ទំព័រ៣៥។

9Marks Online PDF

នូវគោលបំណងដែលព្រះអង្គបានបើកសម្ដែង សម្រាប់សកលលោកទាំងមូល» តាមរយៈ «ដំណឹងល្អ និងលទ្ធផលដែលទ្រង់បានតែងតាំងឡើង»។ ការអធិស្ឋានគឺជា «ការគិតអំពីគំនិតរបស់ព្រះ»[២៤]—ជាគំនិតដែលនឹងត្រូវទទួលបាននូវការព្រះសណ្ដាប់ និងទទួលបាននូវចម្លើយជានិច្ច។

## *តើយើងត្រូវអធិស្ឋានដោយរបៀបណា និងនៅពេលណា?*

មានសៀវភៅជាច្រើនបានសរសេរលើប្រធានបទអំពីការអធិស្ឋាន។ អ្នកខ្លះ បានចេញជារបៀបអំពីវិធីសាស្ត្រខ្លះៗសម្រាប់ការអធិស្ឋាន។ អ្នកផ្សេងទៀតបានពិនិត្យមើល អំពីជីវិតនៃការអធិស្ឋានរបស់មនុស្សមួយចំនួននៅក្នុងព្រះគម្ពីរ ឬក៏ពួកបរិសុទ្ធដ៏អស្ចារ្យក្នុងប្រវត្តិសាស្ត្រនៃពួកជំនុំ។ ដោយមានសៀវភៅជាច្រើនអំពីការអធិស្ឋាន និងការដឹងអំពីការរីកចម្រើន ដែលខ្ញុំត្រូវមានក្នុងជីវិតអធិស្ឋានផ្ទាល់ខ្លួនរបស់ខ្ញុំ ខ្ញុំក៏មានការស្ទាក់ស្ទើរក្នុងការផ្ដល់យោបល់សម្រាប់អ្នកដទៃ ដើម្បីពិចារណា។ ប៉ុន្តែ ដោយសារព្រះគុណ និងព្រះហឫទ័យមេត្តាករុណារបស់ព្រះ នោះទ្រង់បានប្រាប់យើងអំពីរបៀប និងពេលដែលយើងត្រូវអធិស្ឋាន។

យើងអាចបង្រួមរបៀប និងពេលនៃការអធិស្ឋានមកក្នុងការបង្រៀនពីរក្នុងព្រះគម្ពីរ៖ ចូរអធិស្ឋានឥតឈប់ឈរ និងចូរអធិស្ឋានដោយព្រះវិញ្ញាណ។

## ឥតឈប់ឈរ

ជាញឹកញាប់ សាវ័ក ប៉ុល បានលើកទឹកចិត្តពួកជំនុំដែលគាត់បាន

---

២៤ ក្នុងសៀវភៅដូចគ្នា, ទំព័រ៦១-៦១។

9Marks Online PDF

សរសេរទៅ ឲ្យអធិស្ឋានឥតឈប់ឈរ។ លោកបានដាស់តឿនពួកជំនុំថែស្សាឡូនីចឲ្យ «អធិស្ឋានឥតឈប់ឈរ» (១ថែស្សាឡូនីច ៥:១៧)។ សាវ័ក ប៉ុល ក៏បានសរសេរទៅកាន់គ្រីស្ទបរិស័ទនៅទីក្រុងរ៉ូមឲ្យមានការ «ខ្ជាប់ខ្ជួនក្នុងសេចក្តីអធិស្ឋាន» (រ៉ូម ១២:១២)។ ហើយគាត់ក៏បានសរសេរទៅកាន់ពួកជំនុំកូឡូសថា «ចូរព្យាយាមក្នុងសេចក្តីអធិស្ឋាន ទាំងចាំយាមក្នុងសេចក្តីនោះឯង ដោយពាក្យអរព្រះគុណ» (កូឡូស ៤:២)។ នេះជាវិធីមួយដែលអ្នកនៅក្នុងពួកជំនុំកូឡូសអាចដាក់គំនិតរបស់ពួកគាត់លើបាន ហើយ «ស្វែងរកអស់ទាំងសេចក្តី ដែលនៅស្ថានលើវិញ ជាស្ថានដែលព្រះគ្រីស្ទគង់ខាងស្តាំនៃព្រះ» (កូឡូស ៣:១-២)។ ឧទាហរណ៍៖ សាវ័ក ប៉ុល បានលើកលោក អេប៉ាប្រាស យកមកធ្វើជាគំរូដែល «គាត់ខំប្រឹងអធិស្ឋានជានិច្ចឲ្យអ្នករាល់គ្នា» (កូឡូស ៤:១២)។ ដោយមើលឃើញពីការល្បួង ការគ្រោះថ្នាក់ និងតម្រូវការក្នុងជីវិតគ្រីស្ទបរិស័ទ នោះសមាជិកពួកជំនុំដែលមានសុខភាពល្អនឹងគោរពតាមការបង្គាប់របស់ព្រះជាម្ចាស់ សម្រាប់ការខ្ជាប់ខ្ជួននៅក្នុងសេចក្តីអធិស្ឋាន។

## ដោយព្រះវិញ្ញាណ

សមាជិកពួកជំនុំដែលមានសុខភាពល្អក៏មិនត្រឹមតែអធិស្ឋានឥតឈប់ឈរនោះទេ តែគាត់ក៏នឹងអធិស្ឋានដោយព្រះវិញ្ញាណផងដែរ។ «ការអធិស្ឋានដោយព្រះវិញ្ញាណ» មានការយល់ឃើញផ្សេងៗគ្នា ក្នុងក្រុមគ្រីស្ទបរិស័ទ ហើយមានការយល់ច្រលំជាច្រើនកើតមានលើចំណុចនេះ។ ប៉ុន្តែ ជាថ្មីម្តងទៀត សំបុត្ររបស់សាវ័ក ប៉ុល ទៅកាន់ពួកជំនុំនៅទីក្រុងរ៉ូមគឺមានប្រយោជន៍ណាស់ ដែលគាត់បានសរសេរថា៖ «ព្រះវិញ្ញាណទ្រង់ក៏ជួយសេចក្តីកម្សោយរបស់យើងបែបដូច្នោះដែរ ដ្បិតយើងមិនដឹងជាគួរអធិស្ឋាន

9Marks Online PDF

សូមអ្វីទេ តែព្រះវិញ្ញាណទ្រង់ជួយអង្វរជំនួសយើង ដោយដំងូរដែលរកថ្លែងពុំបានវិញ។ ប៉ុន្តែ ព្រះអង្គដែលស្ទង់ចិត្ត ទ្រង់ជ្រាបនូវគំនិតនៃព្រះវិញ្ញាណ ដ្បិតព្រះវិញ្ញាណជួយអង្វរជួសពួកបរិសុទ្ធ ឲ្យត្រូវនឹងព្រះហឫទ័យព្រះ» (រ៉ូម ៨:២៦-២៧)។

មានលទ្ធផល ដែលគួរឲ្យសោកស្តាយនៃការស្មានជាច្រើនលើបទគម្ពីរមួយដូចជាកណ្ឌគម្ពីរ រ៉ូម ៨:២៦-២៧ គឺថា ពួកគាត់បានមើលរំលងលើការលើកទឹកចិត្តដ៏អស្ចារ្យ និងការសង្កត់ធ្ងន់នេះ។ មានការបង្រៀនដ៏ល្អនៅទីនេះ ដើម្បីលើកទឹកចិត្តយើងឲ្យអធិស្ឋាន។ សូមកត់ចំណាំថា ព្រះវិញ្ញាណ «ជួយសេចក្តីកម្សោយរបស់យើង»។ យើងបានកត់សម្គាល់រួចហើយថា ការអធិស្ឋានគឺជាផ្នែកមួយដែលគ្រីស្ទបរិស័ទបានទទួលស្គាល់យ៉ាងងាយស្រួលថា ជាចំណុចទន់ខ្សោយរបស់ខ្លួន។ ព្រះដ៏ជាព្រះវិញ្ញាណបរិសុទ្ធមានសេចក្តីសប្បុរសយ៉ាងណាហ្ន៎ ដែលទ្រង់ជួយយើងក្នុងផ្នែកនេះ! តើលោកអ្នកធ្លាប់មិនដឹងថាត្រូវអធិស្ឋានអំពីអ្វីដែរឬទេ? ព្រះវិញ្ញាណផ្ទាល់អង្វរជំនួសយើង។ តើលោកអ្នកធ្លាប់ប្រាថ្នាចង់ដឹងច្បាស់ថា តើព្រះហឫទ័យរបស់ព្រះជាម្ចាស់ជាអ្វី ដើម្បីឲ្យលោកអ្នកអាចសុំត្រូវនឹងការនោះដែរឬទេ? ច្បាស់ណាស់ ដែលព្រះវិញ្ញាណបរិសុទ្ធអង្វរជំនួសយើង «ទៅតាមព្រះហឫទ័យរបស់ព្រះ»។

ទាំងអស់នេះ ជាតម្រុយសំខាន់សម្រាប់អត្ថន័យនៃការអធិស្ឋានដោយព្រះវិញ្ញាណ។ ការអធិស្ឋានដោយព្រះវិញ្ញាណគឺជាការអធិស្ឋានដែលមានការគ្រប់គ្រងដោយព្រះវិញ្ញាណ។ ហើយការអធិស្ឋានដែលមានការគ្រប់គ្រងដោយព្រះវិញ្ញាណគឺជាការអធិស្ឋានដែលស្របតាមព្រះហឫទ័យរបស់ព្រះជាម្ចាស់។ ពេលដែលយើងអធិស្ឋានស្របតាមព្រះហឫទ័យរបស់ព្រះ ដូចដែលបានបង្ហាញនៅក្នុងព្រះបន្ទូលទ្រង់ នោះគឺ

9Marks Online PDF

យើងអធិស្ឋានដោយព្រះវិញ្ញាណ។ ការអធិស្ឋានបែបនេះគឺជាសិទ្ធិកំណើតរបស់មនុស្សគ្រប់រូបដែលកើតមកពីព្រះវិញ្ញាណ ហើយបានរាប់ជាកូនរបស់ទ្រង់ (រ៉ូម ៨:១៤-១៧)។ គឺដោយការអធិស្ឋានបែបយ៉ាងដូច្នោះហើយ ទើបយើងក្លាយជាមនុស្សឆ្នើមក្នុងនាមជាគ្រីស្ទបរិស័ទដែលធ្វើចម្បាំង (អេភេសូរ ៦:១៨)។

## *តើយើងត្រូវអធិស្ឋានដើម្បីអ្វី និងសម្រាប់នរណា?*

ដូចដែលយើងបានឃើញនៅក្នុងកណ្ឌគម្ពីរ រ៉ូម ៨:២៦-២៧ វិធីមួយដែលព្រះវិញ្ញាណនៃព្រះជួយដល់ភាពកម្សោយរបស់យើងក្នុងការអធិស្ឋាន គឺដោយការអង្វរជំនួសយើង នៅពេលដែលយើងមិនដឹងថា ត្រូវអធិស្ឋានអំពីអ្វីទេ។ ទោះជាយ៉ាងណាក៏ដោយ ក៏ព្រះអម្ចាស់បានមានបន្ទូលប្រាប់យើងអំពីរឿងមួយចំនួនដែលយើងគួរអធិស្ឋានឲ្យផងដែរ។

## អធិស្ឋានសម្រាប់អ្នកបម្រើ និងគ្រូគង្វាល

ដំណឹងល្អតាមរយៈសាវ័ក ម៉ាថាយ បានកត់ត្រាឧទាហរណ៍មួយសម្រាប់យើង នៅពេលដែលព្រះយេស៊ូវមានព្រះហឫទ័យក្តួលអាណិត ចំពោះប្រជាជនអ៊ីស្រាអែលដែលត្រូវបានគេឃាយី ហើយគ្មានទីពឹង "ដូចហ្វូងចៀម ដែលឥតអ្នកគង្វាល"។ ភ្លាមៗនោះ ព្រះយេស៊ូវបានបង្គាប់ពួកសិស្សទ្រង់ថា "ចម្រូតធំណាស់ តែមានអ្នកច្រូតតិចទេ។ ដូច្នេះ ចូរសូមអង្វរដល់ព្រះអម្ចាស់នៃចម្រូត ឲ្យទ្រង់ចាត់អ្នកច្រូតមកក្នុងចម្រូតទ្រង់" (ម៉ាថាយ ៩:៣៦-៣៨) ។ ប្រហែលជាមានតែគ្រីស្ទបរិស័ទដែលបាននៅក្នុងពួកជំនុំដែលបានរងទុក្ខអស់រយៈពេលដ៏យូរដោយគ្មានគ្រូគង្វាលប៉ុណ្ណោះ ទើបដឹងអំពីភាពបន្ទាន់នៃការអធិស្ឋានមួយនេះ។ រាស្ត្ររបស់ព្រះអម្ចាស់ត្រូវការគ្រូគង្វាល ហើយសមាជិកពួកជំនុំដែលមានសុខភាពល្អនឹងអង្វរ

9Marks Online PDF

ទ្រង់ឲ្យបញ្ជូនគ្រូគង្វាលទៅពួកជំនុំរបស់ខ្លួន និងពួកជំនុំផ្សេងទៀតដែលត្រូវការគ្រូគង្វាលដែរ។ ហើយពួកគាត់មិនត្រឹមតែអធិស្ឋានសុំឲ្យមានអ្នកគង្វាល និងអ្នកបម្រើប៉ុណ្ណោះទេ ពួកគាត់ក៏អធិស្ឋានសូមឲ្យព្រះអម្ចាស់ជួយ និងពង្រឹងអ្នកដែលធ្វើការក្នុងព្រះបន្ទូលក្នុងអំឡុងពេលមានទុក្ខព្រួយ មានការរងទុក្ខ និងមានភាពទន់ខ្សោយ (ភីលីព ១:១៩-២០) ព្រមទាំងទូលសូមឲ្យផ្ដល់ភាពក្លាហាន ដល់គ្រូគង្វាលក្នុងការប្រកាសដំណឹងល្អ (អេភេសូរ ៦:១៩-២០) ហើយផ្ដល់ឱកាសសម្រាប់ការផ្សព្វផ្សាយព័ន្ធកិច្ច និងដំណឹងល្អផងដែរ (កូឡុស ៤:៣-៤)។

## អធិស្ឋានសម្រាប់ពួកបរិសុទ្ធទាំងអស់

ការអធិស្ឋានសម្រាប់គ្រីស្ទបរិស័ទផ្សេងទៀតគឺជាការបង្ហាញជាក់ស្ដែងអំពីសេចក្ដីស្រឡាញ់ និងការយកចិត្តទុកដាក់ (សូមអានកណ្ឌគម្ពីរ អេភេសូរ ៦:១៨)។ ជំនឿគ្រីស្ទបរិស័ទមិនមែនដូចជាកីឡាដែលលេងតែម្នាក់ឯងនោះទេ ហើយការអធិស្ឋានក៏មិនមែនដូចជាហាងទិញដោយជិះឡានចូលទេ ដែលជាកន្លែងដែលយើងអាចកុម្ម៉ង់អ្នកដែលកំពុងចាំទទួលការកុម្ម៉ង់ រួចរង់ចាំបន្តិចសិន ហើយបន្ទាប់មកទទួលបានអ្វីដែលយើងបានកុម្ម៉ង់ «ហើយញ៉ាំតាមផ្លូវ» នោះទេ។ ជីវិតគ្រីស្ទបរិស័ទគឺជាជីវិតគ្រួសារ ហើយការអធិស្ឋានរបស់យើងត្រូវផ្ដោតលើគ្រួសារទាំងមូល ដោយឲ្យតម្លៃអ្នកដទៃខ្លាំងជាងខ្លួនយើង។ វិធីមួយក្នុងការធ្វើការនេះគឺការអធិស្ឋានឲ្យបានទៀងទាត់តាមរយៈបញ្ជីសមាជិកភាពរបស់ក្រុមជំនុំតាមតំបន់របស់ខ្លួន ប្រសិនបើមានបោះពុម្ពជាបញ្ជី។ យើងអាចអធិស្ឋានមួយទំព័រម្ដងៗ ឬតាមអក្សរមួយនៃអក្ខរក្រមក្នុងមួយថ្ងៃបានដែរ។ វិធីមួយទៀតក្នុងការអធិស្ឋានសម្រាប់ពួកបរិសុទ្ធ ទាំងអស់គឺការអធិស្ឋានសម្រាប់ពួកជំនុំ

ផ្សេងៗទៀតនៅក្នុងតំបន់របស់លោកអ្នក និងព្រះវិហារដែលក្រុមគ្រួសារ និងមិត្តភក្តិផ្សេងទៀតរបស់លោកអ្នកជាសមាជិកនៅទីនោះ។ នៅពេលយើងចំណាយពេលសិក្សាព្រះបន្ទូលព្រះអម្ចាស់ជាប្រចាំថ្ងៃ យើងអាចស្រឡាញ់គ្រីស្ទបរិស័ទផ្សេងទៀតបាន ដោយអធិស្ឋានសេចក្តីពិតនៃព្រះបន្ទូលរបស់ព្រះលើជីវិតរបស់ពួកគាត់ដែរ។ យើងអាចអធិស្ឋានសម្រាប់ការដែលពួកគាត់ញែកខ្លួនចេញជាបរិសុទ្ធ (១ថែស្សាឡូនីច ៤:៣)។ យើងអាចអធិស្ឋានសម្រាប់ការប្រឆាំងនឹងសេចក្តីល្បួង និងសម្រាប់ការចាំយាម (ម៉ាថាយ ២៦:៤១)។ យើងអាចអធិស្ឋានសូមឲ្យពួកគាត់បានពេញដោយព្រះវិញ្ញាណ (កាឡាទី ៥:១៦-២៥) និងអ្វីៗផ្សេងទៀតដែលព្រះគម្ពីរបានបង្គាប់ដល់គ្រីស្ទបរិស័ទ។

## អធិស្ឋានសម្រាប់អ្នកដឹកនាំ

លោក ធីម៉ូថេ ដែលជាគ្រូគង្វាលវ័យក្មេងម្នាក់បានទទួលពាក្យទាំងនេះពីសាវ័ក ប៉ុល ដែលជាគ្រូរបស់គាត់ថា៖ «ដូច្នេះ ខ្ញុំទូន្មានសេចក្តីនេះជាមុនដំបូងថា ចូរពោលពាក្យអរព្រះគុណ ពាក្យទូលសូមពាក្យអធិស្ឋាន និងពាក្យទូលអង្វរឲ្យមនុស្សទាំងអស់ គឺឲ្យស្តេច ហើយឲ្យពួកនាម៉ឺនទាំងប៉ុន្មានផង ដើម្បីឲ្យយើងរាល់គ្នាបាននៅជាសុខសាន្ត ហើយស្រេគត់ស្រេគំដោយកោតខ្លាច ហើយដោយនឹងធឹងគ្រប់ជំពូក ដ្បិតយ៉ាងនោះ ទើបបានល្អ ហើយគាប់ព្រះហឫទ័យដល់ព្រះដ៏ជាព្រះអង្គសង្គ្រោះនៃយើង» (១ធីម៉ូថេ ២:១-៣)។ ដោយសារព្រះបានតែងតាំងគ្រប់សិទ្ធិអំណាចក្នុងជីវិត តាំងពីថ្នាក់ដឹកនាំរដ្ឋាភិបាល (រ៉ូម ១៣:១-២) រហូតដល់ឪពុកម្តាយ (អេភេសូរ ៦:១-៣) ហើយបានប្រទានព្រះពរដល់អស់អ្នក ដែលធ្វើតាមអ្នកគ្រប់គ្រងដែលទ្រង់បានតែងតាំងឡើង នោះវាជាការសមហេតុសម

9Marks Online PDF

ផលដែលគ្រីស្ទបរិស័ទគួរតែអធិស្ឋានសម្រាប់អ្នកគ្រប់គ្រងទាំងនោះ។ សមាជិកពួកជំនុំដែលមានសុខភាពល្អនឹងចងចាំជានិច្ច នៅក្នុងការអធិស្ឋានរបស់ខ្លួនសម្រាប់មន្ត្រីជាប់ឆ្នោត បុគ្គលិករដ្ឋាភិបាល គ្រូបង្រៀននៅសាលា និយោជករបស់ខ្លួន ឪពុកម្ដាយ និងអ្នកផ្សេងទៀតដែលមានសិទ្ធិអំណាច។ វាមានប្រយោជន៍ណាស់ក្នុងការរក្សាបញ្ជីមនុស្សទាំងអស់នេះនៅក្នុងព្រះគម្ពីររបស់លោកអ្នក ឬសៀវភៅកំណត់ហេតុអធិស្ឋានរបស់ខ្លួន ទុកជាការរម្លឹក ដើម្បីអធិស្ឋានសម្រាប់អ្នកដឹកនាំទាំងនោះ។

## អធិស្ឋានសម្រាប់អ្នកដែលបំពាន និងបៀតបៀនពួកគេ

នេះគឺជាបង្គាប់របស់ព្រះអម្ចាស់៖ «ចូរឲ្យពរដល់អ្នកណាដែលគេប្រទេចផ្ដាសាអ្នក ហើយអធិស្ឋានឲ្យអ្នកណាដែលធ្វើទុក្ខអ្នក» (លូកា ៦:២៨)។ វាជារឿងធម្មតាទេ ក្នុងការអធិស្ឋានសម្រាប់មនុស្សដែលយើងស្រឡាញ់។ សូម្បីតែអ្នកមិនជឿក៏ «អធិស្ឋាន» បែបនេះដែរ។ ប៉ុន្តែ សេចក្ដីស្រឡាញ់របស់ព្រះគ្រីស្ទជំរុញយើងឲ្យអធិស្ឋានឲ្យ សូម្បីតែអ្នកដែលបំពាន អ្នកបង្កាច់បង្ខូច និងធ្វើឲ្យយើងរងរបួសផងដែរ (ម៉ាថាយ ៥:៤៦-៤៧)។ វាជាការអស្ចារ្យណាស់ ការអធិស្ឋានបែបនេះផ្ដល់ភស្តុតាងថា យើងជាកូនរបស់ព្រះ (ម៉ាថាយ ៥:៤៥) សូម្បីតែការបៀតបៀនចំពោះសេចក្ដីសុចរិតក៏បណ្ដាលឲ្យមានអំណរបានដែរ ដោយសារព្រះគ្រីស្ទបានសន្យាថា ទ្រង់នឹងប្រទានរង្វាន់នៅក្នុងនគររបស់ទ្រង់ដល់យើងផងដែរ (ម៉ាថាយ ៥:១០-១២)។ យើងមិនត្រូវធ្វើដូចជាអ្នកបម្រើដែលគ្មានចិត្តមេត្តានោះទេ ដែលទោះបីជាបានលើកលែងទោសដោយម្ចាស់បំណុលរបស់គាត់ក៏ដោយ ក៏ប៉ុន្តែគាត់នៅតែប្រព្រឹត្តយ៉ាងឃោរឃៅដដែល ចំពោះអ្នកដែលជំពាក់គាត់ (ម៉ាថាយ ១៨:២១-៣៥)។ យើងត្រូវតស៊ូប្រឆាំងនឹងកម្លាំងចិត្តខាងឯ

9Marks Online PDF

សាច់ឈាម ដែលវាឲ្យយើងមិនស្រឡាញ់ដល់អ្នកបៀតបៀនយើង ហើយធ្វើឲ្យយើងមិនអើពើនឹងពួកគេក្នុងការអធិស្ឋាន។ តែ យើងត្រូវជ្រើសរើសជំនួសមកវិញនូវសេចក្ដីអំណរ និងសេចក្ដីសុចរិតដ៏ខ្ពង់ខ្ពស់របស់កូនព្រះដែលអធិស្ឋានឲ្យ សូម្បីតែអ្នកបៀតបៀនខ្លួនផងដែរ។

## *សេចក្តីសន្និដ្ឋាន*

តើអាចមានឯកសិទ្ធិដ៏អស្ចារ្យជាងអ្វី ដែលបានផ្ដល់មកតាន់ពួកគ្រីស្ទបរិស័ទតាមរយៈព្រះគ្រីស្ទ៖ ដើម្បីឲ្យឈរនៅចំពោះព្រះវរបិតារបស់យើង ហើយឆ្លើយតបដោយការអធិស្ឋានដោយព្រះវិញ្ញាណរបស់ទ្រង់ ចំពោះព្រះបន្ទូលរបស់ទ្រង់ ដែលទ្រង់បានមានបន្ទូលមកកាន់យើងដែរឬទេ? ប្រសិនបើយើងនឹងក្លាយជាអ្នកស្ដាប់សេចក្ដីអធិប្បាយតាមអត្ថន័យគម្ពីរ ជាអ្នកជ្រាបជោគនឹងដំណឹងល្អ និងជាអ្នកសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ នោះយើងគួរអធិស្ឋានដោយមានចំណេះដឹងដ៏ជឿជាក់អំពីអ្វី ដែលព្រះអង្គកំពុងតែធ្វើក្នុងពិភពលោកនេះ តាមរយៈព្រះគ្រីស្ទដ៏ជាព្រះរាជបុត្រារបស់ទ្រង់ ហើយអធិស្ឋានសម្រាប់ការរីកចម្រើននៃដំណឹងល្អ និងព្រះហឫទ័យទ្រង់ នៅទូទាំងពិភពលោកនេះ។

## *សម្រាប់ការសញ្ជឹងគិតបន្ថែម*

១. តើលោកអ្នកមានផែនការជាក់លាក់សម្រាប់ការអធិស្ឋានដែរឬទេ? ចូរពិនិត្យមើលផែនការបច្ចុប្បន្នរបស់ខ្លួន ឬសរសេរផែនការថ្មីសម្រាប់ការអធិស្ឋានដែលរួមបញ្ចូលចំណុចដូចខាងក្រោមនេះ៖

ក)ពេលវេលាសម្រាប់អធិស្ឋានបែបឯកជន និងជាក្រុម/សាធារណៈ។

ខ) ចំនួនដង និងកន្លែងសម្រាប់អធិស្ឋាន

9Marks Online PDF

គ) បុគ្គល និងក្រុមមនុស្សជាក់លាក់ ដើម្បីអាចអធិស្ឋានឲ្យ

ឃ) ដំណឹងល្អ និងការងារក្នុងពួកជំនុំ

ង) ខគម្ពីរដែលអ្នកយល់ថា ជាការលើកទឹកចិត្ត និងមានប្រយោជន៍ក្នុងការអធិស្ឋាន។

# បណ្ដាំកថា

**ការសរសេរសៀវភៅនេះ** គឺជាព្រះពរ និងឯកសិទ្ធិមួយ។ ខ្ញុំជំពាក់គុណជាច្រើនដល់ក្រុមនៅ ៩Marks និង Crossway ដែលបានផ្ដល់ឱកាសឲ្យខ្ញុំសរសេរ ហើយជាពិសេសចំពោះ លោកចនណាថាន់ លីម៉ាន (Jonathan Leeman) ហើយនិងលោក លីឌា ប្រោនប៊ែក (Lydia Brownback) សម្រាប់ការផ្ដល់ជំនួយ និងការណែនាំដែលមិនអាចសងជាកម្រៃបាន។ សូមថ្លែងអំណរគុណផងដែរចំពោះគូរកនបម្រើរួមការងាររបស់ខ្ញុំនៅក្នុងដំណឹងល្អនៅពួកជំនុំ ហ្វឹស បាបទិស្ទ នៅ ហ្គ្រែន ខេមិន (First Baptist Church of Grand Cayman) បងប្អូនពួកជំនុំ បុគ្គលិក និងអ្នកដឹកនាំដែលពួកគាត់ទាំងអស់គ្នាបានផ្ដល់ការលើកទឹកចិត្ត ដែលចង្អុលទៅកាន់ព្រះ ហើយក៏បានផ្ដល់ជាគំរូច្រើននៃអ្វីដែលមានសរសេរឡើងនៅក្នុងសៀវភៅនេះ។ ហើយបើគ្មាន គ្រីស្ទី (Kristie) ជាអ្នកជួយដែលខ្ញុំមិនស័ក្តិសមទទួលបាន និងជាព្រះពរដ៏ច្រើនលើសជាងអ្វីដែលខ្ញុំសមនឹងទទួលទេ នោះការងាររបស់ខ្ញុំនឹងមិនសូវទទួលបានផ្លែផ្កា អំណរ និងដំណើរដែលគួរឲ្យចាប់អារម្មណ៍នោះទេ។ ខ្ញុំថ្វាយការអរព្រះគុណយ៉ាងខ្លាំងចំពោះព្រះជាម្ចាស់សម្រាប់ព្រះគុណ និងការណែនាំរបស់ទ្រង់ នៅពេលដែលខ្ញុំបានសរសេរជំពូកទាំងនេះឡើង។ អ្វីៗគ្រប់យ៉ាងដែលមាន

9Marks Online PDF

តម្លៃនៅក្នុងសៀវភៅនេះ គឺកើតចេញពីការធ្វើការរបស់ទ្រង់ មិនមែនជារបស់ខ្ញុំទេ ហើយបើមានភាពមិនត្រឹមត្រូវនៅក្នុងសៀវភៅនេះ នោះគឺដោយសារតែភាពកម្សោយ និងការអសមត្ថភាពរបស់ខ្ញុំ។

នៅពេលដែលខ្ញុំឆ្លុះបញ្ចាំងអំពីភាពទន់ខ្សោយរបស់ខ្ញុំ ក្នុងនាមជាគ្រីស្ទបរិស័ទ ជាគ្រូគង្វាល និងជាសមាជិកពួកជំនុំ ខ្ញុំក៏ទទួលបានការរម្លឹកថា លោកអ្នកក៏អាចជាមានភាពទន់ខ្សោយដែលប៉ះពាល់ដល់ការអានសៀវភៅនេះដូចគ្នាផងដែរ។ មានភាពទន់ខ្សោយពីរយ៉ាងផ្សេងៗពីគ្នា។

ទីមួយ វាអាចទៅរួចទាំងស្រុងបានក្នុងការអានសៀវភៅនេះ ហើយវាយតម្លៃខ្លួនឯងខណៈពេលដែលលោកអ្នកបាត់បង់ការមើលឃើញព្រះយេស៊ូវគ្រីស្ទ និងឈើឆ្កាងទាំងស្រុង។ ដែលនេះមានន័យថា លោកអ្នកអាចទំនងជាអានសៀវភៅនេះ ហើយទាសចេញឆ្ងាយដោយគិតតែពី “ការធ្វើ ធ្វើ ធ្វើ” ជំនួសឲ្យការពឹងលើ “ព្រះគុណ ព្រះគុណ ព្រះគុណ” ឬ “ការទុកចិត្តព្រះ ការទុកចិត្តព្រះ ការទុកចិត្តព្រះ” ទៅវិញ។ ជំពូកនីមួយៗអាចបានក្លាយទៅជាផែនទីបង្ហាញផ្លូវសម្រាប់លោកអ្នកក្នុងការអភិវឌ្ឍន៍ខ្លួនឯង និងការប្រឹងប្រែង កាតព្វកិច្ច ហើយក៏ទំនងការងារដ៏ពិបាកជាប្រចាំថ្ងៃផងដែរ។

ការប្រឹក្សានៃសៀវភៅនេះគឺមិនមែនជាវេជ្ជបញ្ជា ដើម្បីទទួលយកដោយមិនពឹងផ្អែកទៅលើព្រះគុណរបស់ព្រះជាម្ចាស់នៅក្នុងដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទនោះទេ ។ ការថ្កោលទោស និងការវិនិច្ឆ័យ ឬទស្សនៈគ្មានព្រះនិយម មិនមែនជាលទ្ធផលរំពឹងទុករបស់សៀវភៅនេះទេ។ ផ្ទុយទៅវិញ ខ្ញុំអធិស្ឋានឲ្យលោកអ្នកអាចអានសៀវភៅនេះ “*តើសមាជិកពួកជំនុំដែលមានសុខភាពល្អជាអ្វី?* ដោយមានចិត្តអង្វរចង់ឲ្យព្រះអម្ចាស់នៃពួកជំនុំអាចដាស់ពួកបរិសុទ្ធម្នាក់ៗ ដោយការអស្ចារ្យ ដើម្បីឲ្យពួកគេ

9Marks Online PDF

បម្រើតាមរបៀបដ៏អស្ចារ្យណាមួយ។ ខ្ញុំអធិស្ឋាន សូមឲ្យមានការពឹងផ្អែកយ៉ាងជ្រាលជ្រៅទៅលើដើមទំពាំងបាយជូរដ៏ពិត ព្រោះបើដាច់ចេញពីដើមនោះ នោះយើងមិនអាចធ្វើអ្វីបានទាំងអស់។ ខ្ញុំអធិស្ឋានសូមឲ្យដើមទំពាំងបាយជូរដ៏ពិតចម្រើនឡើងនៅក្នុងចិត្តរបស់យើងម្នាក់ៗ នៅពេលដែលយើងកាន់តែចង់ក្លាយជាអ្វីដែលព្រះគ្រីស្ទកំពុងធ្វើឲ្យយើងក្លាយជាយ៉ាងនោះ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រះអម្ចាស់ជំរុញលោកអ្នកឲ្យដាក់ការលើកឡើងនៃសៀវភៅនេះទៅជាការអនុវត្តន៍ផងដែរ។ មិនថាលោកអ្នកនឹងឆ្លើយតបយ៉ាងដូចម្ដេចចំពោះសំណើនៅក្នុងសៀវភៅនេះ ទាក់ទងទៅនឹងការអនុវត្ត ខ្ញុំសូមអធិស្ឋានឲ្យលោកអ្នកធ្វើវាដោយមានការយល់ដឹងកាន់តែច្រើនឡើង និងការពឹងផ្អែកលើជីវិតរបស់ព្រះគ្រីស្ទដែលឥឡូវនេះទ្រង់កំពុងតែធ្វើការនៅក្នុងលោកអ្នក ហើយព្រះវិញ្ញាណក៏បានដៅចំណាំលោកអ្នក ព្រមទាំងប្រទានអំណាចដល់គ្រីស្ទបរិស័ទ ដើម្បីឲ្យធ្វើការល្អគ្រប់ជំពូកបានដែរ។

ទីពីរ វាអាចទៅរួចក្នុងការអានសៀវភៅនេះតាមបែបទស្សនៈបុគ្គលនិយម។ លោកអ្នកអាចនឹងអានចប់សៀវភៅនេះហើយគិតថា «ខ្ញុំត្រូវតែផ្លាស់ប្ដូរខ្លួនខ្ញុំ»។ ហើយប្រាកដណាស់ មានចំណុចជាច្រើនដែលយើងត្រូវរីកចម្រើន ហើយដោយព្រះគុណរបស់ព្រះ នោះយើងនឹងអាចរីកចម្រើនយ៉ាងច្រើនបាន គឺរហូតដល់ព្រះគ្រីស្ទយាងមកវិញ។ ប៉ុន្តែ សៀវភៅនេះនិយាយអំពីពួកជំនុំ ដែលជារូបកាយរបស់ព្រះគ្រីស្ទទាំងមូល នៅកន្លែងជាក់លាក់ណាមួយ។ ភាគច្រើនបានលើកឡើងអំពីតួនាទីរបស់លោកអ្នក និងតួនាទីរបស់ខ្ញុំនៅក្នុងរូបកាយនោះ ប៉ុន្តែទាំងលោកអ្នក និងខ្ញុំ យើងគឺសម្រាប់ និងជាកម្មសិទ្ធិរបស់អ្នកផ្សេងទៀតដែលប្រមូលផ្ដុំគ្នាជារាស្ត្ររបស់ព្រះជាម្ចាស់ (រ៉ូម ១២:៥)។ ដូច្នេះ វិធីដ៏ល្អបំផុត ដើម្បីដាក់សៀវភៅនេះទៅ

9Marks Online PDF

ជាការអនុវត្តន៍ គឺយើងត្រូវធ្វើជាមួយភាពជាដៃគូ ការគាំទ្រគ្នា និងសេចក្ដីស្រឡាញ់របស់គ្រីស្ទបរិស័ទដទៃទៀត នៅក្នុងពួកជំនុំតាមតំបន់របស់លោកអ្នក។ សូមកុំធ្វើជា "គ្រីស្ទបរិស័ទផ្ដាច់ខ្លួន" ខ្វល់ខ្វាយទាំងស្រុង ឬដោយមិនគិតវែងឆ្ងាយ ព្រោះគិតតែអំពីខ្លួនឯង។ ចូររួមដៃជាមួយអ្នកដទៃដែលស្រឡាញ់ព្រះអម្ចាស់ ហើយស្រឡាញ់ពួកជំនុំរបស់ទ្រង់ ហើយរីកចម្រើនជាមួយគ្នានៅក្នុងព្រះគុណ និងចំណេះដឹងអំពីព្រះអម្ចាស់យេស៊ូវគ្រីស្ទរបស់យើង។

អ្នកនិពន្ធម្នាក់ឈ្មោះ ជែរី ប្រ៊ីជីស (Jerry Bridges) បានរម្លឹកអំពីការយល់ដឹងរបស់គាត់លើពួកជំនុំតាមតំបន់ក្នុងកំឡុងឆ្នាំដំបូងៗនៃការដើរក្នុងជីវិតជាគ្រីស្ទបរិស័ទរបស់គាត់។ គាត់សរសេរថា៖

> អស់ជាច្រើនឆ្នាំ ខ្ញុំបានយកវិធីសាស្ត្របុគ្គលនិយម (individualistic approach) ចំពោះជីវិតជាគ្រីស្ទាន។ ខ្ញុំមានការព្រួយបារម្ភអំពីការរីកចម្រើនរបស់ខ្ញុំក្នុងនាមជាគ្រីស្ទបរិស័ទ ការរីកចម្រើនរបស់ខ្ញុំក្នុងភាពបរិសុទ្ធ ការចេះដឹងរបស់ខ្ញុំអំពីការបម្រើនៅក្នុងព័ន្ធកិច្ច។ ខ្ញុំបានអធិស្ឋានសូមឲ្យព្រះជាម្ចាស់ជួយខ្ញុំឲ្យបានបរិសុទ្ធជាងមុនក្នុងជីវិតផ្ទាល់ខ្លួនរបស់ខ្ញុំ និងមានប្រសិទ្ធភាពកាន់តែខ្លាំងក្នុងការផ្សាយដំណឹងល្អរបស់ខ្ញុំ។ ខ្ញុំបានអធិស្ឋានសូមព្រះពរសម្រាប់ពួកជំនុំរបស់ខ្ញុំ និងអង្គការគ្រីស្ទានដែលខ្ញុំបម្រើការ។ ប៉ុន្តែ នៅពេលខ្ញុំបានរៀនបន្ថែមទៀតអំពីការប្រកបគ្នាដ៏ពិតប្រាកដ នោះខ្ញុំក៏បានចាប់ផ្ដើមអធិស្ឋានថា យើងដែលជារូបកាយរបស់ព្រះគ្រីស្ទ សូមឲ្យយើងបានរីកចម្រើននៅក្នុងភាពបរិសុទ្ធ សូមឲ្យយើងក្លាយជាស្មរបន្ទាល់ដែលកាន់តែមានប្រសិទ្ធភាពថែមទៀត ចំពោះព្រះគុណនៃសេចក្ដីសង្គ្រោះរបស់ព្រះគ្រីស្ទ។ រូបកាយទាំងមូល (មិនមែនតែខ្ញុំទេ) ដែលត្រូវតែរីកចម្រើន។

9Marks Online PDF

ក្តីសង្ឃឹមរបស់ខ្ញុំគឺថា ការផ្លាស់ប្តូរដូចគ្នា គឺពី «ខ្ញុំ» ទៅ «យើង» ដែលលោក ដេវើ ប្រ៊ីជីស បានពណ៌នានឹងក្លាយជាការពិតទ្បើងៗសម្រាប់រាស្ត្ររបស់ព្រះអង្គ។ ខ្ញុំអធិស្ឋានថា សៀវភៅដ៏ខ្លីនេះនឹងមានចំណែកមួយចំនួនក្នុងការបង្កើនសេចក្តីស្រឡាញ់របស់យើងចំពោះរូបកាយនៃព្រះអង្គសង្គ្រោះរបស់យើង ហើយការធ្វើបែបនេះនឹងដឹកនាំពួកជំនុំទៅកាន់ភាពរឹងមាំ ការមានជីវិតរស់រវើក និងសុខភាពល្អកាន់តែខ្លាំងទ្បើង។

9Marks Online PDF

ឧបសម្ព័ន្ធ៖

# សេចក្តីសញ្ញាទូទៅនៃពួកជំនុំដែលមានសុខភាពល្អ

**យើងជឿទុកចិត្តថា** ព្រះគុណនៃព្រះជាម្ចាស់បាននាំយើងមក ដើម្បីប្រែចិត្ត ហើយជឿលើព្រះអម្ចាស់យេស៊ូវគ្រីស្ទ ហើយយើងត្រូវថ្វាយជីវិតយើងដាច់ដល់ទ្រង់។ ហើយយើងក៏បានទទួលបុណ្យជ្រមុជទឹកដោយការប្រកាសសេចក្តីជំនឿរបស់យើង ក្នុងព្រះនាមនៃព្រះវរបិតា ព្រះរាជបុត្រា និងព្រះវិញ្ញាណបរិសុទ្ធ។ ឥឡូវនេះ យើងធ្វើសេចក្តីសញ្ញាដោយពឹងអាងសេចក្តីជំនួយដ៏ទន់សន្តោសរបស់ទ្រង់ ហើយយើងបន្តសេចក្តីសញ្ញារបស់យើងជាមួយគ្នាទៅវិញទៅមកដោយម៉ឺងម៉ាត់ និងដោយអំណរ។

យើងនឹងធ្វើការ ហើយអធិស្ឋានឲ្យមានការរួបរួមនៃព្រះវិញ្ញាណក្នុងចំណងនៃសេចក្តីមេត្រី។

យើងនឹងដើររួមគ្នានៅក្នុងសេចក្តីស្រឡាញ់ជាបងប្អូន ខណៈដែលយើងក្លាយជាសមាជិកនៃពួកជំនុំគ្រីស្ទបរិស័ទ។ យើងនឹងអនុវត្តការយកចិត្តទុកដាក់ដោយសេចក្តីស្រឡាញ់ និងការប្រុងប្រយ័ត្នសម្រាប់គ្នាទៅវិញទៅមក ហើយដាស់តឿនដោយស្មោះត្រង់ និងអង្វរគ្នាទៅវិញទៅមកនៅពេលចាំបាច់ផងដែរ។

9Marks Online PDF

យើងនឹងមិនបោះបង់ការជួបជុំគ្នា ហើយក៏មិនធ្វេសប្រហែសក្នុងការអធិស្ឋានសម្រាប់ពួកយើង និងអ្នកដទៃទៀតដែរ។

យើងនឹងខិតខំចិញ្ចឹមបីបាច់អ្នក ដែលនៅក្រោមការមើលថែរបស់យើង ក្នុងការចិញ្ចឹមបីបាច់ និងការដាស់តឿនរបស់ព្រះអម្ចាស់ និងដោយគំរូដ៏បរិសុទ្ធ និងដោយក្តីស្រឡាញ់ យើងក៏នឹងស្វែងរកសេចក្តីសង្គ្រោះនៃគ្រួសារ និងមិត្តភក្តិរបស់យើងផងដែរ។

យើងនឹងត្រេកអរចំពោះសេចក្តីអំណររបស់គ្នាទៅវិញទៅមក និងការព្យាយាមដោយភាពទន់ភ្លន់ និងការអាណិតអាសូរ ដើម្បីយកអាសាគ្នា និងទុក្ខព្រួយរបស់គ្នាទៅវិញទៅមក។

ដោយជំនួយរបស់ព្រះ យើងនឹងព្យាយាមរស់នៅដែលប្រុងប្រយ័ត្នក្នុងពិភពលោកនេះ ដោយបដិសេធអំពើទុច្ចរិត និងតណ្ហាខាងលោកីយ៍។ ហើយចងចាំថា ខណៈពេលដែលយើងត្រូវបានបញ្ចុះដោយស្ម័គ្រចិត្តដោយពិធីជ្រមុជទឹក ហើយបានលើកឡើងពីផ្នូរ (ដែលជានិមិត្តសញ្ញា) ដូច្នេះឥឡូវនេះ យើងមានកាតព្វកិច្ចពិសេសមួយគឺត្រូវរស់នៅក្នុងជីវិតថ្មី និងបរិសុទ្ធមួយនេះ។

យើងនឹងធ្វើការជាមួយគ្នា ដើម្បីបន្តការបម្រើផ្សាយដំណឹងល្អដ៏ស្មោះត្រង់ក្នុងពួកជំនុំនេះ នៅពេលយើងបន្តរក្សាការថ្វាយបង្គំ ពិធីបង្គូរព្រះគុណ ការដាក់វិន័យ និងគោលលទ្ធិនៃពួកជំនុំនេះ។ យើងនឹងរួមចំណែកដោយរីករាយ និងទៀងទាត់ដើម្បីគាំទ្រក្នុងព័ន្ធកិច្ច ការចំណាយរបស់ពួកជំនុំ ការជួយជនក្រីក្រ និងការផ្សព្វផ្សាយដំណឹងល្អដល់អស់ទាំងសាសន៍។

នៅពេលដែលយើងផ្លាស់ប្តូរទីលំនៅចេញពីកន្លែងនេះ យើងនឹងរួបរួមជាមួយនឹងពួកជំនុំផ្សេងទៀត ឲ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ ហើយនៅជាមួយពួកជំនុំថ្មីនោះ ហើយយើងនឹងអនុវត្តវិញ្ញាណនៃសេចក្តី

9Marks Online PDF

សញ្ញានេះ និងគោលការណ៍នៃព្រះបន្ទូលនៃព្រះជាម្ចាស់ផងដែរ។

សូមឲ្យព្រះគុណនៃព្រះអម្ចាស់យេស៊ូវគ្រីស្ទ និងសេចក្តីស្រឡាញ់នៃព្រះ និងការប្រកបគ្នានៃព្រះវិញ្ញាណបរិសុទ្ធបានគង់នៅជាមួយយើងទាំងអស់គ្នា។ អាម៉ែន។

# កំណត់ចំណាំផ្សេងៗ

## សេចក្ដីផ្ដើម

១. ប្រសិនបើលោកអ្នកជាគ្រីស្ទបរិស័ទ ប៉ុន្តែលោកអ្នកមិនមែនជាសមាជិកម្នាក់នៅក្នុងក្រុមជំនុំណាមួយ សូមអនុញ្ញាតឲ្យខ្ញុំណែនាំសៀវភៅដ៏ល្អមួយក្បាល ដែលបានសរសេរឡើង ដើម្បីជួយ ឲ្យលោកអ្នកគិតអំពីមូលហេតុ ដែលលោកអ្នកគួរក្លាយជាសមាជិកនៅក្នុងក្រុមជំនុំ។ ចំណងជើងសៀវភៅជាភាសាអង់គ្លេសគឺៈ Stop Dating the Church និពន្ធដោយលោក Joshua Harris (Sisters, OR: Multnomah, ឆ្នាំ ២០០៤)។

## សញ្ញាសម្គាល់ទី១ៈ សមាជិកពួកជំនុំ ដែលមានសុខភាពល្អម្នាក់ គឺជាអ្នកស្ដាប់ សេចក្ដីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ

១. លោក Mark Dever, Nine Marks of a Healthy Church (Wheaton,IL: Crossway Books, ឆ្នាំ ២០០៤), ទំព័រ៤០។

២. កាលលោក ចនណាសិន អ៊ែតវើត (Jonathan Edwards) មានអាយុ១៩ឆ្នាំ គាត់ក៏បានសរសេរការប្ដេជ្ញាចិត្តនេះដូចតទៅៈ «ការ

9Marks Online PDF

ប្ដេជ្ញាចិត្តៈ នៅពេលដែលខ្ញុំមានចម្ងល់អ្វីមួយទាក់ទងទៅនឹងព្រះជាម្ចាស់ ដែលខ្ញុំត្រូវរកចម្លើយ ភ្លាមនោះខ្ញុំនឹងព្យាយាមធ្វើអ្វីដែលខ្ញុំអាចធ្វើបាន ដើម្បីរកចម្លើយលើសំណួរ ប្រសិនបើកាលៈទេសៈមិនរារាំងខ្ញុំក្នុងការធ្វើបែបនោះ»។ The Works of Jonathan Edwards, ភាគ១ (Peabody, MA: Hendrickson), ទំព័រ៦២។

## សញ្ញាសម្គាល់ទី២៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកសិក្សាស្រាវជ្រាវទេវវិទ្យាតាមព្រះគម្ពីរ

១. លោក J. I. Packer, Knowing God, ២0th Anniversary Edition (Downers Grove, IL: Inter Varsity ឆ្នាំ១៩៩៣) ទំព័រ១២។

២. លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books, ឆ្នាំ២០០៤) សូមអានជំពូកទី២។

៣. លោក Wayne Grudem, Systematic Theology (Grand Rapids, MI: Zondervan, ឆ្នាំ១៩៩៤) ទំព័រ២៦-៣០។

៤. លោក Jeremy Farmer "សារនៃព្រះគម្ពីរ" (The Message of the Bible) បោះពុម្ពផ្សាយដោយ EMU។ លោកអ្នកអាចទាញយកសៀវភៅនេះដោយមានគិតថ្លៃនៅក្នុងគេហទំព័រ៖ cambodianchristianresources.com

៥. សូមទំនាក់ទំនងទៅកាន់រោងពុម្ពប្រែភពប្រាជ្ញា ឬក៏ចូលទៅកាន់គេហទំព័រ www.fountofwisdomph.com ដើម្បីជាវសៀវភៅទាំងនេះ។

9Marks Online PDF

៦. លោកអ្នកអាចទាញយកសៀវភៅនេះដោយមានគិតថ្លៃនៅក្នុងគេហទំព័រ៖ cambodianchristianresources.com/books/what-the-bible-teaches
៧. សូមទំនាក់ទំនងទៅកាន់រោងពុម្ពប្រភពប្រាជ្ញា ឬក៏ចូលទៅកាន់គេហទំព័រ www.fountofwisdomph.com ដើម្បីជាវសៀវភៅទាំងនេះ។

## សញ្ញាសម្គាល់ទី៣៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកជ្រាបជោគនៅក្នុងដំណឹងល្អ

១. លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books), សូមអានជំពូក៣។
២. លោកគ្រូ John Piper, God Is the Gospel: Meditations on God’s Love as the Gift of Himself (Wheaton, IL: Crossway Books, ឆ្នាំ២០០៥), ទំព័រ៣៨។ អក្សរដិតមាននៅក្នុងការបោះពុម្ពដើម។

## សញ្ញាសម្គាល់ទី៤៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ

១. ឧទាហរណ៍៖ យ៉ូហាន ១:១២-១៣; ៣:៣-៨; ៦:៤៤; ១៥:១៦; កិច្ចការ ១១:១៨; អេភេសូរ ១:១៣-១៤; ២:១-៩; ១ពេត្រុស ១:២៣; និង១យ៉ូហាន ៤:១០។

9Marks Online PDF

## សញ្ញាសម្គាល់ទី៥៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកដែលប្រកាសដំណឹងល្អតាមព្រះគម្ពីរ


១. លោក Phillip D. Jensen និងលោក Tony Payne, "Church/Campus Connections: Model ១," in Telling the Truth: Evangelizing Postmoderns, កែសម្រួលដោយលោក D. A. Carson (Grand Rapids, MI: Zondervan), ទំព័រ១៩៥។

២. លោក Michael P. Andrus, "Turning to God: Conversion beyond Mere Religious Preference," in Telling the Truth; see pp. ទំព័រ១៥៥-៦១។

៣. លោក Mark Dever, Nine Marks of a Healthy Church (Wheaton, IL: Crossway Books, ឆ្នាំ២០០៤), ទំព័រ១២៤-៣០។

៤. លោក Michael Andrus, "Turning to God," ទំព័រ១៦១-៦២។


## សញ្ញាសម្គាល់ទី៦៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាសមាជិកដែលមានការប្ដេជ្ញាចិត្ត


១. លោក Mark Dever and លោកPaul Alexander, The Deliberate Church: Building Your Ministry on the Gospel (Wheaton, IL: Crossway, ឆ្នាំ២០០៥), ទំព័រ៦០-៦១។

២. លោក Dietrich Bonhoeffer, Life Together (New York: Harper and Row, ឆ្នាំ១៩៥៤)។


9Marks Online PDF

## សញ្ញាសម្គាល់ទី៧៖ សមាជិកពួកជំនុំដែលមានសុខភាព ល្អម្នាក់គឺជាអ្នកដែលស្វែងរកការដាក់វិន័យ

១. ឧទាហរណ៍៖ ១ថែស្សាឡូនិច ៤:២២ និង ២ថែស្សាឡូនិច ៣:៦, ១១។

២. លោក Jay Adams, Handbook on Church Discipline: A Right and Privilege of Every Church Member (Grand Rapids, MI: Zondervan, ឆ្នាំ១៩៧៤), ទំព័រ១៦។

៣. លោក C. J. Mahaney, Living the Cross Centered Life: Keeping the Gospel the Main Thing (Sisters, OR: Multnomah, ឆ្នាំ២០០៦)។ សូមអានជំពូក២។

៤. នេះគឺជាអាកប្បកិរិយារបស់មនុស្សដែលមិនកោតខ្លាចព្រះនៅក្នុងកណ្ឌគម្ពីរ រ៉ូម ១:១៨, ២១ “ដែលបង្ខាំងសេចក្តីពិត” ហើយ “មិនបានតម្កើងទ្រង់ ទុកជាព្រះទេ ក៏មិនដឹងគុណទ្រង់ដែរ”។

៥. សូមមើលក្នុងជំពូកឧបសម្ពន្ធ៖ សេចក្តីសញ្ញាសាមញ្ញមួយនៃពួកជំនុំដែលមានសុខភាពល្អ សម្រាប់ជាគំរូ។

៦. សូមអាន ម៉ាថាយ ១៨:១៧ និង១កូរិនថូស ៥:៤-៥។

៧. ឧទាហរណ៍៖ ម៉ាថាយ ១៨:១៥ និងកាឡាទី ៦:១។

## សញ្ញាសម្គាល់ទី៨៖ សមាជិកពួកជំនុំដែលមានសុខភាព ល្អម្នាក់គឺជាអ្នកដែលលូតលាស់ខាងឯភាពជាសិស្ស

១. The Works of Jonathan Edwards, ភាគ១ (Peabody, MA: Hendrickson, ឆ្នាំ១៩៩៨), ទំព័រ៦២។

២. លោក Mark Dever, Nine Marks of a Healthy Church

9Marks Online PDF

(Wheaton, IL: Crossway Books, ឆ្នាំ២០០៤), ទំព័រ២១៤។
៣. លោក Don Carson, The Gospel of John: An Introduction and Commentary, Pillar New Testament Commentary Series (Grand Rapids, MI: Eerdmans, ឆ្នាំ១៩៩១), ទំព័រ៥១៧។
៤. ក្នុងសៀវភៅដូចគ្នា។

## សញ្ញាសម្គាល់ទី១០៖ សមាជិកពួកជំនុំដែលមានសុខភាពល្អម្នាក់គឺជាអ្នកចម្បាំងខាងសេចក្តីអធិស្ឋាន

១. លោក Graeme Goldsworthy, Prayer and the Knowledge of God: What the Whole Bible Teaches (Downers Grove, IL: Inter Varsity ឆ្នាំ២០០៣) ទំព័រ៥១។
២. ក្នុងសៀវភៅដូចគ្នា, ទំព័រ១៦។
៣. ក្នុងសៀវភៅដូចគ្នា, ទំព័រ៣៥។
៤. ក្នុងសៀវភៅដូចគ្នា, ទំព័រ៦១-៦១។

## បណ្តាំចុងក្រោយ

១. លោក Jerry Bridges, The Crisis of Caring: Recovering the Meaning of True Fellowship (Phillipsburg, NJ, P&R,ឆ្នាំ១៩៨៥), ៧១-៧២។ អក្សរទ្រេតមាននៅក្នុងការបោះពុម្ពដើម។

9Marks Online PDF

# លិបិក្រមតាមព្រះគម្ពីរ

## កណ្ឌគម្ពីរសញ្ញាចាស់


### លោកុប្បត្តិ

៣:១៥ ៤៣

១៧:១៥ ៤៣

### ទំនុកតម្កើង

៤២:៤ ១០៨

១១៩:១០៣ ២៩

### សុភាសិត

១:៧ ១២១

២០:៣ ៥៤

២៧:៥ ១២០

### អេសាយ

៦:៩ ៣៤

៧:១៤ ៤៣

៤៥:២២ ៤៤

៥៥:១១ ៩០

៥៦:៧ ១៥៨


## កណ្ឌកម្ពីរសញ្ញាថ្មី


### ម៉ាថាយ

១:២០ ៤៣

៣:១ ៩០

៤:១៧ ៩១

៥:៣ ៧៧

៥:៤ ១២២

៥:៥ ១០៥

៥:១០ ១៦៩

៥:២៣ ១០៥

៥:៤៥ ១៦៩

៥:៤៦ ១៦៩

៩:៣៦ ១៦៦

១៨:១៥ ១០០, ១១៦, ១២២, ១៨៧

១៨:១៧ ១២២, ១៨៧

១៨:២១ ១០៥, ១៦៩


9Marks Online PDF

២១:១៣ ១៥៩
២៦:៤១ ១៦៨
២៨:១៩ ៤៥

## ម៉ាកុស

១០:៤៥ ១០៤
១១:១៧ ១៥៩

## លូកា

៦:២៨ ១៦៩
១៨:១ ១៥៣
១៨:៩ ១២៩
២៤:២៧ ៤៦

## យ៉ូហាន

១:៦ ៧៨, ៨៤
១:១០ ៦៨
១:១២ ៧៥, ១៨៥
២:១៥ ៧៩, ៨៤
២:២២ ៧៩
៣:២ ១៤០
៣:៥ ៧៨
៣:១៤ ៨០, ៨៤
៣:១៨ ៨០
៣:២៤ ៨១, ៨៤
៤:១០ ៧៥, ១៨៥
៤:១៣ ៨១
៥:១ ៨០
៥:៤ ៨១, ៨៤
១០:២៧ ២៩
១៣:៣៤ ៩៤, ១០២
១៤:៦ ៩០
១៥:៥ ១៣៥
១៧:២១ ៣១

## កិច្ចការ

១:១៤ ១៥៩
២:៣៨ ៩១
២:៤២ ១៥៩
៤:១២ ៩០
៦:១ ១៥០
៦:៣ ១៥០
១១:១៨ ៧៥, ១៨៥

## រ៉ូម

១:១៦ ២៣, ៩៥
១:១៧ ៨៩
១:១៨ ១១៩, ១៨៧
៨:៥ ៧៤
៨:១៤ ១៦៦
៨:១៥ ៨១, ៨៤

៨:១៦ ៨១

៨:២៦ ១៦៥, ១៦៥, ១៦៦

១០:១៧ ៣៧

១២:៥ ១៧៥

១២:៦ ១០៧

១២:១២ ១៦៤

១២:១៦ ៣១

១៣:១ ១៦៨

១៤:១០ ៤៤

១៤:១៩ ១០៤

១៥:១ ១០៥


## ១កូរិនថូស


១:៨ ៣៧

១:១០ ៣១

៣:៧ ៩០

៣:៩ ៨៩

៤:១ ៩០

៥:២ ១២២

៥:៤ ១២២, ១៨៧

៥:៩ ១០១

៧:៥ ១៥៩

១០:១១ ៤៥

១៤:៤០ ១១៣


## ២កូរិនថូស


១:១៤ ១៤៥

២:៦ ១០១, ១២៣

៥:១៨ ១០៥

៥:២០ ៨៩

៦:១១ ១៤៦

៧:២ ១៤៧

៨:៥ ១៤៧

៩:១៣ ១៥៥

១០:១៥ ១៥៥

១២:១៥ ១៤៧

១៣:៥ ៧៧

១៣:១១ ៣១


## កាឡាទី


១:៨ ៦៧

៤:៦ ៨១, ៨៤

៥:១៦ ១៦៨

៥:២២ ៧៧, ១៣៣

៦:១ ១២២, ១៨៧

៦:២ ១០៥


## អេភេសូរ


១:១៣ ៧៥, ៨២, ១៨៥

២:១ ៧៤


9Marks Online PDF

៤:១១ ១០៤, ១៣៤, ១៣៨
៦:១ ១៦៨
៦:១៨ ១៦៦, ១៦៧
៦:១៩ ១៥៣, ១៦៧

**ភីលីព**

១:១៩ ១៦៧
១:២៧ ៥៣
២:៩ ៤៤
២:១២ ៧៧
៣:១២ ១២៧
៣:១៧ ១៥២

**កូឡូស**

១:១០ ១៣២
២:១៨ ៣៧
៣:១ ១៦៤
៤:២ ១៥៣, ១៦៤
៤:១២ ១៦៤

**១ថែស្សាឡូនីច**

៣:១១ ១៣២
៤:៣ ១៦៨
៥:១៧ ១៦៤

**២ថែស្សាឡូនីច**

១:៣ ១៣២

៣:៦ ១១៧

**១ធីម៉ូថេ**

២:១ ១៦៨
៣:១ ១០០
៤:៧ ៤៥
៤:១២ ១៥២, ១៥២
៥:៩ ១០១
៥:១៣ ១០៥
៥:១៧ ៣០, ១៤៤
៥:២២ ១៥០

**២ធីម៉ូថេ**

២:១៤ ៥៣
២:២៤ ១៤៨
៣:១៦ ១១៥
៤:៣ ៣០

**ទីតុស**

១:៥ ១០០
២:៧ ១៥២
២:១១ ១៣៧
២:១៣ ១៣៩
៣:១០ ១១៧

**ហេព្រើរ**

១:១ ៤៤

៥:១១ ៣៤, ១២៧
៦:១ ១២៧, ១៣២
១០:២៤ ១០៣, ១០៤
១០:២៥ ១៣៧
១២:១១ ១១៣
១៣:១៧ ១០០, ១០០, ១៥១

## យ៉ាកុប

១:២១ ១១៧
១:២២ ៣៥
៣:១៨ ១០៤
៤:៦ ១៣១
៥:១៩ ១២៣

## ១ពេត្រុស

១:៣ ៨២
១:២៣ ៧៥, ១៨៥
៣:៨ ៣១
៥:៣ ១៥២
៥:៥ ១៣១
៥:៦ ៣៧

## ២ពេត្រុស

១:៥ ៧៧, ១៣២
២:២ ៦៨
៣:១៨ ១៣៣

## ១យ៉ូហាន

១:៦ ៧៨, ៨៤
២:១៥ ៧៩, ៨៤
២:២២ ៧៩
៣:២ ១៤០
៣:៥ ៧៨
៣:១៤ ៨០, ៨៤
៣:១៨ ៨០
៣:២៤ ៨១, ៨៤
៤:១០ ៧៥, ១៨៥
៤:១៣ ៨១
៥:១ ៨០
៥:៤ ៨១, ៨៤

## ២យ៉ូហាន

១:១០ ៦៨

យូដាស

១:៣ ៥៣, ៦៨


9Marks Online PDF

IX 9Marks

Building Healthy Churches

ការកសាងក្រុមជំនុំដែលមានសុខភាពល្អ

ព័ន្ធកិច្ច ៩Marks គឺដើម្បីជួយអ្នកដឹកនាំក្រុមជំនុំឲ្យមានចក្ខុវិស័យព្រះគម្ពីរ និងធនធានជាក់ស្តែងសម្រាប់បង្ហាញសិរីល្អរបស់ព្រះដល់ប្រជាជាតិនានា តាមរយៈក្រុមជំនុំដែលមានសុខភាពល្អ។

ដើម្បីបំពេញការនោះ យើងចង់ឃើញក្រុមជំនុំដែលមានសុខភាពល្អ ដោយមានលក្ខណៈ ៩ យ៉ាងខាងក្រោមនេះ៖

១. សេចក្តីអធិប្បាយតាមអត្ថន័យព្រះគម្ពីរ
២. គោលលទ្ធិដែលផ្តោតលើដំណឹងល្អ
៣. ការយល់ដឹងដែលបានផ្លាស់ប្រែចិត្តយ៉ាងពិតប្រាកដ និងប្រកាសដំណឹងល្អតាមព្រះគម្ពីរ
៤. ការយល់ដឹងដ៏ត្រឹមត្រូវពីសមាជិកភាពនៃពួកជំនុំតាមព្រះគម្ពីរ
៥. ការយល់ដឹងពីការដាក់វិន័យពួកជំនុំតាមព្រះគម្ពីរ
៦. ការយល់ដឹងពីការបង្កើតសិស្ស និងការលូតលាស់តាមព្រះគម្ពីរ
៧. ការយល់ដឹងពីការដឹកនាំពួកជំនុំតាមព្រះគម្ពីរ
៨. ការយល់ដឹងពីការអធិស្ឋានតាមព្រះគម្ពីរ
៩. ការយល់ដឹងពីការធ្វើបេសកកម្ម

នៅ ៩Marks យើងបានសរសេរអត្ថបទផ្សេងៗ សៀវភៅជាច្រើន ការពិនិត្យសៀវភៅឡើងវិញ និងទស្សនាវដ្តីតាមប្រព័ន្ធអ៊ីនធឺណិត។ ពួកយើងក៏បានរៀបចំសន្និសីទ បានថតទុកការសម្ភាសន៍ និងផលិតធនធានផ្សេងៗទៀត ដើម្បីជួយទ្រទ្រង់ក្រុមជំនុំ និងបង្ហាញពីសិរីល្អរបស់ព្រះ។

9Marks Online PDF

សូមចូលទៅកាន់គេហទំព័ររបស់យើង ដើម្បីស្វែងរកមាតិកាជាង ៤0+ ភាសា ហើយចុះឈ្មោះ ដើម្បីទទួលបានទស្សនាវដ្ដីតាមប្រព័ន្ធអ៊ីនធឺណិតរបស់យើង ដោយឥតគិតថ្លៃ។ សូមមើលបញ្ជីឈ្មោះពេញលេញនៃគេហទំព័រជាភាសាផ្សេងៗទៀតរបស់យើង នៅតំណខាងក្រោមនេះ៖

9marks.org/international

9Marks Online PDF

ចូលរួមក្រុម
Telegram
ដើម្បីទទួលមេរៀនព្រះបន្ទូល
រៀងរាល់ថ្ងៃ

t.me/khmerdailymanna

សូមស្កែន



ផ្លូវពិត
plovpit.com
















សេចក្ដីបង្រៀនដ៏គួរឲ្យទុកចិត្តបានអំពីព្រះយេស៊ូវ
មាននៅ www.plovpit.com ក្នុងទម្រង់ជាកំណត់
ហេតុបណ្ដាញ វីដេអូ សំឡេង និងសៀវភៅ

# បោះពុម្ពឆាប់ៗនេះ!




*«“តើដំណឹងល្អនៃព្រះយេស៊ូវគ្រីស្ទជាអ្វី?” នេះជាសៀវភៅដ៏ខ្លីមួយ ប៉ុន្តែមានឥទ្ធិពលឆ្លើយនូវសំណួរនេះដោយមានបទបង្ហាញខ្លី និងច្បាស់លាស់។ វាគឺជាការពិភាក្សាដ៏ល្អប្រសើរអំពីដំណឹងល្អ។ សូមអាន ហើយចែករំលែកដល់អ្នកដទៃចុះ»។ —Daniel L. Akin, President*

**តើក្រុមជំនុំអាចប្រាកដប្រជាឲ្យក្រុមជំនុំខ្លួនមានជីវិតរស់រវើកបានដោយរបៀបណា?**

តើក្រុមជំនុំអាចប្រាកដប្រជាឲ្យក្រុមជំនុំខ្លួនមានជីវិតរស់រវើកបានដោយរបៀបណា? ព្រះសពព្រះហឫទ័យឲ្យក្រុមជំនុំតាមតំបន់ជាផ្ទះដែលល្អប្រសើរ និងមានសារសំខាន់ល្អជាងកន្លែងណាផ្សេងទៀតនៅលើផែនដីនេះ។ ដើម្បីសម្រេចការនេះបាន គឺរាល់គ្រប់អ្នកជឿដាច់ខាតត្រូវតែបម្រើក្នុងទីសកម្មណាមួយនៅក្នុងរូបកាយនៃព្រះគ្រីស្ទ។ ប៉ុន្តែ តើមានន័យយ៉ាងដូចម្ដេចដែលថា យើងត្រូវតែធ្វើជាសមាជិកក្រុមជំនុំដែលមានសុខភាពល្អ? នៅក្នុងសៀវភៅដ៏ខ្លីមួយនេះលោកគ្រូ Thabiti Anyabwile បានបង្ហាញមិត្តអ្នកអានអំពីរបៀបដែលពួកគាត់អាចធ្វើបានសម្រាប់ឲ្យក្រុមជំនុំខ្លួនមានសុខភាពល្អ។ គាត់បានលើកឡើងនូវចំណុចសំខាន់ ១០ យ៉ាង—ដែលមានរួមទាំងការផ្សាយដំណឹងល្អ ការបង្កើតសិស្ស ការដាក់ពិន័យលើខ្លួនឯង និងការអធិស្ឋាន—គាត់បានបង្ហាញអំពីរបៀបនៃការចូលរួមក្នុងព័ន្ធកិច្ចនៃក្រុមជំនុំតាមតំបន់ក៏អាចជួយឲ្យអ្នកជឿមានបទពិសោធន៍នៃការលូតលាស់ខាងវិញ្ញាណយ៉ាងល្អប្រសើរនៅក្នុងជីវិតផ្ទាល់ខ្លួនរបស់ពួកគាត់។

យើងរស់នៅក្នុងជំនាន់មួយដែលមានមនុស្សជាច្រើននិយាយអំពីសារៈសំខាន់នៃការដែលគ្រីស្ទបរិស័ទរស់នៅ «ក្នុងសហគមន៍» តែមានមនុស្សតិចណាស់ដែលបានបកស្រាយអ្វីដែលជាអត្ថន័យពិត ស្មោះត្រង់តាមព្រះគម្ពីរ ដែលជំរុញបុគ្គលនីមួយៗឲ្យផ្លាស់ប្រែ។ លោក ថាប៊ីធី អេនីយ៉ាវាល់ បានបំពេញរាល់ទាំងចន្លោះខ្វះខាតនោះ។ ដូច្នេះ សូមអាន សូមសញ្ជឹងគិត សូមអធិស្ឋាន ហើយចែកចាយសៀវភៅនេះដោយសប្បុរសជាមួយក្រុមជំនុំរបស់លោកអ្នកចុះ។»

—ឌី. អេ. ខាសុន (D. A. Carson) សាស្ត្រាចារ្យផ្នែកស្រាវជ្រាវកណ្ឌគម្ពីរសម្ព័ន្ធមេត្រីថ្មីនៃសាលាទ្រីនិធី អីវ៉ាន់ជិលិកខលឌីនិធី (Trinity Evangelical Divinity Research Professor of New Testament, Trinity Evangelical Divinity School)

«សៀវភៅនេះមកដល់មិនយឺតពេលពេកនោះទេសម្រាប់បរិបទនៃក្រុមជំនុំបច្ចុប្បន្នយើងនេះ»។

—លោក អ. អាល់ប៊ឺត មូលើ ជេអ (R. Albert Mohler Jr.) នាយកនៃសាលាទេវសាស្ត្របាទីស្ទភូមិភាគខាងត្បូង

«សៀវភៅនេះផ្តល់នូវការយកចិត្តទុកដាក់ដ៏ប្រសើរ និងចាំបាច់នៅក្នុងការផ្តោតទៅលើសមាជិកភាពម្នាក់នៃពួកជំនុំ។ យើងគ្រប់គ្នាអាចនឹងទទួលបានប្រយោជន៍តាមរយៈសៀវភៅដ៏ល្អនេះ។

—លោកគ្រូ អា ស៊ី ស្ព្រូល (R. C. Sproul) ប្រធាន និងស្ថាបនិកព័ន្ធកិច្ចលីហ្គូនៀ (Ligonier) ជាព្រឹទ្ធបុរសនៃព័ន្ធកិច្ចបង្រៀន និងអធិប្បាយនៃសាលាទេវសាស្ត្រសេន អែនឌ្រូ សាន់ហ្វដ ហ្វ្លរីដា (Saint Andrews Chapel, Sanford, Florida)

លោកគ្រូ THABITI M. ANYABWILE (ទទួលបានអនុបណ្ឌិតវិទ្យាសាស្ត្រនៅឯមហាវិទ្យាល័យ North Carolina State University) បម្រើជាគ្រូគង្វាលនៅឯក្រុមជំនុំ Anacostia River Church នៅរដ្ឋវ៉ាស៊ីនតោន ឌី.ស៊ី ហើយក៏ជាអ្នកនិពន្ធសៀវភៅច្រើនក្បាលដែរ។ គាត់បម្រើជាសមាជិកក្រុមប្រឹក្សានៅ the Gospel Coalition ហើយក៏ជាអ្នកនិពន្ធចម្បងម្នាក់សម្រាប់ពន្ធកិច្ច ៩Marks Ministries ហើយក៏សរសេរជាប្រចាំក្នុងបណ្តាញសង្គម The Front Porch និង Pure Church។ គាត់ និងប្រពន្ធគាត់ (Kristie) មានកូនបីនាក់។

សៀវភៅនេះជាភាគនៃផ្នែកមួយនៃស៊េរី ៩Marks Building Healthy Churches។

IX 9Marks
www.9marks.org

ផ្លូវពិត plovpit.com

សកម្មភាព កម្ពុជា

9Marks Online PDF